# សម័យ(ចតុមុខ លង្វែក និងឧដុង្គ)




អ្នកនិពន្ធ៖  លោក យុន មុនី

គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ៖
“មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍”
ឆ្នាំ២០២២

គណៈកម្មការនិពន្ធ ៖ លោក ឃុន មុនី
គណៈកម្មការរចនាទំព័រ ៖ លោកស្រី សំបាត់ អ៊ាត លោកស្រី ឈុំ ពៅ
គណៈកម្មការត្រួតពិនិត្យ ៖
១. លោក ថ្លាង សន្តុំ
២. លោកស្រី ឡាំ ប៊ុនមករា

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះជាមេរៀនដ៏ជោគជ័យបំផុតមួយដែលចាប់ឬសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨%ក្នុងមួយឆ្នាំ។ លើសពីនេះទៀតអត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ ក៏កំពុងលេចរូបរាងឡើងដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្ម ពិភពលោក និងតំបន់រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានកំពុងបន្តពង្រឹង និងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវ និងនវានុវត្តន៍ដើម្បីពង្រឹងសមត្ថភាព និងជំនាញរបស់ធនធានមនុស្សនៅកម្ពុជាឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ ដោយ មានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាង ហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅ វិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវ ជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគ ទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជន ពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ២០០២នូវបម្លាស់ប្តូរនៃមូល

ដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម ( Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ ( Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការ ផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទា ក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជា មូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយ ពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធនិងកែលម្អសៀវភៅសិក្សាជាប្រចាំគឺជានវានុវត្តន៍នៃ វិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជា ស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបដោយពុទ្ធិ ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិក និងសារគមនាគមន៍ ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរ៉េខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ធនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក លក្ខណៈសម្បត្តិនៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាព នៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយ គុណាធិបតេយ្យ និង ជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះ

លឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំមានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរ និងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន ៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន ១២០ពាន់ចំណងជើង។ ខណៈពេលដែលបច្ចេកវិទ្យា កំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស និស្សិត និងសាធារណៈជនរួមមានការអានសៀវភៅ ការអានលើឧបករណ៍ អេឡិចត្រូនិកការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយ សំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជា បច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀតបច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបាន ផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។ ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយដើម្បីលើកកម្ពស់អំណានតាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំ ជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាននិងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សាឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិនិងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀតដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណានជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ

សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀន បង្រៀនដោយមានដាក់បញ្ចូលកិច្ចការស្រាវជ្រាវ ស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន

គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតឱ្យមានបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថល ជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់

លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សា អាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន

និស្សិតគ្រប់កម្រិតសិក្សា ត្រូវខិតខំនិងចំណាយពេលអាន និងចាត់ទុកវប្បធម៌ និងអាកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ

បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែ ច្រើនថែមទៀត ជាពិសេសការលែលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា"មូលនិធិ ស.គ.ន" និងហៅជាភាសាអង់គ្លេសថាThe Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន បានសម្រេចកំណត់ប្រធានបទជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមាន ឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម ៤.០ ( Digitalization for IR.4.0 ) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម ( Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពវូបនីយកម្មទៅលើទិសដៅនៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្ដល់ការគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សាដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សាគឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀតការរៀបរៀងនិពន្ធនិងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សាមានគោលដៅដូចខាងក្រោម ៖

ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិត នៅកម្រិតឧត្តមសិក្សា

លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់ឋានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវរួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូន

និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវ ជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់ នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិរួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំ សូមចូលរួម ដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូច និងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

# សេចក្តីបញ្ជាក់

នៃមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោងរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ និងកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ការត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ និងរូបភាព គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិការស្រាវជ្រាវគំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡា ឡើយ។

# មាតិកា


បុព្វកថា ........................................ i
សេចក្តីបញ្ជាក់ ........................................ vi
មាតិកា ........................................ vii
អារម្ភកថា ........................................ x
សេចក្តីថ្លែងអំណរគុណ ........................................ xi
ការបរិយាយលើមុខវិជ្ជា ........................................ xii
មូលន័យសង្ខេប ........................................ xiii
មេរៀនទី១ ចតុមុខ និងរាជធានីថ្មី ........................................ 1
១.១. ព្រឹត្តិការណ៍ក្រោយសម័យអង្គរស.វ ទី១៤ ........................................ 1
១.១.១. ក្រោយរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ........................................ 1
១.១.២. ការផ្លាស់ប្តូររាជធានី ........................................ 2
១.១.៣. អស្ថិរភាពនៃរាជធានី ........................................ 2
១.១.៤. ចតុមុខនិង រាជធានីសំខាន់ៗ ........................................ 3
១.២. កម្ពុជាក្នុងបរិបទតំបន់និងពិភពលោក ........................................ 5
១.២.១. នយោបាយពាណិជ្ជកម្មជាមួយចិន ........................................ 5
១.២.២. ការប្រកួតប្រជែងពាណិជ្ជកម្មនៅអាស៊ី ........................................ 6
១.២.៣. ឥទ្ធិពលលើកម្ពុជា ........................................ 6
១.៣. អាយុធ្យានិង ខ្មែរ ........................................ 11
១.៣.១. វិបត្តិផ្ទៃក្នុងខ្សែរាជវង្សនិងអន្តរាគមន៍ពីសៀម ........................................ 11
១.៣.២. វិបត្តិរាជវង្សខ្មែរនិងការដណ្តើមអំណាច ........................................ 12
១.៣.៣. វិបត្តិផ្ទៃក្នុងនិងកង្វះការដឹកនាំ ........................................ 16
១.៣.៤. របៀបគ្រប់គ្រងប្រទេសសម័យចតុមុខ ........................................ 17
១.៣.៥. ជំនឿនិងទំនៀមទំលាប់ ........................................ 18
១.៣.៦. សាសនានិងលទ្ធិផ្សេងៗ ........................................ 20
១.៤. ស្ថានភាពប្រទេសក្នុងពេលសង្គ្រាម ........................................ 21
១.៤.១. ព្រឹត្តិការណ៍រាជបល្ល័ង្គបីនៃសម័យចតុមុខ ........................................ 22
១.៤.២. ការខាតបង់ដោយសារអន្តរាគមន៍ពីសៀម ........................................ 23
១.៤.៣. ព្រះបាទធម្មរាជាក្លាយជាស្តេចគ្រប់គ្រងនគរតែមួយ ........................................ 24
មេរៀនទី២ សម័យលង្វែកនិង អំណាចសៀម ........................................ 26
២.១. ស្ថានភាពភូមិសាស្ត្រសម័យលង្វែកនិងបម្រែបម្រួល ........................................ 26

២.១.១. លង្វែក និងអឺរ៉ុប ........................................ 27
២.១.២. លង្វែក ដាយវៀតនិង លាវ ........................................ 27
២.១.៣. លង្វែកនិង សៀម ........................................ 28
២.២. សាមគ្គីភាព និង វិបុលភាព ........................................ 33
២.៣. កំណត់ត្រាប្រវត្តិសាស្ត្រនិង ហេតុផល ........................................ 34
២.៣.១. ការបែកបាក់បន្ទាយលង្វែកតាមកំណត់ត្រាសៀម ........................................ 34
២.៣.២. ការបែកបាក់បន្ទាយលង្វែកតាមពង្សាវតាខ្មែរ ........................................ 35
២.៣.៣. ការបែកបាក់បន្ទាយលង្វែកតាមកំណត់ត្រាអឺរ៉ុប ........................................ 36
២.៣.៤. ការរំដោះក្រុងលង្វែកពីសៀម ........................................ 36
២.៤. សេដ្ឋកិច្ចសម័យលង្វែក ........................................ 39
២.៤.១. កសិកម្ម ........................................ 39
២.៤.២. ពាណិជ្ជកម្ម ........................................ 39
២.៤.៣. សិប្បកម្ម ........................................ 39
២.៥. ការអប់រំសម័យលង្វែក ........................................ 39
២.៥.១. ជាន់ដើម (ថ្នាក់ដំបូង)=រៀនសរសេរ ........................................ 40
២.៥.២. ជាន់ទី២ រៀនមើលសត្រាច្បាប់ ........................................ 42
២.៥.៣. ជាន់ទី៣ រៀនមើលសត្រាល្បែង ........................................ 43
២.៥.៤. ជាន់ទី៤ រៀនមើលសត្រាទេសន៍ ........................................ 43
២.៦. ក្រសួងសួស្ដី(ក្រសួងអប់រំ) ........................................ 45
២.៦.១. ព្រះគោនិង ព្រះកែវ ........................................ 46
២.៦.២. ការចូលម្លប់របស់កូនស្រីសម័យលង្វែក ........................................ 47
២.៦.៣. អក្សរសាស្ត្រខ្មែរ សម័យលង្វែក ........................................ 48
មេរៀនទី៣ សម័យឧដុង្គនិងការប្រកួតអំណាចរវាងយួន និងសៀម ........................................ 54
៣.១. ស្ថានភាពភូមិសាស្ត្រសម័យឧដុង្គ ........................................ 54
៣.២. រាជធានីឧដុង្គនិងការប្រកួតអំណាចរវាងយួននិងសៀមពីឆ្នាំ ១៦២០-១៦២៩ ........................................ 56
៣.២.១. ការចងសម្ព័ន្ធមេត្រីភាពជាមួយយួន ........................................ 57
៣.២.២. វិបត្តិរាជវង្ស ........................................ 58
៣.២.៣. ព្រះអង្គសូរឬព្រះបរមរាជាអង្គសូរ (១៦៥៨គ.ស.-១៦៧២គ.ស.) ........................................ 58
៣.២.៤. ព្រះបាទជ័យជេដ្ឋាទី៣អង្គស៊ូរជ្ជកាលទី១ ........................................ 59
៣.២.៥. ព្រះបាទជ័យជេដ្ឋាទី៣អង្គស៊ូរជ្ជកាលទី៣ ........................................ 59
៣.២.៦. ព្រះសត្ថាទី២អង្គជីរជ្ជកាលទី២ ........................................ 59
៣.២.៧. ព្រះសត្ថាទី២អង្គជីរជ្ជកាលទី៣(១៧៤៩គ.ស.) ........................................ 60
៣.២.៨. ព្រះរាមាធិបតីទី៣អង្គទង ........................................ 61

៣.២.៩. ព្រះបាទឧទ័យអង្គតន់(ព្រះឧទ័យរាជាទី២)(១៧៥៨គ.ស.-១៧៧៥គ.ស.) ........... 61
៣.៣. វិបត្តិរាជវង្សខ្មែរនិងការអន្តរាគមរបស់យួន ........ 64
៣.៣.១. ព្រះបាទឧទ័យរាជាអង្គចន្ទឬអង្គចន្ទទី២(១៨០៦គ.ស.-១៨៣៤គ.ស.) ........ 65
៣.៣.២. ព្រះក្សត្រីអង្គម៉ី ........ 66
៣.៣.៣. ព្រះអង្គអេង(១៧៧៨គ.ស.-១៧៩៦គ.ស.) ........ 68
៣.៤. ការមកដល់របស់អឺរ៉ុប និងឥទ្ធិពលលើកម្ពុជា ........ 70
៣.៥. ចំណងការទូតនិង ពាណិជ្ជកម្មរបស់កម្ពុជា ........ 70
៣.៦. សៀម យួននិងការប្រជែងអំណាចលើកម្ពុជា ........ 71
៣.៧. ការបាត់បង់ទឹកដីកម្ពុជាក្រោម ........ 74
៣.៨. ឥទ្ធិពលសៀមមកលើខ្មែរ ........ 74
៣.៩. មធ្យោបាយគេចចេញពីសៀម និងយួន ........ 77
៣.១០. សម័យព្រះបាទអង្គដួងនិងស្នាព្រះហស្ថ ........ 79
៣.១០.១ .ការរៀបចំប្រទេស ........ 79
៣.១០.២. ស្នាព្រះហស្ថក្នុងអក្សរសាស្ត្រ ........ 80
៣.១០.៣. អ្នកប្រាជ្ញខាងអក្សរសាស្ត្រខ្មែរ ........ 81
៣.១១. ព្រះបាទអង្គដួង(១៨៤០គ.ស.-១៨៥៩គ.ស.) ........ 88
ឯកសារយោង ........ 90

# អារម្ភកថា

សៀវភៅមួយក្បាលនេះត្រូវបានស្រាវជ្រាវឡើងក្នុងគោលបំណងដើម្បីបង្ហាញពី «សម័យចតុមុខ លង្វែក និងឧដុង្គក្នុងឆ្នាំ១៤៣២គ.ស.ដល់១៨៦៣គ.ស.» ដើម្បីចែករំលែកដល់សិស្សានុសិស្សនិស្សិត មិត្តអ្នកអានបានដឹងនឹងយល់អ្វី ដែលជាមេរៀនសម្រាប់មនុស្សជំនាន់ក្រោយៗទៀត។ ប្រវត្តិរឿងរ៉ាវ «សម័យចតុមុខ លង្វែក និងឧដុង្គក្នុងឆ្នាំ១៤៣២គ.ស.ដល់១៨៦៣គ.ស.»ដែលកូនខ្មែរគួរតែចងចាំជានិច្ច។ខ្ញុំបាទសង្ឃឹមថាសៀវភៅមួយនេះនឹងក្លាយជាឯកសារថ្មីមួយក្នុងចំណោមឯកសារដ៏ទៃទៀត ដែលមិត្តអ្នកអាន ក៏ដូចជាសិស្ស និស្សិតទាំងអស់បានជួបកន្លងមក។ ឯកសារនេះជាឯកសារថ្មីមួយទៀតដែលបានចងក្រងសម្រាប់ទុកជាបទពិសោធន៍ក្នុងសង្គមខ្មែរ កុំឱ្យប្រជាជនខ្មែររស់នៅដើរជាន់ដានប្រវត្តិសាស្ត្រដដែលៗមិនចេះចប់មិនចេះហើយ។ ដើម្បីកុំឱ្យមានការបាត់បង់ទឹកដីបន្តទៅទៀតយើងទាំងអស់គ្នាត្រូវចេះសាមគ្គីគ្នា ឯកភាពជាតិជាធ្លុងមួយ ហើយចេះថែរក្សាការពារទឹកដីដែលនៅសល់ឱ្យបានគង់វង្សជារៀងរហូតតរៀងទៅ ។

ខ្ញុំបាទសូមខន្តីអភ័យទោសរាល់ចំណុចខ្វះខាត និងកំហុសឆ្គងមួយចំនួនដោយអចេតនា។ព្រមទាំងទទួលយកនូវការរិះគន់ និងការកែតម្រូវពីគ្រប់មជ្ឈដ្ឋានដោយសេចក្តីរីករាយបំផុត។

# សេចក្តីថ្លែងអំណរគុណ

ជាការពិតសៀវភៅ«សម័យចតុមុខ លង្វែក និងឧដុង្គក្នុងឆ្នាំ១៤៣២គ.ស.ដល់១៨៦៣គ.ស.» ដែលលេចចេញជារូបរាងនៅពេលនេះគឺបានកើតឡើងពីការខិតខំ និងយកចិត្តទុកដាក់ចូលរួមពីភាគី និងស្ថាប័នពាក់ព័ន្ធជាច្រើន។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ភាគី និងស្ថាប័នពាក់ព័ន្ធទាំងអស់ដូចជា ៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានគាំទ្រយ៉ាងពេញទំហឹងដល់ក្រសួងអប់រំ យុវជន និងកីឡាឱ្យបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ហៅកាត់ថា «មូលនិធិ ស.គ.ន»។

- ក្រសួងអប់រំ យុវជន និងកីឡាដែលបានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ដែលហៅកាត់ថា «មូលនិធិ ស.គ.ន» ដើម្បីរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។

- មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលបានគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសាជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

- ឯកឧត្តនាយកវិទ្យាស្ថានដែលបានចាត់តាំងជាគណៈកម្មការនិពន្ធចូលរួមការរៀបរៀង និពន្ធ និងកែលម្អសៀវភៅនៅកម្រិតឧត្តមសិក្សានេះ។

- នាយកដ្ឋានបណ្តុះបណ្តាលដែលបានចាត់តាំងជាគណៈកម្មការនិពន្ធ និងគណៈកម្មការត្រួតពិនិត្យ លើស្នាដៃនៃការចូលរួមការរៀបរៀង និពន្ធ និងកែលម្អសៀវភៅនៅកម្រិតឧត្តមសិក្សានេះ។

- លោកប្រធាន នាយកដ្ឋានបណ្តុះបណ្តាលដែលបានព្រមព្រៀងទទួលសិទ្ធិជាតំណាងអ្នករៀបរៀងក្នុងការចាត់ចែង និងសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា ចុះហត្ថលេខាលើកិច្ចព្រមព្រៀង និងកិច្ចដំណើការទូទាត់ថវិកាតាមរយៈការស្នើសុំ និងទទួលថវិកាបោះពុម្ព និងផ្សព្វផ្សាយបន្តនូវស្នាដៃរៀបរៀង និពន្ធ និងកែលម្អរបស់អ្នករៀបរៀងក្នុងការរៀន និងបង្រៀនក្នុងគ្រឹះស្ថានសិក្សា និងប្រគល់សិទ្ធិស្របតាមការកំណត់នៃកិច្ចព្រមព្រៀង ស្តីពីការរៀបរៀង និពន្ធ និងកែលម្អសៀវភៅនៅកម្រិតឧត្តមសិក្សា ក្រោមការគាំទ្រនៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។

- គ្រូឧទ្ទេសមុខវិជ្ជា ប្រវត្តិវិទ្យា នៃវិទ្យាស្ថានគរុកោសល្យបាត់ដំបង ដែលបានផ្តល់មតិកែលម្អលើខ្លឹមសារនៃមេរៀននីមួយៗឱ្យកាន់តែមានភាពសុក្រឹត និងមានលក្ខណៈវិទ្យាសាស្ត្រ។

ខ្ញុំបាទសង្ឃឹមថា សៀវភៅនេះនឹងឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់សិស្ស និស្សិត នៅកម្រិតវិទ្យាល័យ និងឧត្តមសិក្សា។

# ការបរិយាយលើមុខវិជ្ជា

ប្រវត្តិសាស្ត្រគឺជាវិទ្យាសាស្ត្រដែលសិក្សាពីព្រឹត្តិការណ៍ ឬហេតុការណ៍ដែលបានកើតឡើងតាំងពីអតីតកាល។ ដែលប្រជាជនរស់នៅក្នុងប្រទេសមួយ ត្រូវតែយល់ និងដឹងពីរឿងរ៉ាវទាំងនោះ។ ការសិក្សាពីប្រវត្តិសាស្ត្រប្រទេសរបស់ខ្លួន គឺបានធ្វើឱ្យយើងយល់ដឹងពីដើមកំណើត ការវិវត្តន៍ បម្រែបម្រួលរបស់របបសង្គម និងការរីកចម្រើនជឿនលឿនក៏ដូចជាការធ្លាក់ចុះអន់ថយរបស់ប្រទេសជាតិ។ ក្រៅពីនេះប្រសិនបើប្រជាជនខ្លួនយើងគ្មានការយកចិត្តទុកដាក់ សិក្សាស្រាវជ្រាវទេ តើយើងទុកឱ្យប្រជាជាតិណាមកខ្វល់យកចិត្តទុកដាក់ជំនួសយើង ដូចនេះហើយការសិក្សាប្រវត្តិដើមកំណើតនេះហើយប្រៀបទៅនឹងការស្រឡាញ់ថែរក្សាការពារ ហើយចង់ចែករំលែកអរិយធម៌របស់ប្រទេសខ្លួនទៅកាន់ជនបរទេស ទៅកាន់ពិភពលោកទាំងមូលឱ្យបានដឹង។ ប្រទេសកម្ពុជាយើងគឺជាប្រទេសមួយដែលមានអរិយធម៌ដ៏ខ្ពង់ខ្ពស់ហើយចំណាស់ជាងគេនៅអាស៊ីអាគ្នេយ៍ ដែលបានកើតឡើងនៅពាក់កណ្ដាលសតវត្សទី១នៃ គ.ស. មកម្លេះ។ រហូតមកដល់បច្ចុប្បន្ននេះប្រទេសកម្ពុជានៅតែរក្សាបាននូវមុខមាត់ ឈរក្នុងលំដាប់មួយនៃបណ្ដា ប្រទេសក្នុងពិភពលោកបានដោយមានការខិតខំប្រឹងប្រែងពីមួយជំនាន់ទៅមួយជំនាន់ក្រោយទៀត ទោះបីជាមានការគម្រាមកំហែងពីសត្រូវឈ្លានពានយ៉ាងណាក៏ដោយ។

ស្នាដៃចងក្រងនេះធ្វើឡើងក្នុងគោលបំណង បម្រើជូនដល់អ្នកសិក្សាទាំងអស់ដែលចង់យល់ដឹងពីប្រវត្តិសាស្ត្រខ្មែរជាពិសេស «សម័យចតុមុខ លង្វែក និងឧដុង្គក្នុងឆ្នាំ១៤៣២គ.ស. ដល់១៨៦៣គ.ស.» ហើយដឹងពីបទពិសោធន៍មួយនេះ ដើម្បីទប់ស្កាត់ការឈ្លានពានពីបរទេសជិតខាង និងការពារកុំឱ្យបាត់បង់ទឹកដីបន្តទៅទៀត។ ខ្ញុំបាទសង្ឃឹមថាសៀវភៅនេះពិតជាបានឆ្លុះពញ្ញាក់ដល់អារម្មណ៍របស់កូនចៅខ្មែរយើងជំនាន់ក្រោយឱ្យចាប់អារម្មណ៍អំពីប្រវត្តិសាស្ត្រជាតិខ្មែរយើងឱ្យកាន់តែទូលំទូលាយដោយខិតខំស្វែងរកឯកសារស្រាវជ្រាវចូលរួមចំណែកថែរក្សាការពារទឹកដីប្រកបដោយទឹកចិត្តស្នេហាជាតិមាតុភូមិ និងការចូលរួមអភិរក្សសម្បត្តិវប្បធម៌ និងសម្បត្តិធម្មជាតិ ក្នុងប្រទេសយើងឱ្យបានគង់វង្សជានិរន្តរ៍។

# មូលន័យសង្ខេប

## សម័យចតុមុខ

ប្រទេសខ្មែរក្នុងសម័យចតុមុខ ពុំសូវមានការរីកចម្រើនដោយសារនៅក្នុងប្រទេសមានសង្គ្រាមផ្ទៃក្នុងរវាងខ្សែរាជវង្ស ដណ្ដើមអំណាចគ្នាមិនចេះចប់មិនចេះហើយ ដែលធ្វើឱ្យប្រទេសជាតិហិនហោចបាត់បង់នូវសម្បត្តិវប្បធម៌មជាតិបាត់បង់ទឹកដីជាបន្តបន្ទាប់រហូតដល់បច្ចុប្បន្ន។ប្រទេសកម្ពុជានាសម័យចតុមុខ នៅឆ្នាំ ១៤៣១គ.ស.-១៥២៥គ.ស.។ នៅឆ្នាំ១៤៣១គ.ស. ព្រះបាទ ពញាយ៉ាត ទ្រង់បានលើករាជធានីពីអង្គរទៅតាំងនៅទួលបាសានក្នុងខេត្រស្រីសឈរ(កំពង់ចាម)វិញ។ តែដោយសារតំបន់នោះរងគ្រោះដោយទឹកជំនន់ព្រះអង្គក៏បញ្ជាឱ្យលើករាជធានីពីទួលបាសាន ទៅតាំងនៅចតុមុខវិញ។ក្រោយពីការកសាងរាជធានីរួចរាល់ ព្រះរាជាទ្រង់តាំងប្រទាននាមឱ្យព្រះនគរថា ក្រុងចតុមុខមង្គល សកលកម្ពុជាធិបតីសិរីធរ បវរតេន្ទបត្តបុរីរដ្ឋរាជសីមាមហានគរ។ការកសាងទីក្រុងចតុមុខមានប្រវត្តិមកពី ស្ត្រីមេម៉ាយម្នាក់មានឈ្មោះដូនពេញ រើសបាន ព្រះពុទ្ធរូប ៤ ព្រះអង្គនិងរូបបដិមាថ្មមានលក្ខណជាព្រាហ្មណ៍បន្ទាប់មកអ្នកស្រុកនាំគ្នាពូនដីជាដំបូកធំ ហើយយកឈើមកសង់ជាវិហារតូចនៅលើកំពូលភ្នំនោះ ហើយនាំយកព្រះពុទ្ធរូបទៅតម្កល់លើវិហារនោះនៅឆ្នាំ ជូត ឆស័ក ព.ស.១៣៧២។ព្រះរាជាសោយរាជ្យនៅសម័យចតុមុខមានដូចជា៖ ព្រះបាទពញាយ៉ាត (១៤០១គ.ស.-១៤៦៣គ.ស.) មានរាជបុត្រទី១ព្រះនាម នរាយណ៍រាជា (១៤៦៣គ.ស.-១៤៦៨គ.ស.) បុត្រទី២ ព្រះបាទស្រីរាជា (១៤៦៨គ.ស.-១៤៨៦គ.ស.) បុត្រទី៣ព្រះធម្មរាជា(១៤៨៦គ.ស.-១៥០៤គ.ស.)។ ព្រះបាទនារាយណ៍រាជាសោយរាជ្យបានតែប៉ុន្មានព្រះវស្សា ក៏សោយទិវង្គតហើយព្រះស្រីរាជា ដែលជាអនុជក៏សោយរាជ្យ បន្ទាប់។នៅក្នុងរជព្រះស្រីរាជានេះដែរប្រទេសខ្មែរនាពេលនោះកើតកោលាហលដោយត្រូវបែងចែកប្រទេសជាបីសោយរាជ្យដោយព្រះរាជាបីព្រះអង្គផ្សេងគ្នាពោលគឺ មួយផ្នែកសោយរាជ្យដោយព្រះបាទស្រីរាជាដែលជាស្ដេចសោយរាជ្យ មួយផ្នែកដោយព្រះបាទស្រីសុរិយោទ័យដែលត្រូវជាក្មួយនឹងមួយផ្នែកទៀតដោយព្រះបាទធម្មរាជាជាព្រះអនុជ។ សង្គ្រាមស៊ីវិលនេះត្រូវបានបញ្ចប់ដោយទទួលបានការអន្តរាគមន៍ ពីសំណាក់សៀមក្រោមការស្នើសុំជំនួយពីព្រះបាទធម្មរាជាដែលជាប់ខ្សែស្រឡាយ ពីព្រះមាតាដែលជាជនជាតិសៀម។ កម្ពុជាសម័យចតុមុខនៅរវាងឆ្នាំ១៤៣១គ.ស. ដល់ ១៥២៥គ.ស.។ជាក់ស្ដែងសង្គ្រាមរវាងព្រះបាទសុគន្ធបទ និងស្ដេចកនបានអូសបន្លាយរយៈពេលយូរ ធ្វើឱ្យប្រជារាស្ត្រកើតក្ដីក្ដៅក្រហាយ ធ្វើឱ្យទ្រង់ទាំងពីរសម្រេចព្រះទ័យផ្អាកសង្គ្រាម ដើម្បីឱ្យរាស្ត្រព្រះអង្គធ្វើស្រែចម្ការសិន។ ជាចុងបញ្ចប់នៅសម័យចតុមុខគឺក្រោយពីស្ដេចកនត្រូវបានចាញ់សង្គ្រាម ហើយធ្វើគត់ដោយព្រះបាទចន្ទរាជា។

## សម័យលង្វែក

កាសិក្សាប្រវត្តិសាស្ត្រខ្មែរនៅសម័យលង្វែកចាប់ពី សតវត្សទី១៥មកបានបង្ហាញឱ្យឃើញថាប្រទេសកម្ពុជាក្នុងដំណាក់កាលនេះបានកើតឡើងនូវវិបត្តិសង្គមមិនចេះចប់មិនចេះហើយរហូតស្ទើរតែបាត់បង់ទឹកដី ដោយការហែកហួរពីយួន និងសៀម។ វណ្ណៈដឹកនាំសង្គមកម្ពុជាជួបវិបត្តិជាបន្តបន្ទាប់។ មូលហេតុនៃវិបត្តិគឺការបែកបាក់ផ្ទៃក្នុងផង និងការទទួលឥទ្ធិពលមកពីក្រៅផង។រដ្ឋអំណាចត្រូវស្ថិតក្នុងកណ្ដាប់ដៃមន្ត្រីដែលជាគ្រហស្ថ និងយោធា ហើយស្ថាប័នរដ្ឋនានាត្រូវពង្រឹងពង្រីកជាមួយគ្នានេះដែរមាន

ការពង្រឹងព្រំប្រទល់ និងអង្គការគ្រប់គ្រងរដ្ឋតាមរបៀបថ្មី។ ការដណ្តើមរាជ្យសម្បត្តិគ្នារវាងក្រុមញាតិវង្សានុវង្ស តែងកើតឡើងជាញឹកញាប់។ នេះបណ្តាលមកពីពុំទាន់មានគោលការណ៍ ច្បាស់លាស់នៅក្នុងកិច្ចបន្តរាជ្យសម្បត្តិ។ មន្ត្រីជាន់ខ្ពស់នៃព្រះបរមរាជវាំង ហើយទំនាស់រវាងគូបដិបក្ខ ដែលដណ្តើមរាជបល្ល័ង្ក សុទ្ធតែក្រុមញាតិវង្សានុវង្សតែងកើតឡើងជាញឹកញាប់ហើយបន្តមកដល់សម័យក្រោយៗ មកទៀត។ តែទោះជាយ៉ាងណាក៏ខ្មែរមិនរលាយដែរ ពីព្រោះខ្មែរមានព្រលឹងការពារជាតិមាតុភូមិពិតប្រាកដ។ សម័យលង្វែកមានការរីកចម្រើនតែនៅក្នុងសម័យស្តេច ចន្ទរាជា រហូតដល់ស្តេចសត្ថាទី១ទេ។តែស្តេចក្រោយៗមកទៀតពុំមាន ការរីកចម្រើនទេដោយសារនៅក្នុងប្រទេសមានការ ដណ្តើមអំណាចគ្នារវាងខ្សែរាជវង្សមិនចេះចប់មិនចេះហើយ ដែលធ្វើឱ្យប្រទេសបរទេសជិតខាងសៀមនិងយួនចូលមកហែកហួរទឹកដីខ្មែរ ចែកគ្នាធ្វើឱ្យប្រទេសជាតិហិនហោចបាត់បង់នូវសម្បត្តិវប្បធម៌ជាតិបាត់បង់ទឹកដីជាបន្តបន្ទាប់។

## សម័យឧដុង្គ

ក្នុងសម័យឧត្តុង្គ ពុំសូវមានការរីកចម្រើនដោយសារនៅក្នុងប្រទេសមានសង្គ្រាមផ្ទៃក្នុងរវាងខ្សែរាជវង្សដណ្តើមអំណាចគ្នាមិនចេះចប់មិនចេះហើយ ដែលធ្វើឱ្យប្រទេសជាតិហិនហោចបាត់បង់នូវសម្បត្តិវប្បធម៌ជាតិ បាត់បង់ទឹកដីអស់ជាច្រើន កុំតែបានព្រះបាទអង្គដួងជួយទាក់ទងបារាំងធ្វើជាអាណាព្យាបាលទាន់ពេលវេលាកុំអីទឹកដីកម្ពុជាត្រូវរលាយ។នៅដើមសម័យឧដុង្គការប្រកាប់ប្រចាក់គ្នាឯង បានធ្វើឱ្យសៀម លូកដៃមិនឈប់។ រីឯអាណ្ណាមវិញដែលកំពុងតែជួបការលំបាកក្នុងចម្បាំងគ្នាឯងជាមួយរាជវង្សឡេ នៅភាគខាងជើងបែរជាបានជួបនិងក្សត្រខ្មែរដែលទៅចងសម្ព័ន្ធភាព គឺហាក់ដូចជាផ្តល់កម្លាំងចិត្តឱ្យគេក្នុងការបំពេញមហិច្ឆតាពង្រីកឥទ្ធិពលរបស់ខ្លួននៅក្នុងតំបន់។ គ្រាន់តែចាប់ផ្តើមនៃចំណងមេត្រីភាពភ្លាម ខ្មែរត្រូវបានអាណ្ណាមប្រើល្បិចសុំខ្ចីទឹកដីទៅហើយ ជាទឹកដីដែលជាចំណុចមាញឹកខាងពាណិជ្ជកម្មផង ជាចំណុចយុទ្ធសាស្ត្រតំបន់ផង និងជាច្រកឆ្ពោះទៅរកពិភពលោកខាងក្រៅតាមផ្លូវសមុទ្រផងដែរ។ ការមិនចងចាំមេរៀនប្រវត្តិសាស្ត្រ ការមិនអើពើសិក្សាពីចរិតប្រទេសជិតខាង បានធ្វើខ្មែរកាន់តែលង់ខ្លួនក្នុងទំនាក់ទំនងជាមួយអាណ្ណាម ហើយក៏ដកខ្លួនមិនរួចពីសៀមដែលជាសត្រូវចាស់ផងដែរ។

បើគេមើលទៅការលេបត្របាក់យកទឹកដីប្រទេសចម្ប៉ាដោយពួកអាណ្ណាម គេឃើញយ៉ាងច្បាស់ពីមហិច្ឆតារបស់ពួកនេះ ហើយគេក៏នឹងឃើញនូវយុទ្ធសាស្ត្រដែលពួកនេះប្រើក្នុងកាលកន្លងមកដែរ។ ក្រោមការឈ្លានពានពីសំណាក់ពួកសៀម និងអាណ្ណាមជាងពីរសតវត្សប្រជាជនកម្ពុជាហាក់ដូចជាល្ងីល្ងើ លែងយល់ថា អ្នកណាជាសត្រូវ អ្នកណាជាមិត្តឱ្យពិតប្រាកដ ហើយពួកគេបានក្លាយជាមនុស្សសន្សំសុខតែរៀងៗខ្លួន។ ប្រជាជនកម្ពុជារួមគ្នាជាប្រជាជាតិមួយ ដោយសារតែព្រះរាជា។ ប៉ុន្តែប្រជាជននេះមានការសាមគ្គីគ្នា តែនៅពេលណាដែលទុក្ខវេទនានៅកន្លែងមួយធ្វើឱ្យមានការប៉ះពាល់ដល់កន្លែងផ្សេងទៀតប៉ុណ្ណោះ មិនមែនរួមគ្នាគ្រប់កាលៈទេសៈនោះទេ។ដរាបណាការឈ្លានពាន ឬការបះបោរ ឬអំពើរំលោភបំពានកើតមាននៅតំបន់ណាមួយដែលមិនមានការប៉ះពាល់ដល់មហាក្សត្រទេ ពួកគេក៏គិតថា សកម្មភាពនោះក៏មិនមានការខូចខាតដល់ខ្លួនពួកគេដែរ។

ក្នុងរយៈកាលនៃសម័យឧដុង្គ ប្រជាជាតិខ្មែរដែលជាពូជអ្នកកសាងអង្គរបានក្លាយជាជាតិមួយដែលរត់ទៅលិចពឹងសៀម ឬរត់ទៅកើតសុំជំនួយពីអាណ្ណាម លែងជាជាតិដែលឯករាជ្យ និងស្វាហាប់ ដូចមុនទៀតហើយ។ប្រជារាស្ត្រ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ក្នុងការអភិវឌ្ឍប្រទេសជាតិត្រូវតែមានការរួបរួម

កម្លាំងគ្នា និងសាមគ្គីគ្នាជាផ្លុងមួយទើបធ្វើឱ្យប្រទេសជាតិមានការរីកចម្រើន។សមស្របទៅនឹងគោលនយោបាយ យុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល បច្ចុប្បន្នដែលដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែននិងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិតប៊ុនរ៉ានីហ៊ុន ហែនដែលដឹកនាំប្រទេសជាតិមានការរីកចម្រើនប្រកបដោយសន្តិភាព។

# មេរៀនទី១

# ចតុមុខ និងរាជធានីថ្មី

## ១.១. ព្រឹត្តិការណ៍ក្រោយសម័យអង្គរស.វ ទី១៤

### ១.១.១. ក្រោយរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧



ប្រាសាទអង្គរវត្តគ្មានការថែរក្សា

សម័យមហានគរបានលាតសន្ធឹងចាប់ពីសតវត្សទី៩ដល់ស.វ ទី១៣មានឥទ្ធិពលខ្លាំងក្លារបស់ខ្លួនគ្របដណ្តប់លើវិសាលភាពផ្ទៃដី ដ៏ធំទូលាយលើ តំបន់អាស៊ីអាគ្នេយ៍។ការឈានឡើងដល់កំពូលនេះ ត្រូវបានដួលរលំនិងបាក់ស្រុតបន្តិចម្តងៗក្រោយពីព្រះបាទជ័យវរ្ម័នទី ៧បានយាងសោយទីវង្គតទៅ។

ក្រោយរជ្ជកាលព្រះបាទជ័យ វរ្ម័ន ទី៧ គេឃើញមានប្រតិកម្មសាសនាពីរកើតឡើងគឺ សាសនាព្រះពុទ្ធនិង ព្រាហ្មណ៍សាសនាក្នុងរាជព្រះបាទជ័យវរ្ម័នទី ៨។ ជម្លោះសាសនា និងរាជវង្សានុវង្សនេះហើយ ដែលធ្វើឱ្យ សម័យមហានគរចាប់ផ្តើមធ្លាក់ចុះបន្តិចម្តងៗជាបន្តបន្ទាប់។ ក្រោយមកទៀតមាននយោបាយមួយបានកើតឡើង នៅក្នុងស្រុកគឺបដិវត្តន៍នាយត្រសក់ផ្អែមគឺជាជនជាតិ សំរ៉ែ បានធ្វើគត ព្រះបាទជ័យវរ្ម័នទី៩( ១៣២៧គ.ស.១៣៣៦គ.ស. )ហើយបានឡើងគ្រងរាជ្យជាក្សត្រនគរ។ក្រៅពីនេះមានការឈ្លានពានពីសំណាក់សៀមជាញឹកញាប់ដោយឆក់ប្លន់ទ្រព្យសម្បត្តិកៀរប្រជាជនសម្លាប់ប្រជាជននិងបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច ជាពិសេសទៅទៀតមានការមិនចុះសម្រុងគ្នារវាងវណ្ណៈខ្ពស់អ្នកដឹកនាំនិងប្រជារាស្ត្រហើយបន្តកើតឡើងនូវវិបត្តរាជបល្ល័ង្កឥតឈប់ឈរ។

នៅសម័យនោះប្រទេសខ្មែរ លែងជាមហាអំណាច មួយខាងទឹកដីទៀតហើយទឹកដីទាំងនោះជារបស់ ស្រុកស្រីអាយុធ្យាលពបុរី គោត្របុរ ត្រូវបាត់អស់ទៅហើយ ឯសាមន្តរដ្ឋចាម្ប៉ាអាណ្ណាមផ្ទាមនក៏លែងមានទៀតដែរហើយ។ព្រំដែនខាងជើងរបស់ខ្មែរធ្លាក់នៅត្រឹម ទន្លេមូនឬនៅលើនោះបន្តិចបន្តួចនិងប្រទេសលាវ។ព្រំដែនខាងលិចទល់និងបស្ចិមបុរីនិងរយ៉ង ខាងពាយ័ព្យទល់និងស្រុកនាងរង នគរាជខាងកើតទល់ នឹងប្រទេសចាម្ប៉ាខាងត្បូងទល់និងសមុទ្រចិន និងឈូងសមុទ្រនគរភ្នំក្លាយទៅជាឈូងសមុទ្រសៀម។គួរឱ្យកត់សំគាល់ថាខេត្តមួយចំនួន នៅខ្មែរយើងខេត្តខ្លះនៅមានឋានៈជា ខេត្តរហូតដល់សព្វថ្ងៃនេះដូចជាពោធិ៍សាត់ បាត់ដំបង ស្ទឹងត្រែង ក្រចេះ។ល។ ខ្លះទៀតធ្លាក់ឋានៈជាស្រុកវិញដូចជាមង្គលបុរី ជីក្រែង ទឹកជោរ។ល។ឯខ្លះទៀតត្រូវរលាយចូលខេត្តឯទៀតអស់។

ចាប់តាំងពីស.វទី១៤មកយើងមានវិបត្តិផ្នែកវប្បធ៌ដោយពុំមានចារសិលាចារឹកទៀតឡើយ។ លុះដល់រជ្ជកាលព្រះបាច័ន្ទរាជា ទើបខ្មែរចេះចារអក្សរលើថ្មឡើងវិញ នៅរូតព្រះពាន់របៀងថេវ រួតបាកាណនៅប្រាសាទអង្គរវត្ត។ចំពោះនយោបាយក្នុងប្រទេសគេឃើញមានវិបត្តិរាជវង្សជាញឹក ញាប់ជាហេតុបណ្តាលឱ្យមានសង្គ្រាមស៊ីវិលឥតឈប់ឈរចម្បាំងនេះដោយសារការគិតប្រយោជន៍ផ្ទាល់ខ្លួនច្រើនជាងប្រយោជន៍រួមគឺគិតតែពីរឿង លុយកាក់ មាសប្រាក់ និងបក្សពួកនិយម។ពេលមានជម្លោះមិនចេះសម្របសម្រួលគ្នាទេគិតតែពីចង់យកឈ្នះរៀងៗខ្លួនហើយរត់ទៅពឹង បរទេសឱ្យមកជួយពេលគេមកជួយបាន

ជ័យជំនះហើយយើងតែងតែសងគុណគេដោយកាត់ទឹកដីម្តងពីរបីខេត្តៗ ជាបន្តបន្ទាប់រហូតស្ទើរតែអស់ទឹកដីដែលដូនតាយើងបន្សល់ទុកឱ្យដ៏ធំទូលាយ។

តាមពង្សាវតារនៅក្នុងវិស័យរដ្ឋបាលក្រោយសម័យមហានគរផ្ទៃដីប្រទេសខ្មែរទាំងអស់បានបែងចែកជា ៧០ ខេត្តរួមមាន៖ ខេត្ត លង្វែក ខេត្តអម្រិន្ទបូរ ខេត្តក្រគរ ខេត្តគ្រង ខេត្តខ្លុង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តឬស្សីសាញ ខេត្តពាមសីមា ខេត្តមង្គលបុរី ខេត្តរយ៉ង ខេត្តសុរិន្ទ ខេត្តសិង្ហារ ខេត្តកំពង់សៀម ខេត្តស្ទឹងត្រែង ខេត្តជើងព្រៃ ខេត្តគោកសេះ ខេត្តស្មោង ខេត្តជីក្រែង ខេត្តអន្លង់រាជ ខេត្តព្រំទេព ខេត្តព្រៃក្តី ខេត្តសៀមរាប ខេត្តកំពង់ស្វាយ ខេត្តជាំក្សាន្ត ខេត្តម្លូរព្រៃ ខេត្តត្នោត ខេត្តទឹកជោរ ខេត្តសៀមបូក ខេត្តសម្បុកសម្បូណ៌ ខេត្តក្រចេះ ខេត្តធ្លូង ខេត្តបាសាន ខេត្តទទឹងថ្ងៃ ខេត្តព្រៃវែង ខេត្តត្បូងឃ្មុំ ខេត្តស្វាយទាប ខេត្តរោងដំរី ខេត្តបាភ្នំ ខេត្តរំដួល ខេត្តព្រៃនគរ ខេត្តលង់ហោ ខេត្តជើងបាដែង ខេត្តសំរោងទង ខេត្តបាទី ខេត្តលើកដែក ខេត្តទ្រាំង ខេត្តបន្ទាយមាស ខេត្តថ្ពង់ ខេត្តបាសាក់ ខេត្តបារៀ ខេត្តពាម ខេត្តកោះស្លាកែត ខេត្តកំពត ខេត្តកំពង់សោម ខេត្តទឹកខ្មៅ ខេត្តបាណាម ខេត្តមេសរ ខេត្តព្រះត្រពាំង ខេត្តក្រមួនសរ ខេត្តដូនណៃ...។ល។

### **១.១.២. ការផ្លាស់ប្តូររាជធានី**



**ការផ្លាស់ប្តូររាជធានីពីអង្គរមកទួលបាសាន**

ការដេកថយតាមក្បួនយុទ្ធសាស្ត្ររបស់ព្រះបាទពញាយ៉ាត៖ប្រវត្តិសាស្ត្រខ្មែរនៅឆ្នាំ១៤៣១គ.ស.ព្រះបាទពញាយ៉ាតទ្រង់បានលើករាជធានីពីអង្គរទៅតាំងនៅទួលបាសាន ក្នុងខេត្តស្រីសឈរ (កំពង់ចាម) ក្រោយមកតាំងនៅចតុមុខវិញដោយមូលហេតុជិតប្រទេសសៀមនិងទឹកជំនន់នៅរដូវវស្សា។ដោយសារតែស្តេចសៀមបានចូលមកឈ្លានពានទីក្រុងអង្គរជាញឹកញាប់ដូចជាស្តេចសៀមវាយបានទីក្រុងអង្គរគ្រប់គ្រងនៅទីនោះលើកទី១អស់រយៈពេល៨ឆ្នាំ ចាប់ពីឆ្នាំ១៣៥៣គ.ស.ដល់១៣៥៩គ.ស.។ លើកទី២អស់រយៈពេល៤ចាប់ពីឆ្នាំ១៣៨៣គ.ស.ដល់១៣៨៤គ.ស.។ ហើយពួកវាតែងតែលើកបុត្រារបស់វាឱ្យសោយរាជ្យនៅទីក្រុងអង្គរជាបន្តបន្ទាប់ដូចជា៖

- ព្រះចៅបាអាតសោយរាជ្យពីឆ្នាំ ១៣៥៣គ.ស.-១៣៥៥ គ.ស.
- ព្រះចៅបាសាត សោយរាជ្យពីឆ្នាំ ១៣៥៦គ.ស.-១៣៥៩ គ.ស.
- ព្រះចៅកំបង់ពិសី សោយរាជ្យនៅឆ្នាំ ១៣៥៩ គ.ស.
- ព្រះឥន្ទរាជាឬពញាព្រែក សោយរាជ្យពីឆ្នាំ ១៣៨០គ.ស.-១៣៨៤ គ.ស. [1]។

### **១.១.៣. អស្ថិរភាពនៃរាជធានី**

តំបន់ទួលបាសានជាតំបន់ដែលព្រះបាទពញាយ៉ាត តស៊ូប្រឆាំងនឹងសៀមដែលទ្រង់បានបង្កើតមូលដ្ឋានកងទ័ពនៅទីនោះ។ ក្រោយមកដោយសារតំណបន់នោះរងគ្រោះថ្នាក់ដោយសារទឹកជំនន់ខ្លាំងនៅរដូវវស្សា ទើបព្រះអង្គក៏បញ្ជាឱ្យលើករាជធានីពីទួលបាសានទៅតាំងរាជធានីថ្មីនៅចតុមុវិញ។ ក្រោយ

[1] -អេង សុត មហាបុរសខ្មែរ ឆ្នាំ ២០០៩

ពីការកសាងរាជធានីរួចរាល់ព្រះរាជាទ្រង់បានប្រទាននាមថា៖ ក្រុងចតុមុខមង្គលសកលកម្ពុជាធិបតី សិរីធរបវរឥន្ទបត្តបុរីរដ្ឋរាជសីមាមហានគរ។

## ១.១.៤. ចតុមុខនិង រាជធានីសំខាន់ៗ

តាមប្រភពរឿងព្រេង និងរាជពង្សាវតាខ្មែរបាននិយាយថាទីក្រុងភ្នំពេញមានប្រវត្តិនៃការកកើតដូចខាងក្រោម៖

កាលនោះមានស្ត្រីមេម៉ាយម្នាក់មានទ្រព្យសម្បត្តិស្តុកស្តម្ភឈ្មោះថាដូនពេញ។ ផ្ទះរបស់ គាត់ ស្ថិតនៅទីទួលមួយខ្ពស់នាត្រើយខាងលិចនៃទន្លេប្រាបឈាម (ទន្លេចតុមុខសព្វថ្ងៃ)។ ថ្ងៃមួយនារដូវវស្សាមានទឹកជំនន់មួយយ៉ាងធំនៅប្រទេសឡាវបណ្តាលឱ្យបាក់ច្រាំងរលំដើមគគីរជាច្រើនអណ្តែតមកតាមទន្លេមេគង្គមកដល់ទន្លេប្រាបឈាម។ ក្នុងចំណោមដើមគគីរទាំងអស់នោះ មានដើមគគីរធំមួយបានអណ្តែតមកទើរនៅត្រង់មាត់កំពង់ដូនពេញ។ គាត់បានបបួលញាតិមិត្តជិតខាងជិះទូកទៅចងដើមគគីរនោះ ហើយអូសយកមកលើគោក។ អ្នកទាំងនោះរើសំរាមនៅគល់គគីរ ស្រាប់តែឃើញព្រះពុទ្ធរូបបួនអង្គ និងរូបបដិមាថ្មជាព្រាហ្មណ៍ នៅក្នុងប្រហោងដើមគគីរនោះ។ អ្នកស្រុកបានដង្ហែរបដិមាទាំងនោះទៅតម្កល់ទុកនៅផ្ទះដូនពេញ។ ក្រោយមកគាត់បានឱ្យគេជញ្ជូនដីជាដំបូកយ៉ាងធំ នៅភាគខាងឦសានផ្ទះគាត់ ព្រមទាំងឱ្យគេយកដើមគគីរនោះសង់ព្រះវិហារតូចមួយលើទួលដែលបានពូនរួច បន្ទាប់មកគាត់បាន យកព្រះពុទ្ធរូបទាំងនោះទៅតម្កល់ក្នុងព្រះវិហារដែលបានសង់រួចក្នុងឆ្នាំ ១៣៧២គ.ស.។ ក្រោយមកទៀតដូនពេញបានឱ្យគេសង់ខ្ទមមួយនៅខាងទិសឦសាននៃព្រះវិហារ រួចយកព្រះបដិមាថ្មទៅតម្កល់ទុកនៅទីនោះដោយដាក់ឈ្មោះថា អ្នកតាព្រះចៅតរៀងមក( សព្វថ្ងៃគេហៅថា លោកតាព្រះចៅ)។ ពីធីបុណ្យសម្ពោធក៏ត្រូវប្រារព្ធធ្វើឡើងដើម្បីសម្ពោធព្រះពុទ្ធសាសនាយ៉ាងអធិកអមធម។ មូលហេតុនេះហើយទើបភ្នំនោះគេឱ្យឈ្មោះថាភ្នំដូនពេញក្រោយមកឈ្មោះនោះនៅសល់ត្រឹមភ្នំពេញដូចយើងហៅសព្វថ្ងៃនេះ[2]។

### មូលហេតុដែលមកតាំងរាជធានីនៅចតុមុខ

ចតុមុខជាទីតាំងដ៏ល្អ(ភ្នំពេញ) ដែលស្ថិតនៅត្រង់ទីប្រសព្វទន្លេធំ និងទន្លេសាបគឺត្រង់ទន្លេចតុមុខជាក្រុងដែលមានកំផែងព័ទ្ធជុំវិញអាចត្រួតពិនិត្យជំនួញ ដែលមកពីប្រទេសឡាវ ក៏ដូចជាជំនួញក្អម ផ្ទាំង ត្រីងៀត ទឹកត្រីមកតាមទន្លេសាបពិសេស ទំនិញនាំចូលពីប្រទេសចិន។ ហើយតំបន់នេះមានជនជាតិខ្មែររស់នៅយ៉ាងច្រើននៅពេលដែលប្រទេសកម្ពុជាសម្រេចចិត្តក្លាយជាប្រទេសធ្វើជំនួញមក។ ឯការ តាំងរាជធានីនៅតំបន់អង្គរលែងមានន័យទៀតហើយ ក្នុងវិស័យសេដ្ឋកិច្ច។ ម្យ៉ាងទៀតចតុមុខជាតំបន់ដែលងាយស្រួលធ្វើពាណិជ្ជកម្ម ហើយឆ្ងាយពី អយុធ្យា ស្រួលធ្វើជំនួញជាមួយចិន ចាម លាវ យួន និងជាមណ្ឌលចាស់របស់ហ្វូណន។

### ប្រវត្តិនៃការកសាងរាជធានីចតុមុខ

ក្រោយពីសម្រេចព្រះទ័យមកតាំងរាជធានីចតុមុខមកព្រះពញាយ៉ាតត្រាស់បង្គាប់ឱ្យ សម្តេចចៅពញាកែវ និងឧកញ៉ាហោរាធិបតីខៀវ ព្រមទាំងមន្ត្រីឯទៀតឱ្យទៅពិនិត្យមើលដីតំបន់ ភ្នំពេញ។ លុះធ្វើការពិនិត្យតាមក្បួនសព្វគ្រប់ហើយមន្ត្រីទាំងនោះថ្វាយដំណឹងទៅព្រះរាជាថា ទិសអាគ្នេយ៍នៃភ្នំដូនពេញ

[2] -ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ១៩៧៣

មានជ័យភូមិល្អល្មមសាងរាជធានីបាន ព្រះអង្គបានត្រាស់ឱ្យអស់មេស្រុកកេណ្ឌរាស្ត្រមកជួយកសាងរាជធានីលើកដីធ្វើកំពែងសង់ប្រាសាទ និងតំណាក់តូចធំប្រើរយៈពេលយ៉ាងខ្លី។ លុះសង់រួចហើយព្រះអង្គយាងមកគង់នៅភ្នំដូនពេញដោយមាននាម៉ឺនសព្វមុខមន្ត្រីដង្វែរមកជាមួយផង។ ពេលមកដល់ទ្រង់ត្រាស់បង្គាប់ចៅពញាតេជោ មេស្រុកខេត្តសំរោងទងឱ្យកេណ្ឌរាស្ត្រលើកដីចាក់បំពេញនៅ ជុំវិញវត្តភ្នំ។ ព្រះរាជាទ្រង់ត្រាស់បង្គាប់ឧកញាវង្សាងនុជិតផ្លុង ជាមេស្រុកខេត្តបាទីឱ្យជីកព្រែកបង្ហូរទឹកទន្លេឱ្យចូលទៅបារាយ៍ក្នុងរាជធានីដើម្បីយកទឹក ប្រើប្រាស់ជូនដល់រាស្ត្រ ព្រែកនោះគេត្រូវហៅថា ព្រែកឧកញ៉ាផ្លុង។ បើតាមការស្រាវជ្រាវទៅឃើញថា ពីដើមព្រែកនេះស្ថិតនៅតាម បណ្តោយសួនច្បារ នៅមុខស្ថានីយ៍កណ្តាលនៃអយស្ម័យយាន្ត គឺស្របនឹងវិថីបន្ទាយព័ទ្ធជុំវិញរាជធានី។នៅទិសខាងត្បូងជាព្រែកតាកែវ ខាងលិចជាព្រែកអូរគរខាងជើងជាព្រែកពោងពាយឬព្រែកចិនជំដែកព្រោះនៅកន្លែងនោះមានជនជាតិចិនរកស៊ីបរជំដែក។ ក្រៅពីមុខងារការពារក្រុងព្រែកទាំងនោះមានមុខងារសំខាន់ម្យ៉ាងទៀត គឺយកទឹកសម្រាប់ឱ្យរាស្ត្រធ្វើស្រែ។ រាស្ត្រនិងមន្ត្រីគ្រប់ស្រទាប់ជាន់ថ្នាក់បានសង់គេហដ្ឋានរៀងៗខ្លួនក្នុងបរិវេណរាជធានី។ក្រោយមកព្រះរាជា ប្រទាននាមព្រះនគរថា ក្រុងចតុមុខមង្គលសកលកម្ពុជាធិបតីសិរីធរបវរឥន្ទបត្តបុរីរដ្ឋរាជសីមាមហានគរ។ ចំណែកឯទន្លេប្រាបឈាមត្រូវបានប្រសិទ្ធិនាមថ្មីជា ទន្លេចតុមុខ វិញ។ ក្រោយមករាជបុត្រច្បងនាម នារាយណ៍រាជា ទ្រង់ជាឧបរាជ ដែលគង់ក្នុងព្រះដំណាក់ជ្រោយរលួស ឯបុត្រទី២ នាមស្រីរាជាគង់នៅខាងលិចត្រង់ដីទួលមួយកន្លែងដែលគេហៅថាទួលព្រះស្រី(ម្តុំវត្តព្រះពុទ្ធសព្វថ្ងៃ)។ គ្រានោះព្រះវិហារដែល កសាងឡើងដោយដូនពេញក៏ទ្រុឌទ្រោមខ្លះទៅតាមពេលវេលា។ ព្រះបាទពញាយ៉ាត បានកសាងវិហារនោះសារជាថ្មីឡើងវិញ ព្រមទាំងពង្រីក និងពូនភ្នំនោះឱ្យខ្ពស់ជាងមុន ទ្រង់ចាត់ឱ្យក្រាលថ្មកំពូលលើ និងកសាងចេតិយមួយយ៉ាងធំ ពីខាងក្រោយព្រះវិហារ។ បន្ទាប់មកទ្រង់បញ្ជាឱ្យគេយកពុទ្ធបដិមា ដែលនៅសេសសល់នៅនគរវត្តព្រមទាំងយករូបសិង្ហតោមកតម្កល់និង តាំងនៅលើភ្នំនោះ។ ពិធីត្រូវបានប្រព្វឡើងបីថ្ងៃ គេយកបដិមាដែលដូនពេញយកពីដើមគគីរ ពីមុនមកនោះ ទៅតម្កល់ជាន់ខាងលើនៃចេតិយធំ ឯព្រះពុទ្ធបដិមាដែលយកពីនគរវត្តត្រូវបានតម្កល់នៅជាន់ខាងក្រោម។ វត្តភ្នំដូនពេញត្រូវបានប្រសិទ្ធិនាមថ្មីជា វត្តព្រះចេតិយ៍បព៌តវិញ។ ក្រៅពីនេះទ្រង់បានឱ្យគេ កសាងវត្តអារាមជាច្រើនកន្លែងក្នុងរាជធានីដូចជា វត្តពីរនៅខាងកើតវត្តភ្នំគឺ វត្តធម្មលង្ការ និងវត្តកោះ វត្តមួយនៅខាងត្បូងអូរចិនជំដែកគឺ វត្តព្រះពុទ្ធឃោសោ(សព្វថ្ងៃហៅថាវត្តព្រះពុទ្ធឃោសោរាម ឬវត្តចិនជំដែក) នៅជាប់នឹងវត្តពិភទ្ធរង្សីមានវិថីឧកញា អ៊ុំ ខ័ណ្ឌកណ្តាល។នៅខាងមុខវិហារនោះសព្វថ្ងៃ គេឃើញមានរូបទ្វារបាលពីនាក់ជារូបចិន ដែលគេមើលស្គាល់តាមលក្ខណៈ មុខមាត់ សម្លៀកបំពាក់ និងគ្រឿងអាវុធ វត្តមួយនៅមាត់ទន្លេក្បែរព្រែកឧកញ៉ាផ្លុងគឺវត្តពាម ផ្លុង និងវត្តមួយទៀតនៅត្រង់ចេតិយធំគឺ វត្តឧណ្ណាលោម និងវត្តបទុមវតី។ បើតាមអក្សរចរឹកតម្កល់នៅទីនោះពញាយ៉ាតបានកសាងវត្តនេះនៅឆ្នាំ១៤៤២គ.ស. លើកទីមួយមានទំហំ(២០២ម-២៦០ម)វត្តនេះគេហៅថាវត្តខ្លបតាយ៉ងព្រោះនៅខាងត្បូងវត្តនេះមានខ្លបតាយ៉ង។ ហើយព្រះវិហារវត្តនេះត្រូវបាន កសាងថ្មីពីរលើកទៀតៈ

- កសាងលើកទី១:នៅឆ្នាំ ១៨៦៥គ.ស. ក្នុងរជ្ជកាលព្រះបាទនរោត្តម
- កសាងលើកទី២:នៅឆ្នាំ១៩៣៧គ.ស. ក្នុងរជ្ជកាលព្រះស៊ីសុវត្ថិមុន្នីវង្ស

វត្តឧណ្ណាលោមនៅរក្សាឈ្មោះ ដែលឈ្មោះនេះយកតាមចេតិយដែលគេបញ្ចុះសពព្រះឧណ្ណាលោមគឺរោងប្រជុំចិញ្ចើមនៃព្រះអស្សជិតត្ថេរមុខវត្តនេះជិតមាត់ទន្លេទ្រង់ឱ្យសាងរូបអ្នកតាចាំស្រុកគឺអ្នកតាប្រាជ្ញ[3]។

- រាជវង្សពញាយ៉ាត ទ្រង់គង់នៅរាជធានីចតុមុខមានរាជបុត្របីអង្គគឺ៖

- ព្រះនារាយណ៍រាជា( ១៤៦៣គ.ស.-១៤៦៩គ.ស.) ជារាជបុត្រអ្នកម្នាងទេវី(ឯកសារខ្លះថាជារាជបុត្រអ្នកម្នាង ស្រីសៀមស្រងៀម ឬស៊ីសាងាម)។

- មកដល់ឆ្នាំ១៤៦៣គ.ស. ព្រះពញាយ៉ាតបានផ្ទេររាជ្យឱ្យបុត្រច្បង នារាយណ៍នៅឆ្នាំ១៤៦៦ គ.ស. ក្រោយមកទ្រង់ សោយទីវង្គតដោយជរាពេគ។ បន្ទាប់មកនៅឆ្នាំ១៤៦៧គ.ស.ទ្រង់បានក៏សាងចេតិយ៍នៅលើភ្នំដូនពេញដើម្បីបញ្ចុះអដ្ឋិធាតុព្រះបិតា។

- ស្រីរាជា( ១៤៦៩គ.ស.-១៤៨៥គ.ស)ជារាជបុត្រអ្នកម្នាងបុទុមកេសរ(អ្នកម្នាងចន្ទឬចាន់) ព្រះនារាយណ៍រាជាស្នងរាជ្យបាន៥.៦ វស្សាក៏សុគត។ ដោយបុត្រទ្រង់នៅក្មេងពេក ទើបរាជវង្សានុវង្ស និងនាម៉ឺនសព្វមុខមន្ត្រីយាងស្រីរាជាឱ្យឡើងសោយរាជ្យស្នងព្រះជេដ្ឋា។ នៅពេលព្រះអង្គឡើងគ្រងរាជ្យ ដោយមើលឃើញទឹកដី បាត់បង់អស់ច្រើន ក៏បានរៀបចំកងទ័ពឆ្ពោះទៅទិសខាងលិចដើម្បីរំដោះខេត្តភាគខាងលិចមកវិញវាយយកខេត្តបានជាច្រើនមកវិញ តែដោយសារក្បួយសុរិយោទ័យនិង ព្រះអនុជធម្មរាជាក្បត់ក៏ដកទ័ពមកវិញហើតាំងរាជធានីនៅកំពង់សៀម។

- ធម្មរាជា( ១៤៨៦គ.ស.-១៥០៤គ.ស.)ជារាជបុត្រអ្នកម្នាងស្រីសៀមស្រងៀមឬស៊ីសាងាម។ គ្រងរាជ្យនៅ រាជានីចតុមុខដោយកក្បត់នឹងបងប្អូនឯងលួចទាក់ទងសៀមមកជួយធ្វើអន្តរាគមន៍ក្នុងវិបត្តិរាជវង្សខ្មែរ។

- ស្តេចកនឬព្រះស្រីជេដ្ឋាធិរាជរាមាធិបតី (១៥១៤គ.ស.) នៅពេលធ្វើសង្គ្រាមឈ្នះព្រះបាទស្រីសុគន្ធបទរួចហើយបានតាំងរាជានីនៅបន្ទាយព្រៃនគរ (ក្រុងស្រឡប់ពិជ័យព្រៃនគរ)។

- ព្រះបាទចន្ទរាជា(ឆ្នាំ១៥១៧គ.ស.) ក្រោយពេលភៀសខ្លួនទៅប្រទេសសៀមអស់រយៈពេល ៨ឆ្នាំ នៅពេលដឹងថាស្តេចកនក្បត់ ក៏រកល្បិចកុហកស្តេចសៀមដើម្បីចូលមកក្នុងប្រទេសវិញដោយនាំទ័ពមកជាមួយ៥០០០នាក់ កំចាត់ស្តេចកន ពេលចូលមកដល់ខេត្តបាត់ដំបងក៏កែនទ័ពបាន១០០០០នាក់ហើយក៏បានរៀបចំបន្ទាយនៅពោធិសាត់ និងបរិបូណ៌។

## ១.២. កម្ពុជាក្នុងបរិបទតំបន់និងពិភពលោក

### ១.២.១. នយោបាយពាណិជ្ជកម្មជាមួយចិន

ទំនាក់ទំនងជាមួយបរទេសក្នុងរាជព្រះបាទពញាយ៉ាត ចំពោះការទំនាក់ទំនងជាមួយបរទេសវិញ យើងឃើញថាមានប្រទេស ចិន យួន លាវ ចាម ជ្វា បាននាំគ្រឿងបណ្ណាការមកក្រាបទូលថ្វាយ ពឹងបុណ្យបារមីជាច្រើនចំពោះព្រះពញាយ៉ាត។ការទំនាក់ទំនង ជាមួយប្រទេសចិននៅឆ្នាំ១៤២១គ.ស. ទ្រង់បានបញ្ជូនរាជទូតខ្មែរទៅគាល់ព្រះចៅក្រុងចិន។ រាជទូតរូបនេះ បាននាំយកព្រះរាជសារដែលព្រះរាជាបានសរសេរដោយព្រះហស្តផ្ទាល់តម្កល់ក្នុងហិបមួយធ្វើពីមាស ដែលត្រូវថ្វាយជាជង្វាយដល់ ព្រះចៅក្រុង

---

[3] -នួន សុនិមន្ត ប្រវត្តិសាស្ត្រខ្មែរសង្ខេប ឆ្នាំ២០០៩

ចិន និង ដង្វាយមាន ដំរី ភ្លុកដំរី ល័ក្ខ ក្រមួន គ្រឿងក្រអូប និងសត្វក្ងោក...។តែការទំនាក់ទំនងនេះត្រូវបានផ្អាកចាប់ពីឆ្នាំ១៤៣៥គ.ស.ដែលបញ្ជាក់ថាៈ (តាមក្រមនៃស្ថាប័នរាជវង្សមីងឆ្នាំទី៣គីងថៃនៃរជ្ជកាល Tai tsoung គេបានថ្វាយទៅព្រះចៅប្រទេសចិននៅក្រណាត់សូត្រប៉ាក់២ផ្ទាំងសំពត់ផ្កា ស្បៃធ្វើពីសូត្រ៤ផ្ទាំង នៅពេលធ្វើដំណើរត្រឡប់មកស្រុកវិញនាយក្រុម ភស្តុភារនៃខេត្តក្វាងតុង បានទទួលបញ្ជាឱ្យធ្វើបដិសណ្ឋារកិច្ចចំពោះពួកនេះទៀត។

### ១.២.២. ការប្រកួតប្រជែងពាណិជ្ជកម្មនៅអាស៊ី

មជ្ឈមណ្ឌលអំណាចថ្មីនេះបានតាំងនៅចំណុចប្រសព្វគ្នា នៃទន្លេមេគង្គ និង ទន្លេសាប។ ដូច្នេះរាជធានីចតុមុខនេះបានគ្រប់គ្រងខាងពាណិជ្ជកម្មតាមដងទន្លេ ដែលជាទឹកដីបេះដូងនៃប្រទេសខ្មែរនិងនគរលាវ ហើយមានច្រកចេញចូល តាមច្រកនៃដីសណ្តទន្លេមេគង្គ ទៅកាន់ផ្លូវពាណិជ្ជកម្មអន្តរជាតិដែលបានតភ្ជាប់ឆ្នេរសមុទ្រចិន តាមរយៈសមុទ្រចិនខាងត្បូង និង មហាសមុទ្រឥណ្ឌា។ ប្រភេទនៃរដ្ឋ និងសង្គមថ្មីបានលេចឡើង ហើយកាន់តែបើកចំហដល់ពិភពលោកខាងក្រៅ និងកាន់តែពឹងផ្អែកលើវិស័យពាណិជ្ជកម្មជាប្រភពភោគទ្រព្យជាង រដ្ឋមុនៗដែល ពឹងផ្អែកពាណិជ្ជកម្មខាងក្នុងដីគោក។ ទំហំនៃពាណិជ្ជកម្មតាមសមុទ្រជាមួយចិនសម័យរាជវង្សមីង (១៣៦៨គ.ស.-១៦៤៤គ.ស.) បានផ្តល់នូវឱកាសទាញយកផលប្រយោជន៍ជាច្រើនដោយពួកក្រុមសមាជិក នៃពួកអ្នកមុខអ្នកការខ្មែរដែលជាអ្នកក្តោបក្តាប់ផ្តាច់មុខខាងពាណិជ្ជកម្មរបស់ព្រះមហាក្សត្រ។ ការបង្ហាញខ្លួននៃពួកអឺរ៉ុបនៅក្នុងតំបន់នេះនៅសតវត្សទី១៦ក៏បានលើកស្ទួយដល់វិស័យពាណិជ្ជកម្មផងដែរ។

### ១.២.៣. ឥទ្ធិពលលើកម្ពុជា

ជនជាតិអឺរ៉ុបមានពួកព័រទុកាល់និងអេស្ប៉ាញជាដើម បានប៉ុនប៉ងយកសាសនាគ្រឹស្តមកផ្សាយក្នុងប្រទេសខ្មែរចាប់ពីពាក់កណ្តាលទី២គ.ស.ទី១៦។ ទោះបីប្រជាជនខ្មែរភាគច្រើនមិនចូលចិត្តក៏ទ្រង់បានទទួលរាក់ទាក់និងផ្តល់ជំនួយផ្សេងៗ ជាច្រើនដល់អ្នកផ្សាយសាសនា ក្នុងបំណងឱ្យពួកបព្វជិតជាអ្នកជួយអន្តរាគមន៍សុំជំនួយទ័ពមកទប់ទល់និងសត្រូវខាងក្នុង និងខាងក្រៅប្រទេសក៏ដោយក៏ការប៉ុនប៉ងផ្សាយសាសនាថ្មីនេះតែងទទួលបានបរាជ័យគ្រប់ពេលវេលា។

#### ក. ផ្នែកនយោបាយ

ព្រះរាជាមានអំណាចខ្លាំងទោះបី លទ្ធិទេវរាជត្រូវខ្មែរបោះបង់ចោលជាស្ថាពរ តាំងពីបដិវត្តន៍នាយត្រសក់ផ្អែមមកម្ល៉េះក៏ដោយព្រះមហាក្សត្រ នូវមានលក្ខណៈពិសិដ្ឋពុំមានជនណាល្មើស បានឡើយហើយដែលគេនិយមហៅថាព្រះសម្មតិទេព គឺថាជាជនខ្ពង់ខ្ពស់ផុតគេឬក៏ជាទេវតាដោយសន្មត់ក្នុងចំណោមមនុស្សជាអាណាប្រជានុរាស្ត្ររបស់ព្រះអង្គ។ លក្ខណៈពិសិដ្ឋរបស់ព្រះមហាក្សត្រ ខាងលើនេះគឺបានមកពីពិធីរាជាភិសេកឱ្យឡើងសោយរាជ្យសម្បត្តិ។ ពាក្យសោយនេះខ្មែរពីបុរាណលោកបាន ប្រើជាហូរហែររៀងមកមានភស្តុតាងក្នុងសិលាចារឹកជាដើម តែលោកសរសេរថាស្វេយទៅវិញ។ គួរគប្បីជ្រាបថាក្សត្រអង្គណាដែលមិនទាន់បានអភិសេក ហើយគ្រាន់បានទទួលរាជ្យសម្បត្តិ គ្រប់គ្រងរាស្ត្របណ្តោះ អាសន្នសិននោះតាមក្បួនលោកឱ្យហៅថាគ្រងរាជសម្បត្តិដូចជាករណី របស់ព្រះបរមរាជាទី២ចៅពញាយ៉ាតកាលដែលវាយរំដោះ បានរាជធានីអង្គរពីកណ្តាប់ដៃនាយទ័ពសៀម និងព្រះចន្ទរាជាកាលដែលមិនទាន់ច្បាំង

ឈ្នះ ស្តេចកនជាស្ថាពរនៅឡើយ។ ម្យ៉ាងទៀតប្រសិនបើអភិសេកក្នុងពេល ធ្វើសង្គ្រាមលោកឱ្យហៅថា សង្គ្រាមាភិសេកហើយប្រសិនបើអភិសេកក្រោយដែលបានបង្ក្រាបខ្មាំងសត្រូវឱ្យរាបទាបលោកឱ្យហៅថា ប្រាប្តាភិសេកទៅ វិញ។ ត្រង់នេះគួរគប្បីជ្រាបថាក្សត្រអាច អភិសេកសោយរាជ្យពេញលក្ខណៈជាព្រះ មហាក្សត្របានលុះណាតែមានគ្រឿងសម្រាប់រាជ្យគឺ ព្រះខាន់រាជ១ និងលំពែងជ័យ១គ្រឿងព្រះ បញ្ចក្សេត្រ។ប៉ុន្តែបើតាមឯកសារខ្មែរខ្លះ គេបានបញ្ចូលព្រះខាន់រាជនេះ ទៅក្នុងចំណោមគ្រឿង ព្រះ បញ្ចក្សេត្រវិញដែលគេហៅថាបញ្ចកកុធភ័ណ្ឌឬរាជកកុធភ័ណ្ឌគឺៈ

- ព្រះមកុដ
- ព្រះវាលវីជនី(ផ្លិតធ្វើដោយរោមសត្វពណ៌ស)
- ព្រះខាន់
- ស្វេតច្ឆត្រ
- ព្រះសុវណ្ណបាទុកា ( ស្បែកជើងមាស )

ប្រភពដដែលបាននិយាយទៀតថាៈ«កាលពេលដែលស្តេចចេញទៅ ធ្វើរាជសង្គ្រាមក៏ត្រូវយកព្រះ ខាន់ជាប់និងព្រះអង្គទៅផងជាដរាបតែមិនប្រើកាប់ សម្លាប់ផ្តេសផ្តាស់ដូចអាវុធឯទៀតទេលុះតែកាលណា សត្រូវដែលអង់អាចចូលមកដល់ព្រះអង្គដែលត្រូវប្រើអាវុធខ្លីប្រហារនោះទោះនឹងយកព្រះខាន់ប្រហារឱ្យ វិនាសទៅបានរួមសេក្តីថាត្រូវតែសម្លាប់ដោយកិត្តិយស»។ទោះបីចាប់ពីរជ្ជកាលព្រះបាទត្រសក់ផ្អែមមក ខ្មែរយើងប្រកាន់ខ្ជាប់តែព្រះពុទ្ធសាសនាហីនយាន ក៏ដោយតែព្រះខាន់រាជនិងគ្រឿងបញ្ចក្សេត្រត្រូវបាន ពួកបាគូជាអ្នកថែរក្សាយ៉ាងតឹងរឹងហើយនិងមានកិច្ចធ្វើពិធីបូជាជារៀងរាល់ខែផង។ ពួកបាគូនេះ ជា កូនចៅមានតំណរពីពួកព្រាហ្មណ៏បុរោហិតគឺពួកព្រាហ្មណ៏ដែលមាននាទីប្រារព្ធធ្វើពិធីផ្សេងៗ ក្នុងសម័យ អង្គរដែលព្រះរាជាខ្មែរភាគ ច្រើននិយមរាប់អានសាសនាព្រាហ្មណ៏ជាងសាសនាព្រះពុទ្ធ។ តាមរាជពង្សាវ តាខ្មែរថាកាលដែលស្តេចកនមានជ័យជំនះ ហើយសម្តេចឥសីភន្ទបានយកព្រះខាន់ព្រះលំពែងជ័យ និង គ្រឿងបញ្ចក្សេត្រទៅលាក់ទុកក្នុងប្រហោងដើមចំបក់មួយនៅក្នុងព្រៃ។ លុះស្តេចកនទទួលអភិសេកឡើង សោយរាជ្យព្រះអង្គទ្រង់ចាត់ឱ្យគេដើររកគ្រឿង សម្រាប់រាជ្យទាំងនោះតែរកពុំឃើញសោះ។ចំណែកឯព្រះ ចន្ទរាជាកាលដែលនាម៉ឺនសព្វមុខ មន្ត្រីសូមយាងព្រះអង្គទទួលប្រារព្ធភិសេកឡើងសោយរាជ្យសម្បត្តិនោះ ព្រះអង្គទ្រង់ប្រកែកព្រោះ រកគ្រឿងសម្រាប់រាជពុំទាន់ឃើញ។បើតាមរាជ ពង្សាវតាខ្មែរថាគ្រឿងទាំងនោះ ត្រូវរកឃើញឡើងវិញ ដោយសារក្រឡាពាសម្នាក់ដេកយល់សប្តិឃើញគេមកប្រាប់ឱ្យទៅយក។ រួមសេចក្តី មកគ្រឿងសម្រាប់រាជដូចដែលបានពោលខាងលើនេះ មានសារៈសំខាន់ណាស់។បុគ្គលដែលឡើងសោយ រាជ្យតែពុំមានគ្រឿងនេះទេ គេចាត់ទុកថាពុំមានលក្ខណៈជាស្តេចគ្រងរាជ្យពេញលេញទេ។ ដោយហេតុ នេះទោះបីមានគ្រោះថ្នាក់យ៉ាងណាក៏ដោយក៏ព្រាហ្មណ៏បាគូសេវកាមាត្យ ត្រូវខំរំដោះគ្រឿងសម្រាប់រាជ្យ នេះឱ្យបានគួយ៉ាងដូចកាលពីឆ្នាំ១៣៣២គ.ស. នៅពេលដែលសៀមវាយបែករាជធានីអង្គរក្នុងរជ្ជកាល ព្រះ បាទលំពង្សរាជា នោះពួករាជគ្រូបុរោហិតបាននាំយកគ្រឿងសម្រាប់រាជវាយទំលាយទ័ពសៀមរត់រួច ចេញទៅ។ ដូច្នោះយើងឃើញថាអំណាចរបស់ព្រះរាជាស្ថិតនៅលើរាជ ពិធីរាជាភិសេកនេះ១និងលើគ្រឿង សម្រាប់រាជនេះ១ អំណាចទាំងឡាយមានប្រភពមក ពីព្រះរាជា។ ព្រះអង្គជាអ្នកតាក់តែងច្បាប់ ប៉ុន្តែជា

ច្បាប់សាធារណៈប៉ុណ្ណោះ។ព្រះអង្គក៏ជាមេបញ្ជាការលើកងទ័ពជាតិ ហើយតែងតែលើកទ័ពផ្ទាល់ព្រះអង្គទៅប្រយុទ្ធប្រឆាំងនិងមារសត្រូវ ក្រៅប្រទេសក៏ដូចនៅខាងក្នុងប្រទេស ដោយហេតុនេះទើបយើងឃើញព្រះស្រីរាជាលើកទ័ពផ្ទាល់ព្រះអង្គ ទៅរំដោះយកអាណាខេត្តខាងលិច ព្រះចន្ទរាជាព្រះបរមរាជាទី៤និងព្រះសត្ថាទី១សុទ្ធតែបានលើកទ័ព ទៅវាយយកទឹកដីខ្មែរដែលបាត់បង់ ហើយសុទ្ធតែបានទៅដល់រាជធានីស្រីអាយុធ្យាចំណែកព្រះបរមរាជាទី៤ទ្រង់បាន លើកទ័ពទៅតទល់និងលាវដែល មកសងសឹកក្រោយពីប្រជល់ដំរីចាញ់ខ្មែរ។ ដោយសាររាជពិធីរាជាភិសេកព្រះរាជា ក៏បានក្លាយជាមេសាសនាផងដែរ។ព្រះអង្គមានសិទ្ធិជ្រើសរើសមន្ត្រីសង្ឃ និងមានសិទ្ធិដកមន្ត្រីប្រភេទនេះទៀតដោយសារព្រះរាជពិធីដដែលនេះព្រះរាជាក៏មានឋានៈ ជាម្ចាស់ជីវិតលើត្បូងមានសិទ្ធិឱ្យស្លាប់ឱ្យ រស់លើសព្វសត្វនៅលើផែនដីបានសេចក្ដីថាព្រះអង្គជាចៅក្រមដែលអាចវិនិច្ឆ័យទោសកំហុសជាយថាហេតុ ប៉ុន្តែក្នុងករណីចុងក្រោយនេះក៏ដូចក្នុងករណីផ្សេងទៀតដែរព្រះអង្គត្រូវប្រកបដោយទសពិធរាជធំមមានទានសីលជាដើម។ ដូចនេះទោះបីព្រះរាជាជាប្រភពនៃអំណាចគ្រប់យ៉ាងកាន់កាប់ អំណាចគ្រប់ប្រភេទក៏ដោយក៏ពុំមានសេចក្ដីថាព្រះអង្គជាអ្នកកាន់អំណាចផ្ដាច់ការទេ។ផ្ទុយទៅវិញ ព្រះអង្គត្រូវប្រកប ដោយសីលធម៌ឱ្យបរិបូរនិងគោរពច្បាប់ថែមទៀតផង។ ការដែលមានព្រះរាជាខ្លះដូចជាចៅពញាអននិងចៅពញាញោម ពុំគោរពក្រិត្យវិន័យសំរាប់ស្ដេចទ្រង់សោយរាជ្យហើយ បែរជាប្រព្រឹត្តអំពើអបាយមុខរំលោភលើរូបប្រពន្ធកូនអ្នកដ៏ទៃបណ្ដាលឱ្យមានភាពវឹកវរក្នុងផ្ទៃប្រទេសនោះគឺជាអំពើមិនសមរម្យចំពោះ អ្នកដឹកនាំជាតិដែលត្រូវមានករណីកិច្ចមើលសុខទុក្ខលើអាណាចក្រប្រជានុរាស្ត្រទេ។ ក្នុងសម័យកាលដែលយើងបានលើកមកសិក្សា ក្នុងទីនេះយើងឃើញថាព្រះរាជាបានសោយ រាជ្យបន្តបន្ទាប់គ្នាទ្រង់បានគង់នៅក្នុងរាជធានីបីសំខាន់គឺ រាជធានីភ្នំពេញចតុមុខរាជធានីលង្វែកនិងរាជធានីទួលបាសានស្រីសន្ធរ។ តាមព័ត៌មានដែលឯកសារផ្សេងៗ បានផ្ដល់និងតាមដែលយើងអាចពិនិត្យឃើញពេលសព្វថ្ងៃនេះឃើញថា តាំងនៅរាជធានីទាំងនោះសុទ្ធតែជា ចំណុចយុទ្ធសាស្ត្រស្ថិតនៅជិតទន្លេបឹង និងព្រៃជាឧបសគ្គ សំរាប់ការពារខ្លួនបានស្រួល។ម្យ៉ាងទៀតរាជធានីនីមួយៗសុទ្ធតែមានកំពែងនិងគូឬអូរព័ទ្ធជុំវិញហើយមានបន្ទាយសីននៅច្រើនកន្លែង សម្រាប់ ការពារទៀត។រាជធានីលង្វែកជាបន្ទាយមួយមាំមួន ជាងបន្ទាយឯទៀតនេះគឺដោយសារតែមាន ព្រៃឫស្សីយ៉ាងក្រាស់ដែលព័ទ្ធពីក្រៅគូទឹកទៀត ប៉ុន្តែនូវតែធ្លាក់ទៅក្នុងកណ្ដាប់ដៃសៀមដោយខ្មែរយើងចាញ់ល្បិចកល់គេ។

### ខ. នយោបាយក្នុងប្រទេស

គេសង្កេតឃើញមានវិបត្តិក្នុងរាជវង្សជាញឹកញាប់ ជាហេតុនាំឱ្យមានចម្បាំងគ្នាឯងក្នុងស្រុក ចម្បាំងរវាងស្រីរាជាស្រីសុរិយោទ័យធម្មារាជាអស់រយៈពេល១០ឆ្នាំ (១៤៧៥គ.ស.–១៤៨៥គ.ស.) និងចម្បាំងរវាងស្រីសុគន្ធបទ ស្ដេចកនចន្ទរាជា ឆ្នាំ១៥០៩គ.ស.-១៥១២គ.ស.និង១៥១៦គ.ស.-១៥២៥គ.ស. មូលហេតុ នៃចម្បាំងទាំង នេះ គឺបណ្ដាលមកពីការគិតប្រយោជន៏ផ្ទាល់ខ្លួន ច្រើនជាងប្រយោជន៍រួម។យ៉ាងណាមិញព្រះស្រីសុរិយោទ័យច្បាំងនិងព្រះស្រីរាជាមកតែពីប្រយោជន៏ផ្ទាល់គឺសិទ្ធិត្រូវបានស្នងរាជ្យពីបិតា ព្រះបាទស្រីសុគន្ធបទរកកលសម្លាប់ស្ដេចកន មកតែពីខ្លាចមន្ត្រីរូបនេះដណ្ដើមរាជ្យសម្បត្តិព្រះ សត្ថាទី១បានដាក់រាជ្យថ្វាយទៅបុត្រដែលសុទ្ធតែមានវ័យក្មេងៗព្រោះតែខ្លាចរាជ្យសម្បត្តិបានទៅព្រះសុរិយោពណ៌ដែលមានសមត្ថភាពនិងមានប្រជាប្រិយភាពជាង។ លុះជម្លោះបានកើតឡើងហើយអ្នកដឹក

នាំជាតិមិននិយមដោះស្រាយបញ្ហា ដោយសម្របសម្រួលគ្នាទេបែរជាសុខចិត្តទៅពឹងពាក់បរទេសជិតខាងចូលមកផ្សះផ្សាវិវាទផ្ទៃក្នុងរបស់ខ្មែរទៅ វិញ។ហេតុនេះ ហើយទើបព្រះធម្មរាជាទ្រង់បានទៅអន្ទងស្តេចសៀមឱ្យលើកទ័ពចូលមកធ្វើកលចាប់ព្រះស្រីរាជា និងស្រីសុរិយោទ័យយកទៅស្រុកសៀមអស់ទៅ។

**គ. នយោបាយក្រៅប្រទេស**

នៅពេលប្រទេសខ្មែរមិនទាន់មានកង្វល់នៅព្រំដែនខាងកើតនៅឡើយទេ ព្រោះប្រទេស ចាម្ប៉ាកំពុងតែជាប់ដៃធ្វើចម្បាំងជាមួយយួនង្វៀងដែលបានលេបទឹកដី របស់រាជាណាចក្រនេះបន្តិចម្តងៗ ប៉ុន្តែព្រំដែនខាងលិចព្រះរាជាខ្មែរបានព្យាយាមវាយរំដោះយកទឹកដីដែលត្រូវបាត់បង់ទៅតាំងពីស.វទី១៣ ហូតមក។គឺក្នុងគោលបំណងនេះ ហើយដែលព្រះស្រីរាជា ព្រះចន្ទរាជា ព្រះបរមរាជាទី៤និងព្រះសត្ថាទី១បានលើកទ័ពវាយលុករហូតដល់រាជធានីស្រីអាយុធ្យា ហើយរំដោះយកបានទឹកដីមកវិញជាច្រើនឯហេតុដែលនាំឱ្យខ្មែរមានជោគជ័យបែបនេះ គឺបណ្តាលមកពីភូមាបានលើកទ័ពចូលវាយសៀមជាញឹកញាប់វាយបានរាជធានីស្រីអាយុធ្យា២លើក ( ១៥៦៤គ.ស.និង១៥៦៩គ.ស. ) និងដាក់ប្រទេសសៀមជាចំណុះអស់រយៈ១៥ឆ្នាំទៀតផងហើយស្តេចខ្មែរបាន ឆ្លៀតយកឱកាសដែលសត្រូវកំពុងតែ ទន់ខ្សោយនោះលើកទ័ពចូលវាយបន្ថែមទៀតហើយអាច រំដោះយកបានទឹកដីដែលត្រូវបាត់បង់មកវិញ។ត្រង់ចំណុចនេះឯកសារអឺរ៉ុបនិយាយថាខ្មែរបានធ្វើសម្ព័ន្ធមិត្តជាមួយភូមា ដើម្បីវាយសៀមប៉ុន្តែឯកសារខ្មែរ មិនបាននិយាយដល់រឿងនេះទេ។ប្រភពអឺរ៉ុប ដដែលបន្ថែមទៀតថាក្រោយមកខ្មែរបានងាកទៅចងសម្ព័ន្ធមេត្រីជាមួយសត្រូវខ្លួន(សន្ធិសញ្ញាខ្មែរ-សៀមឆ្នាំ១៥៧៤គ.ស.ព្រះសត្ថាទី១ បានបញ្ជាឱ្យស្រីសុរិយោពណ៌លើកទ័ពទៅជួយសៀមវាយឈ្នះភូមា ) ប៉ុន្តែមិនបានផលល្អព្រោះក្រោយពីបានរំដោះខ្លួន ពីចំណុះភូមាសៀមគឺនៅក្នុងក្របខ័ណ្ឌពង្រីកទឹកដីគេតែប៉ុណ្ណោះ។ ម្ល៉ោះហើយនៅចំពោះមុខគ្រោះថ្នាក់ដែលតែងតែគំរាមកំហែងមកលើប្រទេសជាតិព្រះរាជាខ្មែរចាប់ពីព្រះសត្ថាទី១ តរៀងមកបានងាកទៅរកជំនួយពីពួកព័រទុយកាល់ ហើយ ក្រោយមកពួកអេស្ប៉ាញទៀត។ព្រះអង្គបានយកចិត្ត អ្នកផ្សាយសាសនាអឺរ៉ុបយ៉ាងខ្លាំងដើម្បីឱ្យពួកនេះជួយធ្វើអន្តរាគមន៍សុំជំនួយទ័ពប្រឆាំងនឹងសៀម។ ព្រះអង្គបានសន្យាថានិងបើកសិទ្ធិឱ្យពួកនេះផ្សាយសាសនាគ្រិស្តគ្រប់ទិសទី នៅព្រះរាជាណាចក្ររបស់ព្រះអង្គ នឹងជួយសង់ព្រះវិហារនិងផ្តល់ទេយ្យទានមានអង្គជាដើមដល់ពួកនេះ។ពួកអេស្ប៉ាញ នៅម៉ានីលមានបំណងចង់មកតាំងអាណាព្យាបាលភាពលើប្រទេសខ្មែរ ហើយបានបញ្ជូនទ័ពនិងអ្នកផ្សាយសាសនាមកជាច្រើនលើកច្រើនសារតែពុំសម្រេច។ នៅទីបំផុតព្រះស្រីសុរិយោព័ណដែលទ័ពសៀម ចាប់នាំយកទៅក្រុងអាយុធ្យាបានត្រលប់ចូលមកខ្មែរវិញដោយនាំយកឥទ្ធិពលរបស់សៀមមកផ្សាយទៀត។ ពួកសៀមដែលកាន់ពុទ្ធសាសនាដូចខ្មែរដែរនោះប្រឆាំងយ៉ាងខ្លាំងចំពោះការប៉ុនប៉ងផ្សាយសាសនារបស់ពួកអឺរ៉ុបជាពិសេសក្នុងរជ្ជកាលព្រះ នរេសូរ។

**ឃ. ផ្នែកពាណិជ្ជកម្មពាណិជ្ជកម្មៈ**

ដោយសារទន្លេមេគង្គជាផ្លូវគមនាគមន៍ មួយយ៉ាងសំខាន់ក្នុងក្រុងចតុមុខដោយសារតំបន់នេះមានទន្លេបែកចេញជាបួនដែលជាកន្លែងពាណិជ្ជកម្ម មួយយ៉ាងសំខាន់សម្រាប់ប្រទេសខ្មែរយើងហើយក៏ក្លាយជាកំពង់ផែមួយដែលមានឈ្មួញបរទេសចេញចូលលក់ដូរ យ៉ាងច្រើនកុះករ។ ក៏ប៉ុន្តែបើតាមប្រភពដដែលនោះឃើញថា ក្នុងរជ្ជកាលក្រោយៗមកមានឈ្មួញបរទេសជាច្រើនគឺចិន ជប៉ុនជ្វា ចាម ម៉ាឡាយូ

បានមកធ្វើជំនួញក្នុងប្រទេសខ្មែរតាមផ្លូវទឹកជាពិសេសនៅ កំពង់ផែចតុមុខនេះឯងដែលជាផ្សារលក់គ្រឿងទេស ភ្លុកដំរី ស្បែកសត្វ ជំរទឹក។

- **កសិកម្ម៖** ជាសកម្មភាពសេដ្ឋកិច្ចសំខាន់ ជាងគេព្រោះគេបានសង្កេតឃើយថាអ្នកដឹកនាំជាតិតែងតែយកចិត្តទុកដាក់និងបញ្ហាទឹកណាស់។ ក្នុងការស្ថាបនារាជធានីថ្មីម្តងៗព្រះរាជាតែងនឹកគិតទៅដល់ដីធ្លីសម្រាប់ឱ្យរាស្ត្រធ្វើស្រែចំការនិងការជីក អូរជីកប្រលាយជីកព្រែកសម្រាប់យកទឹកផ្គត់ផ្គង់ដល់មុខរបរនេះទៀត។ ក្នុងរជ្ជកាលព្រះបាទចន្ទរាជាព្រះអង្គទ្រង់បានបញ្ជាឱ្យកាប់ឆ្ការព្រៃដើម្បីពង្រីកដីស្រែចំការ ក្នុងគ្រាមានចម្បាំងគ្នាឯងក្នុងស្រុក តែកាលដល់រដូវវស្សាគេតែងតែស្រុះស្រួលគ្នា ទាំងសងខាងដើម្បីរំសាយទ័ពផ្អាកសង្គ្រាម ឱ្យទាហានត្រឡប់ទៅកាន់ទីលំនៅរៀងៗខ្លួន និងប្រកបរបរស្រែចំការ។ធ្វើយ៉ាងនេះយើងឃើញថា ដូនតាយើងយល់ច្បាស់នូវសារៈសំខាន់របស់សេដ្ឋកិច្ចក្នុងពេលចម្បាំងគឺធ្វើស្រែនឹងទឹកធ្វើសឹកនឹងបាយ។ យ៉ាងណាមិញប្រសិនគ្មានបាយទេទាហាននិងអាណាប្រជានុរាស្ត្រទូទៅនិងត្រូវដាច់ពោះស្លាប់គេក៏គ្មានលទ្ធភាពនិងធ្វើចម្បាំងតទៅទៀតដែរ។



អាវុធយុទ្ធភណ្ឌសម័យអង្គរ

- **សិប្បកម្មនិងឧស្សាហកម្ម៖**

ឧស្សាហកម្មដែលសំខាន់ជាងគេទំនងជាការស្លដែក។ មានសន្ទុះខ្លាំង។ប៉ុន្តែរបរប្រើដែកជាវត្ថុធាតុដើមមានរបរដំដែកនេះមានសកម្មភាពខ្លាំងក្នុងរជ្ជកាលព្រះថៅពញាយ៉ាត។ជាក់ស្តែងដោយមានការស្រាវជ្រាវថ្មីៗនេះដូចជាការរកឃើញស្ថានីយ៍និងឡស្លរដែកសម័យបុរាណជាច្រើនដូចខាងក្រោម៖

-ស្រុកប្រាសាទបល្ល័ង្គមានស្ថានីយ៍ ៥កន្លែង ទួលឡ៨កន្លែង

-សន្ទុងខេត្តឧត្តរមានជ័យមានស្ថានីយ៍ ១កន្លែង ទួលឡកន្លែង

-សន្ទុងស្រុកឆែបមានស្ថានីយ៍ ១១កន្លែង ទួលឡ៤៤កន្លែង

-សន្ទុងស្រុករវៀងមានស្ថានីយ៍ ៤៨កន្លែង ទួលឡ១១៧កន្លែង

-សន្ទុងស្រុកជ័យសែនមានស្ថានីយ៍ ៤៥កន្លែង ទួលឡ៥១កន្លែង

-សន្ទុងស្រុកសង្គមថ្មីមានស្ថានីយ៍ ១១កន្លែង ទួលឡ៣៦កន្លែង

-សន្ទុងស្រុកសៀមរាបមានស្ថានីយ៍ ២កន្លែង ទួលឡ៦កន្លែង[4]។

ក្នុងសម័យនោះមានការរីកចម្រើនខ្លាំងក្នុងវិស័យកសិកម្ម ដោយសារព្រះបាទពញាយ៉ាត បានរៀបចំប្រព័ន្ធជារាសាស្ត្រដោយមានគូរទឹក ព័ទ្ធជុំវិញរាជធានីដែលជារបងការពាររាជវាំង និងអាចយកទឹកពីក្នុងនោះមកប្រើប្រាស់បានថែមទៀតដោយមានការជីកប្រឡាយទៅដល់មុខផ្ទះប្រជារាស្ត្រ។ ចំណែកឯវិស័យសង្គម ហេដ្ឋារចនាសម្ព័ន្ធមិនសូវមានការរីកចំរើន ទេព្រោះដោយសារតែប្រទេសមានសង្គ្រាមរ៉ាំរ៉ៃ វិបត្តិ

[4] -លោកបណ្ឌិត ធុយ ចានធួន សៀវភៅ ថ្ម និងដែក ឆ្នាំ២០១០

ផ្ទៃក្នុងរវាងខ្សែរាជ្យគ្នាឯង និងការឈ្លានពានពីប្រទេសជិតខាងទើបធ្វើឱ្យសម័យនោះពុំសូវមានការរីកចម្រើន[5]។

## ១.៣. អាយុធ្យានិង ខ្មែរ

### ១.៣.១. វិបត្តិផ្ទៃក្នុងខ្សែរាជវង្សនិងអន្តរាគមន៍ពីសៀម

ព្រះបាទស្រីរាជាក្រោយពីបានគ្រងរាជនៅឆ្នាំ១៤៦៩គ.ស. មកព្រះអង្គបានចិញ្ចឹមចិត្តដឹក នាំប្រទេសជាតិឱ្យបានថ្កុំ ថ្កើង។ ទ្រង់មានមនសិការជាតិខ្ពស់ដែលស្រណោះចំពោះទឹកដីប៉ែកខាងលិចដែលសៀមលេបយកទៅ។ ព្រះអង្គបានរៀបចំប្រទេសឱ្យមានស្ថេរភាពដោយកសាងកំលាំងទ័ពត្រៀមសម្ភារៈសឹក និងបង្វឹកកងទ័ពឱ្យ ខ្លាំងដើម្បីត្រៀមធ្វើសឹកនឹងសៀម។ ព្រះបាទស្រីរាជាបានធ្វើសង្គ្រាមរំដោះអាណាខេត្តខ្មែរភាគខាងលិចពីសៀមនៅឆ្នាំ១៤៧៥គ.ស. ទ្រង់ប្រកាសធ្វើចម្បាំងរំដោះយកទឹកដីពីសៀមវិញ។ ទ្រង់បានដឹកនាំទ័ពដោយព្រះអង្គផ្ទាល់ហើយចាត់ឱ្យស្រីសុរិយោទ័យដែលជាក្មួយនាំកំលាំង ទ័ពប្រមូលស្បៀងដើម្បីឧបត្ថម្ភដល់សមរភូមិមុខ ឯធម្មរាជាជាឧបរាជនិងជាអនុជត្រូវបានទុកឱ្យ ថែរក្សារាជធានីចតុមុខ។ កងទ័ពខ្មែរដឹកនាំដោយទ្រង់ ផ្ទាល់ទៅទិសខាងលិច ហើយបានកំចាត់ពួកសៀមឱ្យចេញផុតពីទឹកដីខ្មែរដោយរំដោះបានខេត្តទាំង នោះមកវិញគឺបច្ចឹមបុរីនគររាជសីមា រយ៉ង់ និង ចាន់បុរី ។ ក្នុងចម្បាំងរំដោះទឹកដីនេះ ទ្រង់រីករាយណាស់ដែលបានឃើញប្រជារាស្ត្រខ្មែរដែលនៅទីនោះបានរួបរួមកម្លាំងគ្នា និងទ័ពជាតិដើម្បីកម្ចាត់ទ័ពសត្រូវសៀមចេញពីមាតុភូមិ។ ជោគជ័យដ៏ត្រចះត្រចង់នេះបានជម្រុញឱ្យព្រះអង្គសម្រេចព្រះទ័យវាយកម្ទេចកម្លាំងទ័ពសៀមឱ្យចេញផុតពី មាតុភូមិ។ បន្ទាប់មកស្រីរាជាក៏រៀបចំក្បួនទ័ពវាយលុករហូតដល់ក្រុងអាយុធ្យា។ ក្រុងនេះត្រូវបានឡោម ព័ទ្ធព្រោះទ្រង់ប្រាថ្នារំលាយរាជធានីនេះ ចោល។ តែជាអកុសលពេលនោះឧកញ៉ាចក្រីម៉ន ដែលជាប្រមុខ ទ័ពបានស្លាប់ក្នុងសមរភូមិ។ ម្យ៉ាងទៀត ទ័ពខ្មែរថមថយកម្លាំងផែនការរំលាយរាជធានីសៀមក៏ត្រូវអាក់ ខាន។ ទន្ទឹមនឹងនោះដែរវិបត្តិរាជវង្សខ្មែរក៏ផ្ទុះឡើង។ ព្រះអង្គស្រលាញ់ជាតិ ទឹកដី រាស្ត្រ និងយុត្តិធម៌ [6]។

នៅឆ្នាំ ១៤៨៥គ.ស. ព្រះបាទធម្មរាជាដោយមានបំណងចង់សោយរាជ្យតែម្នាក់ឯងបានលបលួចជាសម្ងាត់ទាក់ទងជាមួយស្តេចសៀមសុំជំនួយយោធា។ស្តេចសៀមក៏យល់ព្រមតាមសំណើរដោយបញ្ជូន កម្លាំងទ័ពសៀមមកក្នុងប្រទេសកម្ពុជា ក្នុងលេសមកសម្រុះសម្រួលព្រះរាជាខ្មែរទាំងបីអង្គដែលកំពុងមានទំនាស់។ ពេលទ័ពសៀមមកដល់ក្រុងចតុមុខ ព្រះធម្មរាជាបានរៀបចំយ៉ាងអឹកធឹក ហើយយាងព្រះចៅចក្រពត្រាធិរាជចូលគង់ក្នុងដំណាក់។ បន្ទាប់មកសេនាបតីសៀម-ខ្មែរ ចាប់ផ្តើមពិភាក្សាពីផែនការកម្ចាត់ស្រីរាជានឹងស្រីសុរិយោទ័យ។ ពេលដឹងពីសម្ព័ន្ធភាពស្តេចសៀម នឹងធម្មរាជាមក ស្រីរាជាបានកោះហៅទីព្រឹក្សាមកពិភាក្សាគ្នា ហើយទ្រង់យល់ថា ត្រូវចងមេត្រីភាពគ្នាវិញទើបល្អព្រោះកម្លាំងទ័ពខ្មែរបែកបាក់ ឯរាស្ត្រត្រូវរងគ្រោះ នឹងនឿយណាយក្នុងចម្បាំង។នៅចតុមុខមានបើកអង្គប្រជុំត្រូវបានសម្រេចយកផ្លូវការចរចារបញ្ចប់ ចម្បាំង។ កងទ័ពសៀម- ខ្មែរក៏ចេញពីចតុមុខមកដល់កំពង់សៀមហើយទ័ព្វបន្ទាយស្រីរាជា។ ឧកញ៉ាម៉ឺងចេញទៅជួបព្រះចៅសៀមនិងព្រះធម្មរាជាដើម្បីទូលពីបំណងរបស់ស្រី

---

[5] -មហាបុរសខ្មែរ ឆ្នាំ២០០៩

[6] -ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ ១៩៧៣

រាជាដែល ចង់ចងសម្ព័ន្ធមេត្រីភាព។ ព្រះរាជាទាំងពីរអង្គ ត្រេកអរជាខ្លាំងហើយក៏យាងស្រីរាជាមកប្រថាប់ក្នុងព្រះពន្លា។ ស្តេចទាំងបីអង្គបានលើកពលទាហានចេញពីកំពង់សៀមមកតាំងនៅឧដុង្គក្នុងខេត្តសំរោងទងវិញ។ក្នុងពេលជាមួយគ្នានោះដែរ ស្រីសុរិយោទ័យ ត្រូវបានគេសុំយាងមកឧដុង្គ ដើម្បីរួមពិភាក្សាបញ្ចប់សង្គ្រាម។ ក្នុងឱកាសបង្កើតកិច្ចចចារដំបូងធម្មរាជាបានស្នើរឱ្យស្តេចសៀម ធ្វើជាចៅក្រមផ្សះផ្សាទំនាស់ផ្ទៃក្នុង។ ស្តេចសៀមយល់ព្រមសម្រេច យកស្រីរាជា និងស្រីសុរិយោទ័យទៅអយុធ្យា។ ចាប់ពីពេលនោះមក ទំនាស់ផ្ទៃក្នុងក៏ត្រូវបានបញ្ចប់។

ក្រោយពីបានធ្វើអន្តរាគមន៍មកស្តេចសៀមទារយកខេត្តដែលស្រីរាជារំដោះបានពីមុននោះ។ដោយឈឺព្រះទ័យចាញ់កលព្រះអនុជ ស្រីរាជាព្រះអង្គក៏ប្រឈួនរួចសុគតនៅអយុធ្យាដោយបន្សល់ទុកពញាអុងជាបុត្រផ្ញើរនឹងព្រះចៅសៀម។ មួយឆ្នាំកន្លងមកស្រីសុរិយោទ័យក៏សុគតទៅទៀត។ ដើម្បីសងគុណស្តេចសៀម ព្រះធម្មរាជាបានប្រគល់ខេត្តខ្មែរ ឈ្លើយសឹករបស់សៀម និងព្រមទាំងបណ្ណាការជាច្រើនទៀតប្រគល់ជូនទៅឱ្យសៀមវិញ [7]។

### ១.៣.២. វិបត្តិរាជវង្សខ្មែរនិងការដណ្តើមអំណាច

ប្រទេសជាតិមួយបើមានអ្នកស្រឡាញ់អំណាច ស្រឡាញ់លុយកាក់មាសប្រាក់ និងបក្សពួកនិយម ប្រទេសនោះនឹងងាយធ្លាក់ក្នុងភាពទន់ខ្សោយដោយមិនដឹងខ្លួន (ស្រឡាញ់អំណាចដែលបានមកពីការតស៊ូអត់ធ្មត់លត់ដំខ្លួន មិនមែនយកលុយទៅទិញអំណាចទេ)។ហើយច្បាស់ជាកើតមានចម្បាំងគ្នាឯងនៅក្នុងស្រុកដែលកើតឡើងជាលើកដំបូង ក្នុងសង្គមខ្មែរនៅពាក់កណ្តាលទី២នៃ ស.វទី១៥ត្រូវបាត់ស្មាត់អស់រយៈពេលយ៉ាងយូរ ហើយបានកំរើកឡើងវិញយ៉ាងខ្លាំងនៃស.វទី១៦។

#### ក. ព្រះបាទស្រីសុគន្ធបទនិងការជ្រែករាជ្យរបស់ស្តេចកន (១៥០៤គ.ស.-១៥១២គ.ស.)

នៅពេលដែលព្រះបាទធម្មរាជាសោយទីវង្គតនៅឆ្នាំ១៥០៤គ.ស.បុត្រច្បងរបស់ព្រះអង្គគឺ ចៅពញាដំខាត់រាជាបានឡើងសោយរាជ្យស្នងព្រះអង្គ ដោយមានព្រះនាមសម្រាប់រាជ្យថា ព្រះបាទស្រីសុគន្ធបទគង់នៅរាជធានីចតុមុខ។ ក្រោយបន្តិចមក ព្រះអង្គទ្រង់សព្វព្រះហឫទ័យលើករាជធានីទៅតាំងនៅ ទួលបាសានវិញដោយ ព្រះអង្គស្វែងយល់ថាទីនោះជាចំណុចយុទ្ធសាស្ត្រមួយ មានឧបសគ្គធម្មជាតិ(បឹងធំទន្លេព្រៃញឹក)ស្រួលការពារខ្លួនជាងនៅក្រុងចតុមុខ។ ឯព្រះរាជអនុជ ពញាចន្ទរាជាត្រូវបានតែងតាំងជាមហាឧបរាជនៅឆ្នាំ១៥០៨គ.ស. ហើយនៅការពារក្រុងចតុមុខមើលខុសត្រូវលើអាណាខេត្តត្រើយខាងលិច។ តាមរាជពង្សាវតារខ្មែរបាននិយាយថា កាលដែលព្រះបាទស្រីសុគន្ធបទយាងទៅគង់នៅរាជធានីទួលបាសាននោះ ព្រះអង្គលើកនាងស (ឯកសារខ្លះឈ្មោះនាងពៅ) ជាស្នំឯកមាននាមថា កេសរបុប្ផាទើបស្រុកនោះមានឈ្មោះថា ស្រីសឈរ ដែលតមកទៀតបានក្លាប់ថា ស្រីសន្ធរ រៀងរហូតមក។ នាង ស នេះជាកូនរបស់មន្ត្រីម្នាក់ឈ្មោះពិជ័យនាគ ដែលជាពលព្រះស្រីរតនត្រ័យ។ ប្អូនប្រុសរបស់នាង ស ឈ្មោះ កៅ ឬ កន ត្រូវបានតែងតាំងជាមហាតលិក ក្រោយមកទៀតបានឡើងឋានៈជា យុនហ្លួងព្រះស្តេច មាននាទីមើលខុសត្រូវលើពលព្រះស្រីរតនត្រ័យទាំងអស់និងលើកិរិយាមារយាទនៃពលរដ្ឋទូទៅ។

[7]-ត្រឹង ងា ប្រវត្តសាស្ត្រខ្មែរ ឆ្នាំ ១៩៧៣

តាមរាជពង្សាវតារខ្មែរបាននិយាយថានៅឆ្នាំ១៥០៩គ.ស.ព្រះបាទ ស្រីសុគន្ធបទ ទ្រង់សុបិន ឃើញនាគរាជ ដេញតាមខាំព្រះអង្គ ហើយខាំពាំស្វេតច្ឆត្រថែមទៀត។ ព្រះអង្គទ្រង់បញ្ជាឱ្យហោរាទស្សន៍ទាយមើលហើយហោរាបាននិយាយ ថា មានកោលាហល អ្នកបង្កគឺ យុនហ្លួងព្រះស្តេច ដែលកើតនៅឆ្នាំរោង(នាគ)។ ស្របពេលជាមួយគ្នាមានពាក្យ បណ្តឹងមកថា មានកើតហេតុផ្សេងៗនៅក្នុងព្រះរាជាណាចក្រ។ដោយខ្លាចក្រែង ស្តេចកន ក្បត់ដណ្តើមរាជសម្បត្តិ សមដូចទំនាញរបស់ហោរានោះ ព្រះរាជាទ្រង់បានធ្វើការប្រជុំជាសម្ងាត់នៃពួកមន្ត្រីជំនិត ដើម្បីរិះរកមធ្យោបាយកំចាត់ ស្តេចកន ឱ្យបាន តែស្នំឯកក៏លបលួចស្តាប់ដឹងការណ៍ហើយផ្ញើរសំបុត្រទៅប្រាប់ប្អូនព្រះនាងជាប្រញាប់។តមកទៀត ព្រះរាជាទ្រង់បញ្ជាឱ្យ ពួកមន្ត្រីរៀបចំដង្ហែព្រះអង្គទៅក្រសាលបឹង បង់ សំណាញ់កំសាន្ត តាមចំណូលព្រះហឫទ័យដែលធ្លាប់ធ្វើពីមុនរៀងមក។ ដូចគេបានគ្រោងទុកជាមុនមែន ព្រះ រាជាទ្រង់ធ្វើកលថា សំណាញ់ព្រះអង្គជាប់សំរាមលើកពុំរួច ហើយទ្រង់បានបញ្ជាឱ្យ ស្តេចកន មុជទឹក ទៅដោះ។ ស្តេចកន ទទួលបញ្ជាហើយលោតទៅក្នុងទឹកធ្វើហាក់ដូចជាពុំដឹងខ្លួន ហើយមុជថយចេញ ពីកន្លែងនោះឆ្ងាយទៅ។ ពេលនោះពួកបរិវារដែលជាជំនិតស្មានថា ស្តេចកនបានធ្លាក់ចូលអន្ទាក់របស់ ខ្លួនហើយក៏ប្រញាប់បង់សំណាញ់ ព្រមគ្នាគ្រប់កន្លែងដែល ស្តេចកន លោតចុះទៅ ដោយមានបំណងធ្វើឱ្យ ស្តេចកន ជាប់សំណាញ់រើពុំរួច ស្លាប់នៅក្នុងទឹកនោះទៅ។លុះបានចាកផុតពីគ្រោះថ្នាក់ហើយស្តេចកន បានភៀសខ្លួនទៅដល់ខេត្តបាភ្នំ ហើយប្រើឧបាយកលបោកបញ្ឆោតពួកចៅហ្វាយខេត្តថ ខ្លួនបានទទួលបញ្ជាពីព្រះរាជាឱ្យមកកែនទ័ពទៅ កម្ចាត់មហាឧបរាជចន្ទរាជា ដែលមានចិត្តចង់ឡើងសោយរាជ្យ នៅក្រុងចតុមុខ។ ព្រះរាជា លុះត្រា ជ្រាបដំណឹងថា ស្តេចកន នៅរស់ហើយមានទ័ពប្រឆាំងនឹងព្រះអង្គ ថែមទៀតក៏ទ្រង់បញ្ជាឱ្យឪពុក និង បងស្រី ស្តេចកន សរសេរសំបុត្រហៅត្រឡប់មកវិញ។ ស្តេចកនប្រើឧបាយកលម្តងទៀតដោយប្រាប់ ទៅពួកចៅហ្វាយខេត្ត និងអ្នកស្រុកថា ហ្លួងទ្រង់តឿនពីរឿងសង្គ្រាមវិញ។ពាក្យឃោសនារបស់ ស្តេចកន បានលិចឮដល់មហាឧបរាជ ចន្ទរាជា។ ព្រះអង្គនឹកស្មានថា មានហេតុមិនស្រួលក៏នាំព្រះរាជវង្សានុវង្សប្រញាប់ប្រញាល់ភៀស ខ្លួនទៅសុំជ្រកកោននឹងស្តេចសៀមទៅ។កាលដែលយាងទៅដល់ខេត្តពោធិ៍សាត់ ព្រះ ចន្ទរាជា ទ្រង់បានទៅសំណាក់ផ្ទះមន្ត្រីម្នាក់ឈ្មោះ ពេជ្រ ហើយទ្រង់បានទទួលការទំនុកបម្រុងផ្សេងៗពីមន្ត្រីរូបនេះ។លុះដឹងថាព្រះចន្ទរាជាព្រះអនុជ ស្រីសុគន្ធបទ បានយាងចេញផុតពីប្រទេសហើយ ស្តេចកនក៏ចាប់ផ្តើមធ្វើការវាយលុកចូលរាជធានីទួលបាសាន។ព្រះរាជាទ្រង់បាន លើកទ័ពចេញតទល់ផ្ទាល់ព្រះអង្គត្រូវទទួលបរាជ័យហើយថយទៅកែនទ័ពថែមទៀតនៅក្រុងចតុមុខ។ ស្តេចកនលើកទ័ពតាមវាយបែកបន្ទាយភ្នំពេញទៀតព្រះបាទស្រីសុគន្ធបទ ថយ ទៅគង់នៅលង្វែក។ លុះបន្ទាយលង្វែកត្រូវវាយបែក ព្រះអង្គក៏យាងទៅគង់នៅស្រុកបរិបូណ៌ (អម្រឹន្ទបូរ)រួចនៅទីបំផុត ទៅគង់នៅបន្ទាយស្ទឹងសែនក្នុងខេត្តអាសន្ទុកនៅ ឆ្នាំ១៥១២គ.ស.។ ពេលនោះ យុនហ្លួងព្រះស្តេចកន ទៅតាំងទ័ពបោះបន្ទាយ នៅទួលបាសាន ហើយប្រារព្ធធ្វើពិធីលើកខ្លួនឯងឡើងជាមហាឧបរាជ។រួចស្រេចហើយ ទ្រង់បានបញ្ជា ឱ្យទ័ពលើកឆ្លងទៅបោះនៅកំពង់សៀមទៀត។ ស្តេចកន បានក្លែងសំបុត្រផ្ញើទៅហ្លួងសុំចុះចូល តែសុំម្តាយ និងបងប្អូនមកមុនសិន។ ហ្លួងបញ្ជាឱ្យឆ្លើយវិញថា ត្រូវតែស្តេចកន ចូលខ្លួនមកមុន បើពុំដូច្នោះទេនឹងសម្លាប់ម្តាយ និងបងប្អូនទាំងអស់។ ស្តេចកន លើកទ័ពទៅជិតអាសន្ទុករកឧបាយកលយកម្តាយញាតិ

សន្តានមកវិញ។ ពេលនោះមានមន្ត្រីម្នាក់ស្ម័គ្រចិត្តទទួលបំពេញកិច្ចការ នេះថ្វាយ ស្តេចកន ឈ្មោះ ឪកម៉ឺកសុរិន្ទកែវ។ កាលនោះគឺគេចោទថាមន្ត្រីរូបនេះក្បត់ ស្រាប់តែមានទាហាន២០០នាក់ជួយយកអាសានាំទៅខាងហ្លួងសុំចុះចូល។ បន្ទាប់មកឃុនហ្លួងព្រះស្តេចកននាំទ័ព ចូលវាយលុកបន្ទាយស្ទឹងសែនយ៉ាងខ្លាំង។ ដោយទ្រង់ស្វែងយល់ថាមិនអាចទប់ទល់យូរអង្វែងតទៅទៀតបាន ព្រះរាជាទ្រង់គិតដកថយតាមជើងទឹកទៅតាមខេត្តពោធិ៍សាត់ តែពេលនេះឪកម៉ឺកសុរិន្ទកែវនិងបក្សពួកបះឡើងចូលចោមធ្វើគុតព្រះអង្គបានក្នុងបន្ទាយស្ទឹងសែននោះនៅឆ្នាំ១៥១២ នៃ គ.ស.។ ព្រះរាជបុត្រព្រះអង្គនាម ពញាវជា(បុត្ររបស់អ្នកម្នាងកេសរបុប្ផា)និងបរិវារមួយក្រុមបានភៀសទៅជ្រក កោណក្នុងប្រទេសសៀមជាមួយព្រះ ចន្ទរាជា។ឃុនហ្លួងព្រះស្តេចកនត្រឡប់មកទួលបាសានវិញ ប្រកាសឱ្យរកព្រះខាន់រាជ្យ ព្រះលំពែងជ័យ និងគ្រឿងព្រះបញ្ចក្សេត្រដើម្បីឡើងសោយរាជសម្បត្តិ។

តាមពង្សាវតាខ្លះបានបញ្ជាក់ថា កាលដែលស្តេចកនឡើងសោយរាជ្យនោះ មានព្រះជន្មទើបតែ២៩វស្សាហើយ មាននាមសម្រាប់រាជ្យថា ស្រីជេដ្ឋាធិរាជរាមាធិបតី។ ព្រះអង្គទ្រង់បានបញ្ជាឱ្យមេទ័ព កៅដែលត្រូវជាឪពុកមាបង្កើតឱ្យលើកទ័ព ទៅបង្ក្រាបយកខេត្តទាំងឡាយណាដែលមិនទាន់ចុះចូលព្រះអង្គនៅ ឡើយ។ លុះបានសុខសន្តិភាពបរិបូរណ៍ឡើងវិញហើយ ព្រះអង្គលើកឪពុកមាឱ្យឡើង ឋានៈឱ្យឡើងជាស្តេចចៅហ្វាទឡ្ហៈឯពួកបរិវាឯទៀតក៏បានទទួលយសសក្តិទៅតាមគុណបំណាច់រៀង ៗខ្លួន នៅប្រមាណឆ្នាំ១៥១៤គ.ស. ព្រះបាទស្រីជេដ្ឋា ទ្រង់បានលើករាជធានីទៅតាំងនៅ ចន្លក់ជូនតី (នៅបានតែ៥ខែ) រួចលើកទៅតាំងនៅភូមិស្រឡប់នៅទល់ដែនខេត្តត្បូងឃ្មុំ និងខេត្តបាភ្នំរាជធានីថ្មីនេះ ជាបន្ទាយមួយយ៉ាងមាំដែលព្រះអង្គប្រទាននាមថា ក្រុងស្រឡប់ពិជ័យព្រៃនគរ ។

តាមរាជពង្សាវតាខ្លះបានបញ្ជាក់ថាព្រះបាទស្រីជេដ្ឋា ទ្រង់មានចំណូលហឫទ័យខាងបរបាញ់សត្វចាប់ត្រី ល្បែងស្រី ទតរបាំមហោស្រព តន្ត្រី។ ក្នុងរជ្ជកាលព្រះអង្គមានបោះប្រាក់ស្លឹង(សាច់ ប្រាក់សុទ្ធ) មានរូបនាគសម្រាប់ប្រើប្រាស់ក្នុងប្រទេស ហើយមានប្រវត្តិវិទូខ្លះបាននិយាយសេចក្តីថា នៅសម័យនោះអាណាប្រជានុរាស្ត្របានសុខសម្បូរសប្បាយថែមទៀតផង [8]។

**ខ. ចម្បាំងព្រះបាទស្រីជេដ្ឋានិងព្រះចន្ទរាជា (១៥១៦គ.ស.-១៥២៥គ.ស.)**

និយាយពី ព្រះចន្ទរាជា កាលដែលសុំជ្រកកោនជាមួយ ព្រះចៅសៀមនោះ តែងតែយករបរ ទាក់ដំរីទៅបំរើព្រះអង្គ។ លុះទ្រង់ជ្រាបថាព្រះរៀមត្រូវបក្សពួក ព្រះបាទស្រីជេដ្ឋាធ្វើគត់ហើយ ព្រះចន្ទ រាជាទ្រង់រិះរកគ្រប់មធ្យាបាយដើម្បីត្រឡប់ចូលមាតុប្រទេសវិញ។

នៅឆ្នាំ១៥១៥គ.ស. ព្រះអង្គទាក់បានដំរី ស យកទៅថ្វាយព្រះចៅសៀម ហើយសុំអនុញ្ញាតឱ្យធ្វើមាតុភូមិនិវត្តន៍ចូលស្រុកវិញ តែពុំបានសម្រេចដូច ប្រាថ្នាឡើយ ដោយហេតុនេះព្រះអង្គប្រឌិតថាមានដំរីខ្ពស់ ១០ហត្ថ(៥ម) នៅក្នុងព្រៃភូមិភាគខាងកើត នៃប្រទេសសៀម ។លុះទ្រង់ជ្រាបដំណឹងនេះហើយព្រះចៅសៀមក៏ទ្រង់ត្រាស់បញ្ជាឱ្យព្រះចន្ទរាជា ចេញទៅទាក់ដំរីនោះថ្វាយព្រះអង្គ ឱ្យបានក្នុងការបំពេញបេសកកម្មក្លែងក្លាយនេះ ព្រះចន្ទរាជា ទ្រង់បានទូលសុំពលចំនួន៥០០០នាក់ ដំរីឆ្នាក់១០គ្រឿងសាស្ត្រា វុធ ស្បៀងអាហារ និងដាវអោជ្ញាសឹក។ព្រះ ចៅសៀមក៏ទ្រង់យល់ព្រមតាមសំណូមពរគ្រប់ប្រការ។

[8] -មហាបុរសខ្មែរ ឆ្នាំ ២០០៩

នៅឆ្នាំ១៥១៦គ.ស.មុននឹងចេញបំពេញបេសកកម្មទាក់ដំរីនោះព្រះចន្ទរាជា ទ្រង់យាងទៅជួបជាសម្ងាត់ជាមួយ ពញាអុង ហើយបបួលព្រះអង្គឱ្យវិលត្រឡប់ចូលប្រទេសវិញ។ កាលណោះ ពញាអុង ជាបុត្រធម៌របស់ព្រះចៅសៀម ហើយត្រូវបានតែងតាំងឱ្យកាន់តំណែងជាចៅហ្វាយខេត្ត សុវណ្ណខាត់លោកថៃមទៀត។ ព្រះអង្គទ្រង់បានប្រកែកមិនព្រមវិលចូលមាតុប្រទេសទេ ដោយទ្រង់យល់ថា បានសុខសាន្ត និងបានយសសក្តិគ្រប់សព្វណាស់ទៅហើយ។ ដោយមិនអាចទាក់ទាញ ពញាអុង ឱ្យធ្វើតាមព្រះអង្គទេ ព្រះចន្ទរាជា ទ្រង់បានបញ្ជាទ័ពឱ្យធ្វើដំណើរឆ្ពោះទៅទិសខាងកើត ធ្វើដូចជាខំតាមដានដំរីស ហើយទីបំផុតបានទៅដល់ទល់ព្រំដែនប្រទេសខ្មែរ។ ព្រះចន្ទរាជាទ្រង់បានចាត់ឱ្យគេនាំសារទៅថ្វាយព្រះចៅសៀមថា សុំទ័ពបន្ថែមទៀត។ ប៉ុន្តែ ពញាអុង បានទៅទូលថ្វាយពីល្បិចកិច្ចកលគ្រប់សព្វរបស់ ព្រះចន្ទរាជា ព្រះចៅសៀមទ្រង់ខ្ញាល់ណាស់ហើយទ្រង់បញ្ជាឱ្យលើកទ័ពទៅនាំព្រះចន្ទរាជាមកវិញ។ ក្នុងអំឡុងពេលនោះព្រះចន្ទរាជាបានលើកទ័ពចូលដល់ទឹកដីខ្មែរស្រេចលុះដល់បាត់ដំបងព្រះអង្គបានកែនពល ១០០០០នាក់ ហើយលើកបង្គួសទៅដល់ពោធិ៍សាត់។ លោកឧកញ៉ា សូគ៌ាលោកកែវ ចៅហ្វាយស្រុកខេត្តនេះលុះបានដឹងហើយក៏ប្រញាប់ចាត់ឱ្យនាំដំណឹងនេះទៅថ្វាយព្រះបាទស្រីជេដ្ឋាធិរាជ។ចំណែកតាពេជ្រ បានប្រមូលបក្សពួកហើយទៅវាយឆ្មក់លោតចូលបន្ទាយហើយសំលាប់ចៅហ្វាយស្រុក កែវបាន។ គាត់ក៏ខិតខំបញ្ចុះបញ្ចូលឱ្យពលទាហានចូលខាងព្រះចន្ទរាជា។ ព្រះអង្គសព្វព្រះហឫទ័យយ៉ាងខ្លាំងចំពោះស្នាដៃរបស់ តាពេជ្រ ហើយបានតែងតាំងគាត់ជា ចៅពញាសួគ៌ាលោក ជាជំនួស ឧកញ៉ា សូគ៌ាលោកកែវ។ ម្យ៉ាងទៀត ព្រះបាទចន្ទរាជា បានតែងតាំង តាពេជ្រ ជាមេទ័ពធំ និងកូនទាំង៤នាក់របស់គាត់ជាមេទ័ពរង ហើយទ្រង់បញ្ជាឱ្យលើកទៅវាយយកខេត្ត ក្រគរ ខ្លុង មកគ្រប់គ្រង។ លុះបានទទួលដំណឹងពីការវិលត្រឡប់មកវិញរបស់ព្រះចន្ទរាជាភ្លាម ព្រះបាទស្រីជេដ្ឋាទ្រង់បានបញ្ជាឱ្យ ចៅហ្វាយកៅ លើកទ័ពទៅតទល់នៅត្រង់ក្រគរ។ ដែលមានពលទាហានស្លាប់ច្រើនពេក តាពេជ្រ បញ្ជាឱ្យទ័ពថយចូលទៅក្នុងបន្ទាយពោធិ៍សាត់សិន។ ព្រះបាទស្រីជេដ្ឋា ក៏ដេញតាម ហើយព័ទ្ធបន្ទាយអស់រយៈពេល១២ខែ តែវាយលុកចូលពុំបានសោះ ក៏ដកថយទៅតាំងទ័ពឆ្ងាយពីនោះដើម្បីរងចាំទ័ពជំនួយមកដល់។ នៅក្នុងកាលៈទេសៈបែបនេះហើយដែលតាពេជ្របានធ្វើពលិកម្ម បូជាជីវិត ដើម្បីទៅកែនទ័ពបិសាចមកធ្វើជាទ័ពជំនួយ បន្ទាប់ពីនេះ ការប្រយុទ្ធបង្ហូរឈាមបានកើតឡើងសារជាថ្មីម្តងទៀតរវាងទ័ពព្រះចន្ទរាជានឹងព្រះស្រីជេដ្ឋា។នៅលើកនេះជ័យជំនះក៏បានទៅ ខាង ព្រះចន្ទរាជា ចំណែកឯចៅហ្វាយកៅ បាក់ទ័ពថយទៅត្រើយខាងកើតវិញ។ក្នុងដំណើរជម្រុញទៅខាងមុខព្រះចន្ទរាជាបានលើកទ័ពវាយយកខេត្តជាច្រើនបន្តបន្ទាប់គ្នា។គ្រានោះមានគ្នាខាងព្រះបាទស្រីជេដ្ឋាដែលទទួលបរាជ័យនោះមកសុំចូលជាច្រើន ឯពួកដែលរត់ពួនកាលព្រះបាទស្រីសុគន្ធបទច្បាំងចាញ់ បានចេញមកថ្វាយខ្លួនទាំងអស់។ ពួកនេះបានសុំឱ្យព្រះចន្ទរាជាឡើងសោយរាជ្យ ព្រះអង្គក៏ព្រមឡើងគ្រងរាជ្យសិន ដែលមានព្រះនាមសម្រាប់រាជថា ព្រះបរមរាជាចន្ទរាជា នៅឆ្នាំ១៥១៦គ.ស.។

នៅឆ្នាំ១៥១៧គ.ស.ដោយត្រូវទទួលបរាជ័យអស់ច្រើនលើកច្រើនសារមកហើយ ព្រះបាទស្រីជេដ្ឋា ស្នើរទៅព្រះចន្ទរាជា ផ្អាកសង្គ្រាមដើម្បីឱ្យរាស្ត្រធ្វើស្រែសិន។ សំណើរនេះក៏ទទួលការយល់ព្រមពីព្រះចន្ទរាជា។ដល់ពេលចេញវស្សា ព្រះបាទស្រីជេដ្ឋាបានផ្តើមការវាយលុកបន្តទៀតដោយមានប្រើកល

ល្បិចឱ្យទាហានសុំចុះចូលខាង ព្រះចន្ទរាជា ក្នុងគោលបំណងធ្វើគតស្តេចអង្គនេះឱ្យបាន តែមិនបាន សម្រេច ឯខាងព្រះចន្ទរាជាក៏មានប្រើកលល្បិចដូចគ្នា ហើយក៏មិនបានសម្រេចដូចគ្នា។ ព្រះអង្គក៏ថយទៅ គង់នៅខេត្តពោធិ៍សាត់។

នៅឆ្នាំ១៥២០គ.ស. អគ្គមហេសី បានប្រសូត្របុត្រនាម រាមាធិបតី ហើយឆ្នាំបន្ទាប់មក ស្នំ បទុម បុប្ផា បានប្រសូត្របុត្រនាម ព្រះបរមរាជា។ នៅឆ្នាំ១៥២៥គ.ស. ព្រះចន្ទរាជា ក្រោយពេលដែលទ្រង់ បានចាត់ឱ្យ ទៅទិញកាំភ្លើងធំតូចពីប្រទេសម៉ាឡាយូមកទ្រង់បានផ្តើមការវាយលុកទៅលើទ័ព ព្រះបាទ ស្រីជេដ្ឋាដែលទ្រង់បានរៀបចំធ្វើចម្បាំងដូចគ្នានេះដែរ។ ព្រះចន្ទរាជាបានលើកទ័ពចេញជាបីផ្លូវ។ព្រះអង្គ ទ្រង់នាំទ័ពទៅវាយបន្ទាយស្រីសឈរដោយផ្ទាល់ព្រះអង្គ។ ព្រះបាទស្រីជេដ្ឋា និងថៅហ្វាយ កៅខំវាយ ទម្លុះរត់ចូលទៅក្នុងបន្ទាយស្រឡប់ពិជ័យ។ ព្រះចន្ទរាជាបានបញ្ជាឱ្យលើកទ័ពទៅវាយបន្ទាយនោះទៀត។ ទីបំផុត ក្រោយពីបានតស៊ូយ៉ាងប្ដូរផ្ដាច់អស់រយៈពេល ៣ខែ ព្រះបាទស្រីជេដ្ឋាត្រូវបានគេកាត់ព្រះសិរបាន យកទៅដោតនៅមុខបន្ទាយក្រុងស្រឡប់ពិជ័យ ឯថៅហ្វាយកៅត្រូវបានគេសម្លាប់ ក្នុងបន្ទាយនោះដែរ។ ដូច្នេះ សង្គ្រាមគ្នាឯងដែលមានរយៈពេល៩ឆ្នាំ(១៥១៦-១៥២៥គ.ស.)ត្រូវបានបញ្ចប់ពេលនោះទៅ [9]។

### ១.៣.៣. វិបត្តិផ្ទៃក្នុងនិងកង្វះការដឹកនាំ

នៅពេលដែលស្រីរាជាជាប់ដៃធ្វើសង្គ្រាមជាមួយសៀមស្រីសុរិយោទ័យជាក្មួយបានឆ្លៀតឱកាស ដណ្តើមយកខេត្តមួយចំនួនដូចជា ស្រីសឈរ ត្បូងឃ្មុំ បាភ្នំ ដូនណាយនិងយកខេត្តប៉ែកខាងជើងខ្លះទៀត ដូចជា កំពង់សៀម ស្ទឹងត្រង់ ជើងព្រៃ។ល។ ហើយទ្រង់បានតាំងខ្លួនជាស្តេចបង្កើតជាអាណា ចក្រខាង កើតឡើងមក ដែលមានរាជធានីនៅស្រីសឈរ (ស្រុកស្រីសន្ធរខេត្តកំពង់ចាមសព្វថ្ងៃ) មិនតែប៉ុណ្ណោះ ទ្រង់បានរៀបចំកងទ័ពចេញទៅស្កាត់ផ្លូវស្រីរាជាទៀតផង។ ឯធម្មរាជាក៏មានគំនិតក្បត់ដែរ បានយក លំពែង និងព្រះខាន់រក្សាទុកហើយប្រកាសបង្កើតអាណាចក្រមួយឈ្មោះរាជាណាចក្រខាងលិច។ពេល ទទួលបានដំណឹងថាព្រះអនុជ នឹងក្មួយក្បត់ទ្រង់បានដកទ័ពវិលចូលមាតុភូមិវិញដោយ តាំងរាជធានីនៅ កំពង់សៀម(កំពង់ធំសព្វថ្ងៃ) ហើយបង្កើតបានជាអាណាចក្រខាងជើង។ បន្ទាប់ពីទ្រង់បានវាយបណ្តេញ ទ័ពបះបោរ ស្រីសុរិយោទ័យឱ្យ រត់ចេញពីខេត្តខាងជើងមកនៅត្រើយខាងកើតទន្លេមេគង្គវិញ។ ចម្បាំង គ្នាឯងឥតឈប់ឈរវាងរាជវង្សានុវង្សខ្មែរ បានផ្តល់ផលវិបាកដល់សង្គមគឺ រាស្ត្រខ្មែររស់នៅក្នុងភាពខ្លោច ផ្សា កើតអំពើចោរកម្ម ប្លន់កាប់សម្លាប់ គ្រោះទុរភិក្ស និងជម្ងឺរាតត្បាត អស់រយៈពេល ១០ឆ្នាំ។ ប្រទេស ខ្មែរបានជួបនូវវិបត្តិមួយដ៏ធ្ងន់ធ្ងរដែរបណ្តាលមកពីទំនាស់ក្នុងរាជវង្សខ្មែរ។

ទម្លាប់បន្តសន្តិវង្ស ជាទូទៅគេសង្កេតឃើញរាជសម្បត្តិត្រូវបានបន្តរាជ ពីបិតាជាក្សត្រគ្រងរាជ្យទៅ បុត្របានស្តេចក្តីថានាពេលដែលព្រះបិតា សោយទិវង្គតទៅឬក៏ដាក់រាជ្យ គឺបុត្រច្បងមានសិទ្ធិឡើង សោយរាជ្យស្នងហើយប្រសិនបើបុត្រច្បងត្រូវសុគតមុនសោយរាជ្យគឺបុត្រ បន្ទាប់មានសិទ្ធិស្នងរាជពីព្រះ បិតា។ដោយហេតុនេះហើយទើបយើងឃើញព្រះនារាយណ៍រាជាសោយរាជ្យស្នងពី បិតាព្រះបាទពញាយ៉ាត ព្រះសត្ថាទី១ស្នងរាជ្យពីព្រះបរមរាជាទី៤ឯព្រះបរមរាជាទី៤បានស្នងរាជ្យពីព្រះ ចន្ទរាជាព្រោះបុត្រច្បង នាមរាមាធិបតីបានសុគតមុនសោយរាជ្យ (តាមរាពង្សាវតាខ្លះថាព្រះធរណីស្រូប) ។ក្នុងករណីក្សត្រគ្រង

[9] -ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ ១៩៧៣

រាជ្យពុំមានបុត្រស្នងរាជ្យទេសិទ្ធិនេះត្រូវបានទៅព្រះអនុជជាបន្តបន្ទាប់គ្នា។ ព្រះចន្ទរាជាបានឡើងសោយរាជតំណពីព្រះបាទស្រីសុគន្ធបទ ព្រោះរាជបុត្រក្សត្រអង្គនេះ គឺពញាយសរាជាបានសុគតមុនសោយរាជ្យ។ ប្រសិនបើគេមិនគោរពទំលាប់នេះទេនោះវិបត្តិច្បាស់ជាកើតឡើងចៀសពុំបាននេះជាករណីព្រះបាទស្រីសុរិយោទ័យ ដែលត្រូវបានឡើងស្នងពីព្រះបិតាគឺព្រះនារាយណ៏រាជាតែពុំដូច្នោះបែរជាបានទៅព្រះស្រីរាជាជាអនុជសោយរាជ្យវិញជាហេតុធ្វើឱ្យមានចម្បាំងគ្នាឯងក្នុងស្រុកអស់រយៈពេល១០ឆ្នាំ(១៤៧៥នៃ-១៤៨៥គ.ស.)។ ក្នុងសម័យកាលដែលយើងលើកយកមកសិក្សានេះគេសង្កេតឃើញមានការ អន្តរាគមន៏របស់ពួកមន្ត្រីក្នុងការជ្រើសក្សត្រ ឱ្យឡើងសោយរាជ្យហើយ អន្តរាគមន៏នេះមានប្រសិទ្ធិភាពខ្លាំងណាស់ដែរ។យ៉ាងណាមិញព្រះស្រីរាជាព្រះបរមរាជាទី៧ចៅពញាអននិងព្រះស្រីសុរិយោព៌ណសុទ្ធតែបានឡើងសោយរាជ្យដោយមានការអន្តរាគមន៏របស់នាម៉ឺនសព្វមុខមន្ត្រីនេះឯង។ ក្នុងករណីដែលបុគ្គលណាមួយទោះជាមន្ត្រីជាន់ខ្ពស់ក្តីទោះជាជាប់ព្រះញាតិវង្សក្តីតែបើពុំមានសិទ្ធិទទួលរាជសម្បត្តិទេហើយបែរជាប្រើកម្លាំងអាវុធដើម្បីបានសោយរាជ្យសម្បត្តិ គេឱ្យឈ្មោះថាស្តេចជ្រែករាជ្យ(ស្តេចកនព្រះរាមាជើងព្រៃ) [10]។

### ១.៣.៤. របៀបគ្រប់គ្រងប្រទេសសម័យចតុមុខ

#### ក. រដ្ឋបាលកណ្តាល

ដោយហេតុព្រះរាជាជាប្រភពនៃអំណាចទាំងឡាយហើយពួកបរិវារបស់ព្រះអង្គសុទ្ធតែជារាជវង្សានុវង្សនិងមន្ត្រីជាន់ខ្ពស់ផងនោះគេយល់ឃើញថា គឺពួកបរិវានេះហើយជាអ្នកញ៉ាំងម៉ាស៊ីនរដ្ឋបាលកណ្តាលឱ្យដំណើរការបាន។ដូចយើងបានរៀបរាប់រួចមកហើយក្នុងវគ្គនីមួយៗពីព្រះរាជអាយ្យកាចៅហ្វាទឡ្ហៈនិងមន្ត្រីជាន់ខ្ពស់៤រូបដែលគេហៅថាចតុស្តម្ភគឺ



មន្ត្រីចតុស្តម្ភ

-ឧកញ៉ាយមរាជ(រដ្ឋមន្ត្រីកក្រសួងយុត្តិធម៌)
-ឧកញ៉ាក្រឡាហោម ( រដ្ឋមន្ត្រីក្រសួងទ័ពជើងទឹក
-ឧកញ៉ាវាំង(រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង)
-ឧកញ៉ាចក្រី ( រដ្ឋមន្ត្រីទ័ពជើងគោក )

ដូច្នេះចៅហ្វាទឡ្ហៈនិងមន្ត្រីជាន់ខ្ពស់ទាំង៤រូបនេះគេហៅថាមន្ត្រីសម្រាប់ឯកគឺជាមន្ត្រីដែលត្រូវឡើងទៅព្រះមហាក្សត្រមន្ត្រីទាំងនោះមានមុខងារញ៉ាំងរដ្ឋបាលកណ្តាលឱ្យប្រព្រឹត្តិទៅផងហើយមានអំណាចត្រួតត្រាលើខេត្តខ្លះទៀតផង។ ក្រៅពីនេះនៅមានមន្ត្រីសម្រាប់ទទួលងារត្រូវទៅជាឧភយោរាជមន្ត្រីសម្រាប់ត្រីត្រូវឡើងទៅព្រះឧបរាជនិងមន្ត្រី សម្រាប់ចត្វាត្រូវឡើងទៅ ព្រះវររាជមាតា។មន្ត្រីទាំង៤សម្រាប់នេះលើកលែងតែចៅហ្វាទឡ្ហៈចេញដែលមានឋានន្តរសក្តិ ថាសម្តេចចៅពញាសុទ្ធតែមានឋានន្តរសក្តិជាឧកញ្ញាសក្តិ១០ហ៊ូពាន់(ពាក្យសៀមមានន័យថាក្បាលពាន់គឺទ័ព១០០០នាក់ដែលនៅក្រោម

[10] -អាដេម៉ា ឡឺក្លែរ ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ ២០០៦

បង្គាប់របស់មន្ត្រីណាម្នាក់)។ ក្រៅពីមន្ត្រីជាន់ខ្ពស់ទាំងប៉ុន្មានដូចរៀបរាប់មកហើយនេះគេឃើញមាន មន្ត្រីជាន់កណ្តាលនិងជាន់ទាបជាច្រើនទៀតដែលមានឋានន្តរសក្តិ។ ចំណែកខ្ញុំរាជការដែលមិនទាន់បានទទួលយសសក្តិនៅឡើយទេនេះឱ្យហៅថានាយ។

**ខ. រដ្ឋបាលភូមិភាគ**

នៅសម័យចតុមុខមានការបែងចែក អាណាចក្រយើង ចែកចេញជាប្រមាណ៧០ខេត្តហើយខេត្តទាំងនោះត្រូវប្រមូលផ្តុំជាតំបន់។ក្នុងតំបន់នីមួយៗមានស្តេចត្រាញ់មួយអង្គឈរត្រួតត្រាជួនកាលហៅថា) ស្តេចត្រាញ់ក៏បានពាក្យនេះទំនងជាក្លាយមកពីពាក្យបុរាណដែលមានប្រើក្នុងសិលាចារិកខ្មែរ។ស្តេចត្រាញ់ មួយអង្គមាននាទីគ្រប់គ្រងតំបន់របស់ខ្លួនបើតាមឯកសារពង្សាវតាខ្មែរក្នុងរជ្ជកាលព្រះបាទធម្មរាជាទី១ មានការតែងតាំងស្តេច ត្រាញ់៥អង្គ។ ដូចបានពោលរួចមកខាងលើនេះយើងឃើញថាក្នុងខេត្តនីមួយៗ មានមន្ត្រីជាន់ខ្ពស់ម្នាក់ឈរត្រួតត្រា។ មន្ត្រីនេះគេនិយមហៅថាចៅហ្វាយស្រុកឬមន្ត្រីឈរត្រួតខេត្តទ្រាំង គេហៅថាចៅហ្វាយស្រុកខេត្តទ្រាំងតាមប្រភពរាជពង្សាវតាខ្មែរដដែលគេដឹងថាចៅហ្វាយស្រុកទាំងនោះ សុទ្ធតែជាញាត្តិរបស់ព្រះរាជាតែក្រោយមកចៅហ្វាយស្រុកទាំងនោះច្រើនតែពុំសូវគោរពកោតខ្លាចសេនាបតីទើបត្រូវទំលាក់មកនៅត្រឹមតែចៅពញា។ គួរគប្បីជ្រាបថាទីចៅពញានេះក៏ជាឋានន្តរសក្តិរបស់បុត្រស្តេចគ្រងរាជដែរ។ បើចៅហ្វាយស្រុកណាមានសក្តិ៨ត្រូវតាំងជាពញា (លាង ហាប់អាន)។

**១.៣.៥. ជំនឿនិងទំនៀមទំលាប់**

ទោះបីនៅសម័យនោះព្រះពុទ្ធសាសនាបានជ្រួតជ្រាបចូលក្នុងសង្គមខ្មែរហើយក៏ដោយក៏ជនជាតិខ្មែរយើងពុំបានលះបង់ចោលនូវជំនឿដើមរបស់ខ្លួនឡើយ។ យ៉ាងណាមិញតាំងពីព្រះរាជាដល់ប្រជារាស្ត្រតូចតាចគ្រប់ជាន់ថ្នាក់សុទ្ធតែជឿលើខ្មោចបិសាចអារក្សអ្នកតា។ល។ រាជវង្សាវតាខ្មែរបាននិយាយថាកាលកសាងរាជធានីចតុមុខព្រះបរមពញ៉ាយ៉ាត ទ្រង់ចាត់ឱ្យសាងខ្លាងមឿង (អ្នកតាចាំស្រុក) មួយនៅខាងមុខវត្តឧណ្ណាលោមនិងរូបអ្នកតាទុកជាទ្វារ ព្រះនគរបង្ការសឹកសង្គ្រាមពីប្រទេសជិតខាង។ តាពេជ្រដែលបានបូជាជិវិតដើម្បីទៅកែនទ័ពបិសាចមកជួយអាសាព្រះចន្ទរាជាក្នុងគ្រាច្បាំងជាមួយស្តេចកននោះបានក្លាយជាអ្នកតាមួយរូបដែលប្រជារាស្ត្រខ្មែរគោរពបូជាជារៀងរាល់ឆ្នាំ។ ក្នុងវិស័យជំនឿលើខ្មោចនេះគេជឿទៀតថាដើម្បី កសាងទំនប់ទឹកឬព្រះវិហារឱ្យជាប់បានល្អគេត្រូវយកអ្នកទោសអស់ជីវិតទៅកប់ក្រោមទំនប់នោះ ឬ គេត្រូវយកខ្មោចទៅកប់ក្រោមព្រះវិហារ។ ម្យ៉ាងទៀតខ្មែរនៅគ្រប់ជាន់ថ្នាក់សុទ្ធតែយល់ថាការយល់សប្តិជាការប្រាប់ឱ្យដឹងមុនពីហេតុកាណ៍ដែលបំរុងនិងកើតឡើងម្ល៉ោះហើយទើបគេឱ្យទស្សន៍ទាយមើលពុំដែលខានជាពិសេសក្នុងមជ្ឈដ្ឋានបរមរាជវាំងដែលពួកហោរាជាមន្ត្រីមួយប្រភេទចាំ តែបំពេញមុខការខាងទស្សន៍ទាយនេះឯង។ក្រៅពីនេះខ្មែរនៅមានជំនឿមាំលើពាក្យសម្បថ ដែលគេយល់ថាមានលក្ខណៈសក្តិសិទ្ធិណាស់។ពួកនាម៉ឺនសព្វមុខមន្ត្រីពួកសេនាទាហានសុទ្ធ តែត្រូវផឹកទឹកពិកទ្ធសច្ចាជារៀងរាល់ឆ្នាំជាការសំដែងភក្តីភាពរបស់ខ្លួនចំពោះព្រះមហាក្សត្រ។

រាជវង្សាវតាខ្មែរបានកត់ទុកនូវពិធីជាទំនៀមទំលាប់ យ៉ាងសំខាន់ពីរគឺពិធីបុណ្យចូលឆ្នាំខ្មែរ១និងពិធីបុណ្យអុំទូក១។ បុណ្យចូលឆ្នាំខ្មែរទំនងជាពិធីសំខាន់ជាងគេពីព្រោះទោះបីមានកើតចម្បាំងគ្នាឯងក៏ដោយក៏ត្រូវផ្អាកចម្បាំងនោះសិនដើម្បីបានរៀបចំពិធីបុណ្យនេះ។ ឯពិធីបុណ្យអុំទូកជាឱកាសមួយដែល

គេធ្វើការប្រណាំងទូកនិងអុជកាំជ្រួច។ គឺធ្វើដូច្នោះដើម្បីថ្វាយចង្កូមកែវនៅតំកល់ឯពិភពនាគឯការអុជកាំ ជ្រួចវន្ទាគឺថ្វាយទៅចូឡាមណីចេតិយដែលតំកល់ព្រះចង្កូមកែវនៅឋានត្រៃត្រឹង។

### ក. សិល្បៈ

សិល្បៈខ្មែរច្រើនមានទំនាក់ទំនងជិតស្និតជាមួយនិងសាសនា។ ដោយហេតុថានៅសម័យនោះខ្មែរមានជំនឿលើព្រះពុទ្ធសាសនាសិល្បៈខ្មែរក៏មានការទោទន់ទៅរក សាសនានោះដែរ។ សេចក្ដីដកស្រង់តទៅនេះអាចបង្ហាញឱ្យឃើញនូវប្រធាន និងបច្ចេកទេសក្នុងការប្រើសិល្បៈស្ថាបត្យកម្មនិងចម្លាក់ក្នុងសម័យនោះអស់មុខមន្ត្រីមេការទាំងឡាយកែនកូនជាងកសាង ព្រះមហាស្តូបព្រះចេតិយធំនិងព្រះចេតិយតូចជាបរិវាររចនាដោយថ្មខ្វាត់ខ្វែងឱ្យជាច្រើនបែបច្រើនយ៉ាងព្រះវិហារមានត្រីសូល៍កំពូល៥តាមកំផែងនិងព្រលានព្រះរាមនោះសឹងឆ្លាក់ឆ្លៅជាភាពមនុស្សគ្រុឌនាគសត្វហង្សគោក្របីនិងក្បាច់ភ្ញីផ្កាវល្លិ៍រចនាថ្លៃថ្លាប្រពៃហើយសាងព្រះពុទ្ធរូបជាបន្ទំ និងសណ្ឋិតជាច្រើនអង្គមានសីមា និងរបៀបរោងទងក្លោងទ្វារកំពូលមុខព្រហ្ម សឹងឆ្លាក់ឆ្លាវដោយថ្មកំផែងខ្វាត់ខ្វែងជុំវិញសឹងថ្មបាយអថ្មក្រោមក្រាលថ្មល្អិតហើយមានរូបសឹង្ហតោរាជសីហ៍ដំរីយក្សដាក់គ្រប់ទ្វារ។

### ខ. វប្បធម៌

អក្សរភាសាអក្សរសិល្ប៍គួរគប្បីរំលឹកឡើងវិញថាចាប់តាំងពីដើមស.វទី១៤រៀងមកគេពុំឃើញមានសិលាចារឹកនៅប្រទេសខ្មែរទៀតទេ។ លុះដល់រជ្ជកាលព្រះចន្ទរាជាទោះបីពេលនោះរាជធានីពិតប្រាកដតាំងនៅក្រុងលង្វែកក៏ដោយក៏ព្រះរាជាខ្មែរតែងនាំពួកបរិវារទៅគង់នៅតំបន់អង្គរជាហូរហែរៀងមក។ គឺក្នុងសម័យនោះហើយដែលខ្មែរបានកសាងសិលាចារឹកឡើងវិញ។ សិលាចារឹកទាំងនោះគេបានចារទុកនូវប្រាសាទ នគរវត្តជា៣អន្លើគឺនៅទីដែលហៅថាព្រះពាន់គ្រង់ដែលមានព្រះពុទ្ធរូបច្រើននោះខ្លះនៅថ្នាក់លើបំផុតដែលហៅថា បាកាណនិងនៅព្រះរបៀងថ្នាក់ក្រោម។ សិលាចារឹកទាំងនោះមានទាំងអស់៤០ផ្ទាំងមានចុះកាលកំណត់ពីឆ្នាំ១៥៦៥គ.ស.ដល់១៧៤៦គ.ស. ប៉ុន្តែសករាជដែលប្រើគឺមហាសកសរាជសេចក្ដីក្នុងសិលាចារឹកនោះនិយាយថាពីរឿងធ្វើបុណ្យផ្សេងៗ គឺប្រោសខ្ញុំឱ្យរួចជាអ្នកជាបំបួសមនុស្សលាបំណន់សាងព្រះសាងពិតាននិងថ្វាយរបស់ជាពុទ្ធបូជា។ល។ ជារបស់ស្ដេចខ្លះមន្ត្រីខ្លះនិងរាស្ត្រខ្លះ។ចំពោះសេចក្ដីក្នុងសិលាចារឹកទាំងនោះអ្នកស្រាវជ្រាវខ្មែរមួយក្រុមបានបន្ថែមសេចក្ដីទៀតថា «សេចក្ដីអស់នេះជាពាក្យរបស់អ្នកចុះចាញ់ហើយមានទីពឹងទីរំលឹកចំពោះព្រះរតនត្រ័យប៉ុណ្ណោះ ជាអ្នកសុខចិត្តទទួលសេចក្ដីលំបាកវេទនា ដោយយល់ថាជាផលនៃកម្មអាក្រក់ដែលខ្លួនបានប្រព្រឹត្តមកហើយក្នុងអតីតជាតិតែពុំបានអស់កម្លាំងសេចក្ដីប្រឹងប្រែងឡើយតែង ខំសន្សំកុសលដើម្បីសេចក្ដីសុខចំរើនដល់ខ្លួននិងដល់ប្រទេស។ភាសាដែលប្រើក្នុងសិលាចារឹកទាំងនោះ ជាភាសាខ្មែរធម្មតាក្នុងសម័យកណ្ដាលមានពាក្យពេចន៍បុរាណខ្លះដែរ តែយើងអាចមើលយល់សេចក្ដីបានច្រើន។ ជាការគួរឱ្យស្ដាយពេកណាស់សាស្ត្រាស្លឹករឹតនិងក្រាំងក្នុងសម័យនោះដែលយើងលើកយកមកសិក្សាត្រូវវិនាសបាត់បង់ខ្ទេចខ្ទីអស់ជាច្រើននេះទំនងជាសត្រូវជិតខាងកាលដែលចូលមកលុកលុយស្រុកទេសយើងគេនាំគ្នាដឹកជញ្ជូនយកទៅទុក ជាទ្រព្យសម្បត្តិផ្ទាល់ខ្លួនទៅហើយម្យ៉ាងទៀតប្រហែលជា ត្រូវភ្លើងឆេះក្នុងគ្រាមានសង្គ្រាមនោះហើយ។ ប្រសិនបើមាននៅសេសសល់គឺនៅតាមវត្តអារាមតែច្រើនពុំមានឈ្មោះអ្នកនិពន្ធ។ ចំពោះរឿងនេះមានមតិខ្លះយល់ថាមក

តែពីរបបគ្រប់គ្រងទើបធ្វើឱ្យអ្នកនិពន្ធខ្លាចរអាពុំហ៊ានបញ្ចេញឈ្មោះរបស់ខ្លួនឱ្យអ្នកផងដឹងស្គាល់ទេតែមានមតិខ្លះទៀតយល់ថាមកពីអ្នកចារមានទំលាប់អាក្រក់ លុបបំបាត់ឈ្មោះអ្នកនិពន្ធចោលហើយតាំងខ្លួនជាអ្នកនិពន្ធជំនួសទៅវិញ។ ស្នាដៃមួយដែលគេស្គាល់ឈ្មោះអ្នកនិពន្ធ ពិតប្រាកដគឺល្បើកអង្គរនិពន្ធដោយអ្នកប៉ាងក្នុងឆ្នាំ១៥៩៨គ.ស.កាព្យដែលនិយាយពីការកសាងប្រាសាទអង្គរវត្ត តាមរបៀបរឿងទេពនិទាន។ ប៉ុន្តែអ្នកស្រាវជ្រាវខ្មែរខ្លះបានដាក់កាលកំណត់រឿងនេះខិតមកមុនបន្តិចទៀតគឺនៅឆ្នាំ១៦០៩គ.ស.[11]។

## ១.៣.៦. សាសនានិងលទ្ធិផ្សេងៗ

### ក. ព្រះពុទ្ធសាសនា



ព្រះសង្ឃខ្មែរសម័យបុរាណ

ព្រះពុទ្ធសាសនាបែបហីនយានប្រើភាសាបាលី ដែលបានចូលរួមមកប្រតិស្ឋានក្នុងប្រទេសចាប់តាំងពីបដិវត្តន៍នាយត្រសក់ផ្អែមបានចាក់រឹសគល់យ៉ាងជ្រៅចូលក្នុងសង្គមខ្មែរជនជាតិខ្មែរគ្រប់ស្រទាប់ចាប់តាំងពីព្រះមហាក្សត្រដល់ប្រជារាស្ត្រតូចតាច បំផុតសុទ្ធតែមានជំនឿមុតមាំលើព្រះពុទ្ធសាសនាដែលគេបានចាត់ទុកថាជាទីពឹងទីរលឹកទោះបីគេបានលះបង់ចោលជំនឿដើមរបស់គេលើខ្មោច បីសាចអារក្សអ្នកតាបង់បត់ក៏ដោយ។ សង្គមខ្មែរលែងងាកទៅ រកសាសនាព្រាហ្មណ៍ទៀតហើយ។ប៉ុន្តែនៅព្រះបរមរាជវាំងគេឃើញមានពួកបាគូ ( ព្រាហ្មណ៍ ) ដែលគ្រាន់តែមាននាទីថែរក្សាព្រះខាន់រាជ្យព្រះលំពែងជ័យនិងគ្រឿងបញ្ចក្សត្រនិងរៀបចំព្រះរាជពិធីផ្សេងៗតែប៉ុណ្ណោះ។ ក្នុងសម័យនោះចំនួនវត្តអារាមបានកើតឡើងជាលំដាប់។ ព្រះមហាថេរដែលមាននាទីមើលការខុសត្រូវលើការរៀបចំខាងសាសនានិងលើវត្តអារាមនៅ ក្នុងខេត្តនីមួយៗលែងមានលទ្ធភាពបន្តការគ្រប់គ្រងនោះតទៅទៀតហើយ។ ដោយហេតុនេះសម្តេចព្រះសង្ឃ រាជដោយមានការព្រមព្រៀងជាមួយរាជាគណៈឋានានុក្រមនិងសហការីទាំងអស់ទ្រង់បានស្នើទៅ ព្រះរាជាសូមឱ្យមានការកែប្រែដែលមានបែបផែន។ គួរគប្បីបញ្ជាក់ម្យ៉ាងទៀតថាព្រះសង្ឃនិងវត្តអារាមក្នុងសម័យនោះមានមុខងារយ៉ាងសំខាន់ក្នុងវិស័យសង្គមកិច្ច។ យ៉ាងណាមិញព្រះសង្ឃពុំមែនគ្រាន់តែជា ស្រែបុណ្យប៉ុណ្ណោះទេតែព្រះអង្គជាអ្នកអប់រំផ្តល់ចំណេះវិជ្ជាគ្រប់បែបយ៉ាងគិតតាំងពីចំណេះខាងមុខរបរផងដល់ព្រះពុទ្ធបរិស័ទជើងវត្ត។ នេះហើយជាកត្តាមួយធ្វើឱ្យរាស្ត្រកាន់តែជក់ចិត្តលើសាសនាថែមទៀត។

### ខ. សាសនាគ្រឹស្ត

ជនជាតិអឺរ៉ុបមានពួកព័រទុកាល់និងអេស្ប៉ាញជាដើមបានប៉ុនប៉ងយកសាសនាគ្រឹស្តមកផ្សាយក្នុងប្រទេសខ្មែរចាប់ពីពាក់កណ្តាលទី២គ.ស.ទី១៦។ ទោះបីប្រជាជនខ្មែរភាគច្រើនមិនពេញចិត្តក៏ដោយទ្រង់បានទទួលរាក់ទាក់និងផ្តល់ជំនួយផ្សេងៗជាច្រើនដល់អ្នកផ្សាយសាសនាក្នុងបំណងឱ្យពួកបព្វជិតជាអ្នកជួយអន្តរាគមន៍សុំជំនួយទ័ពមកទប់ទល់និងសត្រូវខាងក្នុង និងខាងក្រៅប្រទេសក៏ដោយក៏ការប៉ុនប៉ងផ្សាយសាសនាថ្មីនេះតែងទទួលបានបរាជ័យគ្រប់ពេលវេលា។

[11] -អាដេម៉ា ឡឺក្លែរ ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ ២០០៦

### គ. លទ្ធិបុគ្គលនិយម

នៅសម័យអង្គរយើងបានឃើញថាចាប់តាំងពីស.វទី៩ដល់ស.វទី១២ គេមានភស្តុតាងជាច្រើន ដែលបង្ហាញថាព្រះរាជាខ្មែរបានកាន់លទ្ធិបុគ្គលនិយស្របពេលជាមួយ និងលទ្ធិទេវរាជ។នៅសម័យដែល យើងយកមកសិក្សានេះរាជពង្សាវតាខ្មែរបានផ្តល់ភស្តុតាងថាលទ្ធិនេះនៅតែមានសកម្មភាពបន្តទៅទៀត។ ប្រភពនេះបានផ្តល់ព័ត៌មានថាព្រះចន្ទរាជាបានក៏សាងព្រះវិហារមួយនៅ ក្នុងខេត្តលោវេ្វៀរច«ទ្រង់ត្រាស ឱ្យសាងព្រះពុទ្ធរូបឈើស្នងមួយព្រះអង្គទៀតស្នងព្រះអគ្គមហេសីព្រះភគវតីស្រីទេពធីតាកំពស់ស្មើនិង ព្រះអង្គសណ្ឋិត ម្ខាងទ្រង់សាងព្រះពុទ្ធឈើមួយព្រះអង្គទៀតស្នងសម្តេចព្រះស្រីទេវីក្សត្រីជាសម្តេចព្រះ រាជបុត្រីកំពស់ស្មើនិងព្រះអង្គសណ្ឋិតម្ខាងទៀត។ ប្រភពរាជពង្សាវតាខ្មែរ បាននិយាយថាកាលដែល សម្តេចចៅហ្វាជុតជំទាវទេវីនារីសោភ័ណដៃ ដែលត្រូវជាបិតាមាតា សម្តេចព្រះអគ្គមហេសីស្រីទេពធីតា ព្រះបរមរាជាទី៤ទ្រង់ត្រាស់បង្គាប់ឱ្យជាងយកថ្មល្អិតល្អន់ កសាងជារូបសម្តេចចៅហ្វាជុង១ជំទាវទេវីនារី សោភ័ណដៃ១តំកល់រូបទាំង២នោះ ក្នុងសាលាមួយទុកឱ្យសម្តេចព្រះមហេសីគោរពរៀងមក [12]។

### ១.៤. ស្ថានភាពប្រទេសក្នុងពេលសង្គ្រាម

ការរស់នៅរបស់អាណាប្រជានុរាស្ត្រក្នុងគ្រាស្រុកកំពុងមាន ចម្បាំងរាំងជល់ឃើញថាមានលក្ខណៈ ខុសប្លែកគ្នាឆ្ងាយណាស់។ ជាទូទៅគេឃើញថាអាណាប្រជានុរាស្ត្រមានកាតព្វកិច្ច ត្រូវបង់ពន្ធជូនរាជការ ប៉ុន្តែមានករណីខ្លះព្រះរាជាទ្រង់សព្វព្រះទ័យលើកលែងមិនយកពន្ធបាន ដូចព្រះធម្មរាជាទ្រង់បានបញ្ជា ឱ្យ លើកលែងពន្ធរាជការខ្លួន និងពន្ធព្រះរាជធានីអស់រយៈពេល៣ឆ្នាំ។ ចំណែកឯព្រះបាទស្រីជេដ្ឋាធិរាជ (ស្តេចកន) កាលច្បាំងឈ្នះព្រះបាទស្រីសុគន្ធបទហើយធ្វើពិធីរាជាភិសេកឡើងសោយរាជ្យនោះព្រះអង្គ ទ្រង់បង្គាប់ឱ្យរាជការ លើកលែងអាណាប្រជានុរាស្ត្រទូទាំងប្រទេសមិនឱ្យបង់ពន្ធក្នុង រយៈពេលមួយឆ្នាំ ហើយគេបានបញ្ជាក់ថាអាណាប្រជានុរាស្ត្របានសម្បូរសប្បាយ។ ម្យ៉ាងទៀតអាណាប្រជានុរាស្ត្រតែងតែ ត្រូវកេណ្ឌឱ្យបំពេញកិច្ចការធំៗដូចជាលើកផ្លូវសង់ស្ពានជីកព្រែកជីកអូរលើកទំនប់។សម្រាប់បំរើ ប្រយោជន៍រួមនិងកិច្ចការខ្លះសម្រាប់បម្រើផលប្រយោជន៍ របស់ព្រះរាជា។ ក្រៅពីកិច្ចការទាំងប៉ុន្មានដែល ត្រូវបំពេញដូចបានរៀបរាប់ រួចមកហើយនេះពួកយុវជនក្នុងព្រះរាជាណាចក្រត្រូវជាប់កំណែនជាទាហាន ក្រៅកំណែនទៀត។ នៅពេលណាស្រុកមានចម្បាំងពួកទាហានប្រភេទនេះត្រូវគេកេណ្ឌឱ្យចូលបំរើក្នុងកង ទ័ពភ្លាមៗ។ ក្នុងករណីស្រុកមានចម្បាំងទោះជាចម្បាំងគ្នាឯងក្តី ចម្បាំងការពារជាតិក្តីអាណាប្រជានរាស្ត្រ ត្រូវជួបប្រទះនឹងទុក្ខវេទនាយ៉ាងខ្លាំងព្រោះក្រៅពីកាតព្វកិច្ចទាំងប៉ុន្មានដែលត្រូវបំពេញខាងលើរាស្ត្រត្រូវ ប្រមូលទ្រព្យសម្បត្តិស្បៀងអាហារផ្គត់ផ្គង់ឱ្យកងទ័ពថែមទៀត។ ពិសេសទៅទៀតក្នុងចម្បាំងនៅសម័យ ណា ក៏ដូចសម័យណាដែរអាណាប្រជានុរាស្ត្រ រមែងតែងតែស្លាប់ដោយខ្មាំងសត្រូវប្រហារផងដោយជម្ងឺ

[12] -អាដេម៉ា ឡឺក្លែរ ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ ២០០៦

តម្កាត់ផ្សេងៗផង។ ឆ្លៀតឱកាសដែលមានការរើករវដូច្នេះចោរខ្មួញតែងតែកំរើកច្រើមធំប្លន់កាប់ចាក់នៅគ្រប់ស្រុកតំបន់។



**ចម្បាំងគ្នាឯងសម័យចតុមុខ**

សម័យអង្គរគឺជាយុគមាសនៃអរិយធម៌ឈានដល់កម្រិតកំពូល លើគ្រប់វិស័យបានក្លាយជានគរចក្រព័ត្រក្នុងតំបន់ដែលគេហៅស្តេចសម័យនោះថា Imperial King ។តែអាណាចក្រដ៏មហាអស្ចារ្យនេះ បានរស់រានត្រឹមជាង៦សតវត្សប៉ុណ្ណោះ។ យ៉ាងណាសាវតារប្រវត្តិសាស្ត្រ កម្ពុជាក្រោយសម័យអង្គរមានភាពស្មុគស្មាញដល់ចំណុចកំពូលដូចគ្នា។

ក្រោយពីការផ្លាស់រាជធានីមកកាន់ចតុមុខ និងបន្ទាប់ពីសោយទិវង្គតនៃព្រះបាទពញាយ៉ាតរួចមកគេមើលឃើញនូវវិបត្តិនយោបាយក្នុងស្រទាប់រាជវង្ស ដែលឈានដល់ការពុះចែកទឹកដីគ្នាគ្រប់គ្រងរហូតដល់ទៅបីតំបន់។សឹកសង្គ្រាមវាយលុកពីសំណាក់នគរអាយុធ្យា មកលើរាជធានីអង្គរបានស្រាកស្រាន្តបន្តិចក្នុងរយៈពេលមួយ។ ស្ថានភាពបណ្តោះអាសន្ននៅតែបង្កជាកង្វល់ រយៈចម្ងាយនៃអាយុធ្យាដែលជាកន្លែងបង្កទ័ពរបស់សៀមមិនឆ្ងាយប៉ុន្មាន ពីក្រុងអង្គរ។ខេត្តភាគខាងលិចមួយចំនួនសៀមក៏បានដណ្តើមយករួចស្រេច។ ចំណែកចំនួនប្រជាជនក៏ត្រូវបានសៀមកៀរយកមិនតិចដែរ ពេលនោះ ខ្មែរបាត់បង់ជីវិតក៏ច្រើន ពលកម្មនិង កម្លាំងចិត្តស្រុតចុះស្ទើរតែកើតជម្ងឺបាក់ស្បាតទៅហើយ។ ក្នុងស្ថានភាពនោះ អង្គរដ៏ធំល្វឹងល្វើយធ្លាប់ជារាជធានីដ៏រុងរឿងជៀសមិនផុតពីការបោះបង់ចោល។ ស្តេចពញាយ៉ាតដែលជាស្តេចវាយបានអង្គរមកវិញ ក៏ជាប់ឈ្មោះជាព្រះរាជាមួយអង្គដែលសុខចិត្តចាកចោលរាជធានីបរមវិស្ណុលោកដ៏រុងរឿងនេះ រួចមកតាំងទីនៅទួលបាសាន ឬព្រះរាំងថ្មី ក្នុងឆ្នាំ១៤៣១គ.ស.ដែលឯកសារខ្លះថាឆ្នាំ១៤៣៣គ.ស។ មិនយូរប៉ុន្មានស្ថានភាពភូមិសាស្ត្រមិនសូវអំណោយផលមាននូវគ្រោះទឹកជំនន់នៅទួលបាសាននោះ ព្រះអង្គក៏បង្គាប់ឱ្យសាងសង់រាជវាំងតាំងនៅទន្លេប្រាបឈាម ដែលជាជ័យភូមិប្រណីត។ ក្នុងសាវតារជាតិ ព្រះបាទពញាយ៉ាតមានបុត្របីអង្គ ប្រសូតចេញពីឧទរអ្នកម្នាងបីផ្សេងគ្នា ដែលក្នុងនោះ ព្រះបាទ នរាយណ៍រាជាជាបុត្រព្រះអង្គជាមួយនឹងអ្នកម្នាងទេវី បុត្រាទី២ គឺអង្គស្រីរាជាជាមួយនឹងអ្នកម្នាងបទុមកេសរ និង បុត្រាចុងក្រោយគឺព្រះបាទធម្មរាជា ដែលមានឈាមក្លាយពីអ្នកម្នាងស៊ីសាងាមដែលជាជាតិសាសន៍សៀម ៤២ឆ្នាំនៃការសោយរាជ្យ អង្គពញាយ៉ាតបានដឹកនាំប្រទេសប្រកបដោយទសពិធរាជធម៌ និង សុខសន្តិភាពចាកឆ្ងាយអំពីការប៉ុនប៉ងទន្ទ្រានពីខ្មាំងសត្រូវ ដោយរក្សាបានស្ថេរភាពនយោបាយក្នុងប្រទេសហើយកិត្យានុភាពនៃការដឹកនាំក៏ល្បីរន្ទឺ។ មុនព្រះអង្គយាងចូលទិវង្គតក្នុងឆ្នាំ១៤៦៦ គ.ស. គឺ ឆ្នាំ១៤៦៣គ.ស. ព្រះអង្គបានអភិសេករាជ្យឱ្យបុត្រច្បងគឺព្រះបាទនរាយណ៍រាជា។ តែគួរឱ្យអនិច្ចា៦ឆ្នាំក្រោយព្រះអង្គនរាយណ៍រាជាបានចូលទិវង្គត ហើយព្រះអនុជដែលជាមហាឧបរាជក៏ត្រូវបាននាម៉ឺនមុខ មន្ត្រីជាន់ខ្ពស់សព្វព្រះទ័យឱ្យលើកសោយរាជ្យបន្ត។

### ១.៤.១. ព្រឹត្តិការណ៍រាជបល្ល័ង្គបីនៃសម័យចតុមុខ

ដំណាក់កាលវាយយកខេត្តពីសៀមមកវិញទឹកព្រះទ័យពុះកញ្ជ្រោលក្នុងការដណ្តើមកវិញខាងតែបាននូវវិសាលភាពទឹកដីមហានគរពីមុនដក់ជាប់ក្នុងដួងហឬទ័យព្រះបាទស្រីរាជាតាំងពីមិនទាន់សោយ

រាជ្យមកម្ដេះ។ក្រោយរាជ្យព្រះអង្គរយៈពេល៦ឆ្នាំព្រះអង្គសច្ចាវាយយកមកវិញនូវទឹកដីភាគខាងលិចទាំងឡាយដែលបាត់បង់ទៅដោយការទន្ទ្រានពីសំណាក់សៀម។ ឆ្លៀតក្នុងឱកាស២ឆ្នាំនៃការជាប់ដៃប្រយុទ្ធក្នុងសមរភូមិ ព្រះបាទសុរិយោទ័យដែលជាក្មួយរបស់ព្រះអង្គស្រីរាជា បានទៅបង្ករាជ្យនិងរៀបចំរាជវាំងដើម្បីគ្រប់គ្រងអំណាចដាច់ដោយឡែកមួយគឺនៅស្រុកសឈរចំពេលដែលព្រះបាទស្រីរាជាបានបញ្ជាឱ្យឧកញ៉ាចក្រីកែវមនោមេត្រីអឹម និងចៅហ្វាយខេត្តបាត់ដំបងត្រូវស្នាក់ការសម្រុកមកវិញនេះទ័ពសៀម។ ជាមួយគ្នានឹងសម្ដេចចៅហ៊្វាទឡ្ហះកែវត្រូវតែរក្សាខេត្តដែលនៅជាប់ឆ្នេរ។ ចំណែកទ្រង់ផ្ទាល់លើកទ័ពឆ្លងទន្លេសាបមកបោះបន្ទាយនៅ កំពង់សៀមត្រៀមលក្ខណៈគ្រប់គ្រាន់ប្រយុទ្ធជាមួយនឹងទ័ពរបស់ក្មួយ។ កាលព្រះអង្គឃ្លាតឆ្ងាយពីនគរចតុមុខអស់កាលតែបីឆ្នាំសោះក្នុងឆ្នាំ១៤៧៨ អនុជ៧ ព្រះអង្គធម្មរាជាបានថ្វាយសារទៅកាន់ព្រះអង្គស្រីរាជាថាខ្លួនឡើងអភិសេកគ្រងរាជ្យនៅរាជធានីចតុមុខហើយ គឺមានទាំងបន្ទាយដ៏រឹងមាំសម្រាប់ទប់ទល់នូវចេតនាសង្គ្រាមណាមួយ ពីខាងព្រះរៀមឬព្រះភាគិនេយ្យ (ក្មួយ) ជម្លោះក្នុងរាជវង្សខ្មែរដណ្ដើមរាជ្យគ្នាទីបំផុត សម័យចតុមុខគឺជាសម័យមួយដែលត្រូវសម្គាល់ជិតដាម ជាអបគមន៍តំបន់នគរបី រាជបល្ល័ង្កបី ស្ដេចបីព្រះអង្គមានខ្សែលោហិតដើមជាមួយគ្នាទាំងស្រុង។

អាណាចក្រខាងជើងគ្រប់គ្រងដោយព្រះបាទស្រីរាជាមានរាជធានីនៅកំពង់សៀម រួមមានខេត្តចំណុះតាំងពីខេត្តលង្វែក រលាប្អៀរ អម្រាគិរីបូណ៌ ក្រគរ គ្រងពោធិ៍សាត់ បាត់ដំបង ឫស្សីសាញ តាមសីមាមង្គលបូរី រយ៉ង សុរិន្ទ ស្រីង្គារ ស្ទឹងត្រែង ជើងព្រៃ គោកសេះ អន្លង់រាជ ព្រំទេពព្រៃក្ដី ស្ទោង ជីក្រែង រលួសសៀមរាប ម្លូព្រៃជាំក្សាន្ត ត្នោត គោកខ័ណ្ឌ

ទឹកដោះរៀងដែលស្ថិតនៅទៅទល់ដែនសៀម។ ដោយឡែកនាភូមិភាគអាណាចក្រខាងកើតគ្រប់គ្រងដោយ ព្រះស្រីសុរិយោទ័យមានរាជធានីនៅស្រីសឈរនិងមានខេត្តចំណុះដូចជា៖ ខេត្តសៀមបូកសម្បុកសម្បូរណ៍ ក្រចេះ ឆ្លូង ត្បូងឃ្មុំ បាសានទទឹងថ្ងៃ ព្រៃវែង បាភ្នំ រំដួលស្វាយទាប រោងដំរី ព្រៃនគរលង់ហោ ជើងបាដែង ដល់ខេត្តដូនណាយរៀងទៅទល់នឹងនគរចាម។រីឯព្រះបាទធម្មរាជា គ្រប់គ្រងមួយភាគធំនាភាគខាងត្បូងប្រទេសរាប់ពីសំពោងទង ថ្លង បាទី លើកដែក ទ្រាំង បន្ទាយមាស ថ្កង បាសាក់បារៀ កំពត កំពង់សោមព្រះត្រពាំង ក្រមួនសចាប់ពីកោះស្លាកែតដល់ពាមកញ្ជើរ។ ស្ថានភាពបែបនេះមិនគួរឱ្យមានយូរទេ ពុំនោះសោតវិបត្តិសង្គម នយោបាយ ក៏ដូចជាសេដ្ឋកិច្ចនឹងរាំងស្ទះ។ ១០ឆ្នាំដែលនគរបីមាននៅក្នុងប្រវត្តិកម្ពុជាកើតមាននូវគ្រោះទុរ្ភិក្សចោរកម្មធក់ប្លន់ សម្លាប់ គុំគួនគ្នាក្នុងជាតិសាសន៍តែមួយ។

### ១.៤.២. ការខាតបង់ដោយសារអន្តរាគមន៍ពីសៀម

នៅឆ្នាំ១៤៨៥គ.ស. ព្រះបាទធម្មរាជាបានធ្វើនយោបាយការទូតនឹងសៀមខ្លាំងឡើងដើម្បីស្វែងរកភាពឯករាជ្យក្នុងគ្រប់គ្រងទឹកដីតែម្ដងឯង។ ព្រះចៅមហាចក្រពត្រាធិរាជ ស្ដេចសៀម សព្វព្រះទ័យជាខ្លាំងទទួលទូតខ្មែរយ៉ាងកក់ក្ដៅ ហើយយល់ព្រមតាមសំណើ ក៏បញ្ជូនទ័ពហៃរក្បួនយ៉ាងគគ្រឹកគគ្រេងមកក្រុងចតុមុខ ថែមទាំងរៀបចំសេនាបតី ខ្មែរ-សៀម ត្រៀមកំទេច ស្រីរាជានិងស្រីសុរិយោទ័យ។ តែក្រោយមកឧកញ៉ាក្រឡាហោម មឹង ដែលជាមេទ័ពរបស់ ព្រះបាទស្រីរាជា បានមកជួបព្រះបាទធម្មរាជា ហើយបានទូលពីបំណងម្ចាស់របស់ខ្លួនសុំចងមេត្រីភាព។ ស្ដេចនៃរាជវាំងចតុមុខមង្គលបានកោះអញ្ជើញព្រះភាគិនេយ្យឱ្យយាងមកប្រជុំបីភាគីនៅឧត្តុង្គ តែព្រះស្រីសុរិយាទ័យ មានបំណងបដិសេធ និងចង់ធ្វើ

សង្គ្រាមបន្តទៀត យ៉ាងណា ព្រះអង្គត្រូវបានមេទ័ពជាច្រើនរូបជំទាស់ចំពោះចលនាបញ្ឆេះសង្គ្រាមរវាងរាជវង្សឯងមិនអស់មិនហើយ គឺចាប់ពីពេលនោះហើយ នគរបីត្រូវបានបង្រួបបង្រួម។

### ១.៤.៣. ព្រះបាទធម្មរាជាក្លាយជាស្ដេចគ្រប់គ្រងនគរតែមួយ



ព្រះបាទស្រីរាជា

ជំនួយផ្នែកយុត្តិធម៌ពីខាងភាគីសៀមបានធ្វើឱ្យស្ដេចសៀមមានប្រៀបក្នុងការស្នើយកខេត្តដែលព្រះបាទស្រីរាជាវាយដណ្ដើមបានកាលពីមុន ដោយត្រូវប្រគល់ឱ្យទៅសៀមវិញរួមមានខេត្តនគររាជសីមា បស្ទឹមបុរី រយ៉ង ចន្ទបុរី និងខេត្តសៀមភាគខាងត្បូងមួយចំនួនទៀត ។ស្ដេចសៀមបាននាំព្រះបាទស្រីរាជា និងព្រះស្រីសុរិយោទ័យ រួមទាំងរាជវង្សខ្មែរមួយចំនួន យាងទៅក្រុងអយុធ្យា ដើម្បីឱ្យរាជបល្ល័ង្គនេះគ្រប់គ្រងដោយព្រះបាទធម្មរាជាតែមួយអង្គឯង។ ព្រះអង្គទាំងពីរបានសោយទិវង្គតនៅក្រុងអយុធ្យាដោយមិនដឹងមូលហេតុច្បាស់លាស់ហើយ ហើយបន្សល់នូវបុត្ររបស់ព្រះបាទស្រីរាជា គឺព្រះបាទពញាអុងត្រូវបានស្ដេចសៀមចិញ្ចឹម។យ៉ាងណាខេត្តមួយចំនួន ដែលធ្លាក់នៅក្រោមអយុធ្យាត្រូវបានវាយដណ្ដើមយកវិញដោយព្រះបាទចន្ទរាជាជាបុត្ររបស់ព្រព្រះបាទធម្មរាជា។ ព្រះបាទចន្ទរាជាបានឡើងសោយរាជ្យក្រោយពីទម្លាក់ស្ដេចកនពីអំណាច។ពេលនេះនគរខ្មែរគ្មានបែងចែកការគ្រប់គ្រងទៀតឡើយ[13]។

[13] -ត្រឹងងា ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ១៩៧៣

# សំណួរត្រិះរិះ

១. ហេតុអ្វីបានជាក្នុងសម័យចតុមុខមានរាជធានីច្រើនកន្លែង?

២. មូលហេតុអ្វីបានជាព្រះមហាក្សត្រខ្មែរប្តូររាជធានីពីអង្គរមកទួលបាសានពីទួលបានសានមកចតុមុខ?

៣. តើនយោបាយនិងការផ្លាស់ប្តូរក្នុងតំបន់និងពិភពលោកជះឥទ្ធិពលយ៉ាងដូចម្តេចលើកម្ពុជា? តើនយោ បាយនិងការផ្លាស់ប្តូររបស់កម្ពុជាបានជះឥទ្ធិពលអ្វីខ្លះទៅលើប្រទេសជិតខាងនិង ពិភពលោក?

៤. បន្ទាប់ពីបង្កើតទ័ពរួចហើយ តើអាយុធ្យាបានអនុវត្តន៍នយោបាយបែបណាចំពោះខ្មែរ?

៥. តើអាយុធ្យាបានធ្វើអន្តរាគមន៍ ក្នុងបញ្ហាជម្លោះខ្មែរបានយ៉ាងដូចម្តេច?

៦. តើទំនាក់ទំនងខ្មែរនិងអឺរ៉ុប ដាយវៀតនិង លាវផ្តល់ផលវិបាកអ្វីខ្លះ?

៧. តើបម្រែបម្រួលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសបានផ្តល់ឥទ្ធិពលនិងផលវិបាកអ្វីខ្លះដល់កម្ពុជា?

៨. តើទំនាក់ទំនងអវិជ្ជមាននិង វិជ្ជមានរវាងភូមា សៀម ខ្មែរ  លាវ ផ្តល់មេរៀនជាបទពិសោធន៍អ្វីខ្លះដល់មនុស្សជំនាន់ក្រោយ?

៩. តើសង្គ្រាមរំដោះយកអាណាខេត្តខ្មែរទិសខាងលិចពីសៀមផ្តល់អត្ថន័យជាប្រវត្តិសាស្ត្រដល់ខ្មែរជំនាន់ដូចម្តេច?

១០. អន្តរាគមន៍របស់ស្តេចសៀមនៅក្នុងវិបត្តិរាជវង្សខ្មែរបានផ្តល់បទពិសោធន៍ដូចម្តេចខ្លះដល់សង្គមខ្មែរក្រោយដូចម្តេចខ្លះ? រកមូលហេតុដែលធ្វើឱ្យស្តេចកនយកជ័យជំនះបានលើព្រះបាទស្រីសុគន្ធបទ ។

១១. សង្គ្រាមរវាងស្តេចកន និងព្រះចន្ទរាជាផ្តល់ផលវិបាកអ្វីខ្លះដល់សង្គមខ្មែរនាពេលនោះ ?

# មេរៀនទី២
# សម័យលង្វែកនិង អំណាចសៀម

## ២.១. ស្ថានភាពភូមិសាស្ត្រសម័យលង្វែកនិងបម្រែបម្រួល

សម័យលង្វែកប្រទេសកម្ពុជាមានព្រំប្រទល់

- ខាងកើតជាប់ប្រទេសចាម្ប៉ា
- ខាងលិចជាប់ប្រទេសថៃគឺខេត្តនគររាជនិងក្រុងទេព
- ខាងជើងជាប់ប្រទេសឡាវ
- ខាងត្បូងជាប់សមុទ្រចិន14។



ផែនទីក្រុងលង្វែក

បន្ទាយលង្វែកជាទីតាំងប្រវត្តិសាស្ត្រខ្មែរមួយ ស្ថិតនៅក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង និង ជាកន្លែងយុទ្ធសាស្ត្រមួយមានទន្លេ បឹង ជាពិសេសព្រៃក។ ដែលត្រូវបានចាប់ផ្តើមកសាងនៅឆ្នាំ១៥២៦គ.ស. និងកសាងរួចរាល់ឆ្នាំ១៥២៩គ.ស. ដោយព្រះអង្គចន្ទរាជា។ លង្វែកទីតាំងយុទ្ធសាស្ត្រមួយមានទន្លេ បឹង ពិសេសព្រៃ។ មូលហេតុនេះហើយ ទើបព្រះចន្ទរាជាបញ្ជាមន្ត្រី ឧកញ៉ាសេនាបតីឱ្យកេណ្ឌរាស្ត្រកាប់ឈើ ជញ្ជូនថ្មរែកដី ដើម្បីសង់បន្ទាយនិងរាជវាំង។ ក្រុមមេការឱ្យគេជីកដីបុកគ្រឹះរៀបថ្ម ៦ហត្ថ ជុំវិញបន្ទាយជាបីជ្រុងហើយលើកដីច្រុះក្ការ ដែលមានទំហំបណ្តោយជិត៣គ.ម ទទឹង២គ.ម កំពស់១៧ហត្ថ កំរាស់ខ្នងលើ១០ហត្ថ ជើងទេរខាងក្រោម២២ហត្ថ ឯជ្រុងទីបួនគឺទន្លេ។ ទ្រង់បានឱ្យគេធ្វើកំពែងការពារ៥ជាន់ ព្រមទាំងដាំរបងឫស្សីយ៉ាងក្រាស់ កំរាស់ ២សិន (១៦០ម) មានគូទឹក មានទ្វារ៨ ក្នុងទ្វារនីមួយៗមានសើនមួយ។ សើនទាំង៨ មានកំរាស់២២ហត្ថ សម្រាប់ដាក់កាំភ្លើងធំ។ ខាងក្នុងកំពែងទាំងប្រាំជាន់ ដាក់សុទ្ធតែទាហានកាំភ្លើងច្រូង(កាំភ្លើងវែង)។ ក្នុងកំពែងជាន់ទី១ ដាក់សុទ្ធតែទាហានកាំភ្លើងធំ ហើយនៅមុខកំពែងនេះមានរោងដំរីនិងរោងសេះ។ កំពែងទី២ ដាក់សុទ្ធតែទាហានកាំភ្លើងវែង សាលាជំនុំ សាលាដំបូង និងសាលាឧទ្ធរណ៍។ ក្នុងកំពែងទី៣ សុទ្ធតែទាហានអាវុធខ្លី មានដាវ ផ្គាក់ កាំបិត។ កំពែងទី៤ ដាក់សុទ្ធតែទាហានរក្សាព្រះអង្គ រោងល្ខោន និងព្រះពន្លាទតល្ខោន។ នៅក្នុងកំពែងទី៥ មានរោងបញ្ចក្សេត្រ និងដំណាក់សំរិទ្ធវិមាន កំសាន្ត ភិរម្យ ក្រុមបារគូ បុរោហិត និងក្រុមមហាលិក។ ក្នុងកំផែងនេះដែរ មានរាជវាំងកំពូលប្រាំបិទមាស និង លាបម្រ័ក្យ សម្រាប់ព្រះមហាក្សត្រធិរាជផ្ទំ ហើយមានតម្កល់វត្ថុសក្តិសិទ្ធិ គឺព្រះកែវ ឬព្រះត្រឡែងកែង និងព្រះគោ ចំនួន១២ ដែលនៅក្នុងពោះព្រះគោទាំងនោះ មានរក្សានូវគម្ពីរក្បួនសាស្ត្រាដ៏មានតម្លៃលើសលប់។ មានផ្ទះ ស្រីស្នំ ក្រុមការ បុត្រាបុត្រីនិងមានឃ្លាំងធំៗទុកស្រូវ អង្ករ អំបិល ប្រហុក ត្រីងៀត ត្រីឆ្អើរ និងឃ្លាំងសាស្ត្រាវុធ[15]។ម្យ៉ាងទៀតតាមជំនឿរបស់ខ្មែរ ព្រះគោនិងព្រះកែវជាបងប្អូនបង្កើតនិងគ្នា ដែលអ្នកស្រុកតែងតែគោរពបូជា ទុកជាវត្ថុសក្តិសិទ្ធិដោយសារនៅក្នុងបន្ទាយលង្វែកមានរូបព្រះ

[14] -ប៊ុន ជឿន ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ ២០០៦

[15] -.លោក អាដេម៉ា ឡឺក្លែរ ប្រវត្តិសាស្ត្រខ្មែរឆ្នាំ ២០០៦

គោ ព្រះកែវ គេមានជំនឿថានេះជាបន្ទាយមួយយ៉ាងរឹងមាំសម្រាប់ការពារសត្រូវផងនិងជាឃ្លាំងវប្បធម៌ជាតិបន្ទាប់ពីអង្គរ។

## ២.១.១. លង្វែក និងអឺរ៉ុប



ជនជាតិអឺរ៉ុបដំបូងមកដល់កម្ពុជា

ទំនាក់ទំនងជាមួយជនជាតិអឺរ៉ុបលើកដំបូង នៅក្នុងរជ្ជកាលព្រះចន្ទរាជា មានជនជាតិអឺរ៉ុបដំបូងដែលមកដល់ប្រទេសកម្ពុជានោះ គឺជនជាតិព័រទុយហ្គាល់។ នៅឆ្នាំ១៥៥៥ គ.ស មានបព្វជិតជនជាតិនេះខាងគណៈដូមិនិ កាំងមាន (ហ្គាប៉ាដាក្រូ)GaspardaCrue ជាមិត្តភក្តិស្និទ្ធស្នាលរបស់លោក(អាល់បូហ្គូហ្គ) Albu-querque បានមកដល់ក្រុងលង្វែក។បព្វជិតរូបនេះ មានបំណងផ្សព្វផ្សាយសាសនាគ្រឹស្តនៅប្រទេសកម្ពុជា។ ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យទទួលរាក់ទាក់ណាស់ ប៉ុន្តែបេសកកម្មរបស់បព្វជិតនេះបរាជ័យព្រោះរាស្ត្រខ្មែរនៅសម័យនោះ មានជំនឿយ៉ាងខ្លាំងលើព្រះពុទ្ធសាសនា គ្មានគំនិតកាន់សាសនាផ្សេង ឡើយ។ ការបរាជ័យនេះនាំឱ្យពួកព័រទុយហ្គាល់ត្រឡប់ទៅកាន់ប្រទេសចិននៅឆ្នាំ១៥៥៦ គ.ស.។ ក្នុងសម័យសង្វែក ក្រៅពីអ្នកផ្សាយសាសនា មានអ្នកផ្សងព្រេងឯទៀត ដែលបានមកប្រទេសកម្ពុជា ហើយបានកត់ត្រាទុកនូវហេតុការណ៍ ដែលពួកគេបានឃើញ ឬជួបផ្ទាល់។ កំណត់ហេតុទាំងនោះហើយ ដែលអ្នកប្រវត្តិសាស្ត្របានយកធ្វើជាឯកសារប្រវត្តិសាស្ត្រ សម្រាប់ឆ្លុះមើលសង្គមខ្មែរនា ស.វទី១៦។

ឧទាហរណ៍អត្ថបទខាងក្រោមជារបស់លោក(ឌីយូហ្គោដូគូតូ) DiogoDoCoutoជនជាតិព័រទុយហ្គាល ជាភស្តុតាងមួយ។ លោកបានសរសេរថា (ប្រមាណជាក្នុងឆ្នាំ ១៥៥០គ.ស. ឬឆ្នាំ១៥៥១គ.ស នៅពេលដែលព្រះមហាក្សត្រនៃប្រទេសកម្ពុជា ទ្រង់យាងទៅទាក់ដំរីក្នុងព្រៃស្បាតក្នុងព្រះរាជាណាចក្រនោះ បរិវាររបស់ព្រះអង្គបានលុកចូលទៅក្នុងព្រៃ ដើម្បីដេញសត្វ ក៏ប្រទះនឹងសំណង់យ៉ាងធំសម្បើមដែលមានព្រៃគុម្ពោតដុះពេញខាងក្នុង ហើយដែលមិនអាចកាប់ ឆ្ការ ដើម្បីចូលទៅខាងក្នុងបាន)។ ដំណឹងនេះបានជ្រាបដល់ព្រះរាជា ព្រះអង្គក៏យាងទៅដល់ទីនោះ ហើយទ្រង់ទតឃើញនូវវិសាលភាព និងកំពស់នៃជញ្ជាំងខាងក្រៅ ទ្រង់ក៏បញ្ជាឱ្យកាប់ឆ្ការដុតព្រៃភ្លាមមួយរំពេច ដើម្បីទ្រង់ទតឃើញខាងក្នុង។ ក្រោយពេលដែលព្រៃត្រូវបានសំអាតអស់ហើយ ព្រះរាជាទ្រង់យាងទតសព្វទីកន្លែង ហើយទ្រង់មានសេចក្តីស្ញប់ស្ញែងចំពោះ ទំហំធំធេងនៃសំណង់នោះ។ ហេតុនោះ ទ្រង់ត្រាស់ឱ្យពួកបរិវារទៅនៅទីនោះវិញ។ ដូចនេះអត្ថបទនេះចង់បញ្ជាក់ឡើងវិញអំពីការរកឃើញនូវប្រាសាទសិលានៅតំបន់អង្គរ ដែលត្រូវបានបោះបង់ចោល អស់ពេលជាងមួយសតវត្សរ៍មកហើយ។

## ២.១.២. លង្វែក ដាយវៀតនិង លាវ

### ក. ទំនាក់ទំនងជាមួយប្រទេសលាវ

នៅឆ្នាំ១៥៧២គ.ស. ស្តេចលាវនៃនគរឡានសាង ទ្រង់បញ្ជាឱ្យនាម៉ឺន២នាក់ ពល ១០០នាក់ មកបបួលខ្មែរ ប្រជល់ដំរីដាក់នគរ ដោយសន្យាថាបើដំរីនគរណាចាញ់នគរនោះត្រូវចំណុះនគរម្ខាងទៀតដែលមានដំរីឈ្នះ។ បរមរាជាទី៤ គង់នៅកំពង់ក្រសាំងតំបន់អង្គរទ្រង់យល់ព្រមចំពោះសំណើរបស់ស្តេចលាវ។

ការប្រយុទ្ធរវាងដំរីទាំងពីរក៏ប្រព្រឹត្តទៅក្បែរក្រុងលង្វែក។ ដំរីលាវមានកំពស់ដល់ទៅ៨ហត្ថ ឯដំរីខ្មែរមានកំពស់តែ៧ហត្ថ។ ទោះបីចាញ់ប្រៀបដំរីលាវបន្តិចក៏ដោយ ក៏ដំរីខ្មែរបានទទួលជោគជ័យយ៉ាងត្រចះត្រចង់។ ពេលនោះខ្មែរបានឃាត់លាវ ១០០នាក់ទុកឱ្យនាម៉ឺន២នាក់នាំដំណឹងទៅថ្វាយស្តេចលាវឱ្យនាំបណ្ណាការមកថ្វាយរាជាខ្មែរ។ ស្តេចលាវ ខ្ញាល់ខ្លាំង ក៏បញ្ជាឱ្យលើកទ័ពចូលវាយខ្មែរទាំងផ្លូវគោកទាំងផ្លូវទឹក។ ទ័ពលាវចូលឡោមវាយបន្ទាយខ្មែរនៅ អាសន្ទុក ហើយចាប់បានខ្មែរទុកជាឈ្លើយជាច្រើននាក់។ ស្តេចខ្មែរនិងស្តេចលាវលើកទ័ពតទល់គ្នា។ ទ័ពខ្មែរជាអ្នកឈ្នះក្នុងសង្គ្រាមនេះ។ ចាប់បានឈ្លើយ១០០០នាក់ នៅបារាយណ៍ ហើយនាំទៅខេត្តខាងត្បូងនិងខាងលិច។ ព្រះបរមរាជាទី៤ ទ្រង់យាងមកក្រុងលង្វែកវិញ ទ្រង់ចាត់ឱ្យធ្វើបុណ្យឆ្លងជោគជ័យឱ្យលាវខ្លះទៅស្រុកបាភ្នំ និង៥០០ នាក់ទៀតនៅថែរក្សាវត្តភ្នំ។ ពួកនេះខ្មែរហៅថា លាវបាក់ទូក។

**ខ.ទំនាក់ទំនងជាមួយយួន**

ចំពោះនយោបាយក្រៅប្រទេសវិញខ្មែរពុំបានគិតអំពី ព្រំដែនខាងកើតទេពីព្រោះពួកចាមជាប់រវល់ធ្វើសង្គ្រាមជាមួយពួកយួនផ្ទៀងដើម្បីការពារទឹកដីរបស់ខ្លួន។រីឯប៉ែកខាងលិច ព្រះរាជាខ្មែរបានព្យាយាមធ្វើសង្គ្រាមរំដោះទឹកដីដែលបានបាត់បង់ក្នុងស.វទី១៣-១៤ នោះមកវិញ។ ក្នុងបំណងនេះហើយបានជាព្រះបាទស្រីរាជា ព្រះច័ន្ទរាជា ព្រះបរមរាជាទី៤ ព្រះសត្ថាទី១បានលើកទ័ពទៅវាយលុករហូតដល់រាជធានីអាយុធ្យារំដោះទឹកដីមកវិញបានជាច្រើនដោយសារសៀមជាប់ដៃច្បាំងជាមួយភូមា។ក្រោយមកសៀមបានលើកទ័ពចូលមកវាយខ្មែរជាញឹកញាប់ ចំពោះមុខគ្រោះថ្នាក់នេះព្រះបាទសត្ថាទី១បានងាកទៅរកជំនួយពីពួកព័រទុយហ្គាល់និងអេស្ប៉ាញវិញតែពុំបានដូចបំណង។

**២.១.៣. លង្វែកនិង សៀម**

**ក. ទំនាក់ទំនងជាមួយសៀមនិងការរំដោះខេត្តភាគខាងលិច**

ស្តេចខ្មែរ ឆ្លៀតឱកាសដែលប្រទេសសៀមកំពុងតែចុះខ្សោយ ដោយមានការវាយលុកពីសំណាក់ភូមា ដែលបានដណ្តើមយករាជធានីអាយុធ្យានៅឆ្នាំ១៥៦៤គ.ស.នោះ ព្រះបរមរាជាទី៤ ទ្រង់បានបន្តកិច្ចការរបស់ព្រះបិតាទ្រង់ គឺការវាយរំដោះអាណាខេត្តភាគខាងលិចជាបន្ត។

នៅឆ្នាំ១៥៦៨គ.ស.ក្រុងអាយុធ្យាមានបញ្ហាម្តងទៀតជាមួយភូមា ទ័ពខ្មែរបានចូលវាយលុកបន្ថែមព្រោះគ្រានោះភូមាបានកៀរពលរដ្ឋសៀមយកទៅអស់ជាច្រើន។ ទ្រង់នាំទ័ព ២០ ០០០នាក់ ចូលវាយក្រុងអាយុធ្យាដល់ជាយក្រុង តែកងទ័ពខ្មែរត្រូវបានថយមកវិញ ដោយសៀមបាញ់មេទ័ពជួរមុខរបស់ខ្មែរស្លាប់។

នៅឆ្នាំ១៥៦៩គ.ស ភូមាវាយយកបានអាយុធ្យាជាថ្មីម្តងទៀតនឹងដាក់សៀមចំណុះអស់រយៈពេល ១៥ឆ្នាំ។ នៅពេលដែលសៀមកំពុងតែវិកវរ ឆ្នាំ១៥៧០គ.ស. ខ្មែរបាននាំទ័ពវាយយកបានខេត្តនគររាជសីមា ហើយដាក់មន្ត្រីខ្មែរការពារទៀតផង។ នៅឆ្នាំ១៥៧៤គ.ស. ព្រះមហាធម្មរាជា និងព្រះនរេសូរ នាំទ័ពទៅជួយព្រះចៅហង្សាវតី វាយស្រុករៀងចន្ទន៍ ពេលនោះខ្មែរលើកទ័ពជើងទឹកចូលវាយក្រុងអាយុធ្យាម្តងទៀត តែចៃដន្យទ័ពសៀមត្រលប់មកវិញ ព្រោះនរេសូរ ប្រឈួនគ្រុនសន្និ ទ័ពសៀមមកទាន់ទ័ពខ្មែរក៏បានវាយទ័ពខ្មែរឱ្យថយម្តងទៀត។ ចំពោះចម្បាំងខ្មែរ-សៀម លើកនេះ មកពីទ័ពខ្មែរស៊ើបការណ៍

ដឹងថាស្តេចសៀមជាប់រវល់ច្បាំងជាមួយឡាវ(ជួយភូមាដោយបង្ខំ)ទុកកូនឱ្យនូវការពារនគរ ទើបទ័ពខ្មែរ-ចិន ដឹកនាំដោយ ចៅពញាចិនចាត់តុក បានប្រើល្បិចវាយស្រុកតូចៗពីចន្ទបុរីដល់ធនបុរី ដើម្បីឱ្យស្តេចសៀមចេញជួយ ទើបវាយលុកយកក្រុងអាយុធ្យា។ ដោយល្បិចនេះទើបអាណាខេត្តខាងលិចទាំងអស់ចាប់ពីនគររាជសីមា ចុះមកដល់ចន្ទបុរី ត្រូវទ័ពខ្មែររំដោះបានទាំងស្រុង។ ដោយត្រូវភូមា និងខ្មែរកៀបសង្កត់ខ្លាំងពេក សៀមក៏បង្ខំចិត្តចុះសន្ធិសញ្ញាមិត្តភាពជាមួយនឹងខ្មែរនៅឆ្នាំ១៥៧៤គ.ស. ព្រមទាំងថ្វាយចំពោះព្រះរាជាខ្មែរនូវខេត្តនគររាជសីមា បស្ចឹមបុរី ចន្ទបុរី។

**ខ. អាយុធ្យា និងលង្វែក ព្រះបាទចន្ទរាជា(១៥១៦គ.ស.-១៥៦៦គ.ស.)**

ក្នុងរាជព្រះចន្ទរាជាសៀមយល់ថាប្រទេសកម្ពុជាធ្លាប់ចំណុះសៀមតាំងពីរាជធម្មរាជាទី១ស្តេចសៀមបាន ចាត់ទូតបញ្ជាឱ្យព្រះអង្គចន្ទនាំសួយសារអាករ ជាសត្វដំរីទៅថ្វាយតាមទម្លាប់ពីមុន។ ព្រះអង្គបានប្រកែកមិនព្រម ចំណុះសៀម សៀមក៏នាំទ័ពចូលមកវាយខេត្តអង្គរ។ ព្រោះព្រះអង្គកេណ្ឌទ័ពទៅតទល់ជាមួយសៀម នៅត្រង់ស្ទឹងអង្គរក្នុងភូមិមួយរហូតធ្វើឱ្យសៀមចាញ់យ៉ាងដំណំ ហើយឈាមហូរក្រាលដីនៅតំបន់នោះទើបក្រោយចប់សង្គ្រាម ព្រះអង្គប្រទាននាមកន្លែងនោះថា តំបន់សៀមរាប(ខេត្តសៀមរាបសព្វថ្ងៃ) ជាអនុស្សាវរីយ៍នៃជោគជ័យរបស់ខ្មែរលើសត្រូវឈ្លានពានសៀម។ដើម្បីជាការសងសឹកនៅឆ្នាំ១៥៣០គ.ស. ព្រះចៅសៀមទ្រង់បញ្ជាឱ្យពញាអុង នាំទ័ព ៩ ម៉ឺននាក់ មកវាយខ្មែរ ម្តងទៀត។ ព្រះចន្ទរាជា ទ្រង់លើកទ័ពទៅតទល់គ្នានៅខេត្តពោធិសាត់។ នៅតាមផ្លូវពីលង្វែក ទៅសមរភូមិ ទ្រង់ទតដើមពោធិ៍១ដើម ងាប់យូរហើយតែលាស់សន្លឹកឡើងវិញ។ ទ្រង់គិតថានេះជាប្រផ្នូលល្អ ទ្រង់បានយកផ្កាស្លាម្លូ ទៀនធូបទៅបូជា ហើយនាំទ័ពទៅច្បាំងក៏ទទួលបានជោគជ័យដូចប្រាថ្នា។ ឯទ័ពសៀមដែលឡើងគោកត្រង់ឈូងសមុទ្រក៏ត្រូវទ័ពខ្មែរវាយឱ្យបាក់ទ័ពថយទៅវិញ។ ក្នុងចម្បាំងជើងគោកនៅខេត្តពោធិសាត់មេទ័ពសៀម ត្រូវស្លាប់អស់ច្រើនក្នុងចំណោមនោះមានពញាអុងដែរ ដែលត្រូវព្រួញលើខ្នងដំរី ឯពលទាហានស្លាប់ពាក់កណ្តាល អាវុធយុទ្ធភ័ណ្ឌក៏ត្រូវរឹបអូសជាច្រើន។ ព្រះអង្គបានឱ្យ គេធ្វើបុណ្យថ្វាយព្រះភ្លើងដល់សពពញាអុង និងកសាងព្រះវិហារបញ្ចុះធាតុ។ ឯដើមពោធិ៍ដែលរស់ឡើងវិញនោះទ្រង់ត្រាស់ឱ្យហៅថា ព្រះពោធិ៍មានបុណ្យ រួចទ្រង់ក៏យាងត្រឡប់ចូលបន្ទាយលង្វែកវិញ[16]។

នៅឆ្នាំ១៥៣១គ.ស.ឆ្លៀតដែលខ្មែរកំពុងតែមានប្រៀបលើទ័ពសៀមទ្រង់បានលើកទ័ពទៅរំដោះអាណាខេត្តភាគខាងលិចដែលបានបាត់បង់ក្នុងរាជ្យព្រះរាជាមុនៗ និងខេត្តចន្ទបុរីមកវិញ។ ឆ្នាំ ១៥៥៦ គ.ស. ស្តេចភូមា **បាយិនណោង** បាននាំទ័ពចូលវាយសៀម។ ពេលដែលសៀមកំពុងប្រយុទ្ធជាមួយភូមា ព្រះចន្ទរាជា ទ្រង់បាននាំទ័ព ចូលវាយសៀមនៅឆ្នាំ១៥៥៧ រំដោះបានខេត្តចន្ទបុរី និងខេត្តផ្សេងៗទៀតនៅជិតតំបន់នោះ។ ព្រះអង្គបានលើកទ័ពទៅវាយសៀមពីរលើក ពីឆ្នាំ១៥៥៨គ.ស. ដោយនាំឈ្លើយជាច្រើនមកស្រុកខ្មែរ នៅឆ្នាំ១៥៦៤គ.ស. ភូមាកាន់កាប់ក្រុងអាយុធ្យា។

[16] -.លោក អាដេម៉ា ឡឺក្លែរប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ២០០៦

### គ. អាយុធ្យា និងលង្វែក ព្រះបាទបរមរាជា(១៥៦៦គ.ស.-១៥៧៦គ.ស)

ក្រោយពីព្រះចន្ទរាជា សោយទិវង្គតទៅ ព្រះមហាឧបរាជដែលត្រូវជារាជបុត្របន្ទាប់ព្រះនាមបរមរាជា ឡើងសោយរាជ្យបន្តពីព្រះបិតា។ ហើយទ្រង់មានបុត្រ៤អង្គះ

- ព្រះសត្ថា (ប្រសូតនៅឆ្នាំ១៥៣៩គ.ស.)
- ព្រះស្រីសុរិយោពណ៌ (បុត្រព្រះម្នាងកេសរមាលា ប្រសូតនៅឆ្នាំ១៥៥៤គ.ស.)
- ពញានូ (បុត្រព្រះម្នាងកេសរមាលា ប្រសូតនៅឆ្នាំ១៥៥៨គ.ស.)
- ចៅពញាអន (បុត្រព្រះម៉ែនាងវង ប្រសូតនៅឆ្នាំ១៥៦៣គ.ស.)

ស្រីសុរិយោពណ៌បានយកបុត្រីរបស់ ពញាយសរាជា ព្រះនាម ជាតិក្សត្រី ហើយនាមបុត្រព្រះនាម ជ័យចេស្តា។ ទ្រង់ជាព្រះមហាក្សត្រមួយអង្គ ដែលបានជួយឧបត្ថមព្រះពុទ្ធសាសនាទ្រង់បានកសាងវត្ត ព្រះឥន្ទទេព នៅក្នុងបន្ទាយលង្វែក ព្រះអង្គសុគតនៅឆ្នាំ១៥៧៦គ.ស (១៥៧៤គ.ស) ក្នុងពេលនាំទ័ពទៅវាយប្រទេសសៀម។

ឃ. អាយុធ្យា និងលង្វែកព្រះបាទសត្ថាទី១ (១៥៧៦គ.ស.-១៥៨៦គ.ស.)

ព្រះសត្ថា (ព្រះសត្ថាទី១ ឬព្រះបរមរាជាទី៥) ឡើងស្នងរាជ្យជំនួសបិតា។ ព្រះអង្គអភិសេក អ្នកនាងពៅ (ព្រះភគវតីស្រីចក្រពត្តិរាជ) ជាអគ្គមហេសី និងអភិសេកព្រះអនុជបន្ទាប់ព្រះនាម ស្រីសុរិយោពណ៌ ជា មហាឧបរាជ។នៅឆ្នាំ១៥៧៤គ.ស. បានប្រសូត្របុត្រនាម ជ័យជេដ្ឋា និងឆ្នាំ១៥៨០គ.ស. មានបុត្រមួយអង្គទៀតនាម ចៅពញាតន់។ ទ្រង់មានស្នំលាវឈ្មោះ ពេជម៉ែលាវ ដោយបានប្រសូត្របុត្រនាម ចៅពញាញោម។នៅឆ្នាំ១៥៨៦គ.ស. ព្រះសត្ថាទី១ទ្រង់បានដាក់រាជ្យ ថ្វាយទៅព្រះរាជបុត្រច្បងជ័យជេដ្ឋា ដែលមានព្រះជន្ម១១ ព្រះវស្សា។ ឯពញាតន់ មានឋានៈឧបរាជ ដែលមានព្រះជន្មទើបតែ៦ព្រះវស្សា។ ដោយព្រះរាជបុត្រទាំងពីរនៅក្មេងពេកកិច្ចការគ្រប់គ្រងរដ្ឋស្ថិតនៅក្រោមការកាន់កាប់របស់ព្រះសត្ថាទី១ ដដែល ទង្វើរបស់ព្រះសត្ថាទី១ បានធ្វើឱ្យមានការអាក់អន់ចិត្ត ពីបណ្តារាជវង្សានុវង្ស នាម៉ឺនសព្វមុខមន្ត្រី និងរាស្ត្រ។ ពេលនោះសង្គមកើតមានចោរលួច ចោរប្លន់ និងអសន្តិសុខជាច្រើនកន្លែង។

ក្នុងចន្លោះឆ្នាំ១៥៧៤គ.ស.-១៥៨០គ.ស. ព្រះសត្ថាទី១បានលើកទ័ពវាយក្រុងពេជ្របុរីចំនួន បីលើក និងយកបានក្រុងនេះ ចាប់បានឈ្លើយជាច្រើន។ ពេលប្រទេសសៀមចំណុះភូមា សៀមបានសុំជំនួយពីកម្ពុជា ដោយសំអាងលើសម្ព័នភាពរវាង ខ្មែរ-សៀម កាលពីឆ្នាំ១៥៧៤គ.ស. ព្រះសត្ថាទី១ព្រមផ្តល់ជំនួយជាទ័ពដល់សៀម រហូតទទួលបានជោគជ័យលើភូមា។ ពេលនាំទ័ពមកវិញ នរេសូរ ទតឃើញស្រីសុរិយោពណ៌គង់សំយុងព្រះបាទ ពុំបានគង់ក្រាបដូចអ្នកផង ទ្រង់ព្រះពិរោធណាស់។ នរេសូរ បានកេណ្ឌរាស្ត្រខ្មែរក្នុងពេលធ្វើដំណើរមកជួបស្តេចខ្មែរ។ ស្រីសុរិយោពណ៌ ទ្រង់ខ្ចាល់ពីរឿងនេះយ៉ាងខ្លាំងក៏នាំទ័ពចូលនគរវិញ។ សៀមរមិលគុណខ្មែរបាននាំទ័ពវាយខ្មែរ ស្តេចសៀមយល់ថា កាលដែលខ្មែរជួយសៀមនោះ ធ្វើឱ្យប្រទេសសៀមអាប់កិត្តិយសនិងមុខមាត់។ ដូចនេះ នរេសូរតែងមានគំនុំ ចង់យកស្រុកខ្មែរជាចំណុះដោយរំលោភលើកិច្ចចរចា។នៅឆ្នាំ១៥៨១គ.ស. ខ្មែរបាននាំទ័ពរំដោះបាន នគររាជសីមា ចន្ទបុរី។ តែមកដល់ឆ្នាំ១៥៨២គ.ស. នរេសូរបានវាយយកវិញ។ ក្រោយមកនៅឆ្នាំ១៥៨៤គ.ស. សៀមបានប្រកាសឯករាជ្យពីភូមា។ ព្រះសត្ថាទី១ យល់ថាសៀមនឹងមកសងសឹកវិញ ទ្រង់ក៏ព្រមនៅចំណុះសៀម។

នៅឆ្នាំ១៥៨៥គ.ស. ស្តេចភូមា **ណាន់ដាបាយិន** បានលើកទ័ពមកវាយសៀមម្តងទៀត។ ព្រះបាទសត្ថាទី១យល់ថាក្រុងអាយុធ្យាគង់នឹងបាត់បង់ដោយសារភូមាម្តងទៀត ទើបផ្តាច់មេត្រីភាពពីសៀម ហើយនាំទ័ពចូលវាយ បស្ទិមបុរី...។ លុះសៀមលើកទ័ពមក ខ្មែរក៏ដកថយសិន ដោយមានដំណឹងថាសម្តេចព្រះភគវតីប្រឈួន ទ្រង់នាំទ័ពត្រឡប់មកលង្វែកវិញ។ នៅឆ្នាំ១៥៨៦គ.ស. នរេសូរខឹងនឹងព្រះសត្ថា ក៏បានលើកទ័ពមកវាយខ្មែរយកខេត្តបាត់ដំបង ពោធិសាត់ និងចូលមកដល់លង្វែក ធ្វើការឡោមព័ទ្ធបន្ទាយបន្ទាយនេះអស់កាល៣ខែ ដោយសៀមខ្វះស្បៀងកើតជំងឺឆ្លងរាតត្បាតស្លាប់ទ័ពអស់ជាច្រើន សៀមបានដកថយទៅវិញ ទ័ពខ្មែរចេញពីបន្ទាយដេញវាយសៀមរត់ខ្ចាត់ខ្ចាយ។ សៀមបរាជ័យលើកនេះ នរេសូរមិនអស់ចិត្តក៏ចាត់ឱ្យគេសួររាស្ត្រខ្មែរ  បានដឹងថាមានទេវរក្ស ១៣ អង្គជួយថែរក្សានគរខ្មែរ។ មុននឹងទ័ពសៀមដកទ័ពថយទៅ សៀមបានប្រើឧបាយកលបាញ់ប្រាក់ដួងជាច្រើនចូលក្នុងគុម្ពឫស្សី ដែលជារបងការពារយ៉ាងមាំនៃបន្ទាយលង្វែក។ សៀមបានចាត់ចារបុរសពីរនាក់ចូលមកធ្វើវិទ្ធង្សនានិងបង្កើតឱ្យមានចលាចលផ្ទៃក្នុងរបស់ខ្មែរ មហាតលិកសៀមបានក្លែងធ្វើជាអ្នកបួសនាម តិបញ្ញោនិងសុប្បញ្ញោ ចូលមកធ្វើពិធីដកសិល្ប៍សាស្ត្រ ដែលមកបញ្ចុះក្នុងរូបទេវរក្ស។ សុប្បញ្ញោ ប្រើមន្តអាគម ធ្វើឱ្យអ្នកស្រុកឈឺឯតិបញ្ញោ ជាអ្នកដោះឱ្យជា។ រាស្ត្រខ្មែរក្រោយពីដឹងថាសៀម បានបាញ់ប្រាក់ដួងចូលក្នុងគុម្ពឫស្សី មានចិត្តត្រេកអរក្រៃលេង នាំគ្នាកាប់ឆ្ការព្រៃឫស្សីដើម្បីយកប្រាក់ ទោះបីមានបំរាមពីព្រះរាជាយ៉ាងណាក៏ដោយក៏រាស្ត្រខ្មែរនៅតែ ប្រព្រឹត្តរហូតដល់កុម្ពឫស្សីធ្លុះធ្លាយអស់។ ដំណឹងនេះ បានឮដល់ស្តេចសៀម នៅឆ្នាំ១៥៩៣គ.ស. សៀមក៏លើកទ័ពចូលវាយក្រុងលង្វែកជាបីផ្លូវ។ ទោះបីទ័ពខ្មែរខំតស៊ូយ៉ាងណាក្តី ទ័ពសៀមនៅតែវាយយកបានជាបន្តបន្ទាប់នូវបន្ទាយពោធិសាត់ បន្ទាយបរិបូណ៌។ ស្រីសុរិយោពណ៌ បានកេណ្ឌទ័ព ប្រមូលស្បៀងការពារបន្ទាយលង្វែក ចំពោះទ័ពខ្មែរដែលតស៊ូ នៅនគរវត្ត ក៏ទប់ពុំជាប់។ ឯទ័ពជើងទឹកក៏ចាញ់ទៀត។ សៀមវាយកាន់តែខ្លាំងឡើងៗស្រីសុរិយោពណ៌ដកថយមកនៅបន្ទាយរលាប្អៀរ ហើយសុំជំនួយពីលង្វែក។  សៀមបានព័ទ្ធបន្ទាយ លង្វែក។ ព្រះសត្ថាទី១ នាំបុត្រជ័យជេដ្ឋា និងចៅពញាតន់ភៀសទៅគង់នៅស្រីសន្ធរ ក្រោយមកភៀសទៅស្ទឹងត្រែង ទីបំផុតភៀសទៅគង់នៅវៀងចន្ទ និងរាជធានីប្រទេសលាវ។

ចំណែកស្រីសុរិយោពណ៌ បានស្ថិតនៅក្នុងបន្ទាយលង្វែកដើម្បីប្រយុទ្ធនឹងសៀម។ ទីបំផុត នៅតែសៀមយកបានក្រុងលង្វែកនៅឆ្នាំ ១៥៩៥គ.ស.  ដោយចាប់ព្រះអង្គនិងបុត្រនាម ជ័យចេស្តា  ព្រមទាំងឧទ័យរាជា។ការបែកក្រុងលង្វែកបណ្តាលឱ្យជាតិជួបផលវិបាកយ៉ាងខ្លាំង ព្រោះប្រទេសជួបនូវវិបត្តិកាន់តែខ្លាំងឡើងហើយប្រទេសធ្លាក់ទៅជារដ្ឋទន់ខ្សោយមួយ នៅតំបន់អាស៊ីអាគ្នេយ៍។ កម្ពុជាបាត់បង់កេតនភណ្ឌជាតិ ក្បួនខ្នាត ច្បាប់ អ្នកប្រាជ្ញ បណ្ឌិត វប្បធម៌ខ្មែរ ត្រូវសៀមបំផ្លាញស្ទើរតែអស់។ ប្រទេសធ្លាក់ក្នុងអនាធិបតេយ្យ គ្រោះទុរភិក្ស កើតមានពេញផ្ទៃប្រទេស។ ក្នុងរយៈកាល១០ឆ្នាំ មានមហាក្សត្រ៤អង្គសោយរាជ្យបន្តបន្ទាប់     និងមានការជ្រែករាជ្យដល់ទៅពីរលើក។  ប្រទេសកម្ពុជាបានបាត់បង់អាណាខេត្តខាងលិច និងពាយ័ព្យដូចជា ខេត្តចន្ទបុរី បស្ទឹម បុរី នគររាជសីមា បាត់ដំបង សៀមរាប ពោធិសាត់[17]

[17] -ត្រឹងងារ ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ ១៩៧៣

។ ចំណែកស្រីសុរិយោពណ៌ បានស្ថិតនៅក្នុងបន្ទាយលង្វែកដើម្បីប្រយុទ្ធនឹងសៀម។ ទីបំផុត នៅតែសៀមយកបានក្រុងលង្វែកនៅឆ្នាំ ១៥៩៥គ.ស. (១៥៩៤គ.ស.) ដោយចាប់ព្រះអង្គនិងបុត្រនាម ជ័យចេស្តា ព្រមទាំងឧទ័យរាជា។

**ង. ទំនាក់ទំនងជាមួយជនជាតិអឺរ៉ុប**

បរមរាជាទី៤ទ្រង់យល់ថាសកម្មភាពខាងជំនួញនឹងកើតមានឡើងព្រោះទ្រង់សុំឱ្យអង្គការកណ្តាល នៅ Alasca(អាឡាស្កា) បញ្ជូនអ្នកផ្សាយសាសនាមកកាន់ប្រទេសកម្ពុជា។ ដូចនេះទើបគេឃើញមាន បព្វជិតពីរអង្គបានមកដល់ប្រទេសកម្ពុជាគឺបុព្វជិត(ឡូពូកាដូសូ និងដោម៉ាឌីរ) Lopo Cardoso និង Joao Madeira គេមិនដឹងថាសង្ឃទាំងពីរអង្គនេះបានមកដល់កម្ពុជាក្នុងឆ្នាំណាទេ តែបើតាមហេតុការណ៍កើតនោះ សង្ឃទាំងពីរបានមកដល់លង្វែកមុនឆ្នាំ១៥៧០គ.ស. ព្រោះក្នុងកំណត់ហេតុរបស់លោក Cardoso ឬ Medeira) បានបង្ហាញថាជនជាតិព័រទុយហ្គាល់បានរកឃើញប្រាសាទនៅតំបន់អង្គរ។ ដោយក្រុមអ្នកផ្សព្វផ្សាយសាសនានេះ ពុំបានធ្វើឱ្យជំនួញលូតទៅមុខនៅកម្ពុជា ដូចទ្រង់បានគិតទុកនោះ ទ្រង់ចាប់ផ្តើមធ្វើលើរូបបព្វជិតទាំងនោះ។ បុព្វជិត(ស៊ីលវែសទ្រីដាសឺវីដូ) Sylvestre d’Acevedo បានមកជំនួសបព្វជិត Mdeira ឯបព្វជិត Cardoso ក៏ត្រូវត្រឡប់ទៅវិញ។ បន្ទាប់មកមានបុព្វជិតពីរអង្គទៀត បានមកដល់កម្ពុជាតែមិនយូរប៉ុន្មាន ក៏ត្រឡប់ទៅវិញទៀត។ អ្នកដែលនៅក៏មិនបានផ្សាយសាសនាឱ្យជ្រួតជ្រាបក្នុងសង្គមខ្មែរដែរ[18]។

ដូចជាក្នុងរាជព្រះសត្ថា ជាក្សត្រទន់ខ្សោយពុំមានប្រជាប្រិយ មានចិត្តច្រណែននឹងស្រីសុរិយោពណ៌ផងនោះ ព្រះអង្គ ត្រូវការជំនួយដើម្បីប្រឆាំងនឹង **សត្រូវទាំងខាងក្នុងនិងខាងក្រៅប្រទេស**។ ទ្រង់យកចិត្តពួកអ្នកផ្សាយសាសនាគ្រឹស្ត ដោយផ្តល់សិទ្ធិពេញលេញ និងអនុញ្ញាតិឱ្យសង់ព្រះវិហារគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ព្រះសត្ថាបានឧបត្ថម្ភពួកនេះ ជាអង្ករ និងវត្ថុផ្សេងៗទៀតផង។

នៅឆ្នាំ១៥៨៥គ.ស. លោក Sylvestres បានបញ្ជូនបព្វជិតបន្ថែមគឺ(អង់តូនីញ៉ូឌូតា និងអង់តូនីញ៉ូកាល់ឌីរ៉ា) Antonio Dorta និង Antonio Caldeira មកប្រទេសកម្ពុជា។ តែដោយការធ្វើទុកបុកម្នេញខ្លាំងពេក ទើបបុព្វជិតទាំងពីរត្រឡប់ទៅវិញ។ តែដោយឥទ្ធិពល លោក Sylvestres ធ្វើឱ្យព្រះសត្ថាយល់ព្រមឱ្យបព្វជិតនេះផ្សព្វផ្សាយសាសនាគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា នៅឆ្នាំ១៥៨៩គ.ស.។ក្រោយមកលោក Sylvestres បញ្ជូនបព្វជិតកាន់តែច្រើនឡើងៗ ដូចជា(ដោជីម៉ាតូនិងល្វីសដឹហ្វុនសេកា) Jorge de Mota និង Luis de Fonseca។ តែក្នុងឆ្នាំ ១៥៨៥គ.ស. ជនជាតិព័រទុយហ្គាល់ដែលមានវ័យ ២០ឆ្នាំឈ្មោះ Diogo Veloso បានមកដល់ខ្មែរ ជាមួយពួកខ្លួនគឺ ការនីរ៉ូ,ម៉ាឆាដូ,សាគ្រីដូ,ឌីយូហ្គោ,ដឹឆាវែសកាមីហ្សារេស)Carneiro, Machado, Sagredo, Diogo de Chaves Camizares។ នៅឆ្នាំ១៥៩៣ គ.ស. អ្នកផ្សងព្រេងជាតិអេស្ប៉ាញ បានមកដល់កម្ពុជាទៀត គឺលោក(រីសដឹហេមែនហ្គោហ្សាឡេសនិងវ៉ាហ្គាសម៉ាជូកា) Ruiz de Heman Gonzale’z និង Vargas Machuca។ ក្រុមទាំងនេះ ព្រះសត្ថាទុកជា

[18] -.លោក អាដេម៉ា ឡឺក្លែរ ប្រវត្តិសាស្ត្រខ្មែរឆ្នាំ ២០០៦

ដៃជើងរបស់ទ្រង់។ ទ្រង់បានអភិសេកប្អូនជីដូនមួយស្រីរបស់ទ្រង់ ឱ្យចៅ Diogo Veloso ឯលោក Ruiz ត្រូវបានព្រះអង្គតែងតាំងជាអង្គរក្សរបស់ទ្រង់។

នៅឆ្នាំ១៥៩៣គ.ស. នរេសួរ លើកទ័ពមកវាយប្រទេសកម្ពុជាលើកទី២ទៀត។តាមរយៈ Veloso ព្រះសត្ថាបានទាក់ទងជាមួយអ្នកកាន់អំណាចព័រទុយហ្គាលនៅ(ម៉ាឡាកា) Malaca តែពួកនេះមិនអាចជួយខ្មែរបាន ព្រោះជាប់ច្បាំងជាមួយម៉ាឡាយូ Acheh និង Johore នាំឱ្យព្រះសត្ថាងាកទៅរកពួកអេស្ប៉ាញវិញ នេះបើតាមយោបល់ Ruiz និង Vargas។ តែការទំនាក់ទំនងពុំទទួលបានផលឡើយ ព្រោះសៀមបានវាយយកក្រុងលង្វែកមុន[19]។

## ២.២. សាមគ្គីភាព និង វិបុលភាព

ក្រោមការដឹកនាំរបស់ព្រះបាទចន្ទរាជានិងដោយសារជំនឿរបស់ខ្មែរ គោរពព្រះគោនិងព្រះកែវជាបងប្អូនបង្កើតនិងគ្នា ដែលអ្នកស្រុកតែងតែគោរពបូជា ទុកជាវត្ថុសក្តិសិទ្ធិដោយសារនៅក្នុងបន្ទាយលង្វែកមានរូបព្រះគោ ព្រះកែវ គេមានជំនឿថានេះជាបន្ទាយមួយយ៉ាងមាំសម្រាប់ការពារសត្រូវផងនិងជាឃ្លាំងវប្បធម៌ជាតិបន្ទាប់ពីអង្គរ ។ហើយមានតម្កល់វត្ថុសក្តិសិទ្ធិ គឺព្រះកែវ ព្រះត្រឡែងកែង និងព្រះគោ ចំនួន ១២ ដែលនៅក្នុងពោះព្រះគោទាំងនោះ មានរក្សានូវគម្ពីរក្បួនសាស្ត្រាដ៏មានតម្លៃលើសលប់។ មានផ្ទះស្រីស្នំ ក្រមការ បុត្រាបុត្រីនិងមានឃ្លាំងធំៗទុកស្រូវ អង្ករ អំបិល ប្រហុក ត្រីងៀត ត្រីឆ្អើរ និងឃ្លាំងសាស្ត្រាវុធ[20]។

ព្រះអង្គបានត្រាស់ឱ្យកសាងបន្ទាយលង្វែកឆ្នាំ ១៥២៧-១៥២៩គ.ស ដោយមានរយៈពេល ៣ ឆ្នាំ ដែលមានកំផែងដីថ្មយ៉ាងរឹងមាំនិងខាងក្នុងបន្ទាយមានដំណាក់ជាច្រើនមានរោងល្ខោន ឃ្លាំងវត្ថុ។

ក្រៅពីវិស័យផ្សេងៗចម្រើនវិស័យពាណិជ្ជកម្ម កម្ពុជាជាមួយនិង អឺរ៉ុប អេស្ប៉ាញ៉ុល ព័រទុយហ្គាល់ក៏មានសក្តានុពលល្អផងដែរអាចបាននិយាយទៅមិនចាញ់ក្រុងអាយុធ្យានៃប្រទេសស្យាមនោះទេ សម័យលង្វែក ចាត់ទុកថាគឺជាសម័យរុងរឿងបន្ទាប់ពីសម័យអង្គរ ។

- ផ្នែកកសិកម្ម៖មានសកម្មភាពខ្លាំង ព្រោះព្រះរាជាសម័យនោះបានយកព្រះទ័យទុកដាក់នឹងបញ្ហានេះណាស់។ ព្រះអង្គតែងតែគិតគូរដល់ដីធ្លីសម្រាប់ប្រជារាស្ត្រធ្វើស្រែចំការ ថែមទាំងបានជីកអូរព្រែក ប្រឡាយ សម្រាប់ផ្គត់ផ្គង់ទឹកដល់កសិកម្ម។ ក្នុងរជ្ជកាលព្រះបាទចន្ទរាជា ទ្រង់បានបញ្ជាទ័ពឱ្យកាប់ឆ្ការព្រៃដើម្បីវាតទីដីស្រែចំការ សម្រាប់ប្រជារាស្ត្រ។ នៅរដូវបង្កបង្កើនផល និងប្រមូលផល គេតែងតែបញ្ឈប់ សង្គ្រាមដើម្បីជួយប្រជារាស្ត្រក្នុងការប្រកបរបរកសិកម្ម។

- ផ្នែកពាណិជ្ជកម្ម៖ដោយសារបឹងទន្លេសាបសម្បូរត្រី ហើយដីនៅជុំវិញសម្បូរជីជាតិ និងទន្លេមេគង្គជាផ្លូវទឹកដ៏សំខាន់សម្រាប់ដឹកនាំទំនិញទៅលក់ឯបរទេស វិស័យពាណិជ្ជកម្មមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ក្នុងរជ្ជកាលព្រះបាទពញាយ៉ាត ស្តេចកន ចន្ទរាជា ។ប្រទេសកម្ពុជាសុទ្ធតែបាននាំទំនិញទៅលក់នៅបរទេស ហើយទិញមកវិញនូវគ្រឿងសាស្ត្រាវុធ។ ព្រះបាទបរមរាជាបានធ្វើទំនាក់ទំនងជាមួយ

[19] -លោក អេង  សុត មហាបុរសខ្មែរ ឆ្នាំ ២០០៩

[20] -.លោក អាដេម៉ា ឡឺក្លែរ ប្រវត្តិសាស្ត្រខ្មែរឆ្នាំ ២០០៦

ពួកអឺរ៉ុប ជប៉ុន ចិន ជ្វា ឱ្យមកធ្វើជំនួញនៅស្រុកខ្មែរយ៉ាងច្រើនសន្ធឹកសន្ធាប់។ ពួកនេះបាននាំទំនិញដូចជាកំណាត់សំពត់ ឧបករណ៍ប្រើប្រាស់ផ្សេងៗហើយនាំចេញទៅវិញនូវគ្រឿងទេស ភ្លុកដំរី ស្នែង ជ័រទឹកស្បែក។

- ផ្នែកសិប្បកម្មៈ សកម្មភាពសំខាន់ក្នុងសម័យនោះគឺការស្លដែក ដែលមានសន្ទុះខ្លាំងក្លាចាប់ពីរជ្ជកាលព្រះបាទចន្ទរាជា ព្រោះព្រះអង្គបានយកព្រះទ័យទុកដាក់នឹងបញ្ហានេះណាស់។ ប៉ុន្តែការប្រើដែលជាវត្ថុធាតុដើម មានរបរដំដែកជាដើម មានសកម្មភាព តាំងពីក្នុងរជ្ជកាលព្រះបាទពញាយ៉ាតម្ល៉េះ។

## ២.៣. កំណត់ត្រាប្រវត្តិសាស្ត្រនិង ហេតុផល

### ២.៣.១. ការបែកបាក់បន្ទាយលង្វែកតាមកំណត់ត្រាសៀម



ប្រជារាស្ត្រកាប់ឆ្កាគុម្ពឫស្សី

សៀវភៅព្រះរាជពង្សាវតាអយុធ្យារបស់ប្រទេសថៃបានសរសេរចាប់ពីទំព័រ ១៣៩ ដល់ទំព័រ ១៥៤ ដែលមានលក្ខណៈផ្ទុយពីសៀវភៅ ព្រះរាជពង្សាវតាខ្មែរ របស់ប្រទេសកម្ពុជា។ បន្ទាប់ពីបានវាយបកទៅលើព្រះចៅនៃរាជវង្ស តុងអ៊ូ (Tong_oo) នៅរាជធានី ហង្សាវតី (ប្រទេសភូមា) រួចមក ព្រះចៅ ណារ៉េសួរ (King Naresuan) របស់សៀមបានលើកទ័ពចូលធ្វើសង្គ្រាមប្រឆាំងក្រុងកម្ពុជាធិបតី។ ក្នុងឯកសារព្រះរាជពង្សាវតាអយុធ្យា នោះមករៀបរាប់ថា៖ «នៅក្នុងសង្គ្រាមជាមួយខ្មែរលើកនេះសៀមបានកេណ្ឌកងទ័ពមានទាំងជើងគោកនិងជើងទឹក កងទ័ពសេះ កងទ័ពដំរី ជាច្រើនកង ដើម្បីវាយបង្ក្រាបមកលើទ័ពខ្មែរ។ សៀមបានប៉ះប្រយុទ្ធ ជាមួយកងទ័ពខ្មែរនៅក្រុងសិរីសោភ័ណ(បន្ទាយមានជ័យ) បាត់ដំបង ពោធិ៍សាត់ និងនៅស្រុកបរិបូណ៌ ដែលធ្វើឱ្យកងទ័ពទាំងសងខាងស្លាប់ ជាច្រើនម៉ឺននាក់។» ឯកសាថៃដដែលនេះ បានរំលឹកអំពីវីរភាពរបស់កងទ័ពខ្មែរ ដែលមានថ្វីដៃខ្លាំងពូកែ សុខចិត្តពលីជីវិតនៅក្នុងសមរភូមិ មិនចុះញ៉មជាមួយទ័ពសៀមជាដាច់ខាត។ «តែទោះជាយ៉ាងនេះក្តី ដោយសារកងទ័ពសៀមមានចំនួនច្រើនជាង ទើបធ្វើឱ្យបន្ទាយការពារតាមតំបន់នីមួយៗ ត្រូវបានទ័ពសៀមដណ្តើមបាន ព្រមទាំងបានចាប់ចៅហ្វាយខេត្តទាំងនោះ ជាឈ្លើយសឹកទៀតផង។លុះពេលវាយមកដល់រាជធានីលង្វែក (Lawaek) ស្តេច នរេនសួរ បានចេញព្រះរាជបញ្ជាឱ្យកងទ័ពគ្រប់ផ្នែកទាំងអស់ឡោមព័ទ្ធបន្ទាយ។ ព្រះរាជពង្សាវតាអាយុធ្យាបាន សរសេរថា៖ « ព្រះចៅនរេសួរ បានគង់ប្រថាប់នៅលើដំរីខាងមុខកងទ័ព ដើម្បីប្រយុទ្ធនៅក្នុងសមរភូមិ។ (ព្រះបាទអគ្គទសរតន៍ ក៏គង់នៅលើដំរីខាងមុខកងទ័ពដែរ។ រីឯកងទ័ពស្រួចដ៏ក្លាហាន (សៀម) បានឈរនៅលើខ្នងដំរីនៅពីមុខក្លោងទ្វារខាងជើងដែរ ដឹកនាំដោយ(ប្រាយ៉ាម៉ាហាយុទ្ធា) "Praya Maha Yotha" (ពញា មហាយុទ្ធា)។ » «"Praya Maha Yotha" (ប្រាយ៉ាស៊ីរតចាឌីចូ)"Praya Si Ratcha Decho" ប្រាយ៉ាថៃណាំនិងប្រាយ៉ារតចាម៉ានូ)"Praya Thai Nam" និង"Praya Ratcha Manu" បានបញ្ជាដំរីរបស់ពួកគេ សំរុកចូលទៅកំទេចទ្វាររាជធានី។ កងទ័ពខ្មែរដែលឈរការពារ នៅតាមច្រកទ្វារនីមួយៗ បានបាញ់ព្រួញ កាំភ្លើងតូចធំ និងគ្រាប់រំសេវ ចេញទៅគ្រប់ជ្រុងទាំងអស់ ធ្វើឱ្យទ័ពសៀមស្លាប់ និងរបួសជាច្រើននាក់។ ប៉ុន្តែ "Praya Maha Yotha" នៅតែ

បញ្ឆាដំរីឱ្យរត់ទៅមុខ និងកំទេចទ្វាររបស់រាជធានី ឱ្យទាល់តែបាន។ ទីបំផុត នៅថ្ងៃសៅរ៍ ៣កើត ខែពិសាខ ឆ្នាំវក ភ្លោងទ្វារបន្ទាយ ឬរាជធានីលង្វែក ក៏ត្រូវបានដួលរលំ។ ទាហ៊ានសៀមបានចូលទៅក្នុងរាជធានី និងចាប់ខ្មែរជាច្រើននាក់ ហើយបានចាប់យកស្តេចខ្មែរ ទៅថ្វាយស្តេចសៀម។

សរុបសេចក្តីមក«ត្រង់ចំណុចនៃការរៀបរាប់អំពីចម្បាំងនេះ សៀវភៅព្រះរាជពង្សាវតាអយុធ្យាមិនបាននិយាយអំពីការបាញ់ប្រាក់ខ្លួង ចូលក្នុងគុម្ពឬស្សីឡើយ។ ហេតុនេះយើងគួរតែពិចារណា និងសិក្សាលើសៀវភៅ ព្រះរាជពង្សាវតាខ្មែរឡើងវិញ ដែលបានលើកឡើងថាទ័ពសៀមបានបាញ់ប្រាក់ដួងហើយប្រជាជនខ្មែរខ្លួនឯង ជាអ្នកកាប់ឆ្ការព្រៃឬស្សីទាំងនោះទើបធ្វើឱ្យទ័ពសៀមមានឱកាសវាយចូល និងកំទេចរាជធានីបាន។ តើរវាងរាជពង្សាវតាខ្មែរ និងអយុធ្យា មួយណាដែលយើងអាចទុកចិត្តបាន?»

ការកង្វះតម្លាភាព ឯកសារ «ព្រះរាជពង្សាវតាអយុធ្យា» ដោយពួកគេអះអាងថា សៀម បានសរសេររឿងរ៉ាវនេះដោយខ្លួនឯង ដើម្បីលើកតម្កើនស្តេច និងប្រវត្តិសាស្ត្ររបស់សៀមខ្លួនឯង។ នេះបើទោះជាឯកសារនេះ រៀបរៀងឡើង និងសរសេរដោយជនជាតិបរទេស (ផ្សេងពីខ្មែរ និងសៀម)លោកបណ្ឌិត ចិន្ត ច័ន្ទរតនា ជំនាញខាងបូរាណវិទ្យា និងប្រវត្តិសិល្បៈ។«បញ្ហាបាញ់ប្រាក់ដួង គឺមាននិយាយនៅក្នុងព្រះរាជពង្សាវតាក្រុងចាស់ របស់ហ្លួងប្រសើតអក្សរនីតិ និងឯកសារប្រវត្តិការកសាងជាតិ របស់ ព្រះនរេសួរ របស់កងទ័ពជើងទឹកថៃ។ «ថៃសរសេរថា គេចាប់បានស្តេចខ្មែរយកទៅកាត់ក ក្រោយបែកបន្ទាយលង្វែក។ តាមពិតស្តេចខ្មែរបានភៀសខ្លួនទៅខេត្តអាចម៍ក្រពើរួចទៅហើ ដោយកងរក្សាព្រះអង្គបានវាយបើកផ្លូវឈាមដើម្បីជម្លៀសព្រះអង្គនិងរាជវង្សានុវង្សគេចចេញពីសត្រូវ។ ការដែលចាប់បាននោះគឺស្រីសុរិយោព៌ណនិងបុត្រាទាំងពីរទៅវិញទេ។

### ២.៣.២. ការបែកបាក់បន្ទាយលង្វែកតាមពង្សាវតាខ្មែរ

ការបាក់បែកបន្ទាយលង្វែក ដែលជារាជធានីដ៏រឹងមាំចុងក្រោយរបស់ខ្មែរ បានកើតឡើងដោយសារប្រជាជនខ្មែរជាអ្នកកាប់ឆ្ការព្រៃឬស្សី ដើម្បីយកប្រាក់ខ្លួង ឬយ៉ាងណា?

តាមអ្នកស្រាវជ្រាវប្រវត្តិនៃការដួលរលំបន្ទាយលង្វែកនៅចុងសតវត្សរ៍ទី១៦ក្នុងឆ្នាំ១៥៩៤ គ.ស. បានកើតឡើងដោយសារភាពលោភលន់ និងកង្វះការពិចារណាវែងឆ្ងាយ របស់ប្រជាជនកម្ពុជាខ្លួនឯងហេតុបានកាប់ឆ្ការកំពែងព្រៃឬស្សីជុំវិញរាជធានី ដើម្បីយកប្រាក់ខ្លួង និងដើម្បីបង្កភាពងាយស្រួល ឱ្យសៀមលើកទ័ពវាយបំបែករាជធានីមែនឬ? មានមតិជាច្រើន បានលើកឡើងខុសៗគ្នា ជាពិសេសមានការប្រទាំងប្រទើសគ្នា រវាងឯកសារព្រះរាជពង្សាវតាខ្មែរ របស់ប្រទេសកម្ពុជា និងព្រះរាជពង្សាវតាអយុធ្យារបស់ប្រទេសថៃ ទាក់ទងនឹងហេតុការណ៍ នៃការធ្វើសង្គ្រាមរបស់សៀមប្រឆាំងខ្មែរ នៅក្នុងសម័យកាលនោះ។ចំណែកឯលោក «MC Sovann» វិញ បានសរសេរទម្លាក់កំហុស ទៅលើអ្នកប្រវត្តិសាស្ត្រថៃ ដែលសរសេរពង្វាង ខុសពីប្រវត្តិពិតថា៖ «បើប្រវត្តិសាស្ត្រសរសេរថា ស្តេចសៀមប្រើល្បិចនោះ ដូចជាប្រមាថចេស្តាស្តេច។ អញ្ចឹងបានអ្នកប្រវត្តិសាស្ត្រសរសេរតែកន្លែងខ្លាំង និងការវាយសន្ធប់លើខ្មែរ។ ជាការពិតណាស់ បើសិនជាអ្នកប្រវត្តិសាស្ត្រសៀមសរសេរថា សៀមប្រើល្បិចលើខ្មែរនោះសបញ្ជាក់ឱ្យឃើញថាសៀមគ្មានសមត្ថភាពបំបែកក្រុងលង្វែក ទើបបានជាបាញ់ប្រាក់ខ្លួង ចូលគុម្ពឬស្សី។»។

លោក វង្ស សុធារ៉ា បានបញ្ជាក់ថា តាមការស្រាវជ្រាវថ្មី ប្រាក់ដួង មិនមាននៅក្នុងសម័យលង្វែកទេ គឺមានតែពាក្យថា"ដុំប្រាក់"(រាងស្រដៀងក្រចកសេះ)។ រីឯប្រាក់ដួងគឺទើបតែបង្កើតនៅរាជព្រះបាទអង្គដួង ហរិរាមា ឥស្សរាធិបតី នាឆ្នាំ១៨៤១គ.ស. នេះទេ។

តាមឯកសារពង្សាវតាខ្មែរ បានបង្ហាញថា ស្តេចសៀម នរេសូរ ឱ្យគេយកជ័រទឹក យកមកជះដុតកំពែងឬស្សី។បើតាមពង្សាវតាខ្មែរជារឿងត្រឹមត្រូវជាងដោយសារគុម្ពឬស្សីគេអាចដុតឆេះលឿនជាងកាប់។

### ២.៣.៣. ការបែកបាក់បន្ទាយលង្វែកតាមកំណត់ត្រាអឺរ៉ុប



ការមកដល់របស់ពួកអឺរ៉ុប

ក្រុងលង្វែកក្នុងស្រុកកំពង់ត្រឡាចមានភាពទាក់ទាញ ប៉ុន្តែសាមញ្ញ។ វាពិបាកស្រមៃថារាជធានីដ៏អស្ចារ្យមួយដែលព័ទ្ធដោយជញ្ជាំងនៅខាងកើត ស្រះទឹក និងព្រៃឈើជុំវិញគឺនៅទីនេះ ហើយក៏ជាកន្លែងដែលកប៉ាល់ពាណិជ្ជករនានាមកពីប្រទេសឆ្ងាយៗដូចជាប្រទេសហូឡង់ ឬប្រទេសអេស្ប៉ាញបានមកបោះយុថ្កាឈប់នៅទន្លេសាបជិតនេះ។

ការកត់ត្រារបស់ពួកព័រទុយហ្គេ ថាស្តេចខ្មែររត់ទៅខេត្តអាចម៍ក្រពើ ហើយអ្នកដែលត្រូវចាប់ខ្លួននោះ គឺជាព្រះស្រីសុរិយោពណ៌ទៅវិញទេ ហើយក៏មិនបានសម្លាប់ដែរ ព្រោះព្រះអង្គបានត្រឡប់មកឡើងសោយរាជ្យ នៅស្រុកខ្មែរវិញ។» សូម្បីក្នុងចំណោមប្រជាពលរដ្ឋខ្មែររយៈពេល ៦ ទសវត្សរ៍ក្នុងសតវត្សរ៍ទី ១៦ ដែលក្នុងសម័យនោះ ក្រុងលង្វែក ជារាជធានីរបស់កម្ពុជាត្រូវបានចងចាំថាជាសម័យកាលងងឹតមួយដែលពោរពេញដោយការចាញ់ និង «ភាពអាម៉ាស់ខ្លាំង» នៅក្រោមកណ្តាប់ដៃពួកឈ្លានពានមកពីអាយុធ្យាក្នុងឆ្នាំ១៥៩៣គ.ស.

### ២.៣.៤. ការរំដោះក្រុងលង្វែកពីសៀម

#### ក. ព្រះរាមាជើងព្រៃឆ្នាំ១៥៩៤គ.ស.-១៥៩៦គ.ស.



ការរំដោះក្រុងលង្វែកពីសៀម

ព្រះអង្គត្រូវជាញាតិព្រះសត្ថាទី១។ នៅឆ្នាំ១៥៩៤ គ.ស.ព្រះអង្គបាននាំទ័ពចូលវាយសៀម នៅឧដុង្គ ព្រមទាំងរំដោះបានក្រុងលង្វែកជាស្ថាពរ។ ទ្រង់បានឡើងសោយរាជ្យ នៅស្រីសន្ធរ (ខេត្តកំពង់ចាម) ព្រះសត្ថា និងបុត្រទាំងពីរសុគត់ទៅប្រទេសលាវ។នៅឆ្នាំ១៥៩៦គ.ស ជម្លោះមួយបានផ្ទុះឡើងរវាងឈ្មួញចិន និងពួកទាហានជើងទឹកអេស្ប៉ាញ។ ឈ្មួញចិនប្រមាណជា **១០០នាក់**ត្រូវស្លាប់ ហើយទំនិញនិងសំពៅក៏ត្រូវរឹបអូសទាំងអស់។ Veloso បានសុំអនុញ្ញាតិពីព្រះរាមជើងព្រៃចូលគាល់ ដើម្បីបំភ្លឺឧប្បត្តិហេតុដែលកើតឡើងនោះ តែទ្រង់ដាក់ល័ក្ខខណ្ឌថា ទាល់តែពួកអេស្ប៉ាញព្រមសងទំនិញទៅពួកចិនទាំងអស់ជាមុនសិន ទើបទ្រង់អនុញ្ញាតិឱ្យចូលគាល់។ Veloso និង Ruiz សម្រេចថា ត្រូវតែប្រើកម្លាំងទ័ព ដោយនាំទាហាន **៣៨**នាក់ ទៅព័ទ្ធវាំងនៅស្រីសន្ធរ រួចសម្លាប់រាមាជើងព្រៃ ក្នុងពេលរាត្រី ហើយត្រឡប់មកភ្នំពេញវិញ។ ហើយពួកនេះបាននាំដំណឹងទៅថ្វាយព្រះសត្ថា

នៅប្រទេសលាវ តែពេលទៅដល់ប្រទេសលាវទើបដឹងថាព្រះសត្ថានិងបុត្រជ័យជេដ្ឋាបានសោយ ទីវង្គត ទៅហើយ។ ក្រោយមកក្រុមនេះបាន ដង្ហែរបុត្របន្ទាប់ គឺចៅពញាតន់ ចូលប្រទេសកម្ពុជាវិញ។

ព្រះចៅនរេនសួរស្តេចសៀម ក្រោយពីបានជ័យជម្នះលើខ្មែរហើយ ក៏ទ្រង់តែងតាំងមហាមន្ត្រីសៀម និងពលទាហាន ២០០០នាក់ ឱ្យនៅក្នុងស្រុកឧដុង្គ ដើម្បីត្រួតត្រាកិច្ចការប្រទេសខ្មែរ។ ឯព្រះអង្គទ្រង់នាំរេហ៍ពលយាងត្រឡប់ទៅក្រុងអាយុធ្យាវិញ។ ពេលនោះ សម្តេចព្រះរាមាធិបតីអុង នៅខេត្តជើងព្រៃ ដែលអ្នកផងនិយមហៅថា ព្រះបាទរាមាជើងព្រៃ ដែលជាព្រះញាតិរបស់ព្រះមហិន្ទរាជាព្រះសត្ថា ទ្រង់បានកេណ្ឌទ័ពទៅវាយកម្ចាត់ពួកសៀម នៅឧដុង្គនោះឱ្យបរាជ័យ ហើយដកទ័ពរត់ត្រឡប់ទៅស្រុកវិញអស់ក្នុងឆ្នាំ១៥៩៤គ.ស. នៃគ្រិស្តសករាជ។ បន្ទាប់មក ព្រះអង្គក៏ទ្រង់ឡើងគ្រងរាជ្យនៅរាជជានីស្រីសន្ធរ ដោយមានព្រះនាមក្នុងរាជ្យថា ព្រះរាមាធិបតីបរមរាជាធិរាជ។

ព្រះរាមាធិបតីព្រះរាមជើងព្រៃ ទ្រង់គ្រងរាជ្យបានតែបីឆ្នាំប៉ុណ្ណោះ ក្នុងខែមករា ឆ្នាំ១៥៩៦គ.ស. លោក វេឡូសូ ជាប្អូនថ្លៃព្រះសត្ថា និងស្មៀនគ្របក្ខពួក ដែលឯកសារខ្លះថាបានទៅស្រុកកំណើត តែឯកសារខ្លះថា ត្រូវបានព្រះមហិន្ទរាជាព្រះសត្ថា បញ្ជាឱ្យទៅសុំជំនួយពីលោកទេសាភិបាលអេស្ប៉ាញ៉ុល នៅហ្វីលីពីន បានត្រឡប់មកដល់ប្រទេសកម្ពុជា វិញ ដោយនាំទាំងកម្លាំងទ័ពជំនួយមួយចំនួនមកផង។ ពេលមកដល់ វេឡូសូ ដឹងថា ក្រុងលង្វែក បានត្រូវវាយបែកដោយទ័ពសៀម រួចទៅហើយ ហើយព្រះមហិន្ទរាជាព្រះសត្ថា និងព្រះញាតិវង្សមួយចំនួន ទ្រង់បានភៀសខ្លួនទៅប្រទេសលាវ ហើយមានព្រះរាជាថ្មី គឺព្រះរាមាជើងព្រៃ បានឡើងសោយរាជ្យនៅប្រទេសខ្មែរដូច្នោះ ក៏មានការអាក់អន់ស្រពន់ចិត្តជាខ្លាំង។ គាប់ជួនជាខែមេសា នៃឆ្នាំនោះមានជម្លោះរវាងពួកឈ្មួញចិន និងពួកទាហានជើងទឹកអេស្ប៉ាញ៉ុល បានកើតឡើង ហើយដែលបានធ្វើឱ្យឈ្មួញចិន ប្រមាណ ១០០នាក់ស្លាប់ រួចទំនិញទាំងអស់របស់ចិន ត្រូវរឹបអូសនោះ លោក វេឡូសូ បានសុំអនុញ្ញាតពីព្រះរាមាជើងព្រៃ ដើម្បីចូលគាល់ ហើយស្រាយបំភ្លឺព្រះអង្គអំពីបុព្វហេតុដែលកើតមាននោះ។ ប៉ុន្តែព្រះរាមាជើងព្រៃ ទ្រង់បានដាក់លក្ខខណ្ឌថា ទាល់តែពួកអេស្ប៉ាញ៉ុលសងទំនិញទាំងអស់ទៅពួកចិន សិន ទើបព្រះអង្គអនុញ្ញាតឱ្យចូលជួបបាន។ ដោយហេតុនោះ លោក វេឡូសូ និងលោក រ្វីស បានសម្រេចចិត្តប្រើកម្លាំងទ័ព ដើម្បីវាយលុកព្រះរាជវាំងស្រីសន្ធរ ហើយធ្វើគតព្រះរាមាជើងព្រៃ ក្នុងឆ្នាំនោះទៅ។មានឯកសារខ្លះទៀតដូចព្រះរាជពង្សាវតារមហាបុរសខ្មែរ បានអធិប្បាយថា កាលបើត្រឡប់មកដល់ប្រទេសខ្មែរវិញហើយដឹងថា ព្រះមហិន្ទរាជាព្រះសត្ថា និងព្រះញាតិវង្សទ្រង់ភៀសព្រះអង្គទៅខេត្តស្ទឹងត្រែង ហើយមានស្តេចថ្មី គឺព្រះរាមាជើងព្រៃ ទ្រង់ឡើងសោយរាជ្យនៅរាជជានីស្រីសន្ធរ ដូច្នោះ លោក វេឡូសូ និងបក្ខពួក បានធ្វើឧបាយកលជាសុំចូលគាល់ព្រះរាមាជើងព្រៃ ដោយនាំយកកាំភ្លើងវែងមួយចំនួន និងកាំភ្លើងខ្លីក្រំមាសយ៉ាងល្អ ដែលខ្លួនទើបនឹងបានមក យកទៅថ្វាយព្រះអង្គ ដើម្បីសុំជ្រកក្រោមបុណ្យបារមី។ ព្រះរាមាធិបតីព្រះរាមាជើងព្រៃ មិនបានជ្រាបពីឧបាយកលនេះ ក៏ទ្រង់អនុញ្ញាតឱ្យចូលគាល់តាមសំណើ។ លោក វេឡូសូ យកកាំភ្លើងវែងរបស់ខ្លួន ២៤ ដើមដាក់ក្នុងហិប ឱ្យទាហាន អេស្ប៉ាញ៉ុល សែងជា ១២ស្នែងចូលទៅ ហើយកាំភ្លើងខ្លីក្រំមាសនោះ លោក វេឡូសូ កាន់ចូលទៅដោយខ្លួនឯង។ ដល់មុខព្រះភ័ក្ត្រព្រះរាជាហើយ ក៏លុតជង្គង់ថ្វាយកាំភ្លើងក្រំមាសនោះ ដោយហុចខាងស្នៃកាំភ្លើងទៅមុន។ លុះព្រះរាជាលូកព្រះហស្តមកទទួលយកកាំភ្លើងនោះ វេឡូសូ

ក៏ក្រឡាស់ថ្វាយខាងត្រែកាំភ្លើងរួចគាស់កៃ គ្រាប់កាំភ្លើងផ្ទុះឡើង ត្រូវព្រះរាមាជើងព្រៃ សុគតទៅ។ ព្រះរាមាជើងព្រៃ ទ្រង់ឡើងគ្រងរាជ្យនៅឆ្នាំ១៥៩៤គ.ស. ហើយទ្រង់សុគតដោយគ្រាប់កាំភ្លើងរបស់អេស្ប៉ាញ៉ុល នៅឆ្នាំ១៥៩៦គ.ស. នៃគ្រិស្តសករាជ នៅរាជធានីស្រីសន្ធរ។

**ខ. ចៅពញាតន់ ឬ ព្រះបរមរាជាទី៦ (ឆ្នាំ១៥៩៨គ.ស.-១៥៩៩គ.ស.)**

ព្រះអង្គជាក្សត្រមានសិទ្ធិឡើងសោយរាជ្យ ហើយពួកនាម៉ឺនសព្វមុខមន្ត្រីទទួលស្គាល់ទៀតផង។ ទ្រង់ឡើងសោយរាជ្យនៅស្រីសន្ធរ។ ពួកព័រទុយហ្គាល់ អេស្ប៉ាញ និងជប៉ុនបានផ្តល់ការគាំទ្រចំពោះព្រះអង្គ។ ដើម្បីសងគុណ ពួកអេស្ប៉ាញ ដែលបានជង្វែរព្រះអង្គឱ្យមកសោយរាជ្យ ពញាតន់បានតែងតាំងពួកអេស្ប៉ាញ ឱ្យកាន់ការងារធំៗមួយចំនួនដូចជា Veloso ត្រូវឡើងជាមេស្រុកខេត្តបាណាម និង Ruiz ជាមេស្រុកខេត្តទ្រាំង។ ទ្រង់បានផ្ញើរសារទៅក្រុងម៉ានីល ដើម្បីសុំឱ្យពួកបព្វជិតនិមន្តមកកម្ពុជា ទ្រង់សន្យាថានឹងជួយសង់ព្រះវិហារ និងអនុញ្ញាតិឱ្យជាតិខ្មែរចូលសាសនាគ្រិស្តទៀតផង។ ដើម្បីពង្រឹងអំណាច ទ្រង់បានសុំជំនួយជាទ័ព និងបព្វជិតទៅទេសាភិបាលថ្មីនៅប្រទេសហ្វីលីពីន។

នៅថ្ងៃទី១៧ កញ្ញា ១៥៩៨គ.ស. ទាហាន អេស្ប៉ាញ២០០នាក់ និងបុព្វជិតដូមីនីកាំង២អង្គ មកប្រទេសកម្ពុជា តែត្រូវខ្យល់ព្យុះបក់ឱ្យវង្វេងផ្លូវទៅដល់ប្រទេសចិនវិញ។ ក្រោយមកទៀត មានកប៉ាល់មួយមកដល់ចតុមុខ នៅ **ឆ្នាំ១៥៩៩គ.ស.**។ បន្ទាប់មកមានជម្លោះមួយកើតឡើង រវាងពួកនាវិក អេស្ប៉ាញ និងពួកជ្វា។ Veloso និង Ruiz បានមកដល់កន្លែងជម្លោះក៏ត្រូវគេសម្លាប់ទាំងពីរនាក់។ ដំណឹងនេះបានឮដល់ពញាតន់ទ្រង់បាននាំទ័ពមកដោយផ្ទាល់ ហើយពួកចាម ជ្វាបះបោរក៏បានសម្លាប់ព្រះអង្គទៀត។

**គ. ចៅពញាអន ឬ ព្រះបរមរាជាទី៧ (១៥៩៩គ.ស.-១៦០០គ.ស.)**

ព្រះអង្គជាបុត្រពៅរបស់ព្រះសត្ថា ពួកនាម៉ឺនបានយាងឱ្យសោយរាជ្យនៅស្រីសន្ធរ។ ទ្រង់បន្តនយោបាយរបស់ដូនតាទ្រង់ ដោយអំពាវនាវឱ្យពួកអ្នកផ្សាយសាសនាគ្រីស្ត និងទាហានជួយការពារទ្រង់។ ព្រះអង្គជាក្សត្រមិនប្រកបដោយទសពិតរាជធម៌ទេព្រោះថ្ងៃមួយយាងទៅប្រពាតព្រៃនៅភូមិតាមាក់ ទ្រង់សព្វព្រះទ័យលើស្ត្រីម្នាក់ជាប្រពន្ធមេស្រុកឈ្មោះពញាថ្មី។ ទ្រង់បញ្ជាឱ្យចាប់បង្ខំស្រីរូបនោះ នាងនោះប្រកែកក៏ត្រូវទទួលទារុណកម្មរហូតដល់បាត់បង់ជីវិត។ ប្តីនាងក្តៅក្រហាយចំពោះអំពើរំលោភជិះជាន់ក៏រត់ចូលខាងកែវព្រះភ្លើង។ ក្នុងឱកាសបុណ្យចម្រើនព្រះជន្ម បរមរាជាទី៧ កែវព្រះភ្លើងក៏បាននាំបក្សពួកបន្លំចូលធ្វើគត់ព្រះអង្គបាននៅរាជវាំង ស្រីសន្ធរនៅឆ្នាំ១៦០០គ.ស.។

**ឃ. ចៅពញាញោម ឬសម្តេចព្រះកែវហ្វា**

ព្រះអង្គជាបុត្រព្រះសត្ថា ឡើងសោយរាជ្យនៅព្រះជន្ម២១ព្រះវស្សាគង់នៅរាជវាំងស្រីសន្ធរ។ ព្រះស្រីសុរិយោពណ៌ ជាសត្រូវរបស់ព្រះអង្គ។ ពញាញោមបានបន្តនយោបាយរបស់ក្សត្រសោយរាជ្យមុនៗគឺយកចិត្តទុកដាក់ខ្លាំងណាស់ជាមួយពួកអ៊ឺរ៉ុប។ ព្រះអង្គជាក្សត្រមិនរវល់កិច្ចការផែនដី ចូលចិត្តបរបាញ់សត្វ និងបៀតបៀន ប្រពន្ធអ្នកដទៃ ជិះជាន់កៀបសង្កត់រាស្ត្រ។ ហេតុនេះហើយទើបអាយ្យការ

(ទេវីក្សត្រ) របស់ទ្រង់ ជំនុំជាមួយមន្ត្រី សុំស្តេចសៀម ដើម្បីយាងព្រះស្រីសុរិយោពណ៌មករៀបចំកសាងប្រទេសឡើងវិញ[21]។

## ២.៤. សេដ្ឋកិច្ចសម័យលង្វែក

### ២.៤.១. កសិកម្ម

ផ្នែកកសិកម្មមានសកម្មភាពខ្លាំង ព្រោះព្រះរាជាសម័យនោះបានយកព្រះទ័យទុកដាក់នឹងបញ្ហានេះណាស់។ ព្រះអង្គតែងតែគិតគូរដល់ដីធ្លីសម្រាប់ប្រជារាស្ត្រធ្វើស្រែចម្ការថែមទាំងបានជីកអូរ ព្រែកប្រឡាយ សម្រាប់ផ្គត់ផ្គង់ទឹកដល់កសិកម្ម។ ក្នុងរជ្ជកាលព្រះបាទចន្ទរាជា ទ្រង់បានបញ្ជាទ័ពឱ្យកាប់ឆ្ការព្រៃដើម្បីវាតទីដីស្រែចម្ការ សម្រាប់ប្រជារាស្ត្រ។ នៅរដូវបង្កបង្កើនផល និងប្រមូលផល គេតែងតែបញ្ឈប់សង្គ្រាមដើម្បីជួយប្រជារាស្ត្រក្នុងការប្រកបរបរកសិកម្ម។

### ២.៤.២. ពាណិជ្ជកម្ម

ដោយសារបឹងទន្លេសាបសម្បូរត្រី ហើយដីនៅជុំវិញសម្បូរជីជាតិ និងទន្លេមេគង្គជាផ្លូវទឹកដ៏សំខាន់សម្រាប់ដឹកនាំទំនិញទៅលក់ឯបរទេស វិស័យពាណិជ្ជកម្មមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ក្នុងរជ្ជកាលព្រះបាទពញាយ៉ាត ស្តេចកន ចន្ទរាជា ប្រទេសកម្ពុជាសុទ្ធតែបាននាំទំនិញទៅលក់នៅបរទេស ហើយទិញមកវិញនូវគ្រឿងសាស្ត្រាវុធ។ព្រះបាទបរមរាជាបានធ្វើទំនាក់ទំនងជាមួយពួកអឺរ៉ុបជប៉ុន ចិន ជ្វា ឱ្យមកធ្វើជំនួញនៅស្រុកខ្មែរយ៉ាងច្រើនសន្ធឹកសន្ធាប់។ ពួកនេះបាននាំទំនិញដូចជាក្រណាត់សំពត់ ឧបករណ៍ប្រើប្រាស់ផ្សេងៗ ហើយនាំចេញទៅវិញនូវគ្រឿងទេស ភ្លុកដំរី ស្នែង ជ័រ ស្បែក ។

### ២.៤.៣. សិប្បកម្ម

សិប្បកម្មនៅមានការអន់ថយនៅឡើយ។ សកម្មភាពសំខាន់ក្នុងសម័យនោះគឺការស្លដែក ដែលមានសន្ទុះខ្លាំងក្លាចាប់ពីរជ្ជកាលព្រះបាទចន្ទរាជា ព្រោះព្រះអង្គ បានយកព្រះទ័យទុកដាក់នឹងបញ្ហានេះណាស់។ ប៉ុន្តែការប្រើដែលជាវត្ថុធាតុដើម មានរបរដំដែកជាដើម មានសកម្មភាព តាំងពីក្នុងរជ្ជកាលព្រះបាទពញាយ៉ាតម្ល៉េះ។

## ២.៥. ការអប់រំសម័យលង្វែក

ទោះបីមានចលនាជាច្រើនបានកើតទន្ទឹមគ្នានឹងសង្គ្រាម ស្រុកកើតកលិយុគ ប្រទេសជាតិធ្លាក់ចុះឱនថយ បម្លាស់ប្តូររាជធានីនិងសាសនា។ តែកត្តាទាំងអម្បាលម៉ាននេះពុំមែនថាកម្ពុជាត្រូវរលត់ជោគវាសនានោះទេ។ ស្រដៀងគ្នានេះ ការសិក្សា នាសម័យនោះបានថមថយ តែទោះបីយ៉ាងណាក៏ដោយប្រការនេះ មិនមែនជាមហន្តរាយ ពុំអាចស្តារឡើងវិញនោះទេគឺថាការសិក្សាអប់រំនៅតែរស់រានឥតដាច់ឡើយ។ នៅសម័យចាស់វេលាខ្មែរកាន់ព្រហ្មញ្ញសាសនាព្រាហ្មណ៍ជាគ្រូបង្រៀនដល់ពួកក្សត្រ និងយុវអភិជនទាំងឡាយ ហើយនៅតាមអាស្រមនានា កូនចៅអ្នកស្រុកមានព្រាហ្មណ៍សាស្ត្រាចារ្យនៅកន្លែងផ្ទាល់ (អជ្ឈាបកៈ) ជាអ្នកជួយបង្ហាត់បង្រៀន ប៉ុន្តែនៅពេលព្រះពុទ្ធសាសនាថេរវាទបានប្រតិស្ឋានខ្ជាប់ខ្ជួន ភារកិច្ចជាអ្នកបង្រៀនបានផ្ទេរមកឱ្យព្រះសង្ឃដែលបួសគង់នៅតាមវត្តអារាមទាំងឡាយក្នុង អាណាចក្រ។ គឺ

[21] -លោក អេង សុត មហាបុរសខ្មែរឆ្នាំ ២០០៩

ជាប្រការសំខាន់បំផុតនៃអតីតកម្ពុជាដែលត្រូវដឹងអំពីការ«អប់រំ» ប្រជារាស្ត្រ បើនិយាយឱ្យទូលាយគឺនៅក្រោមការបង្ហាត់បង្រៀនឧបត្ថម្ភនៃអ្នកប្រាជ្ញបណ្ឌិតព្រាហ្មណ៍។ក្សត្រទាំងឡាយ(ជ័យវរ្ម័ទី២ ជ័យវរ្ម័ទី៣) បានទទួលការសិក្សាអប់រំនៅព្រះបរមរាជវាំង តែផ្ទុយទៅវិញ កូនចៅរបស់ប្រជារាស្ត្រប្រាកដជាទទួលការសិក្សាអប់រំនៅតាម«អាស្រម» និង «សាលា» ដែលដឹកនាំដោយអ្នកប្រាជ្ញ បណ្ឌិតព្រាហ្មណ៍[22]។

### ២.៥.១. ជាន់ដើម (ថ្នាក់ដំបូង)រៀនសរសេរ

កាលកុមារដឹងក្តីហើយ មានអាយុប្រមាណ ៧, ៨, ៩, ១០ឆ្នាំ មាតាបិតាតែងនាំកូនទៅឱ្យសិក្សានៅតាមវត្តអារាមរៀបចំសំពត់ខោអាវ ខ្លួនប្រាណកូន ហើយរើសរកថ្ងៃល្អ។គេច្រើនរើសយក ថ្ងៃ ព្រហស្បតិ ព្រោះថ្ងៃនេះជាទេព្ទសំដីហើយគេជឿថាកុមារចាប់ផ្តើមរៀននៅថ្ងៃនេះនឹងចេះដឹងឆាប់។រើសថ្ងៃបានហើយនាពេលព្រឹក មាតារៀបអាហារភោជនទុកជាចង្ហាន់ប្រគេនលោក លុះរៀបរួចហើយស្វាមីភរិយានាំកូនទៅវត្តចូលទៅជួបលោកគ្រូចៅអធិការក្រាបបង្គំបីដង បង្គាប់កូនឱ្យថ្វាយ បង្គំបី ដងហើយលើកភោជនាហារប្រគេន ទើបថយមកអង្គុយនៅទីសមគួរលើកដៃប្រណម្យទូថាៈ «ព្រះតេជព្រះគុណម្ចាស់ ! ខ្ញុំព្រះករុណាទាំងពីរនាក់ នាំកូនឈ្មោះ មកប្រគេនទុក ជាសិស្ស ឱ្យសិក្សាចំណេះវិជ្ជា មានអក្សរ ជាដើម។សូមព្រះតេជគុណមេត្តាប្រោសបង្ហាត់បង្រៀនច្បាប់ លោកច្បាប់ធម៌ ចំណេះវិជ្ជាគ្រប់ប្រការឱ្យទាន។ ខ្ញុំព្រះករុណាទាំងពីរនាក់សុំតែភ្នែក និងឆ្អឹងទេសាច់ឈាមប្រគេនព្រះតេជគុណទាំងអស់» ពាក្យនេះមានន័យថាសូមមេត្តាបង្រៀនសព្វសារពើវិជ្ជាបើនៅទាស់ខុសឆ្គងត្រង់ណា កាយ ឬវាចាចិត្ត មេត្តាប្រោសពុតប្រដៅឱ្យទានឱ្យទាល់តែបានទៅជាមនុស្សចេះដឹងនឹងគេឡើង។ និយាយទូលលោកហើយ បែរមកនិយាយនឹងកូនថាៈ "កូន!ម៉ែឪនាំកូនឯងមកប្រគេនព្រះតេជព្រះគុណឱ្យសិក្សារៀនសូត្រ។ កូនត្រូវប្រតិបត្តិព្រះតេជគុណកុំបីឱ្យមានផ្តាំផ្តង មើលបម្រើទឹកក្តៅ ទឹកត្រជាក់តាមការគួរ ហើយខំប្រឹងរៀនសូត្រឱ្យចេះដឹង ឱ្យម៉ែឪបានសប្បាយចិត្ត ធ្វើឱ្យត្រកូលយើងថ្កុំថ្កើនរុងរឿងតទៅ"។

កុមារដែលមាតាបិតាបានប្រគេនឱ្យទៅលោកគ្រូបាធ្យាយហើយ ដេកនៅក្នុងវត្តអារាមរហូត និងប្រណិប័តន៍គ្រូអាចារ្យតទៅ។ ទំនៀមទំលាប់នេះហើយ ជាប្រពៃណីខ្មែរយើងពីបូរាណ។ បើពិនិត្យពិចារណាឱ្យបានហ្មត់ចត់ទៅ នេះមិនមែនជាទំនៀមទម្លាប់ខ្មែរយើងសុទ្ធសាធទេ។ កាលដើមឡើយ ជារបស់ព្រាហ្មណ៍។ ក្នុងគម្ពីរព្រាហ្មណ៍ ដូចច្បាប់មនុស្ស ឬច្បាប់គ្រឹហស្តសូត្រស្ដីថា កូនព្រាហ្មណ៍កាលបើដល់អាយុសិក្សាហើយ (១០, ១១, ១២ ឆ្នាំ) មាតាបិតាត្រូវយកទៅប្រគេនឱ្យឫសីជាអធ្យាបក (គ្រូបង្រៀន) ដើម្បីសិក្សា ត្រៃវេទ (ត្រ័យវិទ្យា)។ កុមារព្រាហ្មណ៍នេះ ហៅថា ព្រាហ្មណ៍ចារិន ឬព្រាហ្មណ៍ ចារី (អ្នកប្រព្រឹត្តឱ្យបានទៅជាព្រាហ្មណ៍ ឬប្រព្រឹត្តបានក្តីប្រសើរ)។ នៅជាមួយគ្រូ រកអាហារភោជន រក្សាភ្លើងតទៅ រហូតដល់ចេះ ត្រៃវេទ និងវេទាង្គ(អង្គរបស់វេទ) ៦ ប្រការគឺ ៖

- សិក្សា(§ikshá) សិក្សាសូរសាស្ត្រ ការហាត់ថាឬហាត់និយាយបញ្ចេញសម្តីឱ្យច្បាស់លាស់
- ឆន្ទ (Chanda) សិក្សាក្បួនកាព្យ, សិក្សាឱ្យចេះនូវលក្ខណៈរបស់ឆន្ទៈ
- និរុក្ត(Nirukta)សិក្សាអានវេទឱ្យត្រឹមត្រូវតាមជើងកាព្យ,កំពីអធិប្បាយសព្ទឬរៀនអធិប្បាយសព្ទក្នុងវេទទាំងមូល

[22] -ចៅ លិន សង្គមវិទ្យាអប់រំ ឆ្នាំ ២០១២

-វ្យាករណ៍Vyákaraça សិក្សាវេយ្យាករណ៍ ( បាណិនិPáçini) ការសិក្សាវេយ្យករណ៍ដោយសព្វគ្រប់

- ជ្យោតិស្ចJyotisha សិក្សាតារាសាស្ត្រ ការសិក្សាឱ្យចេះទ្យោតិសាស្ត្រ

-កល្បៈKalpaសិក្សាឱ្យចេះធ្វើពិធីបូជាភាគពិស្តាររបស់គម្ពីរឬការសិក្សាសេចក្តីពិស្តារ (វចនានុក្រម ខ្មែរពុទ្ធសាសនបណ្ឌិត្យ១៩៦៧គ.ស.ត្រង់ពាក្យវេទាង្គ និងវចនានុក្រមសំស្ក្រឹត

- អង្លេស, Monier Monier-Williams, ១៨៩៩គ.ស., ទំព័រ១០១៦ )[23]។

លុះចេះវេទ ចេះ វេទាង្គសព្វគ្រប់ហើយ ទើបទទួលបាននាមថា «បារគូ» (អ្នកដល់នូវត្រើយនៃវិជ្ជា ) ដល់វិលមកផ្ទះវិញទើបមាតាបិតារៀបពិធីប្រសិទ្ធីឱ្យបានពេញជាព្រាហ្មណ៍ពេញលក្ខណៈគឺទ្វិជៈ «កើតពីរ ដង» គឺកើតពីមាតាម្តង និងកើតពីត្រៃវេទម្តងទៀត។ ប្រពៃណីដូចបានរៀបរាប់មកនេះហៅថា ឧបនយសំស្ការ គឺពិធីប្រសិទ្ធីកូនឱ្យបានជាព្រាហ្មណ៍ពេញលក្ខណៈ។ ពាក្យថាឧបនយសំស្ការមានពីរម៉ាត់ គឺ **ឧបនយ** (ឧ + នី ) ប្រែថា «នាំយកទៅប្រគល់ឱ្យ (អធ្យាបក=គ្រូ) + **សំស្ការ**(សំ+ស+ការ ) ប្រែថា«សម្រាំង ប្រសិទ្ធី»។ សំស្ការនេះនៅប្រទេសឥណ្ឌាសម័យបូរាណទាំងអស់មាន៤០ប្រការគឺក្នុងជីវិតព្រាហ្មណ៍ម្នាក់ៗ រាប់តាំងពីកើតរហូតដល់ស្លាប់ទៅវិញត្រូវធ្វើសំស្ការ៤០ ដង។ឧទាហរណ៍ មានគភ៌លម្ពនសំស្ការ (ពិធីធ្វើ ឱ្យឧទរមានគភ៌ )រហូតដល់ អាវាហវិវាហសំស្ការ ជាទីបំផុត។ តែសព្វថ្ងៃនេះ គេច្រើនតែធ្វើតែ ១២ ប្រការទេ។ ដោយឡែកប្រទេសខ្មែរយើង មិនប្រើពាក្យ«សំស្ការ»នេះទេ ព្រោះយើងកាន់ព្រះពុទ្ធសាសនា។ តាមពុទ្ធសាសនា យើងប្រើពាក្យ «មង្គល»(សេចក្តីចម្រើន ) ជំនួសវិញ។ យើងនិយាយថា អាវាហវិវាហមង្គល( មង្គលរៀបការ )នាមករមង្គល(មង្គលឱ្យឈ្មោះ )សិប្បុគ្គហនមង្គល( មង្គលឱ្យរៀន )ដូច្នេះ យើងយល់បានថា ការសិក្សាពុទ្ធសាសនា តែប្រពៃណីជាព្រាហ្មណ៍ ផ្សំនឹងទំនៀមខ្មែរ កើតបានទៅជាអារ្យធម៌មួយឡើង ដែលផ្សេងពីព្រះពុទ្ធសាសនា និងលទ្ធិព្រាហ្មណ៍។

### ឧបករណ៍សិក្សា

- កុដិ ឬសាលាជាសាលារៀន គ្មានតុ កៅអីទេ។ សិស្សទាំងអស់រៀនរួមគ្នាតែកន្លែងមួយ។ ពេលព្រឹក មិនអាចរៀនបានទេ ព្រោះជាពេលលោកបិណ្ឌបាត។ ដូច្នេះ ការសិក្សា ច្រើនប្រព្រឹត្តទៅនៅពេលសៀល ចាប់ពីពេលឆាន់ត្រង់រួចទៅ។

- ក្តារឈ្នួនធ្វើពីបន្ទះឈើស្រាល(ដើមគរ )ទទឹង ០,២៥ម បណ្តោយ ១,២០ម មុខម្ខាងឈូសស្អាតលាបពណ៌ខ្មៅ (គេច្រើនប្រើធ្យូងដើមធ្លកសំរាប់ឱ្យខ្មៅ ) សម្រាប់សរសេរមុខម្ខាងទៀតគ្រាន់តែឈូសរំលីង តែមិនលាបពណ៌ទេព្រោះមិនប្រើសម្រាប់សរសេរឡើយ។

- ដីសគឺដីដែលមានពណ៌សគេច្រើនយកដីឥដ្ឋនៅបាតស្រះ បាតស្ទឹង បាតទន្លេមកលញ់ឱ្យមូលប៉ុនៗម្រាមដៃ ហាលថ្ងៃឱ្យស្ងួត ទើបយកមកសរសេរ។

- ទឹកល្បប់ គឺទឹកដែលលាយឡំដោយសំណល់ផ្សេងៗដូចជា ផង់ធ្យូង ម្រែងភ្លើង លាយជាមួយទឹកបាយ គេលាយទុកក្នុងត្រឡោកដូង ឬក្នុងកូនក្អមសម្រាប់លុបក្តារខៀន។ ពេលរៀន លោកគ្រូនិមន្តទៅកាន់ទីកន្លែងរៀន។ សិស្សអង្គុយជួបជុំគ្នាដោយពួកៗ តាមថ្នាក់ គឺសិស្សទើបរៀនសរសេរ សិស្សរៀនមើល

---

[23] - Monier Monier-Williams, ១៨៩៩, ទំព័រ១០១៦ )

សត្រាច្បាប់ សត្រាល្បែង សាត្រាទេសន៍។ លោកគ្រូនិមន្តទៅជិតសិស្សថ្មីមុនគេ ហើយបង្គាប់ឱ្យអង្គុយបត់ជើង ឱ្យដាក់ក្តារខៀននៅលើភ្លៅ ស៊កដៃឆ្វេងទ្រក្តារ ដៃស្តាំកាន់ដីសសរសេរ។ ដំបូង លោកគ្រូដាក់ច្បាប់ឱ្យ (អក្សរគំរូ) បង្គាប់កាន់ដីស ឱ្យសរសេរពីឆ្វេងទៅស្តាំ។ លោកដឹកដៃឱ្យរៀនសរសេរ។ ជួនកាលបង្គាប់ឱ្យសិស្សដឹកបន្ទាត់គាប ហើយបង្គាប់សិស្សឱ្យសរសេរអក្សរតាមចន្លោះបន្ទាត់គាបនោះ មិនឱ្យសរសេរហួសទៅលើបន្ទាត់ ឬឱ្យធ្លាក់ចុះមកក្រោមបន្ទាត់ទេ។ ជាពិសេស លោកគ្រូសរសេរបទនមស្ការ ៣ បទ ជាអក្សរមូលទុកជាច្បាប់អាទិតាំងគឺ

- **នមោ** = សូមនមស្ការ
- **ពុទ្ធាយ** = ចំពោះព្រះពុទ្ធ
- **សិទ្ធំ** = សូមឱ្យបានសម្រេចការសិក្សា

ពេលសិស្សកំពុងសរសេរ លោកគ្រូបង្រៀនឱ្យអានបណ្តើរ ឱ្យអានបទនមស្ការជាភាសាសំស្ក្រឹតនេះ ជាភាសាសំស្ក្រឹតនេះ ជាភាសាខ្មែរគឺ ឱ្យអានថា៖

- **ន មោ ពុ ទ្ធា យ សិ ទ្ធំ** ឱ្យចេញជាបទ ដូចតទៅៈ
- **ន**អឺយ **ន ន ន**
- **មោ** អឺយ**មោ មោ មោ**
- **ពុ**អឺយ**ពុ ពុ ពុ** (អានថា ពុត)
- **ទ្ធា**អឺយ**ទ្ធា ទ្ធា ទ្ធា** (អានថា ធា)
- **យ**អឺយ**យ យ យ**
- **សិ**អឺយ **សិ សិ សិ** (អានថា សិត)
- **ទ្ធំ**អឺយ **ទ្ធំ ទ្ធំ ទ្ធំ** (អានថា ធំ)

បើសិស្សសរសេរបទនមស្ការនេះបានហើយ លោកគ្រូបង្រៀនឱ្យសរសេរស្រៈពេញតួគឺ អអាឥឦ ហើយបង្គាប់ឱ្យអានថា អអឺយអ អ អ។ល។ តទៅទៀតលោកគ្រូបង្រៀនឱ្យសរសេរព្យញ្ជនៈ ក ខ គ ឃ ង ច ឆ។ ហើយឱ្យអានតាមទំនងដូចគ្នា។ បន្ទាប់ពីនោះ លោកដាក់ឱ្យរៀនសរសេរស្រៈនិស្ស័យ គឺស្រៈ ា ិ ី ឹ ឺ។រហូតដល់ចប់។រៀនចេះស្រៈពេញតួ ស្រៈនិស្ស័យនិងព្យញ្ជនៈអស់ហើយ លោកគ្រូបង្រៀនឱ្យបំបែកព្យញ្ជនៈផ្សំនឹងស្រៈនិស្ស័យ ប្រកបព្យញ្ជនៈ ផ្ទើជើងជាលំដាប់ ឱ្យសិស្សចេះសរសេរ និងអានរត់មាត់។ ការរៀនបែបនេះហៅថា "រៀនផ្ទាល់មាត់"។ កាលបើសិស្សបានរៀនចប់ផ្នែកបំបែក ផ្ទើជើង ប្រកបចប់គ្រប់ហើយលោកគ្រូប្រដៅ (មានន័យថា សាកល្បង ត្រួតពិនិត្យ) គឺសរសេរអក្សរមួយតួៗហើយឱ្យសិស្សអានឱ្យត្រូវ។ បើពិនិត្យឃើញថាសិស្សអានរហ័ស ស្ទាត់ជំនាញហើយ ទើបលោកអនុញ្ញាតឱ្យទៅមើលសត្រាច្បាប់។

### ២.៥.២. ជាន់ទី២ រៀនមើលសត្រាច្បាប់

ការរៀនមើលសាស្ត្រាច្បាប់នេះគឺ ដំបូងឱ្យរៀនមើល (អាន) ជាពាក្យរាយ មិនទាន់ឱ្យមើលជាបទតាមច្បាប់ទេព្រោះសត្រាច្បាប់ទាំងអស់សុទ្ធតែជាពាក្យកាព្យដូច សត្រាច្បាប់ក្រម កេរកាល ច្បាប់ប្រុស ច្បាប់ស្រី ច្បាប់រាជនេតិ (ច្បាប់ព្រះរាជសម្ភារ)។ល។ លោកគ្រូនាំឱ្យរៀនអាន ឱ្យចេះអានត្រឹមត្រូវ

ច្បាស់លាស់តាមក្បួនអក្សររួច ទើបឱ្យសិស្សអានដោយខ្លួនឯងតទៅ។ គេអានហើយអានទៀត អានច្រើនលើកច្រើនសារទាល់តែចាំស្ទាត់រត់មាត់ អាចសូត្រមាត់ទទេបានដោយមិនបាច់មើលអក្សរ។ ការអាននេះលោកគ្រូអង្គុយជិត ផ្ទៀងមើលហើយបង្គាប់ឱ្យសិស្ស ចាប់សត្រាអានតាំងពីដើមដល់ចប់បើលោកឃើញថាសិស្សនេះចេះអានស្ទាត់ជំនាញ ហើយលោកគ្រូពន្យល់សេចក្ដីក្នុងសត្រាច្បាប់នេះបន្ថែមទៀត។ ធម្មតាច្បាប់មានអត្ថន័យជ្រាលជ្រៅណាស់រួចទើបលោកគ្រូឱ្យឡើងមួយថ្នាក់ទៀត គឺមើលសត្រាល្បែង។

### ២.៥.៣. ជាន់ទី៣ រៀនមើលសត្រាល្បែង

ការរៀនមើលសត្រាល្បែង មានដូចគ្នានឹងរៀនមើលសាស្ត្រាច្បាប់ដែរ។ តែម្ដងនេះ លោកគ្រូឱ្យរៀនអានចេញជាបទ ព្រោះសត្រាល្បែងទាំងអស់ សុទ្ធតែបានតែងនិពន្ធឡើងជាបទ មានបទកាកគតិ ព្រហ្មគីតិ កុជង្គលីលា ពំនោល បន្ទោលកាក។ល។ សត្រាល្បែង មានច្រើនច្បាប់ ដូចសត្រាច្បាប់ដែរគឺ សត្រាដុច សុបិន ហង្សយន្ត វិមានច័ន្ទ ស័ង្ខសិល្បជ័យ ជ័យទត្ត សព្វសិទ្ធិ លោកគ្រូបង្រៀន ឱ្យមើលតាមបទសិស្សថាតាមទាល់តែត្រូវបទទើបឱ្យសិស្សអានខ្លួនឯងតទៅ។ គេមើលអាន ដដែលៗអានចុះអានឡើងទាល់តែចាំស្ទាត់ ទើបផ្លាស់ទៅអានសាស្ត្រាមួយផ្សេងទៀត បើឃើញថាសិស្សចេះអានបទត្រឹមត្រូវហើយលោកឱ្យឡើងទៅមើលសត្រាទេសន៍។

### ២.៥.៤. ជាន់ទី៤ រៀនមើលសត្រាទេសន៍

ការរៀនមើលសាស្ត្រាទេសន៍ មានទំនងអានផ្សេងពីសត្រាល្បែង ជាបទ ឬពាក្យរាយធម្មតា។ សត្រាទេសន៍ជា សេចក្ដីមួយបែបនៅក្នុងពួករាយដែរ។ ប៉ុន្តែមិនមែនជាពាក្យរាយធម្មតាសុទ្ធសាធនោះទេ ជាពាក្យរាយជួនគ្នា ឬកម្រងពាក្យជួនរណ្ដំគ្នារដឹកទៅ ដែលគេនិយមហៅថាកម្រងកែវ។ ដូច្នេះលោកគ្រូបង្រៀនសិស្សឱ្យសិស្សរៀនអានលើកដាក់សម្លេងតាមបែបទេសន៍គេហៅថា រៀនទេសន៍សត្រាទេសន៍មានច្រើនច្បាប់ដែរ ដូចជាសត្រាអានិសង្ស អានិសង្សចម្លងបុណ្យ អានិសង្សខ្មោច។ល។ រហូតដល់សត្រាទេសន៍ធំៗដូចជាទសជាតក៍ជាដើម។ សិស្សរៀនដល់ថ្នាក់នេះ ចាត់ទុកជាសិស្សជាន់ខ្ពស់ហើយ។ អ្នកនិពន្ធសត្រាទសជាតក៍ សុទ្ធតែជាអ្នកមានស្នាដៃដ៏ប្រសើរខ្ពង់ខ្ពស់។ ពាក្យពេចន៍ខ្ពស់ មានអានគម្ពីរភាពពាក្យរាយចួនរណ្ដំគ្នា មើលទៅមិនអាក់ ពិរោះស្ដាប់គួរឱ្យចង់មើល ដូចពាក្យតទៅនេះ៖«ព្រាហ្មណ៍ ម្នាលព្រាហ្មណ៍អើយ! រីព្រៃខែត្រហេមពាន្ត សឹងដ៏ជាសំណាក់នៃបក្សាបក្សី តែងអាស្រ័យនៅសព្វពេលវេលា ហើរនាវេហាស៍ យាសយំចុះមកទំដោយលង្វែកមែកសាខា ខ្សៀវខ្សារដោយភាសា ឮសូរល្វេងល្វើយ។ ឯបក្សីទាំងឡាយនោះគឺ គ្រួច ក្រៀល ចង្កៀលខ្យង ត្រយងយំថ្ងូរ តុកទ្រូ ហូហូ តាវៅ ស្វិតថៅ អាអាត់ក្ងាន ក្ង ក្ងោក ប៉ោលតោក ត្រុំ ថ្កុំ ស្ទាំង ភូវាំង លលក សារិកា សឹងដ៏ហើរផ្សៀលឆ្វាត់ ឆ្វេឆ្វាទៅមក ផ្សៀងរកចំណីអាហារ។ សម្លេងកង្កួច ឮគ្រលួច បីដូចតូរ្យតន្ត្រី ត្រែ ស័ង្ខ រគាំង ភេរី ពិណពាទ្យ រនាត ពិរោះរងំ។ល។ រីអស់ព្រៃព្រឹក្សានោះ មានពណ៌ទីទៃៗពីគ្នា ពុំដឹងបើនឹងប្រាប់ទេ។ មានព្រីង ព្រូល ជន្លួស ដៃខ្លា គគីរ ឆាំឆាពុកឆ្មា មហាហង្ស មានទាំងផ្តិលញ្ចៅ បង្គាបង្គោ ម័កប៉ែន គូលេន សិរមាន់ ច័ន្ទន៍ ម៉ាក់បាត លាំងសាតទុរេន មៀន ប្រដាក់ ម័កប្រេង ម័កប្រាង ម័កសាង ម័កដោក ឪឡោក ស្រឡៅ តាត្រាវ អង្គោល អង្កាញ់កណ្ដាក់ ចំបក់ រាំងភ្នំ ស្រគំ ញ កកោះ លំពោះ ក្រវាន់ ចន្ទន៍ ក្រស្នា។ល។ មួយសោត ឯស្រះស្រង់បោក្ខរណី មានទឹកថ្លាយង់យល់ដី មីរដេរដាសដោយផ្កា ឧប្បល ចង្កុលណី លំចងស្បង់ដ សឹងដ៏ដុះលាយ

លេចគ្នា មានផ្កាវីករហង់ មានហ្វូងមច្ឆាហែបហែលរេរាទៅមក ក្រហោ ក្រហែ ទ្រនេល បបែល កំភរ កំភុក មានទាំងត្រីឆ្ពិន ត្រីស្លាត អណ្តាតឆ្កែ ឆ្តោក គជ្រា អណ្តែងងាំង គល់រាំង រាហូ ឆ្តោ ផ្ទក់ ក្អុកក្អី ត្រីក្រាយ ក្លាំងហាយ ក្លាំងហាត ដងខ្ទែង ប្រកែង ទីពោ។ល។»

ថេរវេលាសិក្សានេះ មិនមានកំណត់ច្បាស់លាស់ទេ។ តែបើសិក្សាឱ្យគ្រប់គំរប់បីឆ្នាំ ទើបសន្មត់ថាអស់ការសិក្សាមួយលើក។ ក្នុងការស្នាក់អាស្រ័យនៅក្នុងវត្តនេះសិស្សបានទទួលការអប់រំគ្រប់បែបយ៉ាង លោកគ្រូមិនមែនបង្រៀនតែអក្សរ ធម៌អាថ៌ប៉ុណ្ណឹងទេ លោកអប់រំផែមច្ចរិយាទៀត បង្រៀនឱ្យចេះគោរពគ្រូ គោរពមាតាបិតា ញាតិកាទូទៅ រហូតដល់អ្នកតូចអ្នកធំ ចេះសំពះ ចេះឱនលំទោន ចេះដាក់ខ្លួនឱ្យសមដឹងខ្ពស់ ដឹងទាប ស្គាល់ខុស ស្គាល់ត្រូវ ស្គាល់ល្អ ស្គាល់អាក្រក់ ស្គាល់គុណទោស ស្គាល់រាក់ជ្រៅ គួរមិនគួរ ឱ្យបានជាសិស្សប្រសើរ ឱ្យចេះដើរខ្លួនឯងនៅក្នុងលោករបស់មនុស្សនេះ។ ទៅត្រង់ណាឱ្យគេស្គាល់ថា កូនអ្នកមានពូជត្រកូលខ្ពង់ខ្ពស់ ជាមនុស្សបានទទួលការសិក្សាដ៏ល្អប្រសើរ ជាមនុស្សស្មោះត្រង់ចំពោះ ជាតិ សាសនា ព្រះមហាក្សត្រ ផែនទឹក ផែនដី។

អាស្រ័យដោយការអប់រំនៅវត្តនេះហើយ បានជាប្រជាជនខ្មែរស្លូតត្រង់សុភាពរាបសា។ កុមារអាយុ ១២ឆ្នាំ ត្រូវបួសជាសាមណេរសងគុណមាតា។ បួសហើយត្រូវបន្តការសិក្សាទៅមុខទៀត រៀនសាមណេរ វិន័យ រៀនធម៌សូត្រមន្ត រៀនលេខនព្វន្ត រៀនវិជ្ជាផ្សេងៗតាមត្រូវការ។ បើសាមណេរនេះ សឹកមកជាគ្រហស្ថមានឈ្មោះមួយគេហៅថា «ជី»។ ដល់អាយុ២១ឆ្នាំ ត្រូវបួសជាភិក្ខុ រួចហើយមានការសិក្សាបន្តទៅទៀត រៀនវិន័យ រៀនធម៌អាថ៌ រៀនចំណេះវិជ្ជាផ្សេងៗខាងផ្លូវលោកតាមត្រូវការ។បើនៅក្នុងវត្តរបស់ខ្លួនពុំមានការសិក្សាវិជ្ជាបច្ចេកទេសទេសាមណេរ ឬភិក្ខុអាចលាគ្រូឧបជ្ឈាទៅសិក្សាវិជ្ជាដែលខ្លួនត្រូវការ នៅវត្តដទៃ ទៀត។ ក្នុងវត្តនីមួយៗ តែងមានកិច្ចការវត្ត ភិក្ខុសាមណេរ ក៏ត្រូវធ្វើការនោះៗ ការធ្វើនេះ ទុកដូចជាហាត់ហ្វឹករៀនធ្វើការនោះដែរ។ ដទៃពីនេះមានការសិក្សាជាន់ខ្ពស់ គឺរៀនសំណាក់ព្រះកម្មដ្ឋានស្មិងស្មាធិ ធ្វើចិត្តខ្លួនឱ្យបរិសុទ្ធ ផុតកិលេសក្តីសៅហ្មង។ ខ្លះមានសទ្ធាវិរិយៈមាំមួន នៅជាអ្នកបួសតទៅ បានជាគ្រូសូត្រឆ្វេង-ស្តាំ ជាចៅអធិការ។ ខ្លះមានសទ្ធា និងវិរិយៈទន់ខ្សោយ ក៏សឹកមកជាគ្រហស្ថវិញ គេហៅថា«អ្នក» ហើយក៏មានភរិយាទៅតាមប្រពៃណីអ្នកស្រុកតទៅ។តាមទម្លាប់ខ្មែរក្នុងសម័យបុរាណ ដែលគោរពព្រះពុទ្ធសាសនាណាស់, សូម្បីគ្រហស្ថកំលោះដែលទើបចាកផ្នួសសឹកថ្មីៗ គេក៏ហៅអ្នកនោះថា បណ្ឌិត ដែរ, ហៅក្លាយ បន្ទិត, ហៅក្លាយឃ្លាតមកថា អន្ទិត ព្រោះគេយល់ថា អ្នកនោះបានបួស មានការចេះដឹង មានចរិយាមារយាទត្រឹមត្រូវ (វចនានុក្រមខ្មែរ,ពុទ្ធសាសនបណ្ឌិត្យ,ឆ្នាំ១៩៦៧គ.ស. ត្រង់ពាក្យបណ្ឌិត)។ការសិក្សាដូចបានពោលមកនេះ ជារបៀបការសិក្សានៅគ្រិស្តសតវត្សទី១៩។ របៀបសិក្សានេះ តាមការពិចារណាមើលឃើញថា អាចមានមកតាំងពីសម័យកណ្តាលមកម្ល៉េះ ប៉ុន្តែសម័យមុនអង្គរនិងអង្គរអាចខុសគ្នាច្រើន។ សម័យមហានគរ ការសិក្សាហ្មត់ចត់ គ្រូសុទ្ធតែមានចំណេះវិជ្ជាខ្ពង់ខ្ពស់ ឯអ្នកសិក្សាក៏បានទទួលការចេះដឹងប្រសើរគួរជាទីពេញចិត្ត។ អ្វីដែលគួរចាប់អារម្មណ៍គឺថានៅវេលាដែលខ្មែរកាន់សាសនាព្រាហ្មណ៍ ព្រះពុទ្ធសាសនាក៏ដើរទន្ទឹមគ្នានោះដែរ។ បំផុតយើងមិនត្រូវយកមកលាយគ្នារវាងព្រះពុទ្ធសាសនាសម័យអង្គរ (ហីនយាន និង មហាយាន) និងសម័យកណ្តា(ថេរវាទ) ដាច់ខាត។ ដូចគ្នា ការសិក្សាអប់រំនាសម័យនោះអាចមានភាពខុសគ្នាច្រើន អាស្រ័យកាលៈទេសៈនោះ។ កាលណាស្រុក

ទេសច្ចបរិបត្តិ វិស័យផ្សេងទៀតមិនអាចនឹងរត់រួចឡើយ។ ស្របពេលនោះ វិស័យសិក្សាអប់រំបានប្រែប្រួលដែរ តែច្រើនឬតិចអាស្រ័យលើបញ្ហាចោទធំឬតូច។ការលុយលុកពីសំណាក់ពួកសៀម រំខានដល់អង្គរធ្វើឱ្យខ្មែរបានស្រុតចុះមួយកាល តែវាមិនធ្ងន់ណាស់ណាឡើយ ទើបខ្មែរអាចវាយបកទៅសៀមវិញ (អាចជាក្បួនយុទ្ធសាស្ត្រក្នុងការដែលស្តេចខ្មែរសុខចិត្តប្តូររាជធានីដើម្បីសន្សំកំលាំងវាយប្រហារវិញ) រហូតដល់សាងបន្ទាយដ៏រឹងមាំមួយដែលបច្ចាមិត្រសៀមពុំអាចនឹងចូលវាយបាន។ គ្រោះចង្រៃ ការចាញ់កលសៀមបង្កឱ្យប្រទះការវាយបែកបន្ទាយ លង្វែកដែលជាការដួលរលំមួយយ៉ាងសម្បើម បំផ្លាញដល់វិស័យសិក្សាខ្មែរ។ លុះមកដល់សម័យអាណានិគមបារាំងហើយខ្មែរនៅតែប្រឹងទាំងត្រដាបត្រដួស ចំណែកបារាំងដំបូងគេពុំជឿលើអតីកាល របស់ខ្មែរទេ។ ប្រការល្អមួយ វត្តអារាមបានទទួលតួនាទីជាជង្រុកឬឃ្លាំង វប្បធម៌អារ្យធម៌ កុមារទាំងឡាយតែងបានបួសរៀនសឹងតែគ្រប់រូបក្នុងសាលាវត្ត។ រហូតមកដល់សម័យថ្មីៗនេះ ពោលគឺពេលដែលស្រុកខ្មែរមានបង្កើតសាលារៀនទំនើប តាមបារាំងសែសពាសពេញស្រុកក៏ដោយសាលាវត្តនៅតែមានជីវិតរស់នៅទន្ទឹមគ្នានឹងសាលារៀនបែបបារាំងនេះដែរ បានសេចក្តីថាពុទ្ធសាសនានិងព្រះសង្ឃខ្មែរមានឥទ្ធិពលសំខាន់ទៅលើការអប់រំប្រជាជន។ អ្វីទាំងអស់នេះ ត្រូវចប់ត្រឹមសម័យកម្ពុជា ប្រជាធិបតេយ្យ ដែលអន្តរជានការអប់រំរបស់ខ្មែរប្រៀបដូចការបែកបាក់លង្វែកដូច្នោះដែរ។ ទោះបីសេចក្តីវិនាសដែលត្រូវបានបង្កើតឡើងដោយរបបនេះមានទំហំប៉ុណ្ណាក៏ដោយ វាជាប្រការជ្រុលពេកណាស់ដែលយើងតែងចូលចិត្តភ្ជាប់វាទៅនឹងភាពអន់ថយរបស់ខ្មែរឥឡូវគ្រប់រឿងហេតុ។

## ២.៦. ក្រសួងសួស្តី(ក្រសួងអប់រំ)

នៅសម័យលង្វែកខ្មែរបានបង្កើតក្រសួងមួយក្នុងក្រសួងរាជការដែលមានឈ្មោះថា«ក្រសួងសួស្តី»។ ក្រសួងនេះបានរលត់បាត់ទៅវិញនៅសតវត្សរ៍ទី២០នេះ។ អ្នកសិក្សាស្រាវជ្រាវទាំងអស់បានដឹងអំពីមុខងារនៃក្រសួងនេះតិចតួចណាស់ ក៏ដូចជា ប្រវត្តិនៃកម្ពុជាសម័យកណ្តាលដែរ។ មន្ត្រីនៃព្រះរាជាណាចក្រទាំងនោះហាក់ដូចហោះហើរដូចផ្សែង ហើយបន្សល់ទុកនៅស្នាកស្នាម នៃមន្ត្រីទាំងនោះតិចតួចណាស់ក្នុងសម្បជញ្ញៈខ្មែរទាំងអស់។ ទើបតែលោកស្រី ពៅសាវរស បើកការស្រាវជ្រាវឱ្យទូលំទូលាយទៅលើ«ច្បាប់» នានា និងអត្ថបទប្រៀនប្រដៅដ៏ច្រើន ទើបលោកស្រីបង្កផ្គុំឡើងបន្តិចម្តងៗ នូវក្រសួងពិសេសមួយ។ ក្រសួងនោះមានអត្ថន័យសំដៅការហាត់ហ្វឹកហ្វឺនឆ្ពោះដល់យុវជនទាំងអស់ ដែលមានឈ្មោះថា«ក្រសួងសួស្តី» និងសម្រាប់បង្ហាត់បង្រៀនយុវជនទាំងអស់នោះឱ្យមានចំណេះ និងក្លាយខ្លួនទៅជា«រាជការ» ឬមន្ត្រីសំរាប់ប្រទេស។ តែមានច្បាប់ជាច្រើនដែរ ដែលមានឈ្មោះថា «ច្បាប់សួស្តី»ឬ«សត្រាទូន្មានខ្លួន»សម្រាប់ឱ្យក្រសួងសួស្តីនោះប្រើប្រាស់។ ចំពោះខ្មែរទាំងអស់គឺ មានបំណងដ៏ធំគឺបណ្តុះបណ្តាលវិជ្ជាឱ្យដល់កូនចៅរបស់គេដើម្បីបញ្ចូលទៅធ្វើការនៅក្នុង ក្រសួងរាជការបំរើស្តេច(ក្សត្រិយ៍)គឺក្លាយជាមន្ត្រី។កុលបុត្រទាំងអស់នោះ ដំបូងបង្អស់ត្រូវមាតាបិតាបញ្ជូនខ្លួនឱ្យទៅសំណាក់សិក្សារៀនសូត្រនៅក្នុងវត្តជាមួយព្រះសង្ឃ។ បន្ទាប់មក ត្រូវមាតាបិតានាំកុលបុត្រទាំងនោះឱ្យទៅសំណាក់រៀនហ្វឹកហ្វឺនជាមួយមន្ត្រីណាមួយ ដើម្បីឱ្យមន្ត្រីនោះឱ្យបង្រៀនកូនរបស់ខ្លួន ឱ្យមានមុខរបរអ្វីមួយទៅអនាគត។ បើនិយាយឱ្យជាក់ស្តែងទៅកុលបុត្រដែលជាអ្នកទៅរួមរស់នៅជាមួយក្រុមគ្រួសារនៃមន្ត្រីទាំងនោះ

ហើយជនទាំងនេះត្រូវស្ថិតនៅក្នុងក្រសួងមួយគឺ ក្រសួង«ពល»ឬ«នាយពល»។ ក្នុងអត្ថបទនៃធម្មនុញ្ញ ខ្លះបានចែងអំពីក្រុម«សួស្តី»ដែរ តែពុំសូវញឹកញយទេ និងមានភាពរយាលៗផង ដោយសារមូលហេតុយ៉ាងងាយសោះថា៖អ្នករាជការតូចតាចត្រូវបានមន្ត្រីជាន់ខ្ពស់(មន្ត្រីថ្នាក់លើ) ត្រួតត្រាតាមលំដាប់ថ្នាក់ យ៉ាងធ្ងន់ធ្ងរដល់មន្ត្រីក្មេងៗទាំងនោះ។ ដូច្នោះហើយ ទើបមន្ត្រីក្មេងៗទាំងនោះដែលជាកាន់បញ្ជី «អ្នកធ្វើការរដ្ឋ» និងជាពិសេសគឺក្រុមអ្នកគ្មានសេរីភាពទៀតផង ដែលហៅថាពពួក«ពល» នេះហើយ ដែលគេបង្កើតជាកម្លាំងរបស់រដ្ឋ និងកម្លាំងយោធាតាមទំនៀមរបស់រដ្ឋ។ ហើយសូមគូសបញ្ជាក់ចំណុចយ៉ាងសំខាន់មួយទៀតថាគេបានប្រគល់បញ្ជីនេះដល់ក្រុម«សួស្តី» ពីព្រោះមន្ត្រីក្មេងៗទាំងនោះ សុទ្ធសឹងជាអ្នកប្រកប ដោយចំណេះវិជ្ជាយ៉ាងប្រសើរ។ ទោះនៅក្នុងរាជធានីក្តី ឬនៅតាមខេត្រនានាក្តីក្រុម«សួស្តី» ទាំងនោះជាអ្នកទទួលបន្ទុកទាំងអស់មើលរក្សា«ពល»។ ក្រុម«សួស្តី»នោះហើយដែលជាអង្គការពិនិត្យមើលបែងចែងកិច្ចការទាំងឡាយដល់ «ពល» ទាំងអស់ទៅតាមរដូវ និងតាមសមត្ថភាពនៃពលនោះគឺក្រុម«សួស្តី»នេះទៀត មើលនិងបរពលទាំងនោះនៅក្នុងកិច្ចការពិសេសៗ។ ក្នុងពេលមានកលយុគក្រសួង«សួស្តី»នេះឯងហើយដែលជាអ្នកជ្រើសរើសរកអ្នកដែលក្លាហាន(ទាហាន) និងបរពល(ទ័ព) ទៅក្នុងបន្ទាយនានាគ្រប់ទិសនៃ រដ្ឋ។ តើមានគុណសម្បត្តិយ៉ាងដូចម្តេចខ្លះ ដើម្បីធ្វើមន្ត្រីបាន? លោក អេមូនីញ៉េ អេត្យែន៍(Etienne Aymonier) សតវត្សរ៍ទី១៩-២០ ធ្វើអត្ថាធិប្បាយដោយឥតរុញរាសោះថា «តាមការពិតការជ្រើសរើស«មន្ត្រី»ជាទូទៅ អ្នកមន្ត្រីចាស់ច្រើនតែជ្រើសរើសកូនរបស់ខ្លួនរួចដាក់ឱ្យគាល់ព្រះមហាក្សត្រ ក្នុងឋានន្តរសក្តិជាអ្នកបំរើស្តេច និងជាពិសេស គឺធ្វើយ៉ាងណាឱ្យព្រះករុណាមានព្រះទ័យអាណិតអាសូរប៉ុណ្ណោះ(Le Cambodge, page 65)»។ តាមសក្ខីភាពនៃការអនុវត្តដែលចាត់ទុកថា ជាការដាក់លាក់មួយ នៅសម័យកណ្តាល។ ប៉ុន្តែ ការអនុវត្តប្រាកដពិតមែននោះ ដែលបានលាក់បំបាំងនូវគោលការនៃការដឹកនាំ និងលក្ខណៈទូទៅរបស់ «មន្ត្រី»។ ដោយសារគោលការនេះហើយ ដែលផ្តល់ឱ្យមានចំណុចចួបគ្នារវាងជំនាន់ផ្សេងៗ នៃការអនុវត្តរបស់ប្រវត្តិសាស្ត្រ។ «មន្ត្រី»ខ្មែរបើតាមនិយមន័យបានសេចក្តីថា«អ្នកដែលមានមន្ត្រី»នេះបើតាមក្បួននៃ «រដ្ឋាភិបាល» គឺមានចំណេះវិជ្ជាល្មមគ្រប់គ្រាន់ តែនៅឆ្ងាយអំពីប្រព័ន្ធនៃការជ្រើសរើស «មន្ត្រីច្រើនណាស់»។ អនាគត «មន្ត្រី» ត្រូវចេះក្បួន និងការ«អនុវត្ត» (i.e. La loi et ses applications) ដើម្បី «បំរើព្រះមហាក្សត្រ។សូមអញ្ជើញស្តាប់អំពីច្បាប់«សួស្តី» នៅសម័យនោះ (វគ្គទី២ និងវគ្គទី៣)។

២. បើស្នួនអាពុក នឹងចូលថ្វាយមុខ ព្រះបាទអ្នកជាអម្ចាស់ប្រើរៀន រៀនសាស្ត្រា ឱ្យ ឈ្លាស សព្វប្រាកដកបសេចក្តី។

៣. ហើយរៀនអក្សរ សំបុត្រឱ្យបរ បូណ៌នូវសំដី រៀនតាក់តែងទុក ធ្វេងស្តាំប្រក្រតី កាន់កត់កុំបីចាំពាក្យបិតា។វគ្គទាំងនេះសង្ខេបឱ្យឃើញថាជាវិជ្ជាដែលអនាគត មន្ត្រីទាំងនោះបានទទួលជា «សាស្ត្រា» (ដូចជា វិជ្ជា ចក្រវាលវិទ្យា, វេជ្ជសាស្ត្រ និងសិល្បៈ) អក្សរ, សំបុត្រ និងសំដី។

### ២.៦.១. ព្រះគោនិង ព្រះកែវ

តាមពិតទៅព្រះគោគឺជា ព្រះគោគឺជារូបសំណាក់ ដែលសាងឡើងដើម្បីទុកនូវក្បួនតម្រាសាស្ត្រាប្រចាំនគរខ្មែរ។ ហើយក្នុងសម័យលង្វែកក៏បានសាងសង់ចំនួន១២ថែមទៀតប៉ុន្តែត្រូវសៀមប្រមូលយក

ទៅដោយទាំងក្បួនតម្រាសាស្ត្រប្រចាំនគរទៅដោយគ្មានសេសសល់អ្វីទាំងអស់។ តាមរយៈហេតុការណ៍នេះ ប្រជាជនខ្មែរបានប្រឌិតឡើងព្រេង កថាមួយ គឺរឿងព្រះគោ ព្រះកែវដើម្បីពន្យល់ពីប្រវត្តិសាស្ត្រដ៏ជូរចត់នេះ។ រឿងនេះប្រឌិតឡើងដើម្បីពន្យល់ពីមូលហេតុនៃការបាត់បង់ និងផលវិបាកពីការបាត់បង់បន្ទាយលង្វែកនេះឯង។ តួអង្គព្រះគោតំណាងឱ្យគម្ពីរ ក្បួនខ្នាតរបស់ខ្មែរ ឯព្រះកែវតំណាងឱ្យអ្នកប្រាជ្ញខ្មែរដែលសៀមចាប់យកទៅ[24] ។

### ២.៦.២. ការចូលម្លប់របស់កូនស្រីសម័យលង្វែក

ខ្មែរបុរាណនិយមឱ្យកូនស្រីចូលម្លប់នៅពេលដែលកូនស្រីពេញក្រមុំ គឺនៅពេលនាងមានរដូវគ្រាដំបូង។ ពិធីចូលម្លប់របស់កូនស្រីក្នុងសង្គមខ្មែរគេមិនបានដឹងថា កើតមានតាំងពីសម័យកាលឬឆ្នាំណាមកទេតែគេបានដឹងតាមរយៈរឿងទុំ ទាវ ដែលកើតឡើងនៅសម័យលង្វែក ក្នុងរវាងសតវត្សទី១៦ ហើយបានបន្តមកដល់សម័យព្រះបាទស៊ីសុវត្ថិ មុនីវង្ស ក្នុងរវាងឆ្នាំ ១៩៤០គ.ស ទើបប្រជាពលរដ្ឋខ្មែរយើងបានបោះបង់ចោលរហូតមកដល់បច្ចុប្បន្ននេះ។ ចំពោះវត្ថុបំណង នៃការធ្វើពិធីចូលម្លប់របស់កូនស្រីនោះមានបួនយ៉ាងគឺ

- ប្រកាសភាពពេញក្រមុំរបស់កូនស្រី
- បន្ទុំសម្បុរនិងអប់រំរូបរាងកាយឱ្យកូនស្រី
- បំពេញលក្ខណៈចរិយាវិជ្ជាមេផ្ទះ និងវិជ្ជាជីវៈឱ្យកូនស្រី
- ទាក់ទាញអារម្មណ៍ញាតិមិត្តតាមរយៈ រូបសម្បត្តិ ចរិយាសម្បត្តិ និងវិជ្ជាសម្បត្តិ។

ការចូលម្លប់របស់កូនស្រីនៅពេលពេញក្រមុំដែលបានកំណត់ ដឹងដោយសារការមានរដូវនៅគ្រាដំបូង។ រយៈពេល ចូលម្លប់មាន ៣ខែ ទៅ ៦ខែ ឬក៏លើសនេះក៏មានដែរ ទៅតាមជីវភាពលទ្ធភាពរបស់គ្រួសារនិងការសំរេចលើឪពុកម្ដាយ។ នារីចូលម្លប់ពាក់អាវដៃវែង ស្លៀកសំពត់វែង បិតនៅក្នុងផ្ទះមិនឱ្យត្រូវកំដៅថ្ងៃទេ។ ប៉ុន្តែបើនៅពេលយប់នោះគឺអាចចុះដី ឬចេញក្រៅផ្ទះបាន។ ចាប់ពីថ្ងៃចូលម្លប់មានតែការអុជធូបជំរាបព្រលឹងដូនតាបន្តិចបន្តួចប៉ុណ្ណោះ ហើយក៏មានដាក់ដាំកូនចេកក្រមុំដំណាលគ្នាផងដែរដើម្បីបានផ្លែទុំមួយស្នងនោះបន្ទុំធ្វើបង្អែមនៅពេលចេញពីម្លប់។ នារីនៅក្នុងម្លប់ គឺមានការហាត់ពត់ផ្នែកវិន័យ និងសីលធម៌ក្នុងការរស់នៅ ដោយហាមនូវទំនាក់ទំនងលើការនិយាយ ជាមួយភេទបុរសដែលសូម្បីតែឪពុកនិងបងប្អូនប្រុសក៏ហាមមិនឱ្យនិយាយច្រើនដែរ។ ពេលនោះការទាក់ទងតែទៅលើ ស្ត្រីភេទដូចគ្នាហើយត្រូវបរិភោគម្ហូបបួសដូចជាសណ្ដែក ល្ង បន្លែជាដើមពោលគឺមិនមានការអនុញ្ញាតឱ្យបរិភោគសាច់ឡើយ។ នេះជាពិធីដ៏សំខាន់ពីបុរាណត្រូវអប់រំនារី ដែលត្រូវដល់ពេលឈានដល់ភារកិច្ចថ្មី គឺជាមេផ្ទះនិងដឹកនាំគ្រួសារឱ្យមានសុភមង្គលស្របទៅតាមរបបមាតាធិបតេយ្យ ការនិយមមេជាធំ ដែលជាការអនុវត្តន៍ តាមប្រវត្តិប្រពៃណីព្រះថោងតោង ជាយស្បែននាងនាគ។ ពិសេសគេដឹងថា ស្ត្រីមេផ្ទះមានតួនាទីដ៏ថ្លៃថ្លា ឈានមុខក្នុងការកសាងសេចក្ដីសុខចំរើនរកទ្រព្យសម្បត្តិក្នុងគ្រួសារ ដូចពាក្យចាស់ពោលថា "ទ្រព្យគង់ ដ្បិតស្រី" "សូវស្លាប់បាកុំឱ្យស្លាប់មេ លិចទូកកណ្ដាលទន្លេ កុំឱ្យភ្លើងឆេះផ្ទះ"។ ទាំងសុភមង្គលនិងទ្រព្យ សម្បត្តិ

[24] - .សៀវភៅសិក្សាសង្គមថ្នាក់ទី១១ ឆ្នាំ ២០១១

ដែលកើតមាននៅក្នុងគ្រួសារក៏ជាកោសិកាសង្គម គឺនាំឱ្យជាតិបានរីកចម្រើនផងដែរ។ ម្ល៉ោះហើយការរៀប ចំឱ្យនារី ចូលម្លប់គឺជាឱកាសអប់រំចរិយាមារយាទ សណ្ដាប់ធ្នាប់ ពិសេសគឺ ការស៊ូទ្រាំអត់ធន់គ្រប់គ្រាលំបាកលំបិងជូរចត់ដើម្បីត្រៀមខ្លួនរៀបចំទទួលអំរែកវាសនា នៅពេលមានស្វាមី បង្កើតជាគ្រួសារថ្មី។ ដូចនេះដើម្បីឱ្យបានជាក់ច្បាស់ថែមទៀតនោះតាមរយៈវត្ថុបំណងទាំង៤នៃការចូលម្លប់មានការបកស្រាយដោយសង្ខេបដូចតទៅនេះ។ ចំពោះការប្រកាសពីភាពពេញក្រមុំរបស់កូនស្រីនោះ គឺដើម្បីឱ្យញាតិមិត្តផៅសន្ដានជិតឆ្ងាយដែលរង់ចាំឱកាសចូលស្ដី ដណ្ដឹងកូនស្រីនោះ នឹងបានជ្រាបច្បាស់ថា កូនស្រីគេពេញក្រមុំអាចទទួលភារកិច្ចតាមធម្មជាតិក្នុងការបន្តពូជពង្សបានហើយ។ នេះជាសញ្ញាមួយបានបង្ហាញអំពីទំនាក់ទំនង ទៅតាមច្បាប់ប្រពៃណីដល់បេក្ខភាព នៃកូនកំលោះទាំង ឡាយឱ្យបានដឹងនិងរៀបចំខ្លួន ចូលទាក់ទងស្ដីដណ្ដឹងឱ្យទាន់គេគឺកុំឱ្យខកឬហៅថាចូលមិនទាន់គេ។ បន្ទុំសម្បុរសាច់ឈាម គឺនារីដែលទើបបានឡើងខ្លួន ហើយនៅក្នុងម្លប់ធ្វើការស្រាលៗក្នុងផ្ទះតែងនាំឱ្យសាច់និងសម្បុរល្អដែលជាវត្ថុបំណងរបស់នារី ក្នុងការធ្វើឱ្យសាច់ឈាមស្រស់ថ្លាសាច់ខ្ចីស ម៉ដ្ឋទ្រលុកទ្រលន់ល្វត់ល្វន់។ ចរិយាសម្បត្តិ និងវិជ្ជាជីវៈដែលក្នុងពេលចាស់ទុំបានិយាយឱ្យស្ដាប់ ឬអានសៀវភៅ ឬអានសាស្ត្រាដោយខ្លួនឯង។ ជាមួយនេះមានការរៀនវិជ្ជាមេផ្ទះ ការដេរប៉ាក់ ត្បាញរវៃ ការរៀបចំផ្ទះសំបែង ការនិយាយស្ដីប្រកបដោយសំដីផ្អែមល្ហែមមិនឆេវឆាវ។ នៅពេលចេញពីម្លប់ អាចបណ្ដាលឱ្យញាតិមិត្តជិតខាងស្ងើចសរសើរ និងទាក់ទាញទាំងរូបសម្ផស្ស និងទាំងចំណេះ ដឹងសីលធម៌ គឺមានការប្រែប្រួលដ៏ល្អ។ បានសេចក្ដីថា ទាំងរូបសម្បត្តិ ទាំងចរិយាសម្បត្តិ និងទាំងវិជ្ជាសម្បត្តិរបស់នារី នោះអាចស័ក្តិសមជាមេផ្ទះដ៏ប្រសើរគួរឱ្យចង់ភ្ជាប់សាច់ភ្ជាប់ឈាម ជាគ្រួសារតទៅអនាគត។ ដូចនេ ការចូលម្លប់ គឺជារូបភាព និងជាវិធានការនៃការអប់រំស្ត្រីពីបុរាណក្នុងនាមជាអ្នកត្រៀមខ្លួនចូលបំពេញតួនាទីជាមេគ្រួសារប្រកបដោយសុភមង្គលក្នុងគ្រួសារនៃសង្គមខ្មែរ។ ប៉ុន្តែសម្រាប់បច្ចុប្បន្ននេះ ការអប់រំមានការរីកចម្រើនគឺទាំងយុវជនយុវនារី តែងបានចូលសិក្សារៀនសូត្រតាមសាលារៀនតាំងពីបឋមសិក្សា រហូតដល់ឧត្តមសិក្សាព្រមទាំងមានឯកសារក្បួនខ្នាតជាច្រើន សម្រាប់បណ្ដុះបណ្ដាលធនធានមនុស្សឱ្យបានប្រសើរក្នុងសង្គម[25]។

### ២.៦.៣. អក្សរសាស្ត្រខ្មែរ សម័យលង្វែក

ក្រោយពីសម័យអង្គរុងរឿង ខាងសិល្បៈល្បីល្បាញក្នុងសាកលលោក, ប្រទេសខ្មែរយើងបានជួបប្រទះនឹងសង្គ្រាមជាញឹកញាប់ ដោយមានចម្បាំងរាំងជល់ នឹងប្រទេសជិតខាងផង ច្បាំងដណ្ដើមរាជ្យគ្នាក្នុងស្រុកផង។ ក្នុងរយៈកើតសង្គ្រាមដូច្នេះប្រជាពលរដ្ឋយើងត្រូវតែគេចវេះ រត់ទ័ពរត់សឹកឬត្រូវកេណ្ឌធ្វើជាទាហាន។ ខាងសិល្បៈដែលធ្លាប់ល្បីល្បាញមក ក៏ពុំឃើញមានសកម្មភាពអ្វីឱ្យធំដុំឡើយ។ បុរាណវត្ថុធំៗនៅសម័យអង្គរបានរលុបរលាយបាត់បង់ទៅវិញ និងបានកប់ចោលនៅក្នុងព្រៃជាចំណីរុក្ខជាតិ ហើយពុំសូវមាននរណានឹកឃើញផងសោះ។ ខាងសាសនាប្រជាពលរដ្ឋខ្មែរយើងនៅប្រកាន់ជឿព្រះពុទ្ធសាសនាយ៉ាងមុតមាំ។ ចំណែកខាងអក្សរសាស្ត្រវិញ កវីជំនាញៗ ក្នុងសម័យលង្វែកនិងឧត្តុង្គ ច្រើនតែដកស្រង់រឿងពីគម្ពីរពុទ្ធសាសនាមានរឿងទសជាតកដែលនិទានពីកំណើតព្រះពុទ្ធ១០ជាតិកាលនៅ ជាព្រះពោធិ សត្វជាដើម ក្រៅពីនេះកវីជំនាញជាតិយើងបានខិតខំតុបតែងឡើងនូវសាស្ត្រាល្បែងនិងសាស្ត្រាច្បាប់ទាំងឡាយ

[25] -.https://km.wikipedia.org/wiki/សម័យលង្វែក

ជាច្រើនរឿងច្រើនច្បាប់ មានច្បាប់ក្រមកេរ្តិ៍កាល កូនចៅ ត្រីនេតិជាដើម និងរឿងព្រេងដែលនិយាយតៗគ្នាមក មានរឿងអាឡេវ អាខ្វាក់អាខ្វិន សុភាទន្សាយ ធនញ្ជ័យបណ្ឌិតជាដើម។ តែរឿងទាំងអស់នោះ ពុំឃើញមានដាក់ឈ្មោះករីនិពន្ធ នឹងកាលបរិច្ឆេទនៃការសរសេររៀបរៀង នៅក្នុងពេលណាផងឡើយ។ ចំពោះព្រឹត្តិការណ៍នៃនាមករីនិពន្ធ កាលបរិច្ឆេទ រជ្ជកាលនឹងប្រភពអក្សរសាស្ត្រ នៅលើសាស្ត្រាច្បាប់សាស្ត្រាល្បែង និងរឿងព្រេងទាំងអស់នោះ ដោយពុំមានគោលឋានៈដាក់លាក់ដូច្នេះយើងជាអ្នកស្រាវជ្រាវប្រវត្តិសាស្ត្រមួយរូបសូមផ្ញើនូវគំនិតការស្រាវជ្រាវប្រវត្តិសាស្ត្រទាំងអស់នោះចំពោះអស់លោកអ្នកប្រវត្តិសាស្ត្រទាំងឡាយ សុំឱ្យជួបស្រាវជ្រាវរកឫសគល់ប្រវត្តិសាស្ត្រនោះឱ្យមានគោលស្ថានដាក់លាក់ឡើង ជូនជនរួមជាតិយើង ដើម្បីនឹងលម្អ ឬសម្រស់នៃប្រវត្តិសាស្ត្រាខ្មែរទាំងអស់នោះ ឱ្យមានលក្ខណៈគ្រប់គ្រាន់ទៅជាមត៌ក សម្រាប់កូនខ្មែរបានសិក្សាក្នុងព្រះរាជាណាចក្រទូទៅ។

- នៅសម័យនោះរបៀបការសិក្សាកូនខ្មែរយើងភេទប្រុសអាយុ ៩ ឬ ១០ ឆ្នាំបានចូលទៅនៅវត្តនៅបម្រើលោកគ្រូ ដាំទឹក ដងទឹក ពុះអុស តាមលោកគ្រូទៅសូត្រមន្ត ទៅឆាន់ ទៅទេសនា ។ ការរៀនសូត្រពុំសូវមានពេលម៉ោងហ្មត់ចត់ទេ ក្មេងនៅជាមួយលោកគ្រូទាំងអស់នោះ ក្មេងណាដែលយកចិត្តទុកដាក់ជាងគេ ក៏ឆាប់បានចេះមើលដាច់ ចេះសរសេរទៅបានខ្លះ។ គេសង្កេតឃើញក្មេងដែលចេះរឿងចាំមាត់ហូរហែ តែមើលអក្សរ ឬសរសេរផងមិនកើតក៏មាន។ដល់អាយុ ១៥-១៦ ឆ្នាំក្មេងនោះក៏បានប្រែភេទចូលទៅបួសជាសាមណេរបាន ៥-៦ ឆ្នាំបានបួសជាភិក្ខុភាព ឬមួយក៏សឹកមករៀបចំផ្ទះសម្បែងប្រពន្ធកូនវិញ។ បណ្ឌិតទាំងនោះមានខ្លះមកប្រកបការធ្វើស្រែខ្លះទៀតក៏បានទៅផ្គាប់ផ្គុនបុណ្យសក្តិ បានធ្វើស្មៀនស្មើមន្ត្រីជាច្រើន អ្នកដែលសង្វាតរៀនសូត្រក៏បានចេះដឹងជ្រៅជ្រះដែរ ដោយខ្លះទៅរៀននៅប្រទេសថៃ។

- គ្រូអាចារ្យនៅសម័យនោះ វត្តលោកសង្ឃជាសាលារៀនដោយលោកសង្ឃធ្វើជាគ្រូបង្រៀន ។ លោកសង្ឃជាអ្នកចេះដឹងជាងគេក្នុងតំបន់ស្រែចម្ការ លោកច្រើនទេសនាផ្សាយព្រះពុទ្ធសាសនាពីរឿងធម៌អាថ៌ ដែលសម្តែងពីឋានសួគ៌និព្វានឱ្យពុទ្ធបរិស័ទជឿកម្មផលពីបុព្វេ។ ក្រៅពីនេះលោកបានផ្សាយបង្រៀនជាដំបូង នូវសាស្ត្រច្បាប់ក្រមកេរ្តិ៍កាល ពាក្យចាស់ សាស្ត្រាល្បែង ហង្សយន្ត សង្ខសិល្បជ័យ មរណមាតាជិនវង្ស លក្ខិណវង្សជាដើម។កម្មវិធីសិក្សាកូនខ្មែរនៅសម័យនោះច្រើនជួបប្រទះស្ទើរតែគ្រប់គ្នានូវការរៀនសូត្រវិជ្ជាផ្សេងៗ៖

- រៀនមន្តអាគមអូមអាម ស្នេហ៍និងរបៀបផ្សេងៗ ដូចរៀនធ្វើគ្រូហ្មធំពិសពស់ ពិសខ្ចួយ ពិសត្រីអណ្តែងជាដើមដែលជាការពុំសមហេតុសមផលចំពោះយើងក្នុងសម័យនេះ

- រៀនធ្វើហោទាយកាត់សប្តិ ជាហេតុបណ្តាលឱ្យមានពាក្យខ្មែរបុរាណឆ្លើយប្រាប់ថា "ភូតនៅហោរចោរនៅដាង"

- រៀននពន្តស្តួចស្តើងណាស់ មានចំនួនតិចដែលបានរៀនក្បាច់ចិនហើយច្រើនទន្ទេញមេលេខជាភាសាចិនផង។ គេរៀនតែលេខបូកគុណសងចែកព្រួលៗជាការចប់ចំណោទពុំសូវឮរៀនផងឡើយ

- ខាងអក្សរសាស្ត្រវិញគេរៀនច្បាប់ក្រម កេរ្តិ៍កាលកូនចៅច្បាប់ប្រុស ច្បាប់ស្រី សាស្ត្រាល្បែងល្បើកដុច ហង្សយន្ត សង្ខសិល្បជ័យ គម្ពីរទេសន៍ អភិធម្មប្រាំបួនបរិច្ឆេទអភិធម្មប្រាំពីរគម្ពីរមហាជាតក

មហោសថជាតក៍ជាដើម។ គេរៀនមើលដាច់ដើរនិយាយប្រាប់គ្នាបានជាការចប់ គេពុំសូវរៀនពិចារណាលើច្បាប់ទាំងអស់នោះឱ្យយល់ឃើញច្បាស់លាស់នូវហេតុនិងផលឡើយ។

ការសិក្សាអក្សរសាស្ត្រខ្មែរសម័យលង្វែកនិងឧត្តុងមានរបៀបដូចបានពណ៌នាមកខាងលើនេះ តែបើពិចារណាយកអត្ថរសនូវប្រភេទនៃអក្សរសាស្ត្រទាំងអស់នោះទៅឃើញថាកវីបណ្ឌិតបុរាណជាតិយើងជំនាន់នោះ បានខិតខំរកទ្រឹស្តីនិពន្ធឡើង ដើម្បីបំពេសតិអារម្មណ៍និងកែអផ្សុកនៃប្រជាពលរដ្ឋទូទៅ ឬដើម្បីធ្វើជាគតិដល់អ្នកមានជីវភាពរស់នៅក្នុងចំណោមណាមួយ និងដើម្បីធ្វើគោលច្បាប់ដំបូន្មានខាងសីលធម៌និងវិជ្ជាជីវៈសម្រាប់ទាញសតិសម្បញ្ញៈនៃបណ្តាជនឱ្យភ្ញាក់រឭកគិតទុកដាក់ខ្លួនទៅតាមគោលនៃសម្មាទិដ្ឋិ។ អក្សរសាស្ត្រទាំងនេះក៏មានមហិទ្ធិឫទ្ធិខ្លាំងណាស់ចូលផ្សព្វផ្សាយជ្រួតជ្រាបពាសពេញលើផ្ទៃប្រទេសសូម្បីតែសាមញ្ញជននៅទីកៀនកោះចុងកាត់មាត់ញក ក៏បានទទួលរសជាតិអក្សរសាស្ត្រនេះដែរ។

ហេតុនេះបានព្រះរាជរដ្ឋាភិបាលខ្មែរដោយចង់ឱ្យប្រទេសខ្មែរអាចរក្សាទុកបាននូវកេរ្តិ៍មត៌ក ព្រមទាំងចង់ឱ្យពង្រីកប្រយោជន៍សំខាន់ ៗ ដែលកើតឡើងពីអក្សរសាស្ត្របុរាណនិងទំនើប បានបង្កើតឱ្យមានពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត(សាលាបាលីជាន់ខ្ពស់) និងក្រុមពុទ្ធសាសនបណ្ឌិត្យឡើង វិជ្ជាឋានទាំងពីរនេះមាននាទីបង្ហាត់បង្រៀននឹងដឹកនាំបណ្តាជនជាតិខ្មែរទាំងគ្រហស្ថ ទាំងបព្វជិតឱ្យដើរទៅកាន់អារ្យធម៌ដ៏ប្រសើរផ្នែកខាងសាសនានិងអក្សរសាស្ត្របានចម្រើនឡើងតាមលំដាប់ឱ្យយើងបានឃើញលទ្ធផលជាក់ស្តែងដូចសព្វថ្ងៃនេះ។ នៅក្រុមពុទ្ធសាសនបណ្ឌិត្យ មិនមែនត្រឹមតែមាននាទីផ្សាយព្រះពុទ្ធសាសនាដោយការរៀបរៀងតែង និងរៀបចំបោះពុម្ពផ្សាយ នូវសៀវភៅផ្លូវលោកផ្លូវធម៌ផ្សេងៗ ច្រើនមុខប៉ុណ្ណោះទេ ថែមទាំងបានបង្កើតឱ្យមានបណ្ណាល័យមួយរក្សាទុកនូវមត៌កអក្សរសាស្ត្រ គឺគម្ពីរដីកាសាស្ត្រា ក្រាំង សៀវភៅក្បួនខ្នាត តម្រាប់តម្រាផ្សេងៗ របស់បុរាណនិងទំនើបជាច្រើន។ ឯក្បួនច្បាប់អក្សរសាស្ត្រទាំងអស់ ដែលបានមកតម្កល់ទុកក្នុងបណ្ណាល័យនេះ គឺបានមកដោយសារសទ្ធារបស់ពួកពុទ្ធបរិស័ទខ្លះ បានមកដោយក្រុមពុទ្ធសាសនបណ្ឌិត្យចាត់ភ្នាក់ងារឱ្យទៅកត់ត្រាស្រាវជ្រាវប្រមែប្រមូលរកអំពីវត្តអារាម ភូមិ-ស្រុក តូចធំនិគម ជនបទនានាក្នុងព្រះរាជអាណាចក្រទាំងមូលខ្លះ។ ដូច្នេះយើងយល់ឃើញថាបណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ ជាឃ្លាំងមួយសម្បូរបំផុតនូវឯកសារមត៌កអក្សរសាស្ត្រខ្មែរបុរាណ សម័យលង្វែកនិងឧដុង្គនិងរក្សាទុកនូវសៀវភៅក្បួនខ្នាតអក្សរសាស្ត្រទំនើបជាភាសាបរទេសនិងភាសាខ្មែរជាច្រើន។សព្វថ្ងៃបណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ ដែលបរិបូណ៌ដោយឯកសារអក្សរសាស្ត្រច្រើនយ៉ាងដូច្នោះ បានក្លាយទៅជាបណ្ណាល័យប្រភពអក្សរសាស្ត្រជាឃ្លាំងវិជ្ជាជាវិជ្ជាឋាន សម្រាប់ជាប្រភពរដ្ឋនិងកវីនិពន្ធទាំងផ្នែកគ្រហស្ថទាំងផ្នែកបព្វជិតតែងចេញចូលសិក្សា សាកសួរពិគ្រោះរិះរកក្បួនច្បាប់ក្នុងមន្ទីរជាហូរហែរាល់ថ្ងៃធ្វើការ [26]។ យើងបានអធិប្បាយវែកញែកអំពីរបៀបការសិក្សា កិច្ចការជាស្នាដៃអ្នកជំនាន់មុន និងពណ៌នាអំពីមត៌កអក្សរសាស្ត្រកវីជំនាញជំនាន់នោះ ដែលមានឯកសារតម្កល់ទុកនៅក្នុងបណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យដោយមានបំណងចង់ណែនាំអ្នកមានគំនិតទាំងឡាយ ឱ្យចូលចិត្តស្រឡាញ់អក្សរសាស្ត្រជាតិ ដែលជាកេរ្តិ៍ដំណែលបុព្វបុរសរបស់យើង ព្រមទាំងចង់ឱ្យដឹងនូវដំណើរអក្សរសាស្ត្រពីដើមមកទុកជាគោលសម្រាប់កសាងអក្សរសាស្ត្រថ្មីឱ្យបានចម្រើន ហើយឱ្យមានការប្លែកៗ ផងនាំឱ្យយើងចេះប្រើការរិះគន់ដើម្បី

[26] -.https://km.wikipedia.org/wiki/សម័យលង្វែក

ប្រយោជន៍ដល់ខ្លួនយើង គឺជៀសវាងការភ្លាត់ភ្លាំង ហើយកត់សម្គាល់នូវសេចក្តីល្អត្រូវទុកជាឧទាហរណ៍ រៀនតទៅអនាគត។ ការធ្វើសង្គ្រាមអាចយកឈ្នះចាញ់បានក៏អាស្រ័យ ការដែលយើងចេះប្រើល្បិចដូចជា ចៅពញាសួគ៌ាលោករួមជាមួយចៅពញាយសរាជ ដែលត្រូវជាក្មួយរបស់ព្រះអង្គចន្ទ បានយកគំនិតនេះមក ប្រើនៅពេលដែលដឹងថាខ្លួនមិនអាចមានលទ្ធភាព វាយយកបន្ទាយស្រឡប់ពិជ័យព្រៃនគរបាន អាស្រ័យ ដោយបរិមាណកងទ័ពខ្លួនតិចជាងកងទ័ពរបស់ស្តេចកន។ ប្រឈមមុខនិងស្ថានភាពបែបនេះមេទ័ពទាំង ពីរបានរកឧបាយកលបញ្ឆោតទ័ពស្តេចកនឱ្យភ័យស្លន់ស្លោរត់ចោលបន្ទាយដែលជាទីតាំងរឹងមាំរបស់ ខ្លួន។ ជាក់ស្តែងគេបានចាត់ឱ្យយកចំបើងចងធ្វើជាមនុស្សនិងដាក់ប្រឆេះសម្រាប់អុជយកទៅបន្លំនៅជុំវិញ បន្ទាយ ហើយនៅពេលយប់គេដើរដុតឱ្យឆេះសន្ធោសន្ធៅឡើងរួចហើយស្រែកហ៊ោសន្ទាប់ពីចម្ងាយដើម្បី បំបាក់ទឹកចិត្តទ័ពសត្រូវ។ គេធ្វើរបៀបនេះជាប់ៗគ្នា រហូតដល់១៥យប់ធ្វើឱ្យ សត្រូវមិនបានដេកហើយ ចំណាយគ្រាប់បាញ់ដោយឥតប្រយោជន៍អស់ជាច្រើន។ ដោយនឹកស្មានថាទ័ពសត្រូវមានចំនួនច្រើនជាង ស្តេចកននិងកងទ័ពរបស់ខ្លួន សម្រេចចិត្តរត់ចេញពីបន្ទាយ ដែលជាហេតុធ្វើឱ្យទ័ពរបស់ចៅពញារាជា មានលទ្ធភាព ចូលកាន់កាប់បន្ទាយ ដ៏រឹងមាំនោះបានដោយស្រួលគ្មានការបង្ហូរឈាមហើយចុងក្រោយ ដេញតាមចាប់ស្តេចកនបានដោយគ្មានឧសគ្គ។ទាំងអស់នេះគឺ ជាគំនិតដឹកនាំសំខាន់ៗដែលត្រូវបានយក មកប្រើដោយមគ្គុទេសក៏ របស់សម័យលង្វែកដើម្បីដោះស្រាយបញ្ហាជាមួយសត្រូវបរទេសនិងសត្រូវក្នុង ស្រុក។ ជាក់ស្តែងជាមួយសត្រូវបរទេសទិសខាងលិចមគ្គុទេសក៏យើងបានលើកគោលគំនិតផ្លាស់ប្តូរទីតាំង រាជធានីចុះមកទិសខាងត្បូងប្រទេសដើម្បីរក្សាកម្លាំង និងវាយបកទៅលើសត្រូវនូវថ្ងៃណាមួយពេល ឱកាសហុចឱ្យ។ ទាក់ទងនឹងបញ្ហាទំនាស់ផ្ទៃក្នុងដដែលនេះមានមគ្គុទេសក៏ ផ្សេងទៀតបានប្រើប្រាស់នូវ គោលគំនិត ដ៏សម្បូរបែបដែលជាតុពិតគឺជាការគួបផ្សំរវាងគោលគំនិតផ្នែកយោធា និងនយោបាយដើម្បី យកប្រៀបឈ្នះលើសមរភូមិ ប្រយុទ្ធនិងវាយគួបដិបក្ខឱ្យចុះចាញ់ជាស្ថាពរហើយដណ្តើយកមកវិញនូវ ភាព ស្របច្បាប់បង្រួបបង្រួមទឹកដីឱ្យមកជាទឹកដីកម្ពុជាតែមួយ។ ថ្វីត្បិតតែគោលគំនិតចុងក្រោយនេះ មានទិសដៅប្រើប្រាស់ ដើម្បីបម្រើសង្គ្រាមក្នុងស្រុកក្តី ក៏គោលគំនិតទាំងអស់នេះអាចចាត់ទុកថាមាន តម្លៃជាសាកលអាចយកមកប្រើប្រាស់ជាមួយសង្គ្រាមបរទេសបានដែរ។ ជាទូទៅគេធ្វើសង្គ្រាមតែងតែត្រូវ ការចាំបាច់ នូវភាពប៉ិនប្រសប់ឬហៅថាម៉្យាងទៀតថាសិល្បៈនៃ សង្គ្រាម។ជាក់ស្តែងនូវពេលដែលសត្រូវរួម គ្នាជាផ្លុងមួយ គេត្រូវប្រើសង្គ្រាមចិត្តសាស្ត្រដើម្បី បំបែកបំបាក់សត្រូវធ្វើឱ្យសត្រូវលែងទុកចិត្តគ្នា។ គេគប្បី សម្លឹងមើលថាតើកម្លាំងណាមួយជាកម្លាំងរបស់សត្រូវដើម្បីវាយ ឱ្យចំកម្លាំងនោះធ្វើឱ្យ សត្រូវបាត់កម្លាំង បង្អែក ហើយឈានទៅចុះចាញ់ដោយស្វ័យប្រវត្តិ។ ផ្ទុយទៅវិញពេលសត្រូវហ៊ុំព័ទ្ធគេត្រូវចេះប្រើយុទ្ធវិធី វាយបំបែក ការឡោមព័ទ្ធរបស់ សត្រូវជាជាងនៅក្រាញនៀលវាយប្រយុទ្ធ ទាល់តែសត្រូវចាប់ខ្លួនបានឬ កំទេចកម្លាំង បានទាំងស្រុង។ក្នុងករណីខ្លះទៀត ក្នុងពេលសត្រូវហ៊ុំព័ទ្ធយូរថ្ងៃការលំបាកចំពោះមុខពិតជា មានច្រើន ដូច្នេះមេទ័ពត្រូវហ៊ានពលីអ្វីៗគ្រប់យ៉ាងរហូតលះបង់អាយុជីវិតរបស់ខ្លួនដើម្បីពង្រឹងស្មារតីកង ទ័ព ដែលអស់សង្ឃឹមធ្លាក់ទឹកចិត្តទៅហើយនោះ ឱ្យមានទឹកចិត្តប្រយុទ្ធយ៉ាងក្លៀវក្លាឈានឆ្ពោះទៅរក ជ័យជំនះសារជាថ្មីឡើងវិញ។ ម៉្យាងទៀតនៅពេលកំពុងធ្វើការប្រយុទ្ធគេត្រូវចេះធ្វើល្បិចដោយដកថយ បញ្ឆោតសត្រូវឱ្យធ្លាក់ចូលក្នុងទ័ពអន្ទាក់ ដែលពួនចាំវាយរួចជាស្រេច ដើម្បីធ្វើឱ្យសត្រូវចុះចាញ់ ដោយ

មិនចាំបាច់ចំណាយសាច់ឈាមច្រើនទៀតផង។ទន្ទឹមនឹងនេះដើម្បីយកជ័យជំនះលើខ្មាំង សត្រូវបរិមាណទ័ពក៏ជាការចាំបាច់ដែរ។ដូចនេះ ត្រូវពង្រឹងបរិមាណកងទ័ពឱ្យបានទាន់ពេលវេលាតាមវិធីសាស្ត្រប្រឡងប្រយុទ្ធជាក់ស្តែង លើទីលានដើម្បីជ្រើសរើសអ្នកខ្លាំងពូកែប្រកប ដោយ សមត្ថភាពប្រយុទ្ធពិតប្រាកដព្រមទាំងចេះថែបំប៉នកម្លាំងនោះ ឱ្យមានទឹកចិត្តប្រយុទ្ធជាប់ជាប្រចាំដោយវិធីលើកទឹកចិត្តរបស់ពួកគេ ហើយគួបផ្សំយ៉ាងប៉ិនប្រសប់ជាមួយនឹងគោលនយោបាយ សមរភូមិក្រោយ។បើពិនិត្យទៅឃើញថា កងទ័ពមានការនឿយណាយមិនអាចទ្រាំទ្របាននឹងការប្រយុទ្ធតទៅទៀត។ វិធានការដែលល្អបំផុតនោះគឺត្រូវបើកការចរចាផ្អាក សង្គ្រាមបណ្តោះអាសន្នជាមួយសត្រូវ។នៅពេលខ្លះទៀត បើមើលឃើញថាទន់ដៃជាងសត្រូវហើយនោះអាច បណ្តោយយូរទៅអាចជះឥទ្ធិពល មិនល្អដល់អត្ថិភាពរបស់អំណាច គេត្រូវហ៊ានចរចារជាមួយសត្រូវ ដើម្បីអូសបន្លាយពេលវេលាឱ្យស្ថិតក្នុងអំណាចនោះយូរអង្វែង តទៅទៀតឬចរចារជាមួយសត្រូវដើម្បីបែងចែកទឹកដីគ្នាគ្រប់គ្រងតែម្តង។ បើយើងពិនិត្យទៅឃើញថាសត្រូវមានិន្នាការបែបនេះដែរ។ ដោយឡែកក្នុងការធ្វើសង្គ្រាមគេត្រូវបើកឱ្យមានរណសិរ្សប្រយុទ្ធជា មួយសត្រូវច្រើនប្រទេសឬច្រើនកន្លែង ក្នុងពេលតែមួយដោយមិនផ្អែកទៅលើ កំហឹងអត្តនោម័តរបស់បុគ្គលដែលជា មគ្គុទេសក៏នោះឡើយ។គេគប្បីត្រឡប់ទៅមើលការប្រៀបធៀបកម្លាំង ធ្វើជាគោលដើម្បីរក្សាកម្លាំងប្រយុទ្ធឱ្យនៅគង់វង្សផងហើយអាចបន្តការ ប្រយុទ្ធបានយូរអង្វែងតទៅទៀតដោយគ្មានគ្រោះថ្នាក់ផង។ ក្នុងកាលៈទេសៈខ្លះទៀតដើម្បីយកឈ្នះលើគូសត្រូវចាំបាច់ គេត្រូវរៀបចំកម្លាំងទ័ពនៅលើសមរភូមិទៅតាមក្បួនយុទ្ធសាស្ត្រនឹង មានការចាត់តាំងកម្លាំងនោះឱ្យបានម៉ត់ចត់។ ក្នុងពេលខ្លះទៀតគេត្រូវចេះបង្វែរដានសត្រូវ ឱ្យទៅប្តូរយុទ្ធសាស្ត្រកន្លែងផ្សេងទៀតឆ្ងាយពីទីតាំងសំខាន់ដើម្បី គេមានពេលវេលាគ្រប់គ្រាន់នឹងរៀបចំទីតាំងនោះឱ្យកាន់តែរឹងមាំមុន នឹងការប្រយុទ្ធជាទ្រង់ទ្រាយធំចូលមកចាំ បាច់ដល់ទីតាំងនោះ។ ដោយឡែកបើវាយចូលទីតាំងសត្រូវមិនចុះគេត្រូវរកវិធីបំផ្លាញសត្រូវពីខាងក្នុងដែលប្រើប្រាស់កម្លាំងដែលទុកចិត្តបំផុត ឱ្យចូលទៅសារភាពជាមួយសត្រូវ រស់នៅជាមួយសត្រូវធ្វើឱ្យ សត្រូវភ្លេចខ្លួន ហើយរងចាំឱកាសល្អវាយសត្រូវពីខាងក្នុងនៅពេលកងទ័ពខាងក្រៅចាប់ផ្តើមវាយលុក។ មធ្យោបាយនេះធ្វើឱ្យគេវាយបែកបន្ទាយសត្រូវបានយ៉ាងងាយហើយធ្វើឱ្យសត្រូវចាញ់យ៉ាងឆាប់រហ័ស។

## សំណួរពិភាក្សា

១. តើព្រះរាជាអង្គណាខ្លះដែលបានទៅរំដោះទឹកដីភាគខាងលិចពីសៀម?
២. តើមានការពន្យល់បែបណាខ្លះ ពីមូលហេតុនៃ ការបែកបាក់បន្ទាយលង្វែក?
៣. តើការមកដល់របស់ពួកអឺរ៉ុបបានធ្វើឱ្យនយោបាយពាណិជ្ជកម្ម សេដ្ឋកិច្ច ការអប់រំ និងសាសនាក្នុងសង្គមខ្មែរ ប្រែប្រួលយ៉ាងដូចម្ដេច?
៤. តើខ្មែរមានចំណងការទូតនិងពាណិជ្ជកម្មជាមួយប្រទេសណាខ្លះ?តើចំណងនេះផ្ដល់ផលប្រយោជន៍អ្វីខ្លះដល់កម្ពុជា?
៥. តើការបែកបាក់បន្ទាយលង្វែកប្រទេសខ្មែរជួបផលវិបាកបែបណា?
៦. តើស្ដេចអង្គណាដែលចូលរំដោះក្រុងលង្វែកពីសៀមគ្រប់គ្រង?

# មេរៀនទី៣
# សម័យឧដុង្គនិងការប្រកួតអំណាចរវាងយួន និងសៀម

## ៣.១. ស្ថានភាពភូមិសាស្ត្រសម័យឧដុង្គ



ផែនទីសម័យឧដុង្គ

មនុស្សដែលរស់នៅក្នុងសកលលោក នៃភពផែនដី យើងនេះតែងតែមានប្រវត្តិសាស្ត្ររៀងៗខ្លួនគ្រាន់តែថាប្រទេសនីមួយៗមានចំណាស់ខុសៗ គ្នាប្រទេសខ្លះមានអាយុកាលដ៏យូរលង់ និងប្រទេសខ្លះទៀតមានអាយុកាលក្នុងអំឡុងសតវត្សរ៍ទី១០និងចុង ១៣ នឹងប្រទេសខ្លះទៀតក៏មានការបាត់បង់ទៅវិញក៏មាន ដូចជាប្រទេស ចាម្ប៉ា មនដែលត្រូវបានបាត់បង់ទៅដោយសារការឈ្លានពានទន្ទ្រានយកមកកាន់កាប់ពីប្រទេសអាណ្ណាមនិងភូមា ។ ដូចជាប្រទេសថៃដែលនៅជិតខាងយើង ដែលយើងដឹងគ្រប់គ្នាថាជនជាតិនេះដំបូងឡើយគឺជា ជនជាតិភាគតិចរបស់ចិន ហើយក៏បានមកជ្រកកោននៅមហានគរដែលបានព្រះរាជានៃប្រទេសខ្មែរឱ្យអភ័យដើម្បី ជ្រកកោននឹងរស់រានមានជីវិត នៅលើទឹកដីមហានគររហូតមក តែមកដល់រជ្ជកាលនៃបុត្រារបស់ព្រះបាទជ័យវរ្ម័នទីប្រាំពីរ ប្រទេសបានចុះខ្សោយក្នុងការគ្រប់គ្រងដោយមានវិបត្តិផ្ទៃក្នុង ចោរថៃនេះក៏បានឈ្លានពានទន្ទ្រានកាន់កាប់ទឹកដីប្រទេសខ្មែរមួយផ្នែកដើម្បីធ្វើជានគរ ឬប្រទេសរបស់ខ្លួនរហូតមក ដល់សព្វថ្ងៃនេះ។ រីឯប្រទេសដែលមានអាយុកាលដ៏យូរលង់ឬវ័យចំណាស់ មានដូចជា ចក្រភពរ៉ូម ក្រិច អេហ្ស៊ីប ចិន ឥណ្ឌា នឹងប្រទេសផ្សេងៗទៀតតែនៅក្នុងប្រទេសទាំងនោះក៏មានប្រទេសកម្ពុជាយើងផងដែរ ដែលមានប្រវត្តិកាលដ៏យូរលង់ គឺមាន រាប់ពាន់ ឬ រាប់ម៉ឺនឆ្នាំ មុននៃគ្រឹស្តសករាជ ។ ដោយមានប្រវត្តិកាលដ៏យូរលង់នេះ យើងត្រូវមានការសិក្សាឱ្យបានជាក់ច្បាស់កប់ទុកក្នុងសន្តានរបស់ប្រជាជន ឬ ប្រជាពលរដ្ឋ យើងឱ្យបានដឹងគ្រប់ៗគ្នា ដើម្បីបានជាភស្តុតាងបង្ហាញទៅដល់ជាតិសាសន៍ដទៃ ថាប្រទេសយើងមានអរិយធម៌វប្បធម៌រីកចម្រើនរុងរឿង ឬ អន្តរាយដោយមានការបែកបាក់ផ្ទៃក្នុងមិនមានការរួបរួមសាមគ្គីគ្នា បានធ្វើឱ្យប្រទេសបាត់បងទឹកដី ព្រមទាំងអ្វីៗជាច្រើនដែលដូនតាបន្សល់ទុកឱ្យ[27]។នៅក្នុងប្រទេសកម្ពុជានាសម័យកាលឧត្តុង្គ នោះជាសម័យកាលដ៏ដួចត់បំផុតមួយ ដោយពុំមានការគ្រប់គ្រង់ប្រទេសបានល្អប្រសើរនោះទេ គឺខ្វះអ្នកមានសមត្ថភាពដឹកនាំ ព្រះរាជាទន់ខ្សោយ ឯមន្ត្រីរាជការមិនមានភាពស្មោះត្រង់ បណ្តាលឱ្យមានភាពបែកបាក់សាមគ្គីរវាងមន្ត្រីរាជការ និងប្រជារាស្ត្រព្រោះហេតុថាប្រទេសខ្មែរស្ថិតក្រោមអាណានិគមរបស់ប្រទេសជិតខាងដូចជាប្រទេសអាណ្ណាម និងប្រទេសសៀម ។

ការកសាងរាជធានីឧដុង្គឬឧដ្តុង្គមានជ័យទីក្រុងឧដុង្គចាប់ផ្តើមកសាងឡើងក្នុងសតវត្សរ៍ទី១៧ នៃគ្រឹស្តសករាជ ក្នុងរជ្ជកាលព្រះបាទសម្តេចជ័យជេដ្ឋាទី២ ដូចមានចែងក្នុងព្រះរាជពង្សាវ តារប្រទេសកម្ពុជាគឺក្នុងពុទ្ធសករាជ ១៦៤០ គ្រឹស្តសករាជ១៦២០ ព្រះបាទសម្តេចព្រះជ័យជេដ្ឋាជាម្ចាស់ជីវិតលើ

[27] -ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ ១៩៧៣

ត្បូង ស្តេចគង់នៅព្រះរាជវាំងល្វាឯម ទ្រង់នាំព្រះអគ្គមហេសីព្រះស្នំក្រមការ សេនាបតី និងនាហ្មឺនសព្វមុខមន្ត្រីខ្ញុំរាជការទាំងពួង ចុះព្រះរាជទីន័ងនាវាស្តេចយាងទៅប្រពាតនៅតំបន់អូរក្រេងលាយ ក្នុងខេត្តសំរោងទ្រង់ប្រថាប់នៅព្រះពន្លាជាយូរថ្ងៃ រួចស្តេចយាងក្រសាលនៅផ្ទះតាដុង យាយជ័យ ទ្រង់ទតឃើញទីទួលមួយនៅតំបន់ស្រះកែវ ជាទីមានទេសភាពល្អ ក៏ទ្រង់ចាប់ព្រះរាជហឫទ័យហើយទ្រង់មានព្រះតម្រាស់នឹងមន្ត្រីខ្ញុំរាជការទាំងពួង មានហោរាធិបតីជាដើមថា "យើងចង់កសាងព្រះរាជវាំងគង់នៅទីនេះ តើអស់អនេកទាំងពួងយល់ថាម្តេច?"។ ឧកញ៉ាហោរាធិបតី មុំ គន់គូរពិនិត្យមើលដីនោះ ដោយក្បួនហោរាសាស្ត្រហើយក្រាបបង្គំទូលថា "ទីនេះជាទីជ័យភូមិល្អណាស់ត្រូវតាមក្បួនទាយថា នឹងមានឫទ្ធតបៈតេជៈឈ្នះអស់សត្រូវទាំង៨ទិស"។ លុះព្រះរាជាទ្រង់ជ្រាបដូច្នេះទ្រង់ចាត់ឧកញ៉ាក្រឡាហោម កែវឱ្យជានាយកចាត់ការកសាងព្រះរាជវាំងនៅតំបន់ស្រះកែវនោះ ទ្រង់ចាត់ហើយ ស្តេចត្រឡប់មកព្រះបរមរាជវាំងល្វាឯមវិញ។ លំដាប់នោះ ឧកញ៉ាក្រឡាហោម កែវ បានទទួលនូវរាជានុសិទ្ធនោះហើយក៏បង្គាប់ទៅចៅហ្វាយស្រុកឱ្យកេណ្ឌបណ្តារាស្ត្រកាប់ឈើមកធ្វើជាព្រះរាជវាំងតាមព្រះរាជបញ្ជា។ លុះប្រមូលគ្រឿងសម្ភារៈបានសព្វគ្រប់ហើយ ឧកញ៉ាក្រឡាហោម កែវ បង្គាប់មេការឱ្យចាប់ផ្តើមចាត់ការលើកដីធ្វើជាបន្ទាយយាមល្បាតជុំវិញសង់ជាព្រះរាជវាំង ព្រះរាជមន្ទីរព្រះរាជដំណាក់ធំតូចនឹងចុងព្រះរាជរោងប្រមាណ១០ ខែទើបរួចស្រេចហើយយកសេចក្តីក្រាបបង្គំទូលសូមទ្រង់ជ្រាបសព្វគ្រប់ការ។ លុះទ្រង់ជ្រាបហើយ ព្រះបាទសម្តេចព្រះជ័យជេដ្ឋាជាអម្ចាស់ជីវិតលើត្បូងស្តេចចេញចាកព្រះបរមរាជវាំងល្វាឯមទ្រង់ឡើងគង់ព្រះទីន័ងនាវាធ្វើព្រះរាជដំណើរតាមទន្លេសាប មួយអន្លើដោយព្រះអគ្គមហេសី ព្រះស្នំក្រមការព្រះរាជវង្សានុវង្ស សេនាបតីនាហ្មឺនសព្វមុខមន្ត្រីខ្ញុំរាជការគ្រប់ក្រុមជារាជបរិពារដល់ កំពង់តាដុងយាយជ័យទ្រង់ប្រថាប់នៅទីនោះ ៣រាត្រី ទ្រង់ព្រះរាជបញ្ញត្តឱ្យហៅទីនោះថា "កំពង់ហ្លួង" ហើយទ្រង់ព្រះរាជបញ្ជាភ្នាក់ងារមុខក្រសួង ឱ្យរៀបចំធ្វើព្រះរាជពិធីឡើងព្រះរាជវាំងថ្មី និមន្តព្រះសង្ឃរាជាគណៈចម្រើនព្រះបរិត្ត ៣ ថ្ងៃ ចូលព្រះរាជពិធីនៅថ្ងៃ៥កើត ខែផល្គុនឆ្នាំវកទោស័ក ពុទ្ធសករាជ ២១៦៤ គ.ស. ត្រូវនឹងគ្រិស្តសករាជ ១៦២០គ.ស. ហើយព្រះរាជវង្សានុវង្ស ព្រះអគ្គមហេសីព្រះស្នំក្រមការ សេនាបតីមន្ត្រីខ្ញុំរាជការជារាជបរិពារ ហែរស្តេចឡើងពីកំពង់ហ្លួងចូលទៅគង់ក្នុងព្រះរាជវាំងថ្មី រួចទ្រង់ឱ្យរៀបធ្វើព្រះរាជពិធីសម្ភោជព្រះនគរ៣ថ្ងៃទៀតដោយមានល្បែងមហោស្រពគ្រប់បែបជាឧឡារិកអធិកអធមក្រៃពេក ទើបទ្រង់តាំងព្រះនាមព្រះនគរ (ទីក្រុង) ថ្មីនោះថា "ព្រះបរមរាជវាំងមហានគរ ឧត្តុង្គមានជ័យបុរីរម្យឧត្តមរាជនិវេស្សនដ្ឋាន" ដែលហៅខ្លីថា"ក្រុងឧត្តុង្គមានជ័យ"។

ព្រះបាទស្រីសុរិយោពណ៌យាងត្រលប់ចូលមកប្រទេសកម្ពុជា បានឆ្លងកាត់ខេត្តកំពតហើយក៏ធ្វើពីធីអភិសេកឡើងសោយរាជ្យនៅកោះស្លាកែតនៅឆ្នាំ១៦០៣គ.ស ដោយយកនាមសម្រាប់រាជ្យថា ព្រះបាទសម្តេចព្រះរាជឱង្ការព្រះស្រីសុរិយោពណ៌ទេវរាជានៅក្នុងព្រះជន្ម ៤៦ វស្សា។ មានអគ្គមហេសីនាមភវតីស្រីនៃសុជាតិ ដោយលើកបុត្រានាម ព្រះឧទ័យ ជាឧបរាជដែលមានព្រះជន្មទើបបាន ១៣ វស្សាចំណែកឯពញាញោមនៅជាព្រះកែវហ្វាដដែល។ នៅក្នុងរជ្ជកាលរបស់ព្រះអង្គមានចលនាបះបោរដែលដឹកនាំដោយចៅហ្វាយខេត្តខ្លះដែលមិនពេញចិត្តនឹងពញាញោម។ ដូច្នេះហើយបានជាស្រីសុរិយោពណ៌ចាត់ឱ្យមន្ត្រីទៅបង្រ្កាមចលនាបះបោរទាំងនោះ នៅឆ្នាំ គ.ស.-១៦០៤គ.ស. ស្រីសុរិយោពណ៌បានលើករាជធានី

មកល្វាឯមដែលស្ថិតនៅពីមុខទីក្រុងចតុមុខ។ នៅឆ្នាំ១៦១៨គ.ស. បុត្ររបស់ព្រះអង្គនាមជ័យជេដ្ឋាទី២ ដែលគង់នៅស្រុកសៀមត្រសប់មកវិញហើយមកគង់នៅកោះស្លាកែតជាមួយព្រះអង្គដែរ ។

នៅឆ្នាំ១៦១៨គ.ស. ស្រីសុរិយោពណ៌ដាក់រាជ្យថ្វាយជ័យជេដ្ឋាទី២ដោយហេតុនេះព្រះបាទជ័យជេដ្ឋាទី២ទ្រង់ឡើងសោយរាជ្យ នៅឆ្នាំ១៦១៨គ.ស.ក្នុងព្រះជន្មាយុក២៦ព្រះវស្សាដោយមានព្រះនាមសម្រាប់រាជ្យថា"សម្តេចព្រះរាជឱង្ការព្រះជ័យជេដ្ឋាធិរាជរាមានធិបតី"។ ព្រះបាទជ័យជេដ្ឋាទី២បានប្តូររាជធានីពីល្វាឯមកមឧត្តុង្គមានជ័យនៅឆ្នាំ១៦២០គ.ស. ។ ព្រះអង្គបានរៀបអភិសេកនៅឆ្នាំ១៦២០គ.ស. ជាមួយបុត្រីរបស់ព្រះចៅង្វៀងព្រះនាមអង្គចូវ ជាអគ្គមហេសី ដែលមានព្រះនាមថា "សម្តេចព្រះភគវតីព្រះស្រីវរក្សត្រី"។ តាមរាជពង្សាវការខ្មែរថាៈការរៀប អភិសេក ជាមួយព្រះនាងអង្គនេះ គឺជាព្រឹត្តិការណ៍មួយដែលធ្វើឱ្យអ្នកប្រវត្តិសាស្រ្តចងចាំទុកគឺប្រទេសកម្ពុជាបានបាត់ទឹកដីមួយភាគធំដែលជាដីទំនាបប៉ែកខាងត្បូងមិនសូវមានភ្នំទេដីមានជីជាតិអាចប្រកបរបរកសិកម្មបានយ៉ាងល្អ[28]

## ៣.២. រាជធានីឧដុង្គនិងការប្រកួតអំណាចរវាងយួននិងសៀមពីឆ្នាំ ១៦២០-១៦២៩

ចាប់ពីក្រោយសម័យលង្វែកមក វណ្ណៈដឹកនាំសង្គមកម្ពុជា ជួបវិបត្តិជាបន្តបន្ទាប់។ មូលហេតុនៃវិបត្តិគឺការបែកបាក់ផ្ទៃក្នុងផង និងការទទួលឥទ្ធិពលមកពីក្រៅផង។រដ្ឋអំណាចត្រូវស្ថិតក្នុងកណ្តាប់ដៃមន្ត្រីដែលជាគ្រហស្ថ និងយោធា ហើយស្ថាប័នរដ្ឋនានា ត្រូវពង្រឹងពង្រីកជាមួយគ្នានេះដែរ ក៏មានការពង្រឹងព្រំប្រទល់ និងអង្គការគ្រប់គ្រងរដ្ឋតាមរបៀបថ្មី។ ការដណ្តើមរាជ្យសម្បត្តិគ្នារវាងក្រុមញាតិវង្សានុវង្ស តែងកើតឡើងជាញឹកញាប់។ នេះបណ្តាលមកពីពុំទាន់មានគោលការណ៍ច្បាស់លាស់នៅក្នុងកិច្ចបន្តរាជ្យសម្បត្តិ។ មន្ត្រីជាន់ខ្ពស់នៃព្រះបរមរាជវាំង បានទទួលភាពជ្រើសរើសបេក្ខជន ជាអនាគតមហាក្សត្រ(ក្នុងបណ្តាសាច់ញាតិផ្ទាល់របស់អតីតមហាក្សត្រ)។ ទោះជាយ៉ាងដូច្នេះក្តី ក៏បញ្ហារាជបល្ល័ង្កនៅតែដោះស្រាយពុំរួច ហើយទំនាស់រវាងគូបដិបក្ខ ដែលដណ្តើមរាជបល្ល័ង្ក នៅតែកើតឡើងជាបន្តមក ដល់សម័យក្រោយៗមកទៀត។នៅដើមសតវត្សទី១៧ រាជធានីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានលើកមកតាំងនៅឧដុង្គដោយព្រះបាទ ជ័យជេដ្ឋាទី២។ ក្នុងរជ្ជកាលព្រះបាទ ជ័យជេដ្ឋាទី៤(ឆ្នាំ១៦៩១គ.ស-១៦៩៣គ.ស.) មានការពង្រឹងរដ្ឋបាលនិងពង្រឹងការគ្រប់គ្រងលើកសិករ ដោយបានកែប្រែច្បាប់មួយចំនួនធំ។ ការផ្តន្ទាទោសប្រហាជីវិត និងការដាក់ទោសដ៏ឃោរឃៅមួយចំនួនត្រូវបានបដិសេធ ទន្ទឹមនឹងនេះក៏បានបង្កើតច្បាប់ថ្មីមួយចំនួន ដែលពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរខាងសង្គមកិច្ច។ មេឃុំត្រូវបានជ្រើសតាំងឡើង ហើយមានភារជាអ្នកគ្រប់គ្រង និងដឹកនាំកិច្ចការសព្វសារពើនៅក្នុងឃុំ ហើយនៅតាមឃុំ គេបានរក្សាសំណល់របៀបរបបសហគមន៍បុរាណខ្លះៗ ដូចជាការប្រវាស់ដៃគ្នាក្នុងការងារកសិកម្ម។ ដំបូងបង្អស់មេឃុំ ជាអ្នកដោះស្រាយរឿងក្តីក្តាំ ជម្លោះទាស់ទែងគ្នា ពិសេសសហគមន៍លែងបំពេញតួនាទី ជាមូលដ្ឋាននៃរបៀបរស់នៅក្នុងជនបទស្រែចំការទៀតហើយ។ មូលដ្ឋាននៃរបៀបរស់នៅក្នុងស្រុកស្រែ គឺភូមិ។ កសិករមានសិទ្ធិផ្លាស់ប្តូរទីកន្លែង ដើម្បីរកដីសម្រាប់ធ្វើស្រែចំការ ហើយកសិករត្រូវបង់ពន្ធជូនរដ្ឋ។ កសិករត្រូវបំពេញកាតព្វកិច្ចចំពោះ "មេកម្លាំង" នេះជាពួកអ្នកគ្រប់គ្រង គឺជាមេកើយ។ កសិករម្នាក់ៗត្រូវមានមេកើយរៀងៗខ្លួន។ មេកើយរស់នៅក្នុងរាជធានីច្រើនតែជានាម៉ឺនធំៗរបស់រាជាណាចក្រ។ កាលដែលកសិករមាន

[28]-លោក ប៊ុន ធឿន ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ ២០០៦

មេកើយឬមេកម្លាំងនេះ បានធ្វើឱ្យកសិករទៅជាបុគ្គលត្រឹមត្រូវតាមច្បាប់ នៅពេលដែលគេចង់បំពេញកិច្ចការអ្វីមួយក្រៅពីស្រុករបស់គេ។

### ៣.២.១. ការចងសម្ព័ន្ធមេត្រីភាពជាមួយយួន

អ្នកដឹកនាំប្រទេសខ្មែរយើងបានយល់ថាទំនាក់ទំនងខ្មែរ សៀមចាប់តាំងពីសម័យបោះបង់ចោលទីក្រុងអង្គរហូតមកដល់ការបែកបាក់បន្ទាយសង្វែក សៀមតែងតែយកប្រៀបលើខ្មែរតាមរយៈធ្វើសង្គ្រាម និងកាត់ទឹកដីភាគខាងលិចទើបស្រីសុរិយោពណ៌សម្រេច ព្រះទ័យងាកទៅរកសម្ព័ន្ធភាពជាមួយប្រទេសយួនវិញម្តង។នៅឆ្នាំ១៦០១គ.ស ព្រះស្រីសុរិយោពណ៌បានត្រឡប់មកពីសៀម ស្របតាមបំណងប្រាថ្នារបស់ប្រជារាស្ត្រខ្មែរ ដែលបានសុំយាងព្រះអង្គពីទីក្រុងអាយុធ្យា មកតាមប្រកកំពតមកគង់នៅស្លាកែតជិតភូមិកៀនស្វាយសព្វថ្ងៃ ។ ភាពស្ងប់ស្ងាត់ហាក់កើតមានកន្លែងខ្លះនៅក្នុងប្រទេស ប៉ុន្តែមានកន្លែងខ្លះមានចលនាបោះបោរ ធ្វើឱ្យប្រជារាស្ត្រកិតភ័យនៅឡើយ។ ក្រោយពីបង្ក្រាបការបះបោរស្រួលបួលហើយ ព្រះអង្គទ្រង់បញ្ជាឱ្យគេសង់រាជវាំងនៅល្វាឯម ដែលត្រូវនឹងទីតាំងវត្តអរិយក្សត្រសព្វថ្ងៃ ហើយក៏គ្រងរាជ្យនៅទីនោះពីឆ្នាំ១៦០៣គ.ស. រហូតដល់១៦១៣គ.ស ក្នុងព្រះជន្មាយុ ៦០វស្សា។ ទ្រង់ទទួលរាជាភិសេកជាស្តេចផែនដីនៅឆ្នាំ ១៦១៣គ.ស ។ ព្រះស្រីសុរិយោពណ៌មានបុត្រពីរអង្គដែលគង់នៅប្រទេសសៀមនៅឡើយ គឺជ័យជេដ្ឋា និង ឧទ័យ។ នៅឆ្នាំ ១៦០៥គ.ស ជ័យជេដ្ឋា និង ឧទ័យជាអនុជបានបង្ក្រាបមេបះបោរចាមពីរនាក់ ដែលបានត្រួតត្រាខេត្តបាភ្នំ និងដូនណៃ តាំងពីរជ្ជកាលអង្គនន់មកម្ល៉េះ។

ព្រះបាទជ័យជេដ្ឋាទី២ បានសោយរាជ្យនៅរាជវាំងល្វាឯម ក្នុងជន្មាយុ ៣៤ព្រះវស្សា។ ព្រះអង្គមានអគ្គមហេសីនាមចូវជាបុត្រីស្តេចយួន។ នៅឆ្នាំ ១៦២០គ.ស ព្រះអង្គបានលើករាជធានីពីល្វាឯមមកឧដុង្គ។ ព្រះរាជកិច្ចដំបូងគឺ កំណែទម្រង់ច្បាប់ក្នុងប្រព័ន្ធតុលាខ្មែរ ដោយយល់ឃើញថាមានក្រមមួយចំនួនមិនទាន់មានភាពយុត្តិធម៌នៅឡើយ។ ព្រះអង្គបានកែប្រែក្រមបានចំនួន២៤។ ប៉ុន្តែការងារនិងត្រូវបានរំខានដោយសារការឈ្លានពានពីសៀមពីលើក គឺឆ្នាំ១៦២១គ.ស.និង១៦២២គ.ស។ ច្បាប់ដែលបានត្រួតពិនិត្យរួចត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ ១៦២៤គ.ស ក្នុងតុលាការ។ ចាប់តាំងពីរជ្ជកាលព្រះស្រីសុរិយោពណ៌រហូតដល់ជ័យជេដ្ឋាទី២ ពួកសៀមបានធ្វើការសាកល្បង ដើម្បីដាក់ខ្មែរជាចំណុះម្តង ទៀត។ នៅក្នុងឆ្នាំ ១៦២១គ.ស ស្តេចសៀមឈ្មោះសុងថាម បានលើកទ័ពដោយផ្ទាល់ជាពីរផ្នែក មួយផ្នែកចូលតាមខេត្តបាត់ដំបង និង ពោធិ៍សាត់ ប៉ុន្តែត្រូវខ្មែរវាយខ្ចាត់ខ្ចាយរត់ចេញតាមខេត្តចន្ទបុរី មួយផ្នែកទៀតជាទ័ពជើងទឹកចូលមកតាមខេត្តកំពត និងបន្ទាយមាសក្នុងគោលបំណងវាយយកខេត្តទ្រាំង ប៉ុន្តែសៀមត្រូវបរាជ័យម្តងទៀត ដោយសារខ្មែរបំពុលនៅតំបន់មួយចន្លោះភ្នំសែនហាននិងភ្នំម្រោមដោយជាំបាយស្លរម្ជូរសាច់គោហើយដាក់ក្រសាំងពុល ពេលឃើញទ័ពសៀមមកជិតដល់ក៏នាំគ្នារត់គេចចេញបាត់អស់ ពេលពួកសៀមវាស៊ីឆ្អែតហើយពុលពេញពោង ទើបកងទ័ពខ្មែរយើងចូលមកសម្លាប់ពួកវាចោលអស់ហើយក៏បានឮជាប់ឈ្មោះតំបន់នោះថា«ប្រកសៀម»។ មួយឆ្នាំក្រោយមក គឺឆ្នាំ១៦២២គ.ស សៀមបានសាកល្បងលើកទ័ពម្តងទៀត ប៉ុន្តែត្រូវបរាជ័យ។ ចាប់តាំងពីពេលនោះមក រហូតដល់ដំណាច់សតវត្សទី១៧ សៀមពុំបានបញ្ចេញសកម្មភាពគាបសង្កត់មកលើខ្មែរដែលគួរឱ្យកត់សម្គាល់ឡើយ។ ប៉ុន្តែផ្ទុយទៅវិញ ពួកយួនបានចាប់ផ្តើមកកេរយកទឹកដីខ្មែរបន្តិចម្តងៗពីខាងកើត។ ការរៀបអភិសេកជ័យជេដ្ឋាទី២ និងក្សត្រីអង់ចូវ

បានធ្វើឱ្យប្រទេសខ្មែរជាប់ជំពាក់រឿងចម្រូងចម្រាស់យ៉ាងខ្លាំងនៅពេលដែលពួកយួនបានលេបយកទឹកដីចាម្ប៉ាទាំងមូលនៅសតវត្សទី១៧។ នៅឆ្នាំ ១៦២៣គ.ស គណៈបេសកម្មទូតយួន បានលើកសំណើរសុំឱ្យយួនបង្កើតគ្រិះស្ថានជំនួញនៅប៉ែកខាងត្បូងប្រទេសខ្មែរពីខេត្តព្រៃនគរ និង កំពង់ក្របី ព្រមទាំងសុំអនុញ្ញាតឱ្យមានសិទ្ធិកាន់ក្រសួងគយនៅទីនោះផង។ ចំណុចនេះអ្នកប្រវត្តិសាស្ត្របានចាត់ទុកថា ខ្មែរបានចាញ់កលល្បិចបោកបញ្ឆោតរបស់យួនដែលសុំត្រួតពិនិត្យ ពន្ធដារ និងរស់នៅបណ្តោះអាសន្ន។កាលដែលមិនទាន់សោយរាជ្យព្រះជ័យជេដ្ឋាទី២ មានព្រះជន្មាយុ ២៦វស្សាមានបុត្រពីរអង្គ នាមចៅពញាតូ និង ចៅពញានូ ។ លុះសោយរាជ្យបាន២ឆ្នាំព្រះអង្គមានបុត្រនាមចៅពញាចន្ទ និង បុត្រីចន្ទវតី ឬបុប្ផាវតី ឯព្រះឧទ័យរាជា មានបុត្រ៤អង្គ គឺអ្នកអង្គនន់ទី១ អ្នកអង្គសូរ អ្នកអង្គតន់ និង អ្នកអង្គអិម[29]។

### ៣.២.២. វិបត្តិរាជវង្ស

- ព្រះបាទធម្មរាជាទី២ ឬព្រះរាជសំភារ ឬព្រះពញាតូ (១៦២៩គ.ស.-១៦៣៤គ.ស.)

នៅឆ្នាំ ១៦២៩គ.ស. ព្រះចៅពញាតូបានទទួលអភិសេកឡើងគ្រងរាជ្យបល្ល័ង្កដែលបាទទួលព្រះនាមថា "**ព្រះបាទសម្តេចស្តេចព្រះឱង្ការព្រះស្រីធម្មរាជាធិរាជរាមាធិបតី**"នៅរាជធានី "កោះឃ្លោក"ស្រុកខ្សាច់កណ្តាល។ ព្រះអង្គបានប្រគល់បន្ទុកគ្រប់គ្រងរាជសម្បិត្តិឱ្យទៅព្រះបិតុលាគឺព្រះឧទ័យ។រហូតដល់ឆ្នាំ១៦៣០គ.ស. ទើបព្រះអង្គយាងពីកោះឃ្លោគមកបញ្ជាទ័ពទាំងមូល និងគ្រងរាជ្យ។ ព្រះរាជសំភារជាក្សត្រយកព្រះទ័យទុកដាក់ខាងអក្សរសាស្ត្រនិងសាសនា។ ប៉ុន្តែព្រះអង្គពុំបានសោយរាជ្យយូរឆ្នាំទេ ពីព្រោះព្រះអង្គមានទំនាស់រឿងស្នេហាជាមួយព្រះបិតុលាគឺព្រះឧទ័យ។ ព្រះអង្គមានព្រះទ័យប្រតិព័ទ្ធស្នេហ៍ស្និទ្ធឡើងវិញជាមួយគូដណ្តឹងចាស់គឺព្រះនាងបុប្ផាវតី (ដែលជាមហេសីព្រះឧទ័យ)ក្នុងពេលដែលព្រះឧទ័យមានប្រឈួនយ៉ាងទម្ងន់។ លុះដល់ព្រះឧទ័យជាសះស្បើយវិញព្រះអង្គទាំងពីរទ្រង់ភិតភ័យហើយយាងគេចទៅគង់នៅកោះឃ្លោក។រឿងអាស្រូវនេះបានឮសុះសាយដល់ប្រជារាស្ត្រ ដោយមានការអុចអាលពីមន្ត្រីខ្លះព្រះឧទ័យទ្រង់ពិរោធហើយបាន លើកទ័ពមួយកងទៅវាយកោះឃ្លោក រីឯព្រះរាជសំភារក៏បានកេណ្ឌទ័ពមួយកងដែរ ចេញច្បាំងតទល់ជាមួយព្រះឧទ័យ។ ក្នុងការប្រយុទ្ធព្រះរាជសំភារទទួលបរាជ័យហើយត្រូវបាន ជនជាតិ ព័រទុយកាល់ បាញ់ព្រះអង្គធ្លាក់ពីលើចុងត្នោតសុគតទៅ។ ដូច្នេះព្រះពញាតូនេះគ្មានបានគ្រប់គ្រងប្រទេសឱ្យបានត្រឹមត្រូវទេទាំងទៅច្បាំងយកខេត្តនគរាជ (ត្រាត)ពីសៀមវិញក៏មិនបានជោគជ័យបានត្រឹមតែកៀរយកគ្រួសារខ្មែរជាច្រើន មកដាក់ក្នុងខេត្តសៀមរាបប៉ុណ្ណោះ។មិនតែប៉ុណ្ណោះព្រះអង្គរវល់តែជាប់ព្រះទ័យស្រាវជ្រាវអក្សរសាស្ត្រប្រវត្តិសាស្ត្រ សាសនា ទ្រង់បានបង្កើតស្នាដៃទុកជាកេរ្តិ៍ដំណែលមួយចំនួនសម្រាប់អ្នកជំនាន់ក្រោយ។

### ៣.២.៣. ព្រះអង្គសូរឬព្រះបរមរាជាអង្គសូរ (១៦៥៨គ.ស.-១៦៧២គ.ស.)

ទៅពឹងពាក់យួនដោយសារតែព្រះអង្គសូរនិងព្រះអង្គតន់ចង់សងសឹកទើបទៅពឹងយួន ការនេះធ្វើឱ្យ មេទ័ពយួនចង់ត្របាក់យក ប្រទេសកម្ពុជាដាក់ធ្វើជាចំណុះអាណ្ណាម។ ពេលនោះធ្វើឱ្យ មានចម្បាំងជាមួយយួន តែពួកយួនទទួលបរាជ័យ។ បន្ទាប់មក ព្រះអង្គសូរ បានប្រារព្ធពិធីអភិសេកឡើង សោយរាជ្យដោយមានព្រះនាមសម្រាប់រាជ្យថា "**សម្តេចព្រះបរមរាជាធិរាជរាមាធិបតី**"។ នៅឆ្នាំ១៦៧២គ.ស.

[29] -ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ

ព្រះរាជាអង្គសូរទ្រង់សព្វព្រះទ័យផ្សំផ្គុំបុត្រី ព្រះអង្គនាមអង្គស្រីធីតាជាមួយនិងក្មួយព្រះអង្គស្រីជ័យជេដ្ឋ (ជាបុត្រព្រះបាទបុមរាជា)។ប៉ុន្តែជាអកុសលប៉ុន្មានខែក្រោយមកបុត្រប្រសារបាន ធ្វើគតព្រះអង្គដើម្បីដណ្តើមរាជសម្បត្តិ។

### ៣.២.៤. ព្រះបាទជ័យជេដ្ឋាទី៣អង្គស៊ូរជ្ជកាលទី១

ព្រះអង្គស៊ូដែលទើបមានព្រះជន្ម១៦វស្សា បានឡើងគ្រងរាជ្យស្នងព្រះរៀមនៅឧត្តុង្គដោយមានព្រះនាមថា"ស្តេចព្រះជ័យជេដ្ឋា"។ក្នុងរជ្ជកាលនេះគឺមានចម្បាំងរវាងសាច់សាលោហិតគ្នាឯង គឺនៅឆ្នាំ១៦៨២គ.ស.ព្រះអង្គនន់ដែលបានភៀសព្រះអង្គទៅយួននោះ ទ្រង់បានប្រម៉ែរប្រមូលពួកចិនចំនួលថ្មីនៅដូណៃ -យ៉ាឌិញ ផ្សំជាមួយទ័ពយួនខ្លះ ទៅវាយជ័យជេដ្ឋាទី៣ អង្គស៊ូទៀត។ ក៏ប៉ុន្តែត្រូវបរាជ័យហើយទ័ពចិនក៏ថយទៅនៅកោះទាំងអស់។ ប៉ុន្តែពួកនោះបានចាប់ មាតារបស់ទ្រង់ យកទៅឃុំនៅជ្រោយចង្វារក្រោយមកបានពញាហុកទៅរំដោះមកវិញ។ នៅឆ្នាំ ១៦៨៨នៃ គ.ស ទ្រង់ប្រឈួនដោយជំងឺពិសក្តៅ(ឯកសារខ្លះថាជំងឺអុតធំ)ក៏បានប្រគល់រាជសម្បត្តិថ្វាយព្រះមាតាគឺអ្នកម្នាងទែ។ ៣ខែក្រោយទ្រង់ជាសះស្បើយ ហើយឡើងសោយរាជ្យវិញ។

### ៣.២.៥. ព្រះបាទជ័យជេដ្ឋាទី៣អង្គស៊ូរជ្ជកាលទី៣

ព្រះអង្គឡើងសោយរាជ្យវិញក្រោយពីព្រះភាគិនេយ្យ(ចូលទីវង្គត)។ ក្នុងរជ្ជកាលនោះ ព្រះអង្គបានធ្វើ ចម្បាំង ជាមួយ យួនដោយវាយរុញច្រានទ័ពយួនឱ្យថយពីស្រុកខ្មែរតាមទន្លេមេគង្គ ប៉ុន្តែវាពុំព្រមត្រឡប់ទៅស្រុកទេ បែរជាក្រាញនៅក្នុងដីខ្មែរត្រង់ ព្រៃនគរ កំពង់ស្រការត្រី បារាំដែលលោកឧកញ៉ានរិន្ទអិម(មន្ត្រីក្បត់រត់ទៅចុះចូលយួន) បានសន្យាថា ជាថ្នូរនិងជំនួយទ័ពសម្រាប់លោកវាយនិងជាតិឯងនោះ។ ចាប់ពីពេលនោះមកស្តេចហៀនតុង បានបញ្ជារឱ្យលោកង្វៀងហ៊ីវគីញ ចូលមករៀបចំទឹកដីរបស់ខ្មែរដែលយួនទើបយក ជាកម្មសិទ្ធិរបស់គេនោះ។ ដោយយកស្រុក ដូនណៃ បង្កើតជាស្រុកភៀងឡុង យកដីព្រៃនគរ បង្កើតជាស្រុក តឹងប៊ិញ យកដី បៀងវ៉ា បង្កើតជាបន្ទាយ កឿងត្រឹង។ រួចស្តេចយួនបានប្រមែរប្រមូលរាស្ត្រពីក្វាងប៊ិញឱ្យមករស់នៅលើទឹក ដីថ្មីបង្កើតជា ភូមិ ស្រុកបន្ថែមទៀត។ ពេលនោះជនជាតិចិនក៏មានចំនួនច្រើន យួនក៏បង្កើតភូមិស្រុកឱ្យពួកនោះហើយធ្វើនយោបាយសមានកម្ម គឺជនជាតិចិនដែលនៅត្រង់ដី ត្រឹង បៀន និង កឿងត្រឹងតម្រូវឱ្យចូលសញ្ជាតិយួនទាំងអស់។ នៅពេលនោះគឺមន្ត្រីយួនទាំងអស់ដែលមកឈរនៅត្រង់តំបន់ខាងលើនោះត្រូវឡើងទៅ មេទ័ពម្នាក់ដែលកាន់កាប់អំណាចខាងយោធាផង និងអំណាចខាងរដ្ឋបាលផង ដែលមានទីបញ្ជាការដ្ឋានតាំងនៅ ព្រៃនគរ។ ចំណែកឯដីខ្មែរនៅត្រង់មេសរ យួនបានដាក់អំណាចត្រួតត្រា តែស្ថិតនៅក្រៅផ្លូវការនៅឡើយទេ។ នៅឆ្នាំ១៦៩៩គ.ស. ព្រះជ័យជេដ្ឋាទី៣ទ្រង់បានបង្វែររាជសម្បត្តិទៅឱ្យព្រះ កែវហ្វ៉ាអង្គអិមជារាជបុត្រសន្និសារ ដែលទ្រង់ បានច្បាំងឈ្នះយួន ហើយចាប់បានទាំងឧកញ៉ានរិន្ទអិមទៀត។

### ៣.២.៦. ព្រះសត្ថាទី២អង្គជីរជ្ជកាលទី២

ព្រះអង្គបានប្រគល់ខេត្តមេសរ និងលង់ហោរឱ្យទៅយួនព្រះសត្ថាទ្រង់ទទួលរាជសម្បត្តិ ពីព្រះបិតាម្តងទៀតក្នុងព្រះជន្ម ២៧ វស្សាហើយមាននាមសម្រាប់រាជ្យថា" ព្រះបាទសម្តេចស្តេចព្រះរាជាឱង្ការព្រះបរមរាជាធិរាជរាមាធិបតី" និងតែងតាំងព្រះបិតាជាមហាឧភយោរាជ។ នៅឆ្នាំ១៧៣០គ.ស នៅតំបន់

ប្រសូតខេត្តស្វាយទាប(ស្វាយរៀង)មានពួកលាវតាំងខ្លួនជាអ្នកមានបុណ្យធម្មិជនប្រមូលបក្សពួកមានទាំងខ្មែរជាច្រើនផង លើកទ័ពវាយយួន ព្រះអង្គទ្រង់បញ្ជាឱ្យគេលើកទ័ពទៅបង្ក្រាបពួកបះបោររហូតដល់បាក់ទ័ពត្រឡប់មកស្រុកភូមិវិញ។ ប៉ុន្តែពួកគេកាប់សម្លាប់យួន ទាំងឡាយដែលបានជួបនៅតាមផ្លូវ។ ព្រះសត្ថាទី២ ទ្រង់ជ្រាបរឿងនេះក៏ទ្រង់ចាត់ឧកញ៉ាចក្រីអ៊ុកនាំទ័ពទៅ បង្ក្រាបពួកលាវបះបោរនោះទៀត។

នៅឆ្នាំ ១៧៣១គ.ស ស្តេចយួនឆក់ឱកាសពេលស្រុកខ្មែរមានការរំជើបរំជួលបញ្ជារឱ្យលើកទ័ពមកសងសឹកខ្មែរហើយបានវាយរុញច្រានទ័ពខ្មែររហូតដល់ភ្នំពេញ។ព្រះសត្ថាទី២ ទ្រង់ដកថយទៅនៅ**ពាមក្រែង**(ស្រីសឈរ)សិន។ ក្រោយពីនៅព្រះអង្គ និងរាជវង្សានុវង្សយាងទៅគង់នៅលង្វែកវិញ។ ព្រះសត្ថាទី២ ភ័យខ្លាចព្រះកាយមានកំហុសទ្រង់ក៏បានថយ ទៅសឹងបួហើយផ្ញើសារលិខិតទៅមេទ័ពយួនដោយថាសុំពន្យាពេលដើម្បីព្រះអង្គបង្ក្រាជនបះបោរ។ ប៉ុន្តែពួកបះបោរនៅតែបន្តសកម្មភាពសម្លាប់យួនដដែល។មេទ័ពយួនឈ្មោះទ្រឿង គៀកវិញ បានបន្ទោសព្រះសត្ថាថាចូលដៃនិងពួកបះបោរ។ ព្រះអង្គកិតភ័យខ្លាំងទ្រង់បញ្ជា ឱ្យយកវត្ថុមានតម្លៃ ទៅសូកប៉ាន់ដើម្បីទុកពេលឱ្យព្រះអង្គ បង្ក្រាបពួកបះបោរ។ ទ័ពយួនវាយលុកចូលដល់លង្វែកព្រះសត្ថាទ្រង់ ប្រើឧបាយកលសម្លាប់បានពួកលាវដែលបះបោរ រួចចេញសារភាពទទួលទោសនៅចំពោះមុខទ័ពយួន។ ពេលនោះទ័ពយួនក៏ដកថយវិញអស់ទៅ។ស្តេចយួននាមទុកតុង តម្រូវឱ្យព្រះសត្ថាប្រគល់ខេត្ត ២ គឺ ខេត្តមេសរ និង ខេត្តលង់ហោរឱ្យនៅឆ្នាំ ១៧៣២គ.ស.ដោយយកលេសថា មានជនជាតិយួនបានមក រស់នៅជាច្រើននៅត្រង់តំបន់នោះហើយ។ដូច្នេះជនជាតិយួនបានចូលដល់ ទន្លេមេគង្គ ហើយបន្តដំណើរសម្រុកមកទិសខាងត្បូងទៀត។ ដោយសារព្រះអង្គស្ងួន និងអង្គច័ន្ទ (បុត្ររបស់ព្រះធម្មរាជាទី៣) ដែលភៀសទៅសៀម។ កាលគង់នៅក្រុង អយុធ្យាមានបុត្រាពីរអង្គគឺ អង្គហ៊ីង និង អង្គឌួង ព្រមទាំងបុត្រីនាម អង្គសោភាក្សត្រី ជាមួយអ្នកម្នាងសៀម ឈ្មោះ**ម៉មរ៉ត** បានប្រមូលប្រជារាស្ត្រនៅលង្វែកមកប្រយុទ្ធជាមួយព្រះអង្គនៅភ្នំពេញ។ពេលនោះព្រះស្រីសុជាតា(មហេ សីព្រះសត្ថា) អ្នកផ្តើមរំពុកព្រះស្វាមីនោះទ្រង់បានចាត់ឱ្យទាក់ទងចរចារ ជាមួយក្សត្រដែលទើបនឹងយាងត្រឡប់ពីសៀមក្សត្រទាំងអស់ទ្រង់ព្រមព្រៀងថ្វាយរាជសម្បត្តិទៅព្រះធម្មរាជាទី៣នៅឆ្នាំ១៧៣៨គ.ស.។

### ៣.២.៧. ព្រះសត្ថាទី២អង្គជីវរជ្ជកាលទី៣(១៧៤៩គ.ស)

មេទ័ពយួនជាអ្នកកាន់កាប់អំណាចនៅក្នុងរាជ្យព្រះបាទសត្ថាពេលនោះគឺ មេទ័ពយួនជាអ្នកកាន់អំណាចស្ទើរតែទាំងអស់ អំណាច ហូតពន្ធដារ អំណាចផ្លាស់ប្តូរចៅហ្វាយស្រុកខ្មែរ និង យកច្បាប់ក្រុងវ៉េមកអនុវត្តលើស្រុកខ្មែរថែមទៀត។ ការក្តាប់អំណាចយួនលើទឹកដីខ្មែរនេះធ្វើឱ្យមន្ត្រីរាជការ និងប្រជារាស្ត្រក្តៅក្រហាយ បានជុំរុញឱកាសឱ្យ លោកឧកញ៉ា ក្រឡាហោមឌីក និងឧកញ៉ាសួគ៌ា បញ្ចុះបញ្ចូលចៅហ្វាយស្រុកនៅខេត្ត មហានគរ កំពង់ស្វាយ សៀមរាបកេណ្ឌទ័ព និងលើកទ័ពចូលមកតាមទិសខាងជើង។ ចំណែកឧកញ៉ាទាំងពីរ និង លោកចៅហ្វាយ ស្រុកខេត្ត បាត់ដំបង ពោធិសាត់ នាំចូលពីខាងលិច។ ទ័ពយួនរបស់ព្រះសត្ថានិងទ័ពខ្មែរជួបគ្នានៅខេត្តលោវៀ ក៏ប្រយុទ្ធគ្នា តែមិនមានឈ្នះចាញ់ យួនស្នើសុំទ័ពជំនួយ ពីព្រះសត្ថាទី២ ទ្រង់ភៀសខ្លួនទៅយួនវិញ ដោយព្រះអង្គទោមនស្សតូចព្រះទ័យយ៉ាងខ្លាំង ក៏ប្រឈួនហើយសុគតនៅកណ្តាលផ្លូវក្នុងព្រះជន្ម៤៦វស្សា[30]។

[30] -លោក ប៊ុន ធឿន ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ ២០០៦

### ៣.២.៨. ព្រះរាមាធិបតីទី៣អង្គទង

រជ្ជកាលទី២(១៧៥៦គ.ស.-១៧៥៧គ.ស)បានលះបង់ខេត្តផ្សាដែកនិងមាត់ជ្រូកឱ្យយួនរស់នៅ ព្រះអង្គទងទ្រង់ត្រូវបានមន្ត្រីសេនាបតី បាគូព្រាហ្មណ៍បុរោហិតជំនុំថ្វាយរាជ្យ ដល់ព្រះអង្គនៅ ឆ្នាំ ១៧៥៦ គ.ស. ក្រោយពីព្រះបាទ ស្រីជ័យជេដ្ឋអង្គស្ងួនទ្រង់សោយទីវង្គតនៅឆ្នាំ១៧៥៥គ.ស។ ក្នុងរាជ្យនេះកើតមានវិវាទមួយយ៉ាងធំរវាងព្រះអង្គហ៊ីង និង ព្រះអង្គតន់(ឧទ័យរាជា)ដែលព្រះអង្គទងទ្រង់ពុំបានជ្រាបជាមុន ពេលយប់មួយព្រះអង្គហ៊ីងបានចាត់ឱ្យ សេនាទាហានចូលលបវាយលុក ព្រះអង្គតន់(ឧទ័យរាជា) ក្នុងដំណាក់ ។ ប៉ុន្តែព្រះអង្គ ទ្រង់គេចចេញពីដំណាក់បាន ហើយមានមន្ត្រីជិតជិត ២នាក់នាំព្រះអង្គចេញពី ឧត្តុង្គទៅខេត្តពាម។ បន្ទាប់មកមានមន្ត្រីរាជការ មួយចំនួននាំគ្នារត់ពីឧត្តុង្គទៅតាមព្រះអង្គតន់ លុះយាងដល់ខេត្ត ពាម ហើយព្រះអង្គតន់ទ្រង់ពិភាក្សាកិច្ចការផែនដីជាមួយព្រះសុទាត់ជាបិតាធម៌(ព្រះសុទាត់មាននាមដើម ម៉ាក គុង ជាកូនរបស់ ម៉ា គីវ ឈ្មួញដែលត្រូវតែងតាំងជាសម្ដេចរាជាត្រួតតំបន់ឆ្នេរសមុទ្រ។ ព្រះសុទាត់បានចាត់ឱ្យ ឧកញ៉ាឡាំ ឧកញ៉ាជូ ឧកញ៉ាយស ទៅបញ្ចុះបញ្ចូលរាស្ត្រនៅខេត្ត ទ្រាំង កំពត បន្ទាយមាស បាទី ព្រៃកប្បាស កេណ្ឌបានជាទ័ព ហើយលើកចេញមកតតាំងនឹង ទ័ពព្រះអង្គ ហ៊ីង នៅទីក្រុងឧត្តុង្គមានជ័យតាមជើងគោក។ ចំណែកព្រះអង្គតន់បានដក កងយោធាចេញពីខេត្តពាម ឆ្ពោះមក ភ្នំពេញ ដោយកេណ្ឌទ័ពបណ្ដើរៗទ័ពព្រះអង្គហ៊ីងទន់ដៃបរាជ័យបែក ខ្ចាត់ខ្ចាយហើយព្រះអង្គតន់ទ្រង់ចាត់ឱ្យគេ តាមចាប់ព្រះអង្គហ៊ីង យកមកកាត់ទោសប្រហារជីវិតនៅក្នុងវត្តប្រកក្ការ។ ពីរខែក្រោយមក ព្រះក្សត្រីដែលជា ព្រះទេពីរបស់ព្រះអង្គហ៊ីងកើតមានគំនុំ និងព្រះអង្គតន់ហើយទ្រង់ប្រមូលមន្ត្រីរាជាដែលជិតជិត ដើម្បីគិតលបលួច ធ្វើគតព្រះអង្គតន់។ ព្រះអង្គទ្រង់ជ្រាបទាន់ ក៏នាំសេនាភៀសចេញមកកោះស្លាកែត។ក្រោយមកទ្រង់ជ្រាបថាទ័ពព្រះក្សត្រី និង ព្រះរាជវង្សានុវង្សចេញពីឧដុង្គ នៅខេត្តពោធិសាត់។ ព្រះអង្គតន់ទ្រង់លើកទ័ពចូលឧដុង្គ ហើយបញ្ជារឱ្យចៅហ្វ៊ាអង្គ អួងលើកទ័ពដេញតាមចាប់ក្សត្រដែលភៀសខ្លួន យកមកប្រហារជីវិតលើកលែងតែព្រះអយ្យកោអង្គទងចំណែក អង្គនន់ត្រូវបានឧកញ៉ាប៉ានជួយយកអាសារពង្រត់យកទៅដល់ស្រុកសៀម។ ដោយសារតែមាន វិបត្តិក្នុង រាជវង្សានុវង្ស យួនបានឆ្លៀតបង្កើតចលនាដោយធ្វើការគាបសង្កត់មកលើរាជការខ្មែរនៅក្នុងខេត្ត ទ្រាំង បន្ទាយមាស និងព្រៃកប្បាស។ ដើម្បីដោះស្រាយរំងាប់ចលាចលនេះ ព្រះអង្គទងទ្រង់បានយល់ព្រមលះបង់ឱ្យយួនតាំងនៅក្នុងខេត្ត ផ្សាដែក និងខេត្ត មាត់ជ្រូក នៅឆ្នាំ១៧៥៧គ.ស.មុនព្រះអង្គសុគត។

### ៣.២.៩. ព្រះបាទឧទ័យអង្គតន់(ព្រះឧទ័យរាជាទី២)(១៧៥៨.-១៧៧៥គ.ស.)

នៅឆ្នាំ១៧៥៨គ.ស.ស្ថិតក្រោមអំណាចគ្រប់គ្រងយួនដើម្បីសងគុណចំពោះជំនួយផ្សេងៗ ដែលយួនបានគាំទ្រក្នុងជម្លោះរវាងរាជវង្សានុវង្ស ខ្មែរកន្លងមក និងដើម្បីភាពសុខសាន្តជាមួយយួនព្រះអង្គ ទ្រង់លើកខេត្តខ្មែរមួយចំនួន ពីខេត្តព្រះត្រពាំង និងខេត្តឃ្លាំង ដែលជា ខេត្តពីរចុងក្រោយបង្អស់របស់កម្ពុជាក្រោមឱ្យយួនតាំងនៅ។ នៅឆ្នាំ ១៧៦៨គ.ស ព្រះចៅតាក់ស៊ីន ទ្រង់ចាត់រាជទូត នាំសារមកថ្វាយព្រះអង្គតន់ដើម្បីឱ្យលើកសួយសារអាករ ទៅថ្វាយស្ដេចសៀមជាមេត្រីភាព។ ព្រះអង្គតន់ទ្រង់មិនព្រម ទទួលស្គាល់ថា ជាក្សត្រម្ចាស់ផែនដី ពីព្រោះព្រះចៅតាក់ស៊ីនមិនមែនជារជ្ជក្សត្រ។ ព្រះចៅតាក់ស៊ីនទ្រង់ពិរោធ

ខ្លាំងហើយទ្រង់បញ្ជាឱ្យពញាអភ័យរណេរិទ្ធិដួង ហើយនិនពញាអនុជិតរាជាប៊ុនម៉ា លើកទ័ពមកដល់នគរវត្តក្នុងបំណងនាំព្រះអង្គនន់ឱ្យឡើងសោយរាជ្យនៅកម្ពុជា។

នៅឆ្នាំ ១៧៧០គ.ស. ព្រះចៅតាក់ស៊ីន ទ្រង់ប្រឹក្សាជាមួយមន្ត្រីសេនាបតី ដើម្បីនាំយកព្រះរាជវង្សានុវង្ស ព្រមទាំងព្រះអង្គ ចុលជា ស៊ីសាំង(បុត្រព្រះចៅ ដកមះដឿ)ភៀសនៅស្រុកយួននិងសុំជំនួយទ័ពពីព្រះចៅអាណ្ណាម។ ព្រះចៅតាក់ស៊ីន រៀបចំឱ្យអង្គនន់គង់នៅរាជធានី ឧត្តុង្គគ្រប់គ្រងនគរ ខ្មែរដោយទុកទ័ព៥០០នាក់តាមរក្សាព្រះអង្គនន់។ ព្រះចៅតាកស៊ីនចាត់មន្ត្រីសៀមជាចៅហ្វាយខេត្តពាម ត្រួតខេត្តកំពត ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តពោធិសាត់ និង ខេត្ត បាភ្នំ។ ព្រះចៅអាណ្ណាមបានបញ្ជូនទ័ពជំនួយ លើកជាក្បួនឡើងមករួមនិងទ័ពខ្មែរប្រយុទ្ធតតាំងនិងសៀម ហើយសៀមបានដកថយអស់ទៅខេត្តពាម ចំណែក អង្គនន់ ទ្រង់ភៀសខ្លួនទៅគង់នៅខេត្តកំពត។ លុះថមថយអស់ ព្រះអង្គតន់យាងត្រឡប់ពីយួនមកសោយរាជ្យវិញ តែទ្រង់យាងនៅគង់នៅ ព្រែកមាត់កណ្តុរ។ ឯរាជការយួនក៏បញ្ជូនមន្ត្រីជាន់ខ្ពស់ម្នាក់មកនៅថែរក្សា ចាំជួយសម្រេចកិច្ចការ ផែនដីឱ្យព្រះរាជាខ្មែរ។ ដោយមើលឃើញប្រជារាស្ត្រខ្មែរវេទនាខ្លោចផ្សាណាស់ ស្លាប់ក្នុងចម្បាំង ស្លាប់និងជំងឺអាសន្នរោគ  ដោយជាច់ពោះអស់ស្បៀង ទុរ្ភិក្សផង ព្រាត់ប្រាស់និរាសកូនចៅផង។ឆ្នាំ១៧៧២គ.ស. ព្រះឧទ័យរាជាទី២ អង្គតន់ បញ្ជាឱ្យ ព្រះកែវហ្វ៉ាអង្គដួង ទៅចរចារចងស្ពានមេត្រីជាមួយព្រះចៅតាកស៊ីន តែព្រះចៅតាកស៊ីនមិនជឿបានបញ្ជា ឱ្យចាប់ឃុំឃាំងក្រោយមកព្រះអង្គដួងសុំអនុញ្ញាតឱ្យមាតា ភរិយា និងបុត្រចូលទៅដល់ក្រុងអាយុធ្យា ទើបព្រះចៅតាកស៊ីន ជឿថាស្មោះត្រង់ពិតក៏ឱ្យលើកលែងទោស។

នៅ ឆ្នាំ១៧៧៣គ.ស. អ្នកម្នាងដែរបស់ព្រះអង្គតន់ប្រសូតបុត្រានាមអង្គអេង។ នៅឆ្នាំ១៧៧៤គ.ស. ព្រះឧទ័យរាជា អង្គតន់បានយាងទៅគង់នៅកោះចិន ហើយឱ្យទ័ពយួនថយទៅស្រុកវិញ។ បន្ទាប់មកព្រះអង្គយាងត្រឡប់ចូលរាជធានីឧត្តុង្គវិញ សម្រេចព្រះទ័យដាក់រាជ្យថ្វាយទៅអង្គនន់ នៅឆ្នាំ ១៧៧៥គ.ស. ដើម្បីចៀសវាងការបង្ហូរឈាមគ្នាឯងតទៅទៀត ប៉ុន្តែព្រះអង្គទ្រង់ស្ថិតនៅជាមហាឧភយោរាជ។

| ព្រះរាជាសោយរាជ្យនៅសម័យឧដុង្គ(១៦២០គ.ស.-១៨៦៣គ.ស.) | | | |
|---|---|---|---|
| លេខរៀង | ព្រះនាមសម្រាប់រាជ្យ | ព្រះនាមផ្ទាល់ | រជ្ជកាល នៃ គ.ស. |
| ០១ | ជ័យជេដ្ឋាទី២ | ជ័យជេដ្ឋា | ១៦១៩-១៦២៧ |
| ០២ | ឧទ័យរាជាទី១ | ឧទ័យ | ១៦២៧-១៦៤២ |
| ០៣ | ធម្មរាជាទី២ រឺ រាជសំភារ | ពញាតូ | ១៦២៧-១៦៣២ |
| ០៤ | អង្គទងរាជា | ពញានូរ | ១៦៣២-១៦៤០ |
| ០៥ | បទុមរាជាទី១ | អង្គនន់ទី១ | ១៦៤០-១៦៤២ |
| ០៦ | រាមាធិបតីទី២ | ពញាចន្ទរឺអង្គចន្ទទី២ | ១៦៤២-១៦៥៨ |
| ០៧ | បរមរាជាទី៨ | អង្គសូរទី១ | ១៦៥៩-១៦៧២ |
| ០៨ | រាមាធិបតីទី៣ | អង្គតន់ទី១ | ១៦៦៤-១៦៧៤ |
| ០៨ | បទុមរាជាទី២ | ស្រីជ័យជេដ្ឋទី១ | ១៦៧២-១៦៧៣ |

| | | | |
|---|---|---|---|
| ១០ | កែវហ្វាទី២ | អង្គជីទី១ | ១៦៧៣-១៦៧៧ |
| ១១ | បទុមរាជាទី៣ | អង្គនន់ទី២ | ១៦៧៤-១៦៩១ |
| ១២[១] | ជ័យជេដ្ឋាទី៣ (រាជ្យទី១) | អង្គសូរទី២ | ១៦៧៧-១៦៩៥ |
| ១៣ | អ្នកម្នាងទៃ | ទៃ | ១៦៨៨ (៣ខែ) |
| ១៤ | រាមាធិបតីទី៤ | អង្គយ៉ង | ១៦៩៥-១៦៩៦ |
| ១៥[២] | ជ័យជេដ្ឋាទី៣ (រាជ្យទី២) | អង្គសូរទី២ | ១៦៩៦-១៧០០ |
| ១៦[១] | កែវហ្វាទី៣ (រាជ្យទី១) | អង្គឥមទី១ | ១៧០០-១៧០១ |
| ១៧[៣] | ជ័យជេដ្ឋាទី៣ (រាជ្យទី៣) | អង្គសូរទី២ | ១៧០១-១៧០២ |
| ១៨[១] | ធម្មរាជាទី៣ (រាជ្យទី១) | ជ័យជេដ្ឋាទី៤ | ១៧០២-១៧០៤ |
| ១៩[៤] | ជ័យជេដ្ឋាទី៣ (រាជ្យទី៤) | អង្គសូរទី២ | ១៧០៤-១៧០៧ |
| ២០[២] | ធម្មរាជាទី៣ (រាជ្យទី២) | ជ័យជេដ្ឋាទី៤ | ១៧០៧-១៧១៤ |
| ២១[២] | កែវហ្វាទី៣ (រាជ្យទី២) | អង្គឥមទី១ | ១៧១៤-១៧២២ |
| ២២ | សត្ថាទី២ (រាជ្យទី១) | អង្គជីទី២ | ១៧២២-១៧២៩ |
| ២៣[១] | កែវហ្វាទី៣ (រាជ្យទី៣) | អង្គឥមទី១ | ១៧២៩ (៧ខែ) |
| ២៤ | បរមរាជាទី១០ (រាជ្យទី២) | អង្គជីទី២ | ១៧២៩-១៧៣៨ |
| ២៥[៣] | ធម្មរាជាទី៣ (រាជ្យទី៣) | ជ័យជេដ្ឋាទី៤ | ១៧៣៨-១៧៤៧ |
| ២៦ | ស្រីធម្មរាជា | អង្គឥមទី២ | ១៧៤៧-១៧៤៨ |
| ២៧[១] | រាមាធិបតីទី៥ (រាជ្យទី១) | អង្គទង | ១៧៤៨-១៧៤៩ |
| ២៨ | ស្រីជ័យជេដ្ឋទី២ | អង្គស្ងួន | ១៧៤៩-១៧៥៥ |
| ២៩[២] | រាមាធិបតីទី៥ (រាជ្យទី២) | អង្គទង | ១៧៥៦-១៧៥៧ |
| ៣០ | នារាយណ៍រាជាទី២ | ឧទ័យរាជាទី២ រឺ អង្គតន់ទី២ | ១៧៥៨-១៧៧៥ |
| ៣១ | រាមាធិបតីទី៦ | អង្គនន់ទី៣ | ១៧៧៥-១៧៧៩ |
| ៣២ | នារាយណ៍រាជាទី៣ | អង្គអេង | ១៧៧៩-១៧៩៦ |
| | អន្តររជ្ជកាល: ១៧៩៦-១៨០៥ | | |
| ៣៣ | ចៅហ្វាប៉ុក | | ១៧៩៦-១៨០៥ |
| ៣៤ | ឧទ័យរាជាទី៣ | អង្គចន្ទទី៣ រឺ ឧទ័យរាជា | ១៨០៦-១៨៣៤ |
| ៣៥ | អង្គម៉ី | អង្គម៉ី | ១៨៣៤-១៨៤៧ |
| ៣៦ | ហរិរក្សរាមាឥស្សរាធិបតី | អង្គឌួង | ១៨៤៨-១៨៦០ |

**សំគាល់៖**

- ជ័យជេដ្ឋាទី២ សោយរាជ្យចាប់ពីឆ្នាំ១៦១៨គ.ស. ដល់ ឆ្នាំ១៦២៨គ.ស.
- ឧទ័យ សោយរាជ្យចាប់ពីឆ្នាំ១៦២៨គ.ស. ដល់ ឆ្នាំ១៦២៩គ.ស.
- ធម្មរាជាទី២ ឬពញាតូ ឬព្រះរាជសម្ភារចៅពញាតូ សោយរាជ្យចាប់ពីឆ្នាំ១៦២៨ដល់ ឆ្នាំ១៦៣៤
- អង្គទងរាជឬចៅពញានូ សោយរាជ្យចាប់ពីឆ្នាំ១៦៣៥គ.ស. ដល់ ឆ្នាំ១៦៣៩គ.ស.
- អង្គនន់ សោយរាជ្យចាប់ពីឆ្នាំ១៦៣៩គ.គ.ស.
- រាមាធិបតីទី១ សោយរាជ្យចាប់ពីឆ្នាំ១៦៤២គ.ស. ដល់ ឆ្នាំ១៦៥៩គ.ស.
- ព្រះអង្គសូរ សោយរាជ្យចាប់ពីឆ្នាំ១៦៥៩គ.ស. ដល់ ឆ្នាំ១៦៧២គ.ស.
- ស្រីជ័យជេដ្ឋា សោយរាជ្យចាប់ពីឆ្នាំ១៦៧២គ.ស. ដល់ ឆ្នាំ១៦៧៣គ.ស.
- កែវហ្វាទី២ រឺអង្គជី សោយរាជ្យចាប់ពីឆ្នាំ១៦៧៣គ.ស. ដល់ ឆ្នាំ១៦៧៥គ.ស.
- ជ័យជេដ្ឋាទី៣ សោយរាជ្យចាប់ពីឆ្នាំ១៦៧៥គ.ស-១៦៨៨គ.ស ១៦៨៨គ.ស -១៦៩៥ គ.ស ១៦៩៦គ.ស -ឆ្នាំ១៦៩៩គ.ស  ១៧០០គ.ស-១៧០២គ.ស ១៧០៣-១៧០៦
- នរាយណ៍រាមាធិបតីទី២ ឧទ័យរាជាអង្គយ៉ង សោយរាជ្យចាប់ពីឆ្នាំ១៦៩៥ ដល់ ឆ្នាំ១៦៩៦គ.ស
- អង្គអិម សោយរាជ្យចាប់ពីឆ្នាំ១៦៩៩គ.ស -១៧០០គ.ស  ឆ្នាំ១៧១០គ.ស -១៧២២គ.ស.
- ធម្មរាជាទី៣ សោយរាជ្យចាប់ពីឆ្នាំ១៧០២គ.ស -១៧០៣គ.ស ១៧០៦គ.ស-១៧០៩គ.ស. ១៧៣៨គ.ស-១៧៤៧គ.ស.
- សត្ថាទី២ សោយរាជ្យចាប់ពីឆ្នាំ ១៧២២គ.ស-១៧២៩គ.ស ១៧៣៧គ.ស -១៧៣៩គ.ស
- ធម្មរាជាទី៤ សោយរាជ្យចាប់ពីឆ្នាំ១៧៤៧គ.ស
- អង្គស្ងួន សោយរាជ្យចាប់ពីឆ្នាំ១៧៤៩គ.ស. ដល់ ឆ្នាំ១៧៥៥គ.ស
- អង្គទង សោយរាជ្យចាប់ពីឆ្នាំ១៧៤៧គ.ស.-១៧៤៨គ.ស ១៧៥៦គ.ស -១៧៥៧គ.ស
- ឧទ័រាជាទី២ សោយរាជ្យចាប់ពីឆ្នាំ១៧៥៨គ.ស. ដល់ ឆ្នាំ១៧៧៥គ.ស
- អង្គនន់ សោយរាជ្យចាប់ពីឆ្នាំ១៧៧៥គ.ស. ដល់ ឆ្នាំ១៧៧៩គ.ស
- អង្គអេង សោយរាជ្យចាប់ពីឆ្នាំ១៧៧៩គ.ស. ដល់ ឆ្នាំ១៧៩៦គ.ស
- ឧទ័យរាជាទី៣ សោយរាជ្យចាប់ពីឆ្នាំ១៧៩៦គ.ស ដល់ ឆ្នាំ១៨៣៤គ.ស
- ក្សត្រីអង្គម៉ី សោយរាជ្យចាប់ពីឆ្នាំ១៨៣៤គ.ស ដល់ ឆ្នាំ១៨៤០គ.ស
- អង្គដួង សោយរាជ្យចាប់ពីឆ្នាំ១៨៤០គ.ស ដល់ ឆ្នាំ១៨៦០គ.ស[31]។

## ៣.៣. វិបត្តិរាជវង្សខ្មែរនិងការអន្តរាគមរបស់យួន

ទំនាក់ទំនងជាមួយយួននៅឆ្នាំ ១៦២៣គ.ស យួនបានបញ្ជូនគណៈបេសកម្មម្នាក់មកក្រុងឧដុង្គ ក្នុងគោលបំណងឱ្យខ្មែរអនុញ្ញាតឱ្យយួនបង្កើតគ្រឹះស្ថានជំនួញនៅខាងត្បូងប្រទេសខ្មែរ គឺនៅត្រង់ព្រៃនគរ និងកំពង់ក្របី ព្រមទាំងអនុញ្ញាតឱ្យមានសិទ្ធិកាន់កាប់ក្រសួងគយនៅតំបន់នោះផងដែរ។ ដោយយោគ

[31]-Google Search History Cambodai

យល់ដល់អគ្គមហេសីជាបុត្រីរបស់ក្រុងវេ ព្រះជ័យជេដ្ឋាទ្រង់បានអនុញ្ញាតយល់ព្រមតាមការស្នើសុំរបស់យួន ដែលនេះជាយុទ្ធសាស្ត្ររបស់យួនក្នុងការជណ្តើមយកមណ្ឌលពាណិជ្ជកម្មរបស់ខ្មែរ។មិនតែប៉ុណ្ណោះ ចាប់តាំងពីពេលនោះមក ជនជាតិយួនបានដឹកជញ្ជូនកូនចៅមករស់នៅក្នុងដែនដីខ្មែរសម័យនោះកាន់តែច្រើនឡើងៗ ខណៈព្រះចៅក្រុងវេលើកទឹកចិត្តចំពោះការចំណាកស្រុកនេះ។ ជនជាតិយួនចំណូលថ្មីដែលរស់នៅលើទឹកដីខ្មែរជ្រើសរើសតែកន្លែងណាដែលដីមានជីវជាតិល្អដូចជាតាមច្រាំងទន្លេ និងស្ទឹងទាំងឡាយ ចំណែកខ្មែរជាម្ចាស់ស្រុកបានចាកចេញ ដោយសារពិបាករស់នៅជាមួយជនជាតិចំណូលថ្មីទាំងនោះ។បន្ថែមពីនេះស្តេចយួនបានចាត់ទូតឱ្យមកសុំទឹកដីខ្មែរត្រង់ព្រៃនគរនិងកំពង់ក្របីដើម្បីហ្វឹកហាត់ទាហានធ្វើចម្បាំងជាមួយចិន ដោយសន្យាបង្វិលសងខ្មែរវិញនៅឆ្នាំក្រោយ។

នៅឆ្នាំ១៦២៨គ.ស. បន្ទាប់ពីព្រះជ័យជេដ្ឋាសោយទិវង្គតទឹកដីខ្មែរចាប់ពីភូមិភាគព្រៃនគរបារា និងដូនណៃ ទល់នឹងអតីតរាជាណាចក្រចាម្ប៉ាមានសុទ្ធតែជនជាតិយួនរស់នៅពាសពេញអស់ទៅហើយ។ មានរាជពង្សាវតាខ្មែរខ្លះបាននិយាយថានៅឆ្នាំ ១៦៣៨គ.ស. ព្រះទងរាជាជាបុត្ររបស់ព្រះជ័យជេដ្ឋា ទ្រង់បានតឿនទារទឹកដីពីយួនមកវិញ ប៉ុន្តែត្រូវអគ្គមហេសីយួនរបស់ព្រះជ័យជេដ្ឋាធ្វើអន្តរាគមន៍សុំឱ្យពន្យាពេលឱ្យបានយូបន្តទៀត។បន្ទាប់ពីព្រះអង្គជ័យជេដ្ឋាបានសោយទិវង្គតរាជវង្សខ្មែរបានជួបនូវវិបត្តិ។ ព្រះអង្គនន់ ឬព្រះបាទបទុមរាជាបុត្រច្បងរបស់ព្រះឧទ័យ ដែលជាពូរបស់ព្រះអង្គទងរាជាបានឡើងសោយ ហើយពេលនោះចៅពញាចន្ទបុត្រម្នាក់ទៀតរបស់ព្រះជ័យជេដ្ឋា ខឹងមិនបានឡើងសោយរាជ្យបានឱ្យបក្សពួកចូលវាំងធ្វើគុតទាំងព្រះឧទ័យនិងព្រះអង្គនន់បានសម្រេចរួចក៏ឡើយសោយរាជ្យនៅក្រុងពិជ័យឧដុង្គបន្តនៅព្រះជន្ម២៣ព្រះវស្សា ដោយមាននាមហៅថា ព្រាមាធិបតី។ក្នុងរាជស្តេចថ្មីនេះ ព្រះអង្គបានទាមទារទឹកដីព្រៃនគរ និងកំពង់ក្របីពីយួនមកវិញដែរ ប៉ុន្តែត្រូវអគ្គមហេសីជនជាតិយួនរបស់ព្រះបិតាព្រះអង្គបានអន្តរាគមន៍ជាថ្មីម្តងទៀតដើម្បីសុំពន្យាបន្តទៀត។

### ៣.៣.១. ព្រះបាទឧទ័យរាជាអង្គចន្ទឬអង្គចន្ទទី២(១៨០៦គ.ស.-១៨៣៤គ.ស.)

អំណាចស្ថិតក្រោមឥទ្ធិពលខ្លាំងក្លាពីយួនសាជាថ្មីនៅឆ្នាំ១៨០៦គ.ស.ខែសីហា ព្រះអង្គចន្ទមានព្រះជន្មទើបតែបាន១៥ព្រះវស្សាបានអភិសេកនៅក្រុងបាងកកដោយមាននាមសម្រាប់រាជ្យថា“ព្រះបាទសម្តេចព្រះឧទ័យរាជាធិរាជរាមាធិបតី ព្រះស្រីសុរិយោពណ៌”រួចហើយព្រះអង្គទ្រង់យាងត្រឡប់មកសោយរាជ្យនៅក្រុងឧត្តុង្គវិញ។ បីខែក្រោយមក ចៅពញាអភ័យធីបែសបែន បានយកកូនស្រីឈ្មោះ ទេពមកថ្វាយជាម្នាង។ បន្ទាប់មកព្រះឧទ័យរាជា បញ្ជាឱ្យនាំគ្រឿង បណ្ណាការ ទៅថ្វាយព្រះចៅសៀមសុំយាងក្សត្រាក្សត្រីខ្លះមកវិញ ស្តេចសៀមបានឱ្យនាំព្រះមាតា និងរាជបុត្រី អង្គពៅត្រឡប់មកវិញនៅឆ្នាំ១៨០៧គ.ស.។ ថ្ងៃព្រហស្បត្តិ៍១៤កើតខែពិសាខ ឆ្នាំម្សាញ់ ឯកស័ក គ.ស.១៨០៩ អ្នកម្នាងទេពប្រសូតបុត្រី នាមអង្គប៉ែន។ ខែអស្សុជ ឆ្នាំម្សាញ់ឯកស័ក គ.ស.១៨០៩ ព្រះចៅសៀម ព្រះពុទ្ធយ៉តហ្វាចុឡាលោក សោយទី វង្គត ហើយព្រះរាជបុត្រនាម លើតឡាននភាល័យឡើង សោយរាជ្យស្នងព្រះបិតា។

នៅឆ្នាំ១៨០៩គ.ស នេះដដែល ចៅពញាអភ័យធីបែលបែន ទទួលមរណៈភាព។ ព្រះចៅសៀមទ្រង់តែងតាំង ឧកញ៉ាវិបុលរាជបែនកូនរបស់ចៅពញាអភ័យធីបែសបែន ឱ្យទទួលដំណែង បន្តពីឪពុក។ បន្ទាប់មកទៀតស្តេចសៀម ទ្រង់តែងតាំងព្រះអង្គស្ងួន ជា ឧភយរាជ និងតែងតាំងព្រះអង្គអិម ជាឧបរាជ

ដោយឥតមានប្រឹក្សា និងព្រះរាជាខ្មែរឡើយ ហើយថែមទាំងបញ្ជាឱ្យកេណ្ឌរាស្ត្រខ្មែរយកទៅរក្សាក្រុង បាងកក ផងដែរ។

នៅឆ្នាំ១៨១១គ.សព្រះអង្គស្ងួនទ្រង់ចាំមន្ត្រី រាជការមួយចំនួនចេញពីឧត្តុង្គមានជ័យទាំងយប់ទៅ គង់ នៅ ពោធិ៍សាត់ ដោយសារទំនាស់ ក្នុងរាជវង្ស។ ព្រះឧទ័យរាជាអង្គចន្ទបានទៅជិតដិត ជាមួយយួន ហើយលើកសួយសារអាករទៅថ្វាស្តេចយ៉ាឡុង ៣ឆ្នាំម្តង។ ជាមួយគ្នានេះដែរ ព្រះអង្គចន្ទក៏នៅតែនាំ បណ្ណាការទៅថ្វាយស្តេចសៀមតាមទំនៀមទំលាប់ដែរ។

នៅឆ្នាំ១៨១៤គ.ស សៀមបានលើកទ័ពមកដណ្តើមយកដីខ្មែរ ដោយត្រង់ៗតែម្តងគឺខេត្ត មូលព្រៃ ទន្លេរព្ធៅ និងស្ទឹងត្រែង។ នៅឆ្នាំដដែលនោះឡេវ៉ន់យៀតបានអនុញ្ញាតពីស្តេយួនឱ្យសង់បន្ទាយនៅ ភ្នំពេញ និងនៅល្វាឯម ហើយយកទ័ព១០០០នាក់ ប្រចាំកាធ្វើអាណាព្យាបាលលើកម្ពុជា ព្រមទាំងចាត់ឱ្យ លើកដីសង់ "ដំណាក់ព្រះបារមី" មួយនៅជ្រោយចង្វារសម្រាប់មន្ត្រីយួន ខ្មែរទៅសំពះ រំលឹកគុនស្តេចយួន រៀងរាស់ថ្ងៃ១កើតនិង១៥កើត។ ព្រះរាជ នាម៉ឺនសព្វមុខ មន្ត្រីទាំងអស់ត្រូវស្លៀកពាក់តាមរបៀបយួន (ទាំងព្រះឧទ័យរាជា អង្គចន្ទទាំងនាម៉ឺនសព្វមុខមន្ត្រី សុទ្ធតែ ស្លៀកខោ ពាក់អាវ ជូត ឈ្នួតក្បាលតាម បែបយួនទាំអស់)។

នៅឆ្នាំ១៨១៥គ.ស អ្នកម្នាងក្រចាប់មានបុត្រី នាមអង្គម៉ី។ នៅឆ្នាំដដែលស្តេចយួនទ្រង់បញ្ជាទ័ព យួន៣០០០នាក់ រួមទាំងទ័ពខ្មែរនៅព្រះត្រពាំង១០០០នាក់ឱ្យធ្វើបន្ទាយនៅមាត់ជ្រូក និងឱ្យជីកព្រែកពីរ ក្នុងទឹកដីយួនពីរ គឺ ព្រែក វិញតេ(ប្រវែង៥៣គ.ម)ភ្ជាប់មាត់ជ្រូកទៅសមុទ្រ ត្រង់តំបន់ពាមនិង ព្រែកវិញ អាន(ប្រវែង១៤គ.ម ទទឹង២៤ម) ត្រូវតភ្ជាប់ទន្លេធំទៅទន្លេបាក់។ ពេននេះប្រជារាស្ត្រខ្មែរត្រូវយួនកេណ្ឌ ឱ្យជីកព្រែកទាំងពីរនោះដោយបង្ខំនិងធ្វើបាបគ្មានប្រណី គឺធ្វើការឥតមានពេលសម្រាក ខ្វះទឹកសម្រាប់ ផឹក ខ្វះអាហារ។ យួនវាយសំពងខ្មែរ ដោយចោទថាខ្មែរខ្ជិលធ្វើពុតខ្មែរយឺត។ មួយថ្ងៃៗខ្មែរធ្វើការតាំងពី ព្រលឹមទល់ព្រលប់ ឯទឹកផឹកមានក្លិនលាមកបាយស៊ីទៅហើមពោះបណ្តាលឱ្យ កើតជំងឺបើមានការតវ៉ា យួនវាយខ្មែរកប់ទាំងរស់ យកក្បាល់ធ្វើជើងក្រានដាំតែ(រឿងកំពប់តែអុង)។ អំពើអមនុស្សធម៌នេះ បណ្តាលឱ្យប្រជារស្ត្រខ្មែរព្រះសង្ឃខ្មែរទ្រាំពុំបាន ក៏នាំគ្នាកាប់សម្លាប់យួនអស់ជាច្រើន តែយួនសងសឹក ខ្មែរវិញយ៉ាង សាហាវបំផុត។ នៅឆ្នាំ១៨២០គ.ស មានភិក្ខុមួយអង្គនាម កែគង់ តាំងខ្លួនជាអ្នក សិល្ប៍ បញ្ចុះបញ្ចូលរាស្ត្រនៅ ខេត្ត បាភ្នំ រួចលើកទ័ពទៅសម្លាប់យួន ។ប៉ុន្តែ ព្រះអង្គចន្ទទ្រង់បញ្ជាឱ្យលើទ័ពទៅ បង្ក្រាបចលនានោះ ហើយចាប់បានភិក្ខុ កែគង់យកទៅសម្លាប់។ នៅឆ្នាំ១៨២២ គ.ស អ្នកម្នាងយសរបស់ ព្រះអង្គចន្ទ មានបុត្រី នាមអង្គពៅ។ នៅឆ្នាំ១៨៣៤គ.ស ព្រះឧទ័យរាជាអង្គចន្ទសោយទីវង្គត ក្នុងព្រះជន្ម ៤៤វស្សា(លាង ហាប់អាន ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ ១៩៦៥គ.ស)។

### ៣.៣.២. ព្រះក្សត្រីអង្គម៉ី

អង្គម៉ីត្រូវបានឡើងសោយរាជ្យក្នុងព្រះជន្ម២០វស្សា ក្រោមការរៀបចំរបស់ អុង ខ្លាំម៉ាង ដែលព្រះ ចៅ មិញម៉ាង បុត្រស្តេចយ៉ាឡុងបញ្ជូនមក។ ឯក្សត្រដទៃទៀតពុំមានសិទ្ធិ សោយរាជ្យទេព្រោះមានជាប់ ពាក់ព័ន្ធជាមួយ សៀម។ ក្នុងរជ្ជកាលនេះប្រទេសជាតិស្ថិតនោះក្រោម អំណាចយួនទាំងស្រុង។ យួនបាន រៀបចំប្រទេសខ្មែរដំបូងផ្លាស់ឈ្មោះប្រទេសថា ត្រឹង តីថាញ់ ហើយត្រូវចែកជា៣ ភូជា និង២ ហៀងនៅ

ស្រុក ខ្មែរមានមន្ត្រីខ្មែរម្នាក់និងមន្ត្រីយួនជាច្រើននាក់មើលការខុសត្រូវ ក្នុងកិច្ចការរដ្ឋទាំងឡាយ។ក្នុងនោះមានអភិបាលជាន់ខ្ពស់៣នាក់ គឺ **ទ្រឿង មិញយ៉ាង ថាំវ៉ាន់ឌៀន**និង **ត្រាន់វ៉ាន់ណាង**។ អភិបាលទាំងបីរូបនេះហើយដែលមានតួនាទីរៀបចំ រដ្ឋបាលប្រទេសរបស់ខ្មែរឱ្យទៅជាលក្ខណៈយួន។ យួនបានរៀបចំ ផែនការដូចខាងក្រោម។ប្រទេសខ្មែរត្រូវបានយួនប្តូរឈ្មោះ មនុស្ស ភូមិ ស្រុក ខេត្ត-ក្រុង ទៅជាសំនៀងភាសាយួនដូចជា៖



**ក្សត្រីអង្គមី**

| | |
|---|---|
| -ភ្នំពេញ | ផ្លាស់ទៅជាណាំយ៉ាង (ណាំវ៉ាងឬត្រាន់តាយ-បន្ទាយពេជ្រទៅជាកប៊ិច |
| -ល្វាឯមទៅជា | ឡាឡែម |
| -ឧត្តុង្គ | ទៅជា បាក់កូណាម |
| -សំរោងទង | ទៅជា ឡុងទោន |
| -បន្ទាយមាស | ទៅជា សាយម៉ាត |
| -កំពត | ទៅជា កឹងវ៉ក |
| -បាសាក់ | ទៅជា បានថាក់ |
| -ព្រះត្រពាំង | ទៅជា ត្រាវិញ |
| -ពាមបន្ទាយមាស | ទៅជា ហាទៀង |
| -ស្រុកឃ្លាំង | ទៅជា ស្រុកត្រាំង |
| -ខេត្តប៉ាកណាម | ទៅជាបាណាមក្រោយមកហៅពាមមានជ័យ |
| -ខេត្តបារ៉ាយ | ទៅជាបាឡែ |
| -ខេត្ត ប៊ិញ៉ៀន | ទៅជាប៊ិធៀន |
| -ខេត្តព្រៃវែង | ទៅជាឡាវ៉ែង |
| -ខេត្ត តាំងវិជ័យ | ទៅជាហាយដុង |
| -ខេត្ត សម្បូរណ៍ | ទៅជាសាន់ភូ |
| -កោះសូទិន | ទៅជាខាស៊ុន |
| -លង្វែក | ទៅជាលវៀត |
| -សំរោងទង | ទៅជា ឡុងទង |
| -ក្សត្រីអង្គមី | ទៅជា ង៉ុក វឹង កុង ជូ |
| -ចៅ ហ្វាឡុង | ទៅជាត្រាឡុង |

នៅមានខេត្តជាច្រើនទៀតដែលពុំបានរៀបរាប់អស់និងពុំមានក្នុងឯកសារ។ តាមរាជពង្សាវតាខ្មែរបានបញ្ជាក់ថា កាលណោះអុងតាគុន ជាមន្ត្រីធំនៅថែរក្សាស្រុកភ្នំពេញ បានធ្វើឱ្យនាម៉ឺនសព្វមុខ មន្ត្រីខ្មែរមានការក្តៅក្រហាយ ដោយមានការបង្ខំឱ្យស្លៀកពាក់ ខោអាវឱ្យជួតក្បាល និងឱ្យមានងារសក្តិ ហៅតាម

បែបយួនទាំងអស់។ ម្យ៉ាទៀតចៅហ្វាយស្រុកនៃខេត្តខ្មែរទាំងអស់ សុទ្ធតែមានមន្ត្រីយួននៅអមចាំត្រួតត្រាពិនិត្យ និង ឃ្លាំ មើលជាអចិន្ត្រៃយ៍។ អាណាប្រជានុរាស្ត្រត្រូវបង់ពន្ធជាទម្ងន់ ត្រូវកេណ្ឌឱ្យធ្វើស្រែ កាប់ចំការ ខ្លះបំពេញកិច្ចការសាធារណៈខ្លះសង់បន្ទាយ លើកផ្លូវពីភ្នំពេញខេត្តទ្រាំងបន្ទាយមាសនៅតាមផ្លូវតម្រូវឱ្យសង់រោងមានមនុស្សប្រចាំការ៣នាក់។ចំណែកព្រះពុទ្ធសាសនាក៏ត្រូវពួកយួនធ្វើទុក្ខបុកម្នេញយ៉ាងខ្លាំង។ វត្តអារាមត្រូវរុះរើ ព្រះពុទ្ធរូបត្រូវកម្ទេច។ នៅឯស្រុកក្រោមវិញព្រះចៅមិញម៉ាង បានបង្ខំឱ្យព្រះសង្ឃខ្មែរប្រព្រឹត្តដូចលោកសង្ឃយួនផ្នែកមហាយានដែរ គឺត្រូវកោរសក់ទុកចិញ្ចើមនិងឆាន់សាច់ស្លៀកខោ ពាក់អាវផាយ កត្រង់ពណ៌ឈាមជ្រូក ពេលសូត្រធម៌ត្រូវមានវាយត្រដោកផង។ ទង្វើទាំងអស់នេះជាហេតុនាំឱ្យលោកចៅហ្វាយស្រុក ខេត្ត ព្រះត្រពាំង នាមចៅហ្វ៊ាគុយសុខចិត្តធ្វើពលីកម្ម បូជាជីវិតដើម្បីថែរក្សា កេរមត៌កពីដូនតា តរៀងទៅ។ នៅឯកម្ពុជា ក៏មានមន្ត្រីជាច្រើនបានប្រឆាំងចំពោះការជិះជាន់របស់យួន ខ្លះក៏ត្រូវចាប់បានយកទៅប្រហារជីវិត ខ្លះទៀតរត់រួចចូលទៅខាងសៀម។ក្នុងរជ្ជកាលក្សត្រីអង្គម៉ីការឡើងសោយរាជ្យមានតែសំបកខ្លួន យួនព្យាយាមកែប្រែ ប្រទេសកម្ពុជាឱ្យកាន់តែខិតជិត ក្រោមការគ្រប់គ្រងរបស់ខ្លួន។សិទ្ធិពិសេសរបស់រាជ្យវង្សត្រូវបាន លុបបំបាត់ដើម្បីបញ្ចូលរបៀបគ្រប់គ្រងរដ្ឋបាលមូលដ្ឋានតាមបែបយួន ទៅក្នុង រចនា សម្ព័ន្ធ មន្ត្រីកម្ពុជាត្រូវបានបញ្ជារឱ្យស្លៀកពាក់តាមរបៀបមន្ត្រីយួនដែរ។ នៅពេលជាមួយគ្នានោះកសិករកម្ពុជាដ៏ច្រើនសន្ធឹកសន្ធាប់ត្រូវបានបង្ខំឱ្យធ្វើពលកម្ម ជាទម្ងន់ដើម្បីរៀបចំប្រព័ន្ធធារាសាស្ត្រមានប្រឡាយ និងព្រែកបង្ហូរទឹកនៅក្នុងខេត្តភាគខាងត្បូង និងប្រើខ្មែរកាប់ឈើអូសឈើហ៊ុបទៅស្រុកវា ចុងបញ្ចប់ដោយសារយួនគ្រប់គ្រងលើទឹកដីកម្ពុជា ពួកគេបានធ្វើការប្រឆាំងនឹងព្រះពុទ្ធសាសនា និងការធ្វើទុក្ខបុកម្នេញ ចំពោះព្រះសង្ឃ យួនបានវាយ កំទេចលើជាតុសំខាន់មួយចំនួនដែលជា អត្តសញ្ញាណ របស់ខ្មែរដោយសារតែភាពឃោឃៅរបស់យួនបានធ្វើឱ្យប្រជាជនខ្មែរបញ្ឆេះនូវការបះបោរដ៏ធំមួយនៅក្នុងឆ្នាំ១៨៤០គ.សដែលក្នុងនោះបានគំរាម កំហែងដល់ការគ្រប់គ្រងរបស់យួន។រាស្ត្រខ្មែរក្តៅក្រហាយអត់ទ្រាំនឹងយួនពុំបានក៏នាំគ្នាបះបោរពាសពេញផ្ទៃប្រទេសខ្មែរមាន គំនិតល្អ បានគិតគ្នាជាសម្ងាត់ ហើយបានលើកគ្នា ដើរពិឃាតយួន គ្រប់កន្លែង អស់រយៈពេល ៨ ថ្ងៃ នៅសល់តែទីប្រជុំជនធំៗប៉ុណ្ណោះ[32]។

### ៣.៣.៣. ព្រះអង្គអេង(១៧៧៨គ.ស.-១៧៩៦គ.ស.)

នៅឆ្នាំ ១៧៧៩គ.ស. ព្រះអង្គអេងត្រូវបានលើកឱ្យឡើងគ្រងរាជ្យក្នុងព្រះជន្ម ៧ព្រះវស្សា។ ប៉ុន្តែកិច្ចការផែនដីទាំងអស់ស្ថិតក្នុងដៃចៅហ្វ៊ាមូ។ នៅក្នុងឆ្នាំ ១៧៩៤ ព្រះអង្គអេងបានអភិសេកក្នុងព្រះជន្ម ២២វស្សានៅទីក្រុងបាងកក។ គ្រឿងបញ្ចក្សេត្រជាពិសេសគឺព្រះខ័នរាជ្យដែលចៅហ្វាយបែនបានលួចយកទៅសៀម ក៏បង្វិលមកស្រុកខ្មែរវិញ នៅដើមខែមីនាឆ្នាំ ១៧៩៤គ.ស។ ព្រះអង្គបានយាងមកក្នុងនគរតាមផ្លូវគោក កាត់តាមខេត្តបាត់ដំបង ពោធិ៍សាត់ និង កំពង់ឆ្នាំងអស់រយៈពេល ២១ថ្ងៃ។ នៅសងខាងផ្លូវមានប្រជារាស្ត្រទទួលស្វាគមន៍ហ៊ោកញ្ជ្រៀវយ៉ាងខ្លាំង។ នៅរាជវាំងឧដុង្គ ពួកមន្ត្រីបានរៀបចំពិធីយ៉ាងអឹកធឹក ដើម្បីទទួលព្រះមហាក្សត្រថ្មី។ ប៉ុន្តែមានមន្ត្រីក្បត់ខ្លះដូចជា បែន កែប និង កន ដូចជាពុំសូវពេញចិត្ត ក៏ធ្វើការរាក់ទាក់ទាំងមិនពេញចិត្ត។ នៅក្នុងរជ្ជកាលរបស់ព្រះអង្គប្រជារាស្ត្រហាក់ដូចជាមានភាពសុខ

[32] -លោក លាង ហាប់អាន ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ ១៩៦៥

សាន្ត លើកលែងតែខេត្តភាគខាងត្បូង រាស្ត្រខ្មែររងទុក្ខវេទនាដោយសារគូរបដិបក្ខយួន គឺចលនាតៃសឺន និង ពួកស្តេចង្វៀនតែងតែយកប្រទេសខ្មែរធ្វើជាសមរភូមិ។ ប្រជារាស្ត្រខ្មែរត្រូវជាប់កំណែនទ័ពដោយសារស្តេចខ្មែរទៅជួយយួនខ្មែរជាអ្នកផ្តល់ស្បៀងនិងដឹកជញ្ជូនឱ្យយួន។ បក្សពួកយួនដែលឈ្លោះគ្នានៅលើទឹកដីខ្មែរបានបង្កវិនាសកម្មដល់អាយុជីវិតទ្រព្យសម្បត្តិ ដុតបំផ្លាញផ្ទះសម្បែងនិងប្លន់ទ្រព្យសម្បត្តិរបស់ខ្មែរឥតឈប់ឈរ។ជួនកាលទៀតសមរភូមិបានធ្វើឡើងនៅរដូវវស្សានាំឱ្យការដកស្ទូងមានការរាំងស្ទះបណ្តាលឱ្យខ្មែរដាច់ស្បៀងគ្មាន អ្វីចិញ្ចឹមគ្រួសាររហូតដល់ដាច់ពោះស្លាប់ក៏មានដែរ។ ការលេបយកខេត្តភាគខាងលិចដោយពួកសៀមនៅឆ្នាំ ១៧៨៣ ស្តេចសៀមបានតែងតាំងមន្ត្រីបីនាក់ មានឈ្មោះ បែន កែប និង កន ដោយខុសច្បាប់ឱ្យធ្វើចៅហ្វាយខេត្ត បាត់ដំបង និង ពោធិ៍សាត់ ដើម្បីបំពេញបំណងស្តេចសៀម មន្ត្រីទាំងនោះបានសរសេរសំបុត្រមួយដោយចាត់ឱ្យមន្ត្រីសៀមយកទៅថ្វាយព្រះអង្គអេង នៅឧដុង្គ មានសេចក្តីថា យើងទាំងអស់គ្នាមានបំណងប្រាថ្នាចង់ឱ្យព្រះចៅសៀមធ្វើសារមកឱ្យស្តេចស្រុកខ្មែរ ដើម្បីបញ្ចូល ខេត្តបាត់ដំបង មហានគរ និង ចុងកាល់ ទៅក្នុងទឹកដីសៀមដើម្បីជាកិច្ចតបស្នងព្រះចៅសៀមដែលបានបីបាច់ថែរក្សាព្រះអង្គ (អង្គអេង) នៅពេលព្រះអង្គបានរស់នៅក្នុងស្រុកសៀម។ លុះអានសំបុត្រនោះចប់ហើយព្រះអង្គអេង មានការក្តុកក្តួលព្រះទ័យដោយនឹកស្តាយទឹកដីយ៉ាងក្រៃលែងរួចក៏ធ្វើសារត្រឡប់ ទៅសៀមវិញដែលមានសេចក្តីថា ខេត្តទាំងនេះរួមគ្នាបានជាទឹកដីមួយភាគធំរបស់ប្រទេសកម្ពុជា បើខ្មែរបាត់ខេត្តទាំងនោះទៅឱ្យព្រះចៅសៀម នោះប្រទេសកម្ពុជានៅសល់តែចម្រៀកដីមួយដ៏តូចមិនសក្តិសមជាប្រទេសឡើយ។ ចម្លើយរបស់ស្តេចអង្គអេង ធ្វើឱ្យព្រះចៅតាក់ស៊ីន ក្រេវក្រោធជាខ្លាំង រួចក៏ប្រើពាក្យគំរាមកំហែងនៅក្នុងសារមួយដែលធ្វើជាលើកចុងក្រោយថា បើក្សត្រខ្មែរមិនព្រមកាត់ខេត្តទាំងនោះឱ្យស្តេចសៀមទេនោះប្រទេសយើងទាំងពីរ និងក្លាយជាសត្រូវនឹងគ្នា។ ប្រទេសកម្ពុជាពេលនោះបាត់បង់ មន្ត្រីដែលមានសមត្ថភាព និង ស្មោះត្រង់ ចំណែកឯវិស័យការពារប្រទេស យើងក៏គ្មានកងទ័ពសម្រាប់ការពារខ្លួននិងការវាយលុកណាមួយពីខាងក្រៅ។ ចំណែកវិស័យសេដ្ឋកិច្ចទៀតសោត បានធ្លាក់ចុះដុនដាបដោយសារ សង្គ្រាមក្នុងស្រុក។ កត្តាទាំងអស់នេះដែលធ្វើឱ្យព្រះអង្គមិនហ៊ានតបតនិងការលោភលន់របស់សៀម ក៏អង្វរឱ្យព្រះចៅសៀមយកខេត្តទាំងនោះតែក្នុងខណៈព្រះចៅសៀម (តាក់ស៊ីន) មានព្រះជន្មនៅឡើយ។ លុះព្រះអង្គសុគតខ្មែរសុំខេត្តនោះមកបញ្ចូលក្នុងនគរកម្ពុជាដូចដើមវិញ។ ខេត្តទាំងនោះត្រូវធ្លាក់ក្នុងកណ្តាប់ ដៃសៀមនៅឆ្នាំ១៧៩៥គ.ស. ដោយសារមន្ត្រីក្បត់ជាតិលួងខ្លៅឈ្លក់វង្វេងនិងអំណាចបុណ្យ សក្តិមាសប្រាក់ភ្លេចគិតកំណើតខ្លួនឯង។

នៅខែ មីនា ឆ្នាំ១៧៩៦គ.ស. ព្រះអង្គអេង បានផ្ទេរកិច្ចការប្រទេសជាតិទៅឧបរាជប៉ុក រួចក៏យាងទៅរាជវាំងបាងកកក្នុងបំណងឱ្យព្រះចៅសៀមប្រគល់ខេត្តខ្មែរមកវិញ។ តែស្តេចសៀមធ្វើឫកក្រអឺតក្រទមមិនព្រមស្តាប់ការទទូចអង្វរឡើយ។ បន្ទាប់ពីគង់នៅប្រទេសសៀមមិនបានផ្លែផ្ការួចមកព្រះអង្គបានយាងនិវត្តន៍ចូលប្រទេសវិញ។ នៅខែ ឧសភា ១៧៩៦គ.ស។ ប្រាំពីរខែក្រោយមក ព្រះអង្គក៏សុគតនៅរាជនីឧដុង្គដោយជំងឺគ្រុនចាញ់។ ចាប់ពីឆ្នាំ១៧៩៦នៃ.គ.ស កិច្ចការប្រទេសជាតិស្ថិតក្នុងដៃចៅហ្វាប៉ុក។ មន្ត្រីប៉ុកបានឱ្យគេសាងសង់ចេតិយ៍ នៅលើកំពូលភ្នំឧដុង្គប៉ែកខាងកើត សម្រាប់ដាក់អដ្ឋិធាតុព្រះអង្គអេង។ ពេលព្រះអង្គអេងចូលទីវង្គត់ព្រះអង្គចន្ទ ជារាជបុត្រដែលទើបមានព្រះជន្ម៦វស្សា ដូចនេះកិច្ចការប្រទេស

ជាតិត្រូវមន្ត្រីប៉ុកជាអ្នកទទួលបន្ទុក ។អន្តរាគមន៍របស់ខ្មែរដើម្បីជួយសៀមនិងយួន នៅក្នុងការគ្រប់គ្រងរបស់មន្ត្រីប៉ុកបានលើកទ័ពទៅជួយសៀមនៅពេលដែលស្តេចភូមាឈ្មោះ ប៉ូដាវប៉ាយ វាយលុកប្រទេសសៀមពីបែកខាងជើងនៅចន្លោះឆ្នាំ ១៧៨២គ.ស.-១៨១៩គ.ស។ ស្តេចយួនក៏បានបញ្ជាឱ្យខ្មែរកែនទ័ពចំនួន១០ពាន់នាក់នៅឆ្នាំ១៧៩៩គ.ស. នៅតាមខេត្តព្រៃវែង បាភ្នំ រំដួល និង ស្វាយទាប បញ្ជាដោយឧកញ៉ាវាំងឈ្មោះឡុង ដើម្បីជួយស្តេចង្វៀងប្រឆាំងនិងចលនាតៃសឺន។ កងទ័ពខ្មែរបានធ្វើដំណើរកាត់តាមទិសខាងជើងតាមតំបន់ព្រៃក្រាស់ដែលសម្បូរជំងឺគ្រុនចាញ់ រួចចុះមកតាមទិសខាងជើងក្នុងខេត្តង៉េអានដោយធ្វើឱ្យទ័ពតៃសឺនបរាជ័យរួចត្រឡប់មកប្រទេសវិញនៅឆ្នាំ១៨០២គ.ស.[33]។

## ៣.៤. ការមកដល់របស់អឺរ៉ុប និងឥទ្ធិពលលើកម្ពុជា

ក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី២ ព្រះអង្គមានទំនាក់ទំនង

- ជាមួយពួកហូឡង់ឆ្នាំ១៦២០គ.ស.
- ជាមួយពួកព័រទុយហ្កាល់
- ជាមួយពួកចិនជាអ្នកជំនួញជើងឯកជាងគេនៅអាស៊ីអាគ្នេយ៍
- ជាមួយពួកជប៉ុន

-ជាមួយឥណ្ឌា និងប្រទេសនៅអាស៊ីមួយចំនួន។



ការមកដល់ជនជាតិអឺរ៉ុបនៅសម័យឧដុង្គ

## ៣.៥. ចំណងការទូតនិង ពាណិជ្ជកម្មរបស់កម្ពុជា

ព្រះបាទជ័យជេដ្ឋាទី២ឬជ័យជេស្តា(១៦១៨គ.ស.-១៦២៨នៃគ.ស) ដោយយល់ថាទំនាក់ទំនងខ្មែរ-សៀមចាប់តាំងពីសម័យបោះបង់ចោលទីក្រុងអង្គររហូតមកដល់ការបែកបាក់បន្ទាយលង្វែក សៀមតែងតែយកប្រៀបលើខ្មែរតាមរយៈធ្វើសង្គ្រាមនិងកាត់ទឹកដីភាគខាងលិច ទើបស្រីសុរិយោពណ៌សម្រេចព្រះទ័យងាកទៅរកសម្ព័ន្ធភាពជាមួយប្រទេសយួនវិញម្តង។

នៅឆ្នាំ១៦១៨គ.ស. ព្រះស្រីសុរិយោពណ៌មាន ព្រះជន្ម ៦៤វស្សាបានលើកបុត្រច្បងនាមជ័យជេដ្ឋាទី២ ឱ្យឡើងសោយរាជ្យនៅរាជធានីល្វាឯមក្នុងព្រះជន្ម ៤០វស្សាដោយទុកព្រះឧទ័យជាឧបរាជដដែល។ នៅឆ្នាំ ១៦២០គ.ស ព្រះស្រីសុរិយោពណ៌បានរឹតចំណងមិត្តភាពជាមួយស្តេចយួនដោយស្តីដណ្តឹងបុត្រីស្តេចយួននាមក្សត្រីអង្គចូវ (ង៉ុកវ៉ាន) ជាមហេសីឱ្យព្រះបាទជ័យជេដ្ឋាទី២។ បន្ទាប់មកព្រះអង្គឱ្យគេសង់ព្រះរាជវាំងមួយនៅខាងជើងស្រះកែវបង្កើតទីក្រុងថ្មីមានឈ្មោះថាឧដុង្គមានជ័យ។

នៅឆ្នាំ១៦២៣គ.ស. ប្រទេសអាណ្ណាមបានចាត់រាជទូតមកគាល់ស្តេចខ្មែរនៅក្រុងឧដុង្គ ដើម្បីខ្ចីដីដាក់ទ័ពយួនត្រៀមវាយចិន (ខេត្តកំពង់ក្របីនិងព្រៃនគរ) និងកាន់កាប់កំពង់ផែព្រៃនគរតែរយៈពេល ៥ឆ្នាំ។ ព្រះជ័យជេដ្ឋាមិនហ៊ានប្រកែក នឹងបិតាក្មេកសុខចិត្តប្រគល់ខេត្តដែលមានសកម្មភាពពាណិជ្ជកម្មមមាញឹកបំផុតឱ្យទៅយួន។ នៅឆ្នាំ១៦២៣គ.ស. ដោយសារមិនឃើញខ្មែរលើកសួយសាអាករឱ្យ សៀមក៏លើកទ័ពមកវាយខ្មែរជាពីរផ្នែកតាមខេត្តបរិបូរណ៍និងបន្ទាយមាស។ ក្នុងចម្បាំងលើកនេះខ្មែរទទួលជោគជ័យយ៉ាងត្រចះត្រចង់។ ព្រះបាទជ័យជេដ្ឋាទី២យល់ថាច្បាប់ខ្មែរពីមុនមានភាពអយុត្តិធម៌ច្រើន ព្រះអង្គបានរៀបចំច្បាប់ឡើងវិញបាន ២៤ក្រម។ ព្រះបាទជ័យជេដ្ឋាទី២ សុគតនៅឆ្នាំ១៦២៨គ.ស. ក្នុងព្រះជន្ម

[33] -លោក ប៊ុន ធឿន ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ ២០០៦

៥២វស្សា។នៅក្នុងសម័យព្រះបាទអង្គដួង ក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រះអង្គទ្រង់បានបោះប្រាក់រាងមូល ម្ខាងមានរូបប្រាសាទអង្គរវត្ត ម្ខាងទៀតមានរូបសត្វហង្ស សម្រាប់ប្រើប្រាស់ក្នុងព្រះរាជាណាចក្រ និង ទ្រង់បានទាក់ទាញឈ្មួញចិន និង ឥណ្ឌាឱ្យចូលធ្វើពាណិជ្ជកម្មក្នុងប្រទេសខ្មែរទៀតផង។ឯពន្ធដាត្រូវបានឱ្យទារតាមរបបភាសី ជាហេតុឱ្យរាជការមានលទ្ធភាពរៀបចំថវិកាមួយដែលមានតុល្យភាព។

## ៣.៦. សៀម យួននិងការប្រជែងអំណាចលើកម្ពុជា

**សៀមនិងយួន** ចាប់តាំងពីចុង សតវត្សទី១៨នៃការតែងតាំងរាជវង្សចក្រីទាំងអស់ ត្រូវបានបង្កើតឡើង និង គ្រប់គ្រងដោយរាជវង្សផងដែរ។ យួនបានរួបរួមចាប់តាំងពីឆ្នាំ១៨០២ក្រោមការគ្រប់គ្រងដោយត្រួតត្រារបស់ព្រះចៅអធិរាជ (ហ្គា ឡុង) (Gia Long) បានប្រយុទ្ធកាន់តែខ្លាំងឡើង ដើម្បីដណ្តើមការគ្រប់គ្រងអាងទន្លេមេគង្គ ដ៏មានជីជាតិ ជាបេះដូងនៃប្រទេសកម្ពុជា ។

នៅក្រោយឆ្នាំ១៥៩៤គ.ស. សៀមបានសញ្ជ័យ (បានឈ្នះ) នៃរាជធានីលង្វែក របស់ប្រទេសកម្ពុជា និងធ្វើឱ្យឧបសម្ព័ន្ធអចិន្ត្រៃយ៍ នៃខេត្តបាត់ដំបង និងខេត្តសៀមរាប របស់ប្រទេសកម្ពុជា។ ជាប្រពៃណី និងអាណាព្យាបាលលើរាជវង្សកម្ពុជានិងចាប់ជាចំណាត់ខ្មាំង ពួកគេបានបញ្ជូនទៅតុលាការនៅអយុធ្យា ។ ដូច្នេះសៀមបានគ្រប់គ្រងកម្ពុជា និងគោលនយោបាយជាតិដោយជោគជ័យ និងមានប្រសិទ្ធិភាព។ ក្រោយពីកិច្ចការទាំងអស់ នៃប្រទេសកម្ពុជា ដែលបានដណ្តើមយកក្នុងអំឡុងពេលសង្គ្រាមសៀម និង យួននៅ ឆ្នាំ១៨៣១គ.ស និង ១៨៣៤គ.ស។ សៀមប៉ុនប៉ងដើម្បីយកឈ្នះយួនភាគខាងត្បូង តែត្រូវបរាជ័យ ដោយកងទ័ពយួន បានរុញច្រានឱ្យត្រឡប់ថយក្រោយវិញ។ ប្រទេសយួនបានគ្រប់គ្រងយោធានៃប្រទេសកម្ពុជា និងការស្តារឡើងវិញជាបន្តបន្ទាប់ ដោយព្រះបាទអង្គចន្ទ ដែលធ្លាប់ត្រូវបានទម្លាក់ពីអំណាចដោយសៀម។ តែមួយទសវត្សក្រោយមកមានការមិនសប្បាយចិត្ត ជាមួយនិងការកើនឡើងនៃខ្មែរ-យួនក្នុងចំណោមការទាមទារឥទ្ធិពល យួនបានអនុវត្តន៍ពន្ធគយក្នុងការលើកទឹកចិត្តសៀមដើម្បីធ្វើអន្តរាគមន៍ និងឈ្លានពានជាថ្មីម្តងទៀត ក្នុងអំឡុងពេលសង្គ្រាមសៀម-យួននៃឆ្នាំ១៨៤១គ.ស. និងដល់ ១៨៤៥គ.ស. ប្រទេសយួនបានបង្ហាញពីភាពគ្មានគូប្រៀបនៅលើសមរភូមិ។ ទោះជាយ៉ាងណាសៀមបានចរចា សន្ធិសញ្ញាសន្តិភាពមួយ ដែលប្រទេសកម្ពុជាត្រូវបានដាក់នៅក្រោមអធិរាជភាពរបស់សៀម-យួនរួមគ្នានោះគឺជាទង្វើរចុងក្រោយ នៃការមិនគោរពឱ្យពេញលេញ នៃអាជ្ញាធរជាតិ និង ព្រះរាជវង្សខ្មែរ។

នៅក្នុងសម័យព្រះហរិរក្សរាមាអិស្សរាធិបតីអង្គដួង ឆ្នាំ១៨៤០គ.ស-១៤៥៩គ.ស. ព្រះអង្គដួង ជាព្រះរាជបុត្រពៅនៃព្រះបាទនារាយណ៍រាជាទី៣ អង្គអេង ត្រូវបាននាម៉ឺនសព្វមុខមន្ត្រី និងពញាបឱនតេជោយាងឱ្យឡើងសោយរាជ្យសម្បត្តិ។ ព្រះអង្គទៅគង់នៅវាំងឃ្លាំងស្បែកដែលរាស្ត្របានសាងថ្វាយ នៅជិតពញាឮ។ ឯពញាបឱនតេជោក៏ស្ថិតនៅក្នុងប្រទេសខ្មែរសិនដើម្បីចាំជួយអន្តរាគមន៍ឱ្យបានទាន់ពេលវេលាបើមានការចាំបាច់។

ឯកសារយួនបាននិយាយថានៅពេលនោះ នៅប្រទេសចឹងឡាប (ប្រទេសខ្មែរ) ពួកអ្នកស្រុករួមគ្នា និងពួកសៀមបានធ្វើការប្រយុទ្ធយ៉ាងខ្លាំងក្លា។ ទ័ពយួនទប់មិនជាប់ជាហេតុនាំឱ្យរាជការយួនមានសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង។ ម្ល៉ោះហើយនៅដើមរជ្ជកាលស្តេចធៀវទ្រី (១៨៤១គ.ស.) នាម៉ឺនឈ្មោះ តាក្វាង គឺបានទទួលសុំបោះបង់ចោលប្រទេសចឹងឡាប ដកថយទៅចាំទប់ទល់នៅមាត់ជ្រូកវិញ។ ស្តេចយួនទ្រង់

ជឿតាមហើយបញ្ជាឱ្យ ទ្រឿងមិញយ៉ាងដកទ័ពចេញពីស្រុកខ្មែរ។ លុះមកដល់មាត់ជ្រូកលោកឈីចិត្តពេក ធ្លាក់ឈឺហើយទទួលមរណភាពទៅ។ប្រភពយួនដដែលបាននិយាយថាក្នុងពេលដំណាលគ្នានោះនៅស្រុកក្រោមមានការតស៊ូរបស់លោក លឹម សោម និងព្រះសង្ឃ។ ចំពោះរឿងនេះ ឯកសារខ្លះទៀតបានបញ្ជាក់ថា លោកលឹមសោម រឺ ទេស្សាសោម បានកែនទ័ពនៅស្រុកចាប់ភ្លើង ក្នុងខេត្តព្រះត្រពាំង ក្នុងបំណងសងសឹកជួសថៅហ្វាយគុយ និងដេញកំចាត់សត្រូវឱ្យចេញផុតពីទឹកដីដូនតារបស់លោក។ ដោយមានសេនាឯកប្រុញ និង ម៉ឺនសោម ជួយយ៉ាងសកម្មផងលោកបានលើកទ័ពទៅដល់ផ្ទោរដូង សំលាប់បានយួនជាច្រើន តែនៅទីបំផុតលោកត្រូវទទួលបរាជ័យដោយទ័ពជំនួយរបស់យួនលើកមកពីខេត្តខាងកើត។លោកត្រូវចាប់ដាក់ទ្រុង នាំយកទៅក្រុងវេហើយត្រូវប្រហារជីវិតតាមបញ្ជាស្តេចជៀវទ្រី។លុះមេទ័ពឈ្មោះ ង្វៀងទៀនលឹម និងង្វៀងកុងទ្រី បានបង្ក្រាបការតស៊ូរបស់លោកលឹមសោមនៅស្រុកក្រោមហើយ សៀមបានលើកទ័ពជើងទឹកមកចុះត្រង់កំពត ហើយការប្រយុទ្ធគ្នាជាមួយទ័ពយួនបានប្រព្រឹត្តទៅនៅពាម នៅទីបំផុតសៀមដកទ័ពថយទៅវិញអស់។ ប៉ុន្តែទ័ពសៀមដែលនៅសល់ក្នុងស្រុកខ្មែរ និងទ័ពយួនដែលនៅក្នុងស្រុកក្រោមចេះតែប្រយុទ្ធគ្នាជាបន្តទៅទៀតរហូតដល់ឆ្នាំ១៨៤៥គ.ស។ នៅឆ្នាំនោះស្តេចជៀវទ្រី បានបញ្ជាឱ្យលើកទ័ពធំចូលវាយសៀមយកបានភ្នំពេញ ហើយលើកបង្ហួសទៅព័ទ្ធក្រុងឧដុង្គថែមទៀត។ ខាងខ្មែរ - សៀមសុំចរចារសន្តិភាព យួនមិនព្រម។ តែមិនយូរប៉ុន្មានយួនខ្លួនឯងសុំចរចារម្តងវិញ។ការចរចារបានប្រព្រឹត្តទៅនៅសមរភូមិពោធិបីដើម យួន និង សៀមថា ចង់ទំនុកបំរុងប្រទេសខ្មែរ និង ស្តេចខ្មែរដូចគ្នា ថាត្រូវអភិសេកព្រះអង្គដួង ឱ្យឡើងសោយរាជ្យដោយតំណាងប្រទេសទាំងពីរ សៀមរុះបន្ទាយយួន យួនរុះបន្ទាយសៀម។ សៀមបានដោះលែងមេទ័ព និងទាហានយួនជាឈ្លើយ ឯយួនត្រូវដោះលែងក្សត្រាក្សត្រីខ្មែរមកវិញ។ រហូតដល់ឆ្នាំ ១៨៤៧គ.ស. ទើបព្រះអង្គដួងត្រូវបានអភិសេកឱ្យឡើងសោយរាជ្យនៅឧដុង្គ ដោយមានព្រះនាមសម្រាប់រាជថាព្រះហរិរក្សរាមាអិស្សរាធិបតី។ នៅឆ្នាំក្រោយពញាបឌិនតេជោបានលាព្រះអង្គត្រលប់ចូលក្រុងបាងកកវិញ។ គួរគប្បីជ្រាបថា នៅពេលឡើងសោយរាជព្រះអង្គដួង ទ្រង់តូចព្រះទ័យខ្លាំងណាស់ ចំពោះការបាត់បង់ទឹកដីជាច្រើនដែលត្រូវយួន និងសៀមកេងប្រវ័ញ្ចយកដោយខុស ច្បាប់ ទឹកដីខ្មែរពីដើមមានវិសាលភាពធំទូលាយ ឥឡូវនេះត្រូវរួញតូចជាអតិបរិមា ប៉ុន្តែព្រះអង្គដួងពុំហ៊ានលើកបញ្ហានោះមកចោទ រឺតវ៉ាអ្វីជាមួយយួន និងសៀមឡើយ ពីព្រោះអ្នកជិតខាងទាំងពីរនេះមិនចូលចិត្តឱ្យលើករឿងទឹកដីនេះមកពិភាក្សាឡើងវិញ។ គេយល់ថាទឹកដីទាំងប៉ុន្មានដែលគេបានកាន់កាប់នោះ គឺសុទ្ធជាកម្មសិទ្ធស្របច្បាប់របស់គេទាំងអស់រួចហើយ។

នៅឆ្នាំ ១៨៥៤គ.ស ដោយអត់ទ្រាំពុំបាននឹងអំពើរំលោភទន្ទ្រានយកទឹកដីពីសំណាក់ជនជាតិយួនដែលរស់នៅក្នុងកម្ពុជាក្រោម ព្រះអង្គដួងទ្រង់បានសំរេចព្រះទ័យថា ត្រូវតែសុំជំនួយ និងការពារពីមហាអំណាចអឺរ៉ុបណាមួយ។ ដោយហេតុនោះព្រះអង្គទ្រង់បានបញ្ជូនដោយសំងាត់នូវមន្ត្រីខ្មែរម្នាក់កាន់សាសនាកាតូលិចឱ្យទៅសិង្ហបុរី ដើម្បីយកព្រះសារលិខិតរបស់ ព្រះអង្គសរសេរជាភាសាបារាំងដោយសម្តេចមិស Miche យកទៅថ្វាយព្រះចៅណាប៉ូលេអុងទី៣ តាមរយៈលោកកុងស៊ុលបារាំងប្រចាំនៅទីនោះ។ ជាមួយគ្នានោះព្រះអង្គដួងទ្រង់បានផ្ញើរ គ្រឿងបណ្ណាការខ្លះទៅថ្វាយព្រះចៅប្រទេសបារាំង មាន

ភ្លុកដំរី កុយរមាស រង្គ ស្គរ និងម្រេចជាដើម។ លោកកុងស៊ុលបារាំងបានសន្យាថា នឹងនាំព្រះសារលិខិត និង ដង្វាយទៅក្រុងបារីស។

នៅឆ្នាំ ១៨៥៤គ.ស. លោករាជទូត ដឺម៉ុងទីញី Montigny ត្រូវបានចាត់ឱ្យបំពេញបេសកកម្មជាច្រើននៅឥណ្ឌូចិន និងប្រទេសចិន។ លោកបានទទួលបញ្ជាពីព្រះចៅណាប់ប៉ូលេអុង ឱ្យធ្វើសន្ធិសញ្ញាមិត្តភាព និងខាងជំនួញជាមួយខ្មែរ ប៉ុន្តែការធ្វេសប្រហែសរបស់រាជទូតរូបនេះ បានធ្វើឱ្យព្រះចៅសៀមទ្រង់ជ្រាបពីបំណងរបស់ប្រទេសបារាំង ជាហេតុបណ្តាលសន្ធិសញ្ញារវាងខ្មែរ និងបារាំងពុំបានសំរេចទៅវិញ។ ម្យ៉ាងទៀតលោកដឺម៉ុងទីញី ពុំបានអញ្ជើញទៅជួបនឹងព្រះរាជាខ្មែរទេ លោកគ្រាន់តែបញ្ជាឱ្យបព្វជិតហ៊ាត្រេស ដែលឈរនៅកំពតទៅគាល់ព្រះអង្គ។ ដោយទ្រង់មិនពេញព្រះទ័យ នឹងអាកប្បកិរិយារបស់លោកម៉ុងទីញីផង និងដោយខ្លាចមានការធ្វើទុក្ខបុកម្នេញពីសំណាក់សៀមផង ព្រះអង្គដួងក៏ទ្រង់លះបង់ចោលនូវព្រះបំណងសុំការពារពីប្រទេសបារាំង។ក្នុងព្រះសារលិខិតទី២ ព្រះអង្គទ្រង់បានរំលឹកដល់ព្រះចៅណាប់ប៉ូលេអុង ទឹកដីដែលយួនបានយកហើយដែលស្ថិតនៅចន្លោះត្រើយខាងលិចនៃព្រែកព្រែនគរ និងពាម គិតទាំងកោះត្រល់ និងកោះត្រឡាច ពិតជាដីរបស់ខ្មែរ។ ចំពោះព្រះសារលិខិតទី២នេះ ប្រទេសបារាំងពុំបានឆ្លើយតបអ្វីសោះឡើយ។ នៅឆ្នាំ ១៨៥៦គ.ស. ដោយព្រះអង្គវ័យកាន់តែជរា ហើយដោយនឹកគិតទៅដល់អនាគតនៃប្រទេសជាតិ ព្រះអង្គដួងទ្រង់សូមឱ្យព្រះចៅសៀមតែងតាំងព្រះរាជបុត្រច្បងនាម អង្គវតី ជាមហាឧបរាជ និង ព្រះរាជបុត្របន្ទាប់នាម ស៊ីសុវត្ថិ ជាព្រះកែវហ្វា និងសូមឱ្យបានវិលចូលក្រុងកម្ពុជាដើម្បីជួយបំពេញរាជការផងនាឆ្នាំដដែល យួននៅស្រុកក្រោមបានសង់បន្ទាយនៅបាយផៅ នៅឃ្លាំង និងនៅ លំពូយា ដើម្បីពង្រឹងជំហររបស់ខ្លួននៅក្នុងខេត្តខាងលិច។ វាបានរំលោភអំណាចរបស់ព្រះចៅហ្វាស្រុកសុខ ជាហេតុបណ្តាលឱ្យខ្មែរ ក្រោកឡើងក្រោមបញ្ជាការរបស់សេនាលឹម លើកទៅប្រយុទ្ធនឹងយួនដោយមានជ័យជំនះ នៅតំបន់ទំនប់ និងកំពង់ត្រប់។ ពេលនោះព្រះអង្គដួង ទ្រង់ឱ្យសង់បន្ទាយ និងលើកទ័ពទៅប្រចាំការនៅព្រំដែនយួនឃើញដូច្នោះបានលើកទ័ពទៅរាំងដើម្បីកុំឱ្យខ្មែរខាងកណ្តាល និងខ្មែរខាងក្រោមទាក់ទងគ្នាបាន។និយាយពីនៅស្រុកយួនឯណោះ ក្នុងរជ្ជកាលរបស់ស្តេចទឺឌឹក និងក្នុងរជ្ជកាលមុនៗ មានការធ្វើទុក្ខបុកម្នេញលើរូបអ្នកផ្សាយសាសនា ជាហេតុនាំឱ្យបារាំងធ្វើអន្តរាគមន៍ដោយយកលេសថា ដើម្បីការពារជនទាំងនោះ នៅឆ្នាំ ១៨៥៨ គឺនៅក្នុងស្ថានភាពថ្មីនេះហើយដែលព្រះអង្គដួងបានទាក់ទងសាជាថ្មីជាមួយជនជាតិបារាំង។ តាមរាជពង្សាវតារខ្មែរថា ព្រះអង្គទ្រង់បានជួលទ័ពបារាំងឱ្យជួយវាយយកព្រែនគរ គិតជាឈ្នួល ៥០០ណែនប្រាក់។ ក្នុងពេលដំណាលគ្នានោះ ពួកចាមជ្វានៅខេត្តត្បូងឃ្មុំ បានបះប្រឆាំងនឹងចៅហ្វាយស្រុកខេត្តនេះ ក្រោមការដឹកនាំមេ ៣នាក់គឺ ទួនហ៊ីម ទួនស៊ី និង ទួនអ៊ិត។ ព្រះអង្គដួងទ្រង់លើកទ័ពទៅបង្ក្រាប មេឱ្យមេបះបោរម្នាក់ត្រូវស្លាប់២នាក់ទៀតបានរត់រួចចូលទៅមាត់ជ្រូកតាមរាជពង្សាវតារខ្មែរថានៅឆ្នាំ១៨៥៨គ.ស. លោកមេទ័ពឌូដាដឌឺលាក្រេ Doudart de lagrée បានលើកទ័ពទៅវាយព្រែនគរ ឯព្រះអង្គដួងទ្រង់បញ្ជាឱ្យលោកឧកញ៉ាជាសេដ្ឋីកែប លើកទ័ពទៅវាយទ្រាំងត្បូង បាសាក់ ព្រះត្រពាំង ក្រមួនស មាត់ជ្រូក។ ចំណែកឯពួកចាមជ្វាដែលរត់ទៅមាត់ជ្រូក ចូលទៅបះបោរនាំ រាស្ត្រលើកទៅវាយឧដុង្គ តែត្រូវព្រះឧបរាជ និងព្រះកែវហ្វាចាប់បានពួកមេដឹកនាំហើយបាក់ទ័ពរត់ខ្ចាត់ខ្ចាយទៅវិញអស់។និយាយពីឧកញ៉ា កែប ដែលលើកទ័ពទៅវាយយួនឯស្រុកក្រោមនោះ ឃើញ

ថាមានជោគជ័យ ហើយចេះតែជំរុញទៅមុខ ប៉ុន្តែនៅពេលដែលព្រះរាជាសោយទីវង្គតទៅ (១៨៥៩ គ.ស) ហើយដោយមានការវឹកវរនៅឯរាជធានីឧដុង្គ លោកក៏ដកទ័ពចូលវាយស្រុកក្រោមនោះ គឺដើម្បីទៅបង្ក្រាបពួកចាមផ្ទាបះបោររត់ទៅទីនោះ ហើយដែលរាជការយួនមិនព្រមចាប់ប្រគល់មកឱ្យខ្មែរវិញ។

## ៣.៧. ការបាត់បង់ទឹកដីកម្ពុជាក្រោម

នៅពេលដែលក្រុមបះបោរបានចុះខ្សោយនៅឆ្នាំបន្ទាប់ក្នុងឪកាសនេះសៀម ឆ្លៀតចូលមកត្រួតត្រាលើប្រទេសកម្ពុជា។ ខ្មែរពុំមានអំណាចអ្វីធំដុំឡើយយួនចាត់វិធានការ គ្រប់បែបយ៉ាងលើប្រទេសខ្មែរនិងប្រជាជាតិ ខ្មែរ ឱ្យទៅ ជាយួនធ្វើបាបរាស្ត្រ ខ្មែរ ឱ្យវេទនា ។ហើយលេបយកទឹកដីខ្មែរអស់ជាច្រើនខេត្តទឹកដីខ្មែរដែលបាត់នៅកម្ពុជាក្រោម មាន ២១ខេត្តគឺៈ

-ព្រះត្រពាំង.ស្រុកទ្រាំង .មានត់ជ្រូក.ក្រមួនស.ពលលាវ.ទឹកខ្មៅ.ពាម.ព្រៃកប្ញស្សី .លង់ហោ.ពាមបារ៉ាជ.រោងដំរី.ព្រៃនគរ.ទួលតាមោក.ផ្សារដែក.ចង្វាត្រពាំង.មេសរ.ព្រះសួគ៌ា.កោះគង.កំពង់ប្ញស្សី .អូកាប់កំពង់ក្របី [34]។

ផែនការដើម្បីបំបាត់ ទំនៀម ទំលាប់ប្រពៃណីខ្មែរ យួនកាប់ដើមពោធិ៍ បំផ្លាញព្រះពុទ្ធរូបរំលាយព្រះចេតិយ។ស្តេចមិញម៉ាងបានចាប់បុត្រីទាំងបួនរបស់អង្គចន្ទទៅក្រុងវ៉េពេលទៅដល់លង់ហោរថៅហ្វាយខេត្តនេះឱ្យតែ ក្សត្រី ៣ អង្គគឺអង្គម៉ី អង្គ ពៅ អង្គស្ងួន បន្តដំណើរទៅព្រៃនគរឯអង្គប៉ែន ត្រូវគេទំលាក់ទឹក ចោលនៅលង់ហោរដោយចោទថាចង់នាំព្រះមាតារត់ទៅស្រុកសៀម។

## ៣.៨. ឥទ្ធិពលសៀមមកលើខ្មែរ

ការគម្រាមកំហែងពីសំណាក់ពួកសៀម ជានិវេសន៍ជនចេញមកពីប្រទេសចិន ដែលគេចពីការគ្រប់គ្រង និង ធ្វើបាប ពីសំណាក់ពួកម៉ុងហ្គោល ដែលបានចូលមកត្រួតត្រាប្រទេសចិន។ ពួកសៀម បានចូលមកជ្រកកោនលើទឹកដីខ្មែរ ជាកុលសម្ព័ន្ធហើយបញ្ជូនសួយសារអាករ មករាជធានីអង្គរជារៀងរាល់ឆ្នាំ ។ បន្តិចម្តងៗ ពួកនេះបានរីកចម្រើនសមាជិករបស់ខ្លួន ហើយក្លាយជាសាមន្តរដ្ឋរបស់ អាណាចក្រខ្មែរ ។ មកដល់ស.វទី១៤ សៀមបានមកតាំងរាជាណាចក្ររបស់ខ្លួននៅភាគខាងលិចក្រុងអង្គរ ដែលមានរាជធានីឈ្មោះ អាយុធ្យា នៅឆ្នាំ ១៣៤៧គ.ស។ ចាប់តាំងពីនោះមកពួកនេះបានអនុវត្តន៍នយោបាយឈ្លានពានទឹកដីខ្មែរ ជានិច្ចកាល ជាពិសេសស្របពេលដែលនៅ កម្ពុជាមានវិបត្តិ និង រងការឈ្លានពានពីសំណាក់ពួកចាម្ប៉ា។ ក្នុងគោលគំនិតនេះ ពួកសៀម បានធ្វើការវាយលុកលើអាណាចក្រខ្មែរជាច្រើនលើកច្រើនសារ ដោយពេលខ្លះបានគ្រប់គ្រង លើប្រទេសខ្មែរ ពេលខ្លះដណ្តើមបានទឹកដីខ្មែរភាគខាងលិចហើយបន្តលូកដៃចូលកិច្ចការផ្ទៃក្នុងប្រទេសខ្មែរជារឿយៗ។ គេអាចរាប់ការវាយលុកចូលប្រទេសខ្មែរពីសំណាក់ពួកសៀម ចាប់តាំងពីការកកើតនៃរាជាណាចក្រសៀមនេះ រហូតដល់សម័យឧដុង្គជាង ១០ លើក ដូចខាងក្រោម៖

- នៅឆ្នាំ ១៣៥១គ.ស. ក្នុងរជ្ជកាលព្រះបាទលំពង្សរាជា (១៣៤១គ.ស.-១៣៥២គ.ស.) ព្រះចៅសៀម ព្រះនាម រាមាធិបតីបានលើកទ័ពវាយយកក្រុងអង្គរ
- នៅឆ្នាំ ១៣៩៥គ.ស. ក្នុងរជ្ជកាលព្រះបាទ ធម្មាសោក (១៣៧៣គ.ស.-១៣៩៥គ.ស.)

[34] -លោក សូ អឿ ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ ១៩៩៥

សៀមព័ទ្ធរាជធានីអង្គរជាប់ ៧ខែ ហើយវាយយកបានក្រុងអង្គរ ជាថ្មីម្តងទៀត ដែលកាលនោះដឹកនាំដោយព្រះចៅសៀម រាមាសូរ

- នៅឆ្នាំ១៤២០គ.ស. ក្នុងរជ្ជកាលព្រះបាទបរមសុខាឬបរមសោក្ករាជ (១៤១៧-១៤២០គ.ស.) សៀមវាយបានក្រុងអង្គរ ជាលើកទី៣ ។

- នៅសម័យចតុមុខ ឆ្នាំ ១៤៧៣គ.ស. ក្នុងរជ្ជកាលព្រះបាទ ស្រីរាជា(១៤៦៩- ១៤៨៥ គ.ស.) សៀមវាយលុកយកបានខេត្ត ក្ងរ៉ាត់ មហានគរ និង ចន្ទបុរី ។

- ក្នុងរជ្ជកាលព្រះបាទ ចន្ទរាជា (១៥១៦គ- ១៥៦៦គ.ស.) សៀមវាយបានខេត្តមហានគរនៅឆ្នាំ ១៥២០គ.ស.។

- នៅឆ្នាំ១៥៣០គ.ស សៀម បានបញ្ជូន ពញាអុង ដែលជាបងប្អូនជីដូនមួយនិងចន្ទរាជា ឱ្យមកវាយខ្មែរម្តងទៀតតែត្រូវបរាជ័យ

- នៅឆ្នាំ១៥៧២គ.ស. ឆ្លៀតពេលដែលព្រះបាទបរមរាជា ប្រយុទ្ធនិងពួកលាវ សៀមលើកទ័ពមកដណ្តើមបាន នគររាជសីមា បស្ទឹមបុរី និង ចន្ទបុរី

- នៅឆ្នាំ១៥៨៨គ.ស. ដោយក្បត់និងសន្ធិសញ្ញាមិត្តភាពខ្មែរ-សៀម ពួកសៀម បានលើកទ័ពមកព័ទ្ធក្រុងលង្វែក បីខែ តែមិនបានសម្រេច ហើយប្រើល្បិចបាញ់ប្រាក់ដួងចូល គុម្ពឫស្សីដែលជារបងការពារក្រុងលង្វែក

- នៅឆ្នាំ១៥៩៤គ.ស. សៀមលើកទ័ពមកវាយយកបានក្រុងលង្វែក ដោយបានដាក់ទ័ព ឱ្យនៅត្រួតត្រាអស់រយៈពេលបួនឆ្នាំ

- នៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៨គ.ស. ទាហានថៃប្រហែល ៥០ នាក់បានផ្លាស់ទីលំនៅចូលទៅក្នុងបរិវេណវត្តកែវសិក្ខាគិរីស្វារៈ ដែលគាត់អះអាងថាស្ថិតនៅក្នុងទឹកដីកម្ពុជាប្រហែល ៣០០ ម៉ែត្រ (៩៨០ ហ្វីត) ប្រាសាទព្រះវិហារ។

ដូចនេះយើងឃើញថា សៀមជាមេគ្រោះថ្នាក់មួយ ដែលតែងតែប៉ងលេបត្របាក់យកទឹកដីខ្មែរមិនឈប់។ ព្រះបាទស្រីសុរិយោពណ៌ ដែលត្រូវសៀមចាប់យកទៅកាលពីក្រុង លង្វែកត្រូវសៀមវាយយកបាននោះបានត្រឡប់មកស្រុកខ្មែរវិញហើយបានដឹងច្បាស់ពី គំនិត របស់សៀមនេះ ទើបទ្រង់រិះរកមធ្យោបាយដើម្បីគេចពីគ្រោះថ្នាក់បាត់បង់ទឹកដីទៅក្នុងដៃពួក សៀមនេះ។ ដោយទ្រង់បានសម្លឹងឃើញ នគរថ្មីមួយទៀតនៅទិសខាងកើត ដែលទើបតែកម្ទាត់បាននូវប្រទេសចាម្ប៉ា ដែលធ្លាប់តែយាយីខ្មែរដែរនោះ គឺប្រទេសអាណ្ណាម ។សរុបមកទឹកដីខ្មែរដែលបានបាត់បង់ទៅប្រទេសសៀមអស់ចំនួន៣១ខេត្តដូចជា៖

| ខេត្តខ្មែរដែលបាត់បង់ទៅទឹកដីសៀម | | | |
|---|---|---|---|
| លេខរៀង | ឈ្មោះខេត្តជាអក្សរខ្មែរ | ឈ្មោះខេត្តជាអក្សរឡាតាំង | ឈ្មោះខេត្តជាភាសាសៀម |
| ១ | ខេត្តសុរិន្ទ | Sorin Province | สุรินทร์ |
| ២ | ខេត្តនគររាជ | Norkor Reach Province | นครราชสีมา |

| | | | |
|---|---|---|---|
| ៣ | ខេត្តបុរីរម្យ | Boreyrom Province | จังหวัดบุรีรัมย์ |
| ៤ | ខេត្តសិរីសាកេត | Sereysakeat Province | ศรีสะเกษ |
| ៥ | ខេត្តស្រះកែវ | Sa Kaeo Province | สระแก้ว |
| ៦ | ខេត្តត្រាច | Trach Province | ศรีสะเกษ |
| ៧ | ខេត្តរយ៉ង | Rayong Province | ระยอง |
| ៨ | ខេត្តសង្គ្គឹត | Sangkut Province | |
| ៩ | ខេត្តគោកខ័ណ្ឌ | Kork Khan Province | |
| ១០ | ខេត្តច័ន្ទបុរី | Chanthaburi Province | จันทบุรี |
| ១១ | ខេត្តព្រះជិនបុរី | Preah Chin Borey Province | ปราจีนบุรี |
| ១២ | ខេត្តជលបុរី | Jilburi Province | จังหวัดชลบุรี |
| ១៣ | ខេត្តស្ទឹងជ្រៅ | Stung Chrov Province | |
| ១៤ | ខេត្តឧទង | Utong Province | |
| ១៥ | ខេត្តនាងរង | Neang Rong Province | |
| ១៦ | ខេត្តពលបុរី | Pol Borey Province | ลพบุรี |
| ១៧ | ខេត្តបស្ចឹមបុរី | West Borey Province | |
| ១៨ | ខេត្តសុវណ្ណភូមិ | Sovannaphum Province | |
| ១៩ | ខេត្តយសោធរ | Vishnu Lok Province | |
| ២០ | ខេត្តវិស្ណុលោក | Vishnu Lok Province | |
| ២១ | ខេត្តជ័យភូមិ | Chey Phum Province | ชัยภูมิ |
| ២២ | ខេត្តនគរភ្នំ | Nokor Phnom Province | นครพนม |
| ២៣ | ខេត្តសុខោទ័យ | Sukhothai Province | |
| ២៤ | ទីក្រុងអយុធ្យា | Ayutthaya City | พระนครศรีอยุธยา |
| ២៥ | ខេត្តបឹងកក់ | Boeung Kok Province | |
| ២៦ | ខេត្តសុគន្ធនគរ | Sokun Nokor Province | สกลนคร |
| ២៧ | ខេត្តវជ្ជបុរ | Vachbour Province | |
| ២៨ | ខេត្តស្រីយសោធរ | Srey Sothor Province | |
| ២៩ | ខេត្តជ័យ | Chey Province | |
| ៣០ | ខេត្តស្រីទេព | Srey Tep Province | |
| ៣១ | ខេត្តនគរបឋម | Nokor Primary School | |

### ខេត្តខ្មែរដែលបាត់បង់នៅប្រទេសឡាវ

| | | |
|---|---|---|
| - ខេត្តចំប៉ាស័ក្ត | Champasak Province | ແຂວງ ຈຳປາສັກ |
| - ខេត្តស្រែគង្គ | Sre Kong Province | ແຂວງ ເຊກອງ |
| - ខេត្តអាចម៍ក្រពើ | Achkrapeu Province | ແຂວງ ອັດຕະປື |
| - ខេត្តសួគ៌ខេត្ត | Suokr Khet Province | ແຂວງ ສະຫວັນນະເຂດ |
| - ខេត្តក្រមួន | Kramuon Province | ແຂວງ ຄຳມ່ວນ |
| - ខេត្តសារ៉ាវ៉ាន់ | Saravan Province | ແຂວງ ສາລະວັນ[35]។ |

## ៣.៩. មធ្យោបាយគេចចេញពីសៀម និងយួន



ព្រះបាទអង្គឌួង

នៅឆ្នាំ ១៨៤០គ.ស.ព្រះអង្គដួងបានគ្រងរាជ្យនៅវាំងស្បែក ស្រុកពញាឮ លុះដល់ឆ្នាំ១៨៤៧ គ.ស.ទើបទ្រង់បានអភិសេកឱ្យឡើងសោយរាជ្យជាព្រះមហាក្សត្រនៅឧដុង្គ ។ ក្នុងនាមជាព្រះរាជាដែលគិតដល់អាយុ ជីវិតជាតិ ព្រះអង្គមានព្រះទ័យសោកស្តាយជាខ្លាំង នៅពេលទ្រង់ជ្រាបថាមានទឹកដីខ្មែរជាច្រើនរបស់ខ្មែរបានបាត់បង់ទៅសៀមនិងយួន។ប៉ុន្តែដោយប្រទេសខ្មែរស្ថិតនៅក្នុងស្ថានភាពសេដ្ឋកិច្ចទន់ខ្សោយ និងខ្ទេចខ្ទាំងដោយសារសង្គ្រាមផ្ទៃក្នុងទើបព្រះអង្គមិនអាចរកកម្លាំងដើម្បីដណ្តើមទឹកដីខ្មែរទាំងនោះមកវិញ។ ម្យ៉ាងវិញទៀតដើម្បី រំដោះប្រទេសរួចផុតពីការបែងចែករបស់យួននិងសៀមគឺមានតែមធ្យោបាយមួយ ត្រូវពឹងមហាអំណាចអឺរ៉ុបណាមួយ ដើម្បីបង្ក្រាបសត្រូវទាំងពីឱ្យផុតពីទឹកដីខ្មែរ។ នៅឆ្នាំ១៨៥៤គ.ស.ព្រះអង្គបានចាត់ទូតខ្មែរម្នាក់ឱ្យទៅទាក់ទងជាមួយទូតបារាំងដែលនៅសិង្ហបុរីក្នុងគោលបំណងឱ្យបារាំងជួយការពារខ្មែរ ប៉ុន្តែគម្រោងការនេះត្រូវបរាជ័យ ដោយសាររឿងនេះលេចឮដល់ស្តេចសៀមហើយស្តេចសៀមក៏បានគម្រាមព្រះបាទអង្គឌួងថា បើព្រះអង្គហ៊ានចុះសន្ធិសញ្ញាចងសម្ព័ន្ធភាពជាមួយបារាំង សៀមនឹងលើកទ័ពមកកំទេចខ្មែរជាមិនខាន ។ ពេលឃើញបែបនេះ ព្រះបាទអង្គដួងងក៏មិនហ៊ានឱ្យលោក ដឺមុងទីញ៉ី( De Montingny) ដែលជាតំណាងបារាំងចូលគាល់ឡើយ។ដូច្នេះបារាំងក៏បានផ្អាកការចុះ  សន្ធិសញ្ញាសម្ព័ន្ធភាពបារាំងខ្មែរនេះទៅ។

ដើម្បីគេចចេញពីអំណាចសៀម និង យួន ទ្រង់មានព្រះតម្រិះថា មិនត្រូវគិតពីរឿង ដណ្តើមយកអ្វីដែលបាត់បង់ទៅហើយមកវិញទេ ប៉ុន្តែពេលនេះ កាលៈទេសៈនេះ យើងត្រូវការអ្វីដែលនៅសល់ឱ្យបានជាមុនសិន។ទ្រង់មានការបារម្ភណាស់ចំពោះអនាគត ដោយទ្រង់ពិភាល់ថា សន្តិភាពរវាងសៀម-អាណ្ណាមគ្រាន់តែជាការសម្រាកដើម្បីរកឱកាសផ្តួលគ្នា នឹងបានលេបយកទឹកដីខ្មែរតែម្នាក់ឯងប៉ុណ្ណោះ។ បើមានសង្គ្រាមជាថ្មីការបែងចែកទឹកដីខ្មែរដោយ សៀម និង អាណ្ណាម ពិតជាមិនអាចជៀសរួច។ ពួកសៀមនឹងយកទឹកដី ពោធិសាត់ កំពង់ស្វាយ ឧដុង្គ សម្បូរ ក្រចេះ ត្បូងឃ្មុំ រីង អាណ្ណាមវិញនឹងយកអាណាខេត្តភាគខាងកើតដូចជា បាភ្នំ,ទ្រាំង និង ចតុមុខ ផង។

[35] -Google Search historykmer

ក្នុងព្រះរាជតម្រិះរបស់ទ្រង់ គឺមានតែរកកម្លាំងមហាអំណាចបរទេសណាមួយដែលខ្លាំងជាងសត្រូវសងខាងពីរនេះគឺ ត្រូវតែពឹងមហាអំនាច អឺរ៉ុបណាមួយ បារាំង ឬ អង់គ្លេស។ ដោយហេតុថា ទ្រង់មានបព្វជិតបារាំងម្នាក់ដែលជិតស្និតនិងទ្រង់ឈ្មោះ មីស ទើបទ្រង់មានព្រះរាជបំណងទាក់ទងសុំការចងមេត្រីភាពជាមួយបារាំង។ថ្ងៃទី១៤ខែមិថុនាឆ្នាំ១៨៥៣គ.ស.ដោយមានឈ្មោះអេវែកមីស ជាអ្នកជួយបកប្រែសម្តេចអង្គដួងបាន ផ្ញើសារលិខិតមួយច្បាប់ពីរាជវាំងឧត្តុង្គ ទៅថ្វាយព្រះចៅអធិរាជណាប៉ូលេអុងទី៣តាម រយៈ មន្ត្រីកុងស៊ុលបារាំងនៅសិង្ហបុរីគឺលោកហ្វ្រេដេរិកហ្គោទីយេ( Frederic Gautier)។ព្រះរាជសារដ៏វែងបាន៖

- ជានាយ៉ាងកក់ក្តៅចំពោះស្ថានភាពនៃពួកបេសកបព្វជិតនៅកម្ពុជា
- ត្អូញត្អែរអំពីឧបសគ្គដែលពួកសៀមនិង វៀតណាម រាំងចំពោះពាណិជ្ជកម្ម រវាងកម្ពុជានិងអឺរ៉ុប
- ដំណាលយ៉ាងពិស្តារ អំពីកាលៈទេសៈដែលព្រះអង្គឡើងគ្រងរាជ្យដោយគូស បញ្ជាក់ថាពួកអាណ្ណាមបានកាន់កាប់ទឹកដីអស់ជាងពាក់កណ្តាលនៃប្រទេសកម្ពុជា ។

មន្ត្រីខ្មែរពីរនាក់គឺ កុយដឺម៉ុងតេរ៉ូ (Koy de Monterro) និង ប៉ែន (Pen) បានធ្វើដំណើរទៅសិង្ហបុរីដោយនាំទៅជាមួយនូវវត្ថុអនុស្សាវរីយ៍ខាងក្រោមនេះសម្រាប់ថ្វាយចំពោះព្រះចៅអធិរាជបារាំង ៖

- ភ្លុកដំរីធំ ៤
- កុយរមាស២
- ជ័រវង្គទំងន់៥ហាប គឺ៣០០គីឡូក្រាម
- ស្ករសទំងន់៣០០គីឡូក្រាម
- ម្រេចចំនួន៣០០គីឡូក្រាម ។

បារាំងបានបញ្ជូនតំណាងមកគឺ សាលដឺម៉ុងទីញី (Charles de Montigny)មកឥណ្ឌូចិននៅឆ្នាំ ១៨៥៥គ.ស។ សាលដឺម៉ុងទីញីមកដល់សិង្ហបុរី នៅថ្ងៃទី១៦ខែឧសភាឆ្នាំ១៨៥៦ និងមកដល់ក្រុងបាងកកនៅដើមខែកក្កដា ។ការចរចាជាមួយសៀមបានអូសបន្លាយយ៉ាងយូរ រហូតដល់ ថ្ងៃទី ១៥ ខែសីហា ឆ្នាំ១៨៥៦គ.សទើបមានការចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពនិងពាណិជ្ជកម្ម ជាមួយសៀមភាពខ្វះការប៊ុនប្រសប់ និង ការធ្វេសប្រហែសរបស់សាលដឺម៉ុងទីញី គាត់បានធ្លោយមាត់ឱ្យព្រះចៅ បង្កត របស់សៀមដឹងពីបំណងរបស់គាត់ដែលចង់មកជួបព្រះរាជាកម្ពុជា ដោយខ្លាចបាត់បង់សិទ្ធិត្រួតត្រាលើប្រទេសកម្ពុជានោះសៀមបានរិះរកមធ្យោបាយធ្វើយ៉ាងណាឱ្យលោកដឺម៉ុងទីញីស្នាក់នៅរយៈពេលយូរឯក្រុងបាង កក ហើយឆ្លៀតពេលនោះបញ្ជូនមន្ត្រីរបស់គេមក កាន់រាជវាំងឧដុង្គដើម្បីស្តីបន្ទោសសម្តេចអង្គដួង ។



ផែនទីប្រទេសខ្មែរដែលបាត់ខេត្តទៅសៀម

មេដឹកនាំសៀមបានទាក់ទាញទឹកចិត្ត លោកដឺម៉ុងទីញីដោយរៀបចំបដិសណ្ឋារកិច្ចយ៉ាងគគ្រឹកគគ្រេង ព្រោះគេមានគោលបំណងពីរយ៉ាងសំខាន់គឺ៖

- សៀមចង់ឱ្យប្រទេសខ្មែរស្ថិតនៅចំណុះប្រទេសសៀមតទៅទៀត ។

- សៀមចង់ប្រើប្រាស់ប្រទេសបារាំងធ្វើជាកំពែងការពារទល់និងវៀតណាមផង និងធ្វើជាកូនជញ្ជីងសម្រាប់ឱ្យមានតុល្យភាពជាមួយអង់គ្លេសដែលបានចូលដល់ភូមាហើយ។

នៅចុងខែកញ្ញាឆ្នាំ១៨៥៦គ.ស. អ្នកការទូតបារាំងបានជិះនាវាឆ្ពោះមកកាន់ប្រទេសកម្ពុជាហើយចេញដំណើរពីតំបន់ បាក់ណាម(Paknam) គាត់មកសំចតនៅចន្ទបុរី ពីថ្ងៃទី២៩កញ្ញាដល់ថ្ងៃទី០១ខែតុលា ដើម្បីផ្ទុកអុសសម្រាប់ដុតលើនាវាម៉ារសូ( Marceau)។ លោកសាលដឺម៉ុងទីញីមកដល់ដែនសមុទ្រកំពត នៅថ្ងៃ៥តុលាឆ្នាំ១៨៥៦គ.ស។ អេវ៉ែក មីស បានទូល ថ្វាយសម្តេចអង្គដួងអំពីគម្រោងធ្វើដំណើរនៃអ្នកការទូតបារាំងមកកាន់ប្រទេសកម្ពុជាតាំងពីពេលមុនគាត់មកដល់ទីក្រុងបាងកកមកម៉្លេះ។ ដោយមានជំនួយពី បព្វជិត មីស និង អែសត្រែស ( Hestrest) សម្តេចអង្គដួងបានត្រាស់បង្គាប់ឱ្យរៀបចំកន្លែងស្នាក់នៅយ៉ាងសមរម្យនៅកំពង់ផែកំពត សម្រាប់ ម៉ុងទីញ ព្រមទាំងរៀបចំសំអាតផ្លូវលំពីរាជវាំងឧត្តុង្គទៅកាន់ខេត្តកំពតផងដែរ។ ទោះបីមានការជំទាស់ពីពួកមន្ត្រីរបស់ព្រះអង្គក៏ដោយក៏ព្រះអង្គបានសម្រេចព្រះទ័យថានឹងយាងទៅជួបអ្នកការទូតបារាំងនៅខេត្តកំពត។

គាត់បានមកដល់ខេត្តកំពតរបស់ខ្មែរនៅខែកញ្ញា ១៨៥៦គ.ស។ សៀមដឹងគោលបំណងរបស់សាលដឺម៉ុងទីញី ចង់ទាក់ទងខ្មែរ ក៏គម្រាមព្រះអង្គដួង មិនឱ្យទាក់ទងបារាំង។ ហេតុនេះ បំណងរបស់ព្រះអង្គដួង ចង់បានការការពារពីបារាំងមិនបានសម្រេចទេ។ ដឺម៉ុងទីញី ក៏ធ្វើដំណើរហួសទៅកូសាំងស៊ីនដោយពុំបានធ្វើសន្ធិសញ្ញាណាមួយជាមួយ ព្រះអង្គដួង ឡើយ។ នៅថ្ងៃ១៩ តុលា ឆ្នាំ ១៨៦០គ.ស. ព្រះអង្គដួងចូលទីវង្គត។

## ៣.១០. សម័យព្រះបាទអង្គដួងនិងស្នាព្រះហស្ថ

### ៣.១០.១. ការរៀបចំប្រទេស

ព្រះបាទហរិរក្សរាមាអិស្សរាធិបតីអង្គដួង ជាព្រះរាជាមួយអង្គដែលប្រកបដោយទសពិធរាជធម៌។ ព្រះអង្គទ្រង់យកព្រះទ័យទុកដាក់ក្នុងការរៀបចំប្រទេសឱ្យមានសន្តិភាពក្នុងប្រទេស និងឱ្យមានរបៀបរៀបរយក្នុងរាជការ។ យ៉ាងណាមិញការបែកបាក់សាមគ្គីរវាងខ្មែរនិងចំបាំងឈ្លានពានរបស់បរទេស ជាហេតុនាំឱ្យប្រទេសជួបប្រទះនឹងមហន្តរាយ ភូមិស្រុកត្រូវដុតបំផ្លាញស្រែចំការត្រូវបានបោះបង់ចោលផ្លូវថ្នល់ត្រូវបំផ្លិចបំផ្លាញដោយបរិច្ចេទកម្ម និងដោយទឹកជំនន់ ស្ពានភាគច្រើនត្រូវខូចខាត។ អសន្តិសុខកើតពាសពេញផ្ទៃប្រទេស ព្រោះរាស្ត្រដែលអត់ឃ្លានបានក្លាយទៅជាចោរលួចចោរប្លន់ កាប់សម្លាប់ឥតត្រាប្រណី សកម្មភាពខាងជំនួញឥតមានទាល់តែសោះ។ នៅក្នុងស្ថានភាពដុនដាបបែបហ្នឹងហើយ ដែលព្រះអង្គដួងទ្រង់បានឡើងគ្រងរាជ។ ព្រះអង្គទ្រង់បានខិតខំរៀបចំប្រទេសជាតិឡើងវិញ និងលើកតំកើងជីវភាពប្រជារាស្ត្រ។ រាជធានីឧដុង្គ ត្រូវបានស្ថាបនាឡើងវិញ ចំនួនខេត្តក្នុងព្រះរាជាណាចក្រត្រូវបន្ថយ ខេត្តនីមួយៗ មានទំហំផ្ទៃប្រហាក់ប្រហែលគ្នា ហើយត្រូវបែងចែកជាស្រុក។ ចាប់ពីឆ្នាំ ១៨៥១គ.ស. ដល់ ១៨៥៧គ.ស. ព្រះអង្គបញ្ជាឱ្យលើកផ្លូវមួយពីឧដុង្គ ទៅ កំពត ដែលជាកំពង់ផែសមុទ្រតែមួយរបស់ខ្មែរព្រោះកំពង់ផែព្រៃនគរ ត្រូវបានទៅយួនជាស្ថាពរទៅហើយ។ នៅឆ្នាំ១៨៥២គ.ស ព្រះអង្គទ្រង់ឱ្យលើកផ្លូវមួយទៀតភ្ជាប់រាជធានីឧដុង្គទៅកំពង់ហ្លួង ជាកំពង់ផែសំខាន់មួយទៀតរបស់ខ្មែរក្នុងសម័យនោះ។

ក្នុងរជ្ជកាលព្រះអង្គដួងព្រះអង្គបញ្ជាកុំឱ្យមានការតំឡើង និងការបង្កើតពន្ធថ្មី និងចៀសវាងកុំកែនរាស្ត្រ ឱ្យបំពេញកិច្ចការសាធារណៈក្នុងរដូវធ្វើស្រែចំការ។ ព្រះអង្គមានព្រះទ័យអាណិតអាសូរចំពោះរាស្ត្រដែលរងទុក្ខវេទនា។ ដូច្នេះហើយបានជានៅពេលដែលកើតជំងឺរាតត្បាត ព្រះអង្គទ្រង់យាងដោយផ្ទាល់ទៅចែកស្បៀងអាហារ និងសម្លៀកបំពាក់ឱ្យរាស្ត្រក្រីក្រ។ ម្យ៉ាងទៀតព្រះអង្គទ្រង់ហាមមិនឱ្យបរបាញ់សត្វ និង មិនឱ្យចាប់ត្រីដោយប្រើព្រួលរាំងពេញព្រែកទេ។ ព្រះអង្គស្តីបន្ទោស និងដាក់ទណ្ឌកម្មយ៉ាងធ្ងន់លើពួកជនប្រមឹក ជនជក់អាភៀន និងជនប្រព្រឹត្តល្បែងស៊ីសង ទ្រង់បង្ក្រាបដោយតឹងរ៉ឹងនូវអំពើចងការប្រាក់ដោយយកការធ្ងន់ហួសប្រមាណហើយក្នុងការខ្ចីបុលគ្នាទ្រង់តម្រូវឱ្យមានកិច្ចព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរ រវាងមេបំណុល និង កូនបំណុល។ ជាពិសេសទៅទៀតព្រះអង្គទ្រង់បានបរិច្ចាគព្រះរាជទ្រព្យផ្ទាល់ដើម្បីលោះពួកមនុស្សខ្ញុំគេឱ្យបានរួចខ្លួនវិញអស់ជាច្រើន។

ក្នុងវិស័យវប្បធម៌ ព្រះអង្គទ្រង់បានបង្កើតសាលាតាមវត្តជាច្រើន ទ្រង់បានលើកទឹកចិត្តពួកអ្នកប្រាជ្ញបណ្ឌិត កវី ហើយទ្រង់បានផ្តល់នូវលុយកាក់ និង មធ្យោបាយផ្សេងៗ ដល់ជនណាដែលចង់ធ្វើការសិក្សាស្វែងរកចំណេះវិជ្ជា។ ព្រះអង្គទ្រង់សព្វព្រះទ័យធ្វើការពិភាក្សាជាមួយព្រះសង្ឃពីបញ្ហាសាសនា និងអក្សរសាស្ត្រ និង ទ្រង់បានបរិច្ចាគព្រះរាជទ្រព្យផ្តល់ចំពោះព្រះសង្ឃសម្រាប់កសាងវត្តអារាម និងចំណាយផ្សេងៗ តាមពុទ្ធបញ្ញត្តិ។នៅទីបញ្ចប់នេះ គួរគប្បីបញ្ជាក់ដែរថា ព្រះអង្គដួងជាអ្នកនិពន្ធមួយរូបយ៉ាងឆ្នើម។

ព្រះបាទអង្គឌួងជាស្តេចប្រកបដោយទសពិធរាជធ៌មបានសង្គ្រោះប្រទេសពីការបាក់បែកពីសង្គ្រាម ព្រះអង្គបានរៀបចំប្រទេសឡើងវិញដូចជា៖

- ព្រះអង្គបានកសាងព្រះវិហារនៅឧត្តុង្គបានចាត់អាចារ្យឱ្យបង្រៀនព្រះត្រៃបិតក
- ទ្រង់បានកសាងសាលាទាន
- ទ្រង់ឱ្យអ្នកប្រាជ្ញ បណ្ឌិត ផ្ទៀងផ្ទាត់ កែ ព្រមទាំតែងច្បាប់តាមសម័យនិយម-ទ្រង់បានជ្រើសរើសនាម៉ឺនសុទ្ធតែអ្នកមានចំណេះដឹងជ្រៅជ្រះ
- ទ្រង់បានបញ្ជារឱ្យកុមាររៀននៅតាមវត្ត
- ទ្រង់បានដាក់ទណ្ឌកម្មដល់នាម៉ឺនទុច្ចរិតស៊ីសំណូកនឹងដែលប្រព្រឹត្តអំពើអបាយមុខ
- ទ្រង់បញ្ជារមិនឱ្យយកពន្ធលើសលប់ ចងការប្រាក់យកការប្រាក់ទាបបំផុត
- ទ្រង់បានធ្វើពុម្ព បោះប្រាក់ចាយ
- ទ្រង់បានកសាងផ្លូវពីឧត្តុង្គទៅ កំពត និងធ្វើសំពៅសម្រាប់ធ្វើជំនួញ
- ទ្រង់ចំណាយព្រះរាជទ្រព្យ ចាត់ឱ្យយុវជនខ្មែរទៅរៀនភាសាបរទេសនៅសឹង្ហបុរី
- ទ្រង់បានបង្ក្រាបចាមដែលមានការបះបោរចង់បង្កើតខេត្តនៅត្បូងឃ្មុំទៅជាខេត្តចាមដាច់ពីខ្មែរ

### ៣.១០.២. ស្នាព្រះហស្តក្នុងអក្សរសាស្ត្រ

ព្រះរាជនិពន្ធរបស់ព្រះអង្គឌួងក្នុងអក្សរខ្មែរមាន៖

| | | |
|---|---|---|
| - ព្រះបាទអង្គឌួង | បាននិពន្ធ រឿងចម្ប៉ាថោង | ១៨១០គ.ស. |
| - ព្រះអង្គឌួង | បាននិពន្ធរឿងព្រះវេស្សន្តកម្រងកែវ | (មិនចាំឆ្នាំ) |

- ព្រះបាទអង្គឌួង បាននិពន្ធ រឿង កាកី ១៨១៥គ.ស.
- ព្រះបាទអង្គឌួង បាននិពន្ធ ច្បាប់ស្រី ១៨៣៧គ.ស.

### ៣.១០.៣. អ្នកប្រាជ្ញខាងអក្សរសាស្ត្រខ្មែរ

- អរិយគាមមុនី ភឹង បាននិពន្ធរឿង ព្រះជិនវង្ស ១៨៥៦ គ.ស
- ព្រះធម្មបញ្ញាម៉ែន បាននិពន្ធរឿង ពេជ្ជតា ១៨៥៧ គ.ស.
- អម្រិតក្សត្រីម៉ុក បាននិពន្ធរឿង ទេវន្ទ ១៨៥៩ គ.ស.
- អម្រិតក្សត្រីម៉ុក បាននិពន្ធរឿង ទុំទាវ ១៨៥៩គ.ស.
- ឧញ៉ា យ៉ែម បាននិពន្ធរឿង វិមានច័ន្ទ ១៨៥៩ គ.ស.
- ឧញ៉ា វង្សាក្សត្រីនង បាននិពន្ធរឿង លោកន័យជាតក ១៧៩៤គ.ស.
- ឧញ៉ា វង្សាក្សត្រីនង បាននិពន្ធរឿង បុញ្ញសាសិសា ១៧៩៧គ.ស.
- ឧញ៉ា វង្សាក្សត្រីនង បាននិពន្ធរឿង ភោគកុលកុមារ ១៨០៤គ.ស.
- ឧញ៉ា វង្សាក្សត្រីនង បាននិពន្ធរឿង ចាប់សុភាសិត ១៨០៩គ.ស.
- ឧញ៉ា មៀច បាននិពន្ធរឿង វរជវរនេត្រ ១៨០៦ គ.ស.
- ឧញ៉ា កោសាធិបតីកៅ បាននិពន្ធរឿង ក្រុងសុភមិត្រ ១៧៩៨ គ.ស.
- បណ្ឌិត ស្អាត បាននិពន្ធរឿង មុច្ចលិន្ទ ១៨៣៣ គ.ស.
- ព្រះបទុមបារមីពេជ្រ បាននិពន្ធរឿង របាក្សត្យ ១៨៥៩ គ.ស.
- ភិក្ខុបណ្ឌិត ខៀវ បាននិពន្ធរឿង« សាស្ត្រាចន្ទលីវង្ស» និង ពលក្ខន្ធ
- កវី ចន្ទ បាននិពន្ធរឿង សាស្ត្រា ភិន សុវណ្ណ»
- បណ្ឌិតកោ បាននិពន្ធរឿង «សាស្ត្រា ព្រះសូរ៉ាត»
- កវី យ៉ែម បាននិពន្ធរឿង «សាស្ត្រា វិមានចន្ទ »
- អ្នកឧកញ៉ា ធម្មាធិបតីចន្ទ បាននិពន្ធរឿង «សាស្ត្រា សុខមាណព»
- ចៅពញា ភក្តីសង្គ្រាមបាល» បាននិពន្ធរឿង «សាស្ត្រ សុភោគ»36 ។

**ស័កទាំងដប់តាមច័ន្ទគតិមានដូចជា**

| | | | |
|---|---|---|---|
| ១. ឯកស័ក | ២.ទោស័ក | ៣.ត្រីស័ក | ៤.ចត្វាស័ក |
| ៥. បញ្ចស័ក | ៦.ឆស័ក | ៧.សប្តស័ក | ៨.អដ្ឋស័ក |
| ៩. នព្វស័ក | ១០.សំរិទ្ធស័ក(ហាប់អាន ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ ១៩៦៥)។ | | |

36 -លោក សូ អឿ ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ ១៩៩៥

ការសិក្សាចាប់ផ្តើមចម្រើនឡើងគឺមានសាស្រ្តាច្បាប់សាស្ត្រាល្បែងសាស្ត្រាទេសន៍ កកើតឡើងច្រើន។ ការសិក្សាវិជ្ជាជាន់ខ្ពស់ ក៏កើតមានឡើងវិញដោយមានការចាត់ចែងឱ្យសិក្សា ភាសាបាលីនៅក្នុងក្រុង ក្នុងវត្តធំៗ ពេលនោះក៏មានអ្នកប្រាជ្ញច្រើនដែរ។ ក្នុងព្រះរាជដំណាក់ក៏មានការសិក្សា នៅតាមវត្តអារាមទាំងឡាយទូទៅ នៅក្នុងព្រះរាជាណាចក្រ ក៏សុទ្ធតែមានការសិក្សាដែរ។

ក្នុងរាជព្រះបាទហរិរក្សរាមា (ព្រះអង្គដួង)១៨៤០គ.ស-១៨៥៩គ.ស ព្រះអង្គបានបង្កើតសាលាវត្តជាច្រើនទ្រង់បានលើកទឹកចិត្តពួកអ្នកប្រាជ្ញ កវីដោយផ្តល់ជាលុយកាក់ និងមធ្យោបាយ ផ្សេងៗ ដល់អ្នកដែលចង់ធ្វើការសិក្សាស្វែងរកចំណេះវិជ្ជា។ ព្រះអង្គជាមហាស្តម្ភដ៏ប្រសើរក្នុងការសិក្សាទ្រង់ជាអ្នកប្រាជ្ញទ្រង់ជាកវី ទ្រង់ជាបណ្ឌិត ទ្រង់ជាអ្នកនិពន្ធដ៏វិសេស ហើយទ្រង់ក៏ជាសាស្ត្រាចារ្យឯកផងដែរ។ ក្នុងសម័យនោះព្រះបរមរាជវាំងឧដុង្គជាសាកលវិទ្យាល័យ ដែលមានព្រះអង្គទ្រង់ជាសាកលវិទ្យាធិការ។ ទ្រង់បង្រៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ វិជ្ជាកាព្យ វិជ្ជានិពន្ធ ទ្រង់បង្រៀនបាលី បង្រៀនធម៌ ទស្សនៈវិជ្ជា ពុទ្ធសាសនា និងវិជ្ជាផ្សេងៗទៀតផ្ទាល់របស់ព្រះអង្គ ក្រៅពីភារកិច្ចគ្រប់គ្រង ដឹកនាំប្រទេសដ៏ធ្ងន់ធ្ងរនេះ ទ្រង់បានឆ្លៀតព្រះបរមរាជរោកាស ដ៏មានតម្លៃរបស់ព្រះអង្គទៅក្នុងការសិក្សាទ្រង់បង្រៀនព្រះបរិយត្តិធម៌ដល់ភិក្ខុសាមណេរទៀតផង។ ព្រះរាជដំណាក់ ជាឃ្លាំងដែលនៅចំពីមុខព្រះទីនាំងទេវាវិនិច្ឆ័យឧដុង្គជាមន្ទីរសិក្សា។ ព្រះរាជបរិពារក៏បានទទួលការសិក្សាផងដែរ។ ក្រៅពីកិច្ចការរបស់ខ្លួនម្នាក់ៗសិក្សាបរិយត្តិធម៌រៀនបែបបទផ្សេងៗតាមបំណងប្រាថ្នារៀងៗខ្លួនដូចជាភិក្ខុ សាមណេរនៅតាមវត្តអារាមដែរ។ នៅទីបញ្ចប់នេះយើងគួរគប្បីបញ្ជាក់ដែរថាព្រះបាទ អង្គដួង ជាអ្នកនិពន្ធកវីយ៉ាងឆ្នើមដែរ។ ចាស់ទុំបានដំណាលថា ក្នុងរដូវកាន់បិណ្ឌ ១៥ថ្ងៃ ទូទាំងប្រទេស ក្នុងព្រះរាជដំណាក់ក៏មានធ្វើរាជពិធីនេះដែរ គឺមានការធ្វើនៅវត្ត ព្រឹកល្ងាច ទៀបភ្លឺ។ ពេលព្រឹកព្រះរាជបរិវ្វាធ្វើនៅវត្តព្រឹក ហើយសូត្របទបរាភវសូត្រ ដូចនៅវត្តអារាមដែរ ហើយគេសូត្របទនេះពិរោះណាស់សម្លេងឮគ្រឡូចទៅលើអាកាស ឮរហូតចេញទៅក្រៅព្រះបរមរាជវាំងទៀតផង។ កាលនោះមានអ្នកស្រែម្នាក់ក្រោកពីព្រលឹមចេញទៅភ្ជួរស្រែ លុះលីនឹមដើរដល់មុខព្រះបរមរាជវាំងឮបទពិរោះពេកក៏កាំងស្មារតីគាំងដើរទៅមុខពុំរួចចេះតែលីនឹមត្រឡប់ចុះត្រឡប់ឡើង ទាល់តែចប់បទបរាទើបដឹងខ្លួនដើរទៅស្រែរួច។ បទនេះគួរពិរោះពិតព្រោះសុទ្ធតែសម្លេងស្រីស្នំក្រមការ ដែលបានសិក្សាពីព្រះអង្គផ្ទាល់នៃព្រះករុណាម្ចាស់ជីវិតលើត្បូងត្រឹមត្រូវទៅតាមខ្នាតបន្ទាត់ មិនមែនចេះតែស្រែកឱ្យតែឮង៉ែងៗនោះឡើយ ការសិក្សាវិជ្ជាភាសាខ្មែរ នៅក្រោមព្រះរាជដឹកនាំនេះហ្មត់ចត់ណាស់ ហើយពាក្យមួយមាត់ៗ ដែលអានចេញមកសុទ្ធតែត្រឹមត្រូវជាភាសាខ្មែរដែលហៅថាបោរីវាចា (ភាសាអ្នកក្រុង) ។ដូចជាភាសាអ្នកក្រុងដូចពាក្យថាត្រូវអានតួ សជាទន្តជ(Dental) ប្រកបដោយឮខ្យល់ស តាមធ្មេញចេញមកពាក្យថា ពោះវត្រូអានកំបុត ព្រោះវិសគៈ ឬ វិសជ៌នីយ គ្រាន់តែរៈ មុខដូច្នេះជាដើម។ព្រះករុណាជាម្ចាស់ជីវិត ទ្រង់ជាកវីឯកទ្រង់បង្រៀនពាក្យកាព្យ បង្រៀនឱ្យចេះតែងសេចក្តី ជាកាព្យត្រឹមត្រូវឥតខ្ចោះ តាមលក្ខណៈបទ និងតាមជើងកាព្យដែលមានចែងក្នុងកាព្យវិជ្ជា ដូចសាស្ត្រកាកីដែលជាព្រះរាជនិពន្ធស្រាប់ ហើយសិស្សកវីក្នុងព្រះរាជ្យដំណាក់សុទ្ធតែបានប្រឡងដោយព្រះអង្គផ្ទាល់ស្តេចចេញប្រថាប់ជាប្រធានក្នុងការប្រឡង។ចាស់ទុំបានដំណាលថាដងមួយនោះ ពេលប្រឡងសិស្សកវីព្រះករុណាជាម្ចាស់ជីវិតស្តេចចេញមកប្រថាប់ជាប្រធាននៅក្នុងព្រះរាជដំណាក់ឃ្លាំង សិស្សកវីចូលមក

ប្រឡងពីរនាក់ម្តងៗ ចំពោះមុខព្រះភក្ត្រ។ សិស្សកវីម្នាក់អង្គុយក្នុងបន្ទប់ សិស្សកវីម្នាក់ទៀតអង្គុយនៅក្រៅបន្ទប់ ពេលនោះទ្រង់ត្រាស់បង្គាប់ឱ្យកវីក្នុងបន្ទប់ចេញ អឺយមុន កវីទី១បញ្ចេញថ្វីមាត់ចប់ កវីនៅក្រៅបន្ទប់ចេញ អឺយ តបវិញភ្លាម មិនឱ្យបាត់ផ្សេង សំដីមិត្តខ្លួនទាន់ទេ។ កវីទាំងពីរ លេងសំដីផ្តោះផ្តងឆ្លងឆ្លើយគ្នា ហូរចេញជាពាក្យកាព្យចាប់ចុងជួនរណ្តំគ្នាយ៉ាងពីរោះ ណែងណង គ្មានឱ្យអាក់បន្តិចឡើយ។

ព្រះករុណាដែលទ្រង់ ជាមេប្រយោគ បានផ្ទៀងព្រះកាណ៌ចាំស្តាប់ កាលបើឃើញថាត្រឹមត្រូវហើយ ទ្រង់សព្វព្រះរាជហឫទ័យណាស់ ទ្រង់ព្រះសម្រួល ហើយប្រទានរង្វាន់តាមការគួរ ទើបតែងតាំងជាកវីពេញលក្ខណៈ។ សេចក្តីនេះបញ្ជាក់ថា ការសិក្សាសម័យនោះចាប់ផ្តើមរីកច្រើនណាស់ ហើយក្នុងព្រះរាជដំណាក់មានការសិក្សាជាពិសេស នៅវត្តអារាមទូទាំងព្រះរាជាណាចក្រក៏មានការសិក្សាដែរ។ការសិក្សាប្រតិបត្តិតាមប្រពៃណីដើមដដែល មានតែកុមារាទេដែលទទួលការសិក្សា រីឯកុមារី វិញ ទោះបីមិនមានការហាមឃាត់ជាផ្លូវការតែមានទំនៀមទម្លាប់ចងជាទូទៅពេញប្រទេសថា មិនគួរនឹងឱ្យស្ត្រីមានការសិក្សាទេ វៀរលែងតែក្នុងព្រះរាជដំណាក់។ ការសិក្សានៅសម័យនោះ លោកសំដៅទៅការរៀន អក្សរ រៀនអាន សូត្រកំណាព្យ ស្មូត្រ លេខនព្វន្ត ធម៌អាថ៌និងវិជ្ជាជីវៈបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្នុងការរៀនវិជ្ជាជីវៈខាងប្រុសៗគេរៀនអារ ចាំង ឈូស ដាប់ឈើ ធ្វើផ្ទះ តុ ទូ ទូក ក្តារ ឥដ្ឋ គ្រឿង ត្បាញកញ្ជើ ល្អីកញ្ច្រែង រីឯស្ត្រីវិញរៀនរវៃសូត្រ អំបោះ ត្បាញ ធ្វើគោម ចង្កៀង ទៀនធូប។នៅពេលរៀនចេះចប់ម្តងៗគេធ្វើពិធីប្រលងសាកចំពោះសិស្ស ហើយពិធីប្រលងដែលមានភាពជាឱឡារិកអធិកអធមជាងគេ ច្រើនធ្វើនៅឱកាសមហាកឋិន។ បន្ទាប់ពីប្រលងខាងអក្សរ លេខនិងធម៌អាថ៌រួចស្រីៗត្រូវទៅបញ្ចេញស្នាដៃខាងវិជ្ជាជីវៈ ដូចជារវៃអំបោះ ត្បាញសំពត់ ដេរជាស្បង់ ជ្រលក់ឱ្យហើយជាស្រេចក្នុង១ថ្ងៃ១យប់ ដើម្បីយកទៅដាក់ប្រគេនព្រះសង្ឃនៅឱកាសមហាកឋិន។នៅពេលប្រលងនេះឧបាសកឧបាសិកាពីទីជិត ឆ្ងាយចាស់ ក្មេង ក្រមុំ កម្លោះ បានមកមូមីរ ចោមរោមជិតជុំ មើលសិស្សប្រឡងយ៉ាងសប្បាយរីករាយអធិកអធមក្រៃលែងការសិក្សានៅសម័យនោះ គេចែកជា ៤ជាន់៖

### ក. ជាន់ដើម(ជាន់ដំបូង)រៀនសរសេរ

កាលកុមារដឹងក្តីហើយមានអាយុប្រមាណ ៧.៨.៩.១០ឆ្នាំ មាតាបិតាតែងនាំកូនទៅសិក្សានៅវត្តរៀបចំសំពត់ខោអាវ ខ្លួនប្រាណកូន ហើយរើសរកថ្ងៃល្អ គឺជាថ្ងៃព្រហស្បត្តិ៍ ព្រោះថ្ងៃនេះជាទេព្តាសំដីហើយគេជឿថា កុមារចាប់ផ្តើមរៀននៅថ្ងៃនេះនឹងចេះដឹងឆាប់។ រើសថ្ងៃបានហើយនាពេលព្រឹក មាតាបិតា(កូន)រៀបចំម្ហូបអាហារទុកជាចង្ហាន់ទៅប្រគេនលោកគ្រូចៅអធិការក្រាបបង្គំបីដងបង្គាប់កូនឱ្យថ្វាយបង្គំបីដង ហើយលើកភោជនាហារប្រគេន ទើបថយមកអង្គុយនៅទីសមគួរ លើកដៃប្រណម្យទូលថា៖

- ព្រះតេជគុណម្ចាស់ខ្ញុំព្រះករុណាទាំងពីរនាក់នាំកូនឈ្មោះមកប្រគេនទុកជាសិស្ស ឱ្យសិក្សាចំណេះវិជ្ជា មានអក្សរ។ សូមព្រះតេជគុណមេត្តាប្រោសបង្ហាត់បង្រៀនច្បាប់លោកច្បាប់ធម៌ ចំណេះវិជ្ជាគ្រប់ប្រការឱ្យទាន ខ្ញុំព្រះករុណាទាំងពីរនាក់ សុំតែភ្នែក ឆ្អឹងទេសាច់ឈាមប្រគេនព្រះតេជគុណទាំងអស់។ ពាក្យនេះមានន័យថា សូមមេត្តាបង្រៀនសព្វសារពើវិជ្ជា បើនៅទាស់ខុសឆ្គងត្រង់ណា កាយឬវាចាចិត្ត មេត្តាប្រោសពត់ប្រដៅឱ្យទាន ឱ្យទាល់តែបានទៅជាមនុស្សចេះដឹងនឹងគេឡើង។ និយាយទូលលោកហើយ បែរមកនិយាយនឹងកូនថា «កូន ម៉ែ ឪ នាំកូនឯងមកប្រគេនព្រះតេជគុណ ឱ្យសិក្សា រៀន

សូត្រ ហើយកូនត្រូវប្រតិបត្តិព្រះតេជគុណ កុំបីឱ្យមានផ្តាំផ្តង មើលបម្រើទឹកក្តៅ ទឹកត្រជាក់ តាមការគួរ ខំប្រឹងសិក្សារៀនសូត្រ ឱ្យចេះដឹង ឱ្យម៉ែឪបានសប្បាយចិត្តធ្វើឱ្យវង្សត្រកូលយើងថ្កុំថ្កើងរុងរឿងតទៅ» ។ កុមារដែលមាតាបិតាបានប្រគល់ឱ្យទៅលោកគ្រូបាធ្យាយហើយដេកនៅក្នុងវត្តរហូត និងប្រណិប័តន៍គ្រូអាចារ្យតទៅប៉ុន្តែសព្វថ្ងៃទំនៀមនេះមិនទៀងទាត់ទេ។ កុមារទៅរៀននៅក្នុងវត្តតែពេលថ្ងៃ លុះដល់ពេលល្ងាចវិលមកដេកឯផ្ទះវិញ។ ទំនៀមនេះហើយជាប្រពៃណីខ្មែរយើងតាំងពីបុរាណ។ បើពិនិត្យពិចារណាឱ្យបានហ្មត់ចត់ទៅ នេះមិនមែនជាទំនៀមទម្លាប់ខ្មែរយើងសុទ្ធសាធទេកាលដើមឡើយជារបស់សាសនាព្រាហ្មណ៍ ស្ថិតក្នុងគម្ពីរព្រាហ្មណ៍ដូច ច្បាប់មនុស្ស ឬច្បាប់គ្រឹហ្យសូត្រស្តីថាកូនព្រាហ្មណ៍កាលបើដល់អាយុសិក្សាហើយ(អាយុ ១០,១១,១២ឆ្នាំ) មាតាបិតាត្រូវយកទៅ ប្រគល់ឱ្យឫស្សីជាអធ្យាបក (គ្រូបង្រៀន) ដើម្បីសិក្សាត្រៃវេទ (ត្រ័យវិទ្យា)។កុមារព្រាហ្មណ៍នេះ ហៅថាព្រាហ្មណ៍ចារិន ឬព្រាហ្មណ៍ចារី(អ្នកប្រព្រឹត្តឱ្យបានទៅជាព្រាហ្មណ៍ឱ្យបានក្តីប្រសើរ)។ នៅជាមួយគ្រូរកអាហារភោជនរក្សាភ្លើងតទៅរហូតដល់ចេះ ត្រៃវេទ និងវេទាង្គ(អង្គរបស់វេទ) ៦ប្រការ គឺះ

- កល្បៈ សិក្សាឱ្យចេះធ្វើពិធីបូជា
- សិក្សា សិក្សាសូរសាស្ត្រ
- ឆន្ទ សិក្សាក្បួនកាព្យ
- និរុត្តិ សិក្សាអានវេទឱ្យត្រឹមត្រូវតាមជើងកាព្យ
- វ្យាករណ៍ សិក្សាវេយ្យាករណ៍(បានិណិ)
- ជ្យោតិស្ឋ សិក្សាតារាសាស្ត្រ។

លុះចេះវេទ ចេះវេទាង្គសព្វគ្រប់ហើយ ទើបទទួលបាននាមថាបាត្នរ(អ្នកដល់នូវត្រើយនៃវិជ្ជា) ដល់វិលមកផ្ទះវិញ ទើបមាតាបិតារៀបពិធីប្រសិទ្ធីឱ្យបានជាព្រាហ្មណ៍ពេញលក្ខណៈគឺ ទ្វិជៈ(កើតពីរដង) កើតម្តងពីមាតា និងម្តងទៀតកើតចេញពីត្រៃវេទ។ ប្រពៃណីដូចបានរៀបរាប់មកនេះហៅថា ឧបនយសំស្ការ មានពីរម៉ាត់ គឺ ឧបនយ(ឧប+នី) ប្រែថា នាំយកទៅប្រគល់ឱ្យ (អធ្យាមក=គ្រូ)+សំស្ការ (សំ+ស+ការ)ប្រែថា សម្រាំង ប្រសិទ្ធិ។ សំស្ការនេះនៅប្រទេសឥណ្ឌាសម័យបុរាណទាំងអស់មាន ៤០ប្រការ គឺក្នុងជីវិតព្រាហ្មណ៍ម្នាក់ៗ រាប់តាំងពីកើតរហូតដល់ស្លាប់ទៅវិញត្រូវធ្វើសំស្ការ ៤០ដង។

ឧ.ពេលមានគភ៌លម្អនសំស្ការ(ពិធីធ្វើឱ្យឧទរមានគភ៌) រហូតដល់អាវាហវិវាហសំស្ការជាទីបំផុត ប៉ុន្តែសព្វថ្ងៃនេះគេច្រើនធ្វើតែ១២ ប្រការទេ ដោយឡែកប្រទេសខ្មែរយើងមិនប្រើពាក្យសំស្ការនេះទេព្រោះយើងកាន់ព្រះពុទ្ធសាសនា។តាមព្រះពុទ្ធសាសន យើងប្រើពាក្យមង្គល(សេចក្តីចម្រើន)ជំនួសវិញដោយយើងនិយាយថាអាវាហវិវាហមង្គល(មង្គលរៀបការ)នាំមកនូវមង្គល(មង្គលឱ្យឈ្មោះ)សិប្បគ្គហនមង្គល (មង្គលឱ្យរៀន)ដូច្នេះយើងយល់បានថាការសិក្សាតាមព្រះពុទ្ធសាសនា តែប្រពៃណីជាសាសនាព្រាហ្មណ៍ផ្សំនឹងទំនៀមខ្មែរ កើតបានទៅជាអារ្យធម៌មួយឡើង ដែលផ្សេងពីព្រះពុទ្ធសាសនា និងលទ្ធិព្រាហ្មណ៍។

ឧបករណ៍ សិក្សាមាន កុដិនិងសាលា (គ្មានតុ កៅអី) ក្តារឈ្នួន ដីស (ដីឥដ្ឋបាតស្រះ បឹង ទន្លេមកលញ់ឱ្យមូលប៉ុនៗម្រាមដៃហាលថ្ងៃឱ្យស្ងួត) ទឹកល្បប់(ទឹកដែលលាយឡំដោយសំណុសផ្សេងៗ ដូចជា ផង់ធ្យូង ម្រែងភ្លើង លាយជាមួយទឹកបាយ គេលាយទុកក្នុងត្រឡោកដូង ឬក្នុងកូនក្អមសម្រាប់លុប

ក្ខារខៀន)។ពេលរៀនលោកគ្រូនិមន្តទៅកាន់ទីកន្លែងរៀនបង្រៀនឱ្យសិស្សចេះមើលសាស្ត្រាច្បាប់ សាស្ត្រាល្បែង សាស្ត្រាទេសន៍។ មុនពេលបង្រៀន លោកគ្រូសរសេរបទនមស្ការ ៣បទជាអក្សរមូល ទុកជាច្បាប់តាំងពីបុរាណគឺៈ

- នមោ = សូមនមស្ការ
- ពុទ្ធាយំ = ចំពោះព្រះពុទ្ធ
- សិទ្ធំ = សូមឱ្យបានសម្រេចការសិក្សា

ពេលសិក្សាកំពុងសេសេរ លោកគ្រូបង្រៀនឱ្យអានបណ្ដើរ ឱ្យអានបទនមស្ការ ជាភាសាសំស្រ្កឹត នេះជាភាសាខ្មែរ គឺឱ្យអានថាៈ

- ន មោ ពុ ទ្ធា យ សិទ្ធំ ឱ្យចេញជាបទ ដូចតទៅៈ
- ន អឺយ ន ន ណ
- មោ អឺយ មោ មោ មោ
- ពុ អឺយ ពុ ពុ ពុ (អានថាពុត)
- ទ្ធា អឺយ ទ្ធា ទ្ធា ទ្ធា (អានថាទ្ធា)
- យ អឺយ យ យ យ
- សិ អឺយ សិ សិ សិ (អានថាសិត)
- ទ្ធំ អឺយ ទ្ធំ ទ្ធំ ទ្ធំ (អានថាធំ)

បើសិស្សសរសេរបទនមស្ការនេះហើយ លោកគ្រូបង្រៀនឱ្យសរសេរស្រះពេញតួ គឺ «អ អា ឥ ឦ...សរសេរព្យញ្ជនៈ ក ខ គ ឃ ង និងស្រះនិស្ស័យ គឺ ស្រះ ា ិ ី» រហូតដល់ចប់។

**ខ. ជាន់ទី២ រៀនមើលសាស្ត្រាច្បាប់**

ការរៀនមើលសាស្ត្រាច្បាប់នេះគឺ ដំបូងឱ្យរៀនមើល (អាន) ជាពាក្យរាយ មិនទាន់ឱ្យមើល(អាន) ជាបទតាមច្បាប់ទេព្រោះសាស្ត្រាច្បាប់ទាំងអស់សុទ្ធតែជាពាក្យកាព្យដូចជា សាស្ត្រាច្បាប់ក្រម ច្បាប់កេរកាល ច្បាប់ប្រុស ច្បាប់ស្រី ច្បាប់រាជនេតិ(ច្បាប់ព្រះរាជសម្ភារ)។ លោកគ្រូនាំឱ្យរៀនអានឱ្យចេះអានត្រឹមត្រូវ ច្បាស់លាស់តាមក្បួនអក្សររួច ទើបឱ្យសិស្សអានដោយឯងតទៅ។ គេអានហើយ អានទៀត អានច្រើនលើកច្រើនសាទាល់តែចាំស្ទាត់រត់មាត់ អាចសូត្រមាត់ទទេបានដោយមិនបាច់មើលអក្សរ។ ការអាននេះ លោកគ្រូអង្គុយជិតផ្ទៀងស្ដាប់ មើល ហើយបង្គាប់ឱ្យសិស្សចាប់សាស្ត្រាអានតាំងពីដើមដល់ចប់បើលោកឃើញថា សិស្សនេះចេះអានស្ទាត់ជំនាញហើយ លោកគ្រូពន្យល់សេចក្ដីក្នុងសាស្ត្រាច្បាប់នេះបន្ថែមទៀត។ ធម្មតាច្បាប់ មានអត្ថន័យ និងខ្លឹមសារជ្រាលជ្រៅ ដែលបង្កាប់ន័យរបស់វា។

**គ. ជាន់ទី៣ រៀនមើលសាស្ត្រាល្បែង**

ការរៀនមើលសាស្ត្រាល្បែង មានទម្រង់ដូចគ្នានឹងរៀនមើលសាស្ត្រាច្បាប់ដែរ ប៉ុន្តែម្ដងនេះលោកគ្រូឱ្យរៀនអានចេញជាបទ ព្រោះសាស្ត្រាល្បែងទាំងអស់សុទ្ធតែបានតែងនិពន្ធឡើងជាបទមានបទកាគតិ ព្រហ្មគីត កុជង្គលីលា ពំនោល បន្ទោលកាក។ សាស្ត្រាល្បែងមានច្រើនច្បាប់ ដូចជាសាស្ត្រាច្បាប់សាស្ត្រាដុច សុបិន ហង្សយន្ត វិមានច័ន្ទ ស័ង្ខសិល្បជ័យ ជ័យទត្ត សព្វសិទ្ធិ។លោកគ្រូបង្រៀនមើលតាមបទ សិស្ស

ថាតាមទាល់តែត្រូវបទ ទើបឱ្យសិស្សអានខ្លួនឯងតទៅទៀត។ គេមើលនិងអានដដែលៗ អានចុះអានឡើងទាល់តែចាំស្ទាត់ ទើបផ្លាស់ទៅអានសាស្ត្រាមួយផ្សេងទៀតរហូតទាល់តែអស់សាស្ត្រា ដែលមាននៅក្នុងវត្ត។ លោកគ្រូផ្ទៀងស្តាប់និងមើលទៀត បើឃើញថាសិស្សចេះអានបទត្រឹមត្រូវហើយលោកគ្រូឱ្យទៅមើលសាស្ត្រាទេសន៍។

**ឃ. ជាន់ទី៤ការរៀនមើលសាស្ត្រាទេសន៍**

ការរៀនមើលសាស្ត្រាទេសន៍ មានទម្រង់អានផ្សេងពីសាស្ត្រល្បែង ជាបទឬពាក្យរាយធម្មតា។ សាស្ត្រទេសន៍ ជាសេចក្តីមួយបែបនៅក្នុងពួកព្យាង្គរាយដែរ ប៉ុន្តែមិនមែនជាពាក្យរាយធម្មតាសុទ្ធសាធនោះទេ គឺជាពាក្យរាយជូនគ្នា ឬកម្រងពាក្យជូនរណ្តំរដឹកទៅ ដែលគេនិយមហៅថាកម្រងកែវ។ សាស្ត្រាទេសន៍ មានច្រើនច្បាប់ដែរ ដូចជា ទសជាតក៍ជាដើម។ អ្នកនិពន្ធសាស្ត្រាទសជាតក៍ សុទ្ធតែជាអ្នកមានស្នាដៃដ៏ប្រសើរខ្ពង់ខ្ពស់ ដោយមានពាក្យពេចន៍ខ្ពស់ មានធម៌អាថ៌ គម្ពីរភាព ពាក្យរាយជូនរណ្តំគ្នាមើលទៅមិនអាក់ ពិរោះ ស្តាប់ គួរឱ្យចង់មើល ដូចតទៅនេះ «ព្រាហ្មណ៍ ម្នាលព្រាហ្មណ៍ រីព្រៃខេត្តហេមពាន្តសឹងដ៏ជាដំណាក់នៃបក្សាបក្សី តែងអាស្រ័យនៅសព្វពេលវេលា ហើរនាវេហាស៍ យាសយំចុះមកទុំដោយសង្វែកមែកសាខា ខ្មៀវខ្វារ ដោយភាសា ឬសូរល្វែងល្វើយ។ ឯបក្សីទាំងឡាយនោះគឺ គ្រួច ក្រៀល ចង្កៀលខ្យងត្រយងយំថ្ងូរ»។ថេរវេលានៃការសិក្សានេះមិនមានកំណត់ច្បាស់លាស់ទេ តែបើសិក្សាឱ្យគ្រប់គម្រប់៣ឆ្នាំទើបសន្មត់ ថាអស់ការសិក្សាមួយលើក។ ការសិក្សានៅក្នុងវត្តនេះសិស្សបានទទួលការអប់រំគ្រប់បែបយ៉ាងពិសេសធ្វើឱ្យប្រជាពលរដ្ឋខ្មែរ ស្លូតត្រង់ សុភាពរាបសា រម្យទម្យ...។កុមារអាយុ ១២ឆ្នាំ ត្រូវបួសជាសាមណេរ ដើម្បីសាងគុណមាតា និងបន្តការសិក្សាទៅមុខទៀតដោយរៀនសាមណេរវិន័យរៀនធម៌សូត្រមន្ត រៀនលេខនព្វន្ត រៀនវិជ្ជាផ្សេងៗតាមតម្រូវការ ហើយបើសឹកមកជាគ្រហស្ថ មានឈ្មោះមួយគេហៅថាជី។ ដល់អាយុ២១ឆ្នាំ ត្រូវបួសជាភិក្ខុ រួចហើយមានការសិក្សាបន្តទៅទៀតដោយរៀនវិន័យរៀនធម៌អាថ៌រៀនចំណេះវិជ្ជាផ្សេងៗខាងផ្លូវលោកតាមសេចក្តីត្រូវការ។បើនៅក្នុងវត្តខ្លួនពុំមានការសិក្សាវិជ្ជាបច្ចេកទេសទេ ភិក្ខុនិងសាមណេរអាចលាគ្រូឧបជ្ឈាយ៍ទៅសិក្សាវិជ្ជា ដែលខ្លួនត្រូវការនៅវត្តបន្តទៀត។ ការសិក្សាជាន់ខ្ពស់ គឺរៀនពីសំណាក់ព្រះកម្មដ្ឋានស្មឹងស្មាធិ៍ ធ្វើចិត្តខ្លួនឱ្យបរិសុទ្ធផុតកិលេសក្តីសៅហ្មង។ ការសិក្សាដូចបានពោលមកនេះជារបៀបនៃការសិក្សានៅគ្រឹស្តសតវត្សទី១៩ ហើយរបៀបសិក្សានេះ តាមការពិចារណាមើលឃើញថាមានតាំងពីសម័យបុរាណព្រេងនាយ[37]។

នៅសតវត្សទី១៩ពន្ធដែលសំខាន់ជាងគេគឺពន្ធអាករពងស្រូវគឺពន្ធអាករទាញយកជាស្រូវនៅរដូវច្រូតកាត់។ ការកំណត់ថ្លៃពន្ធគឺស្មើនឹងមួយភាគដប់នៃផលស្រូវដែលធ្វើបាន។ ក្រៅពីពន្ធពងស្រូវមានពន្ធប្រភេទផ្សេងៗទៀត ដូចជាការបង្ខំឱ្យដឹកនាំផលដំណាំ។ អ្នកជាត្រូវបំពេញការងារកំណែន ពួកនេះហៅថា "ពួកពលកម្លាំង" ។ ពួកពលកម្លាំងនេះត្រូវធ្វើការងារក្រោមការដឹកនាំរបស់សមាជិករាជវង្សឬរបស់មន្ត្រីនៅរាជធានី។ ព្រះបាទ អង្គដួង បានធ្វើការកែប្រែក្នុងប្រព័ន្ធកំណែនកសិករហើយគេបានកេណ្ឌកសិករអ្នកជា យកទៅកសាងផ្លូវ កំផែងបន្ទាយជង្រុកស្រូវនិងរៀបចំគ្រឿងសម្ភារៈសម្រាប់សំណង់នានា។ ដោយសារតែជាប់កំណែននេះជាមួយអ្នកមួយចំនួនបានធ្លាប់ខ្លួនទៅជា "ខ្ញុំ" វិញ។មានរបបបំពេញពលកម្មម្យ៉ាង

[37] -លោក ចៅ លិន សង្គមវិទ្យាខ្មែរ ឆ្នាំ២០១១

ទៀត ដែលបានអនុវត្តជាទូទៅគឺ ជំនួយ ដល់ម្ចាស់ដីសក្តិភូមិពីសំណាក់នាក់ជា។ តាមវិធី "ជំនួយ" នេះ គឺ អ្នកជាមានកាតព្វកិច្ចបំពេញពលកម្មដ៏ធ្ងន់ធ្ងរ ជាប្រយោជន៍ដល់ជ សក្តិភូមិណាមួយជាអ្នកជិតខាង។ ជន សក្តិភូមិនោះ មិនបានចេញថ្លៃឈ្នួលចំពោះពលកម្មនេះទេ គឺគ្រាន់តែទទួលរៀបចំបាយទឹកឱ្យហូបតែ ប៉ុណ្ណោះ។ រដ្ឋកាលនោះខាងផ្នែករដ្ឋបាលវិញ អ្នកដឹកនាំជាន់ខ្ពស់ ក្នុងរាជាណាចក្រមាន៤រូប គឺមាន "ព្រះមហាក្សត្រ" បន្ទាប់មក "ឧបយោរាជ" "ឧបរាជ" និង "ព្រះវររាជជននី" ដែលជាមាតារបស់ព្រះ រាជា។ អ្នកទាំង៤រូបនេះ មាន វាសនដ្ឋាន ហៅ"សម្រាប់" រៀងៗខ្លួន។ វាសនដ្ឋាននីមួយៗ មានរាំងមហាម ន្ត្រីនិងបរិវាប៉ុន្តែតែតាមពិត វាសន្នដ្ឋានរបស់មហាក្សត្រដែលមានលក្ខណៈជាស្ថាប័នកំពូល។ ពេលនោះ ព្រះរាជាណាចក្រកម្ពុជា ចែកជា ៥០ខេត្ត ហើយខេត្តចំនួន ៣៥ ស្ថិតក្រោមការត្រួតត្រារបស់វាសនដ្ឋាន ព្រះមហាក្សត្រ។ វាសសន្នដ្ឋានឧបយោរាជត្រួតត្រាខែ៧ វាសនដ្ឋាឧបរាជត្រួតត្រាខេត្ត ៥ និងវាសនដ្ឋាន របស់ព្រះវររាជជននីត្រួតត្រាខេត្ត៣។ ថៅហ្វាយខេត្តជាប្រមុខនៃខេត្តនីមួយៗឯមេស្រុកជាប្រមុខនៃស្រុក នីមួយៗដែរ ជាលំដាប់លំដោយមកទៀតគឺមានឃុំនិងភូមិដែលមានមេឃុំ និងមេភូមិ ជាអ្នកមើលការខុស ត្រូវ ហើយពួកនេះត្រូវបាន ប្រជារាស្ត្រ ជាអ្នកជ្រើសរើស។ ចំណូលជាផលស្រូវដែលប្រមូលបានមកត្រូវ យកទៅប្រើប្រាស់ សម្រាប់ការផ្គត់ផ្គង់វណ្ណៈអភិជននៅរាជធានី និងតន្ត្រីនាម៉ឺនបម្រើរាជការសម្រាប់ការ ចំណាយរបស់ព្រះបរមរាជវាំង និងសម្រាប់កងទ័ពក្នុងរាជព្រះបាទអង្គឌួង(១៨៤៧គ.ស-១៨៦០គ.ស) ព្រះអង្គបានចាប់ផ្តើមធ្វើកំណែទម្រង់ក្នុងប្រទេសដូចជាការកែប្រែនយោបាយមួយចំនួន ឱ្យមានលក្ខណៈ ប្រហាក់ប្រហែលនឹងស្ថាប័ននយោបាយប្រទេសសៀម។

ក្នុងកំណែទម្រង់ស្ថាប័ននយោបាយក្នុងប្រទេសព្រះបាទអង្គដួង បានយកព្រះទ័យដាក់លើវិធាន ការជម្រុះនូវឥទ្ធិពលអាក្រក់របស់នាម៉ឺនមន្ត្រីមួយចំនួនធំដែលបានលក់ខ្លួនឱ្យបរទេស។ ព្រះអង្គបាន រៀបចំ ឱ្យរដ្ឋអំណាចកណ្តាលរឹងមាំឡើងវិញ ហើយព្រះមហាក្សត្រចូលរួមដោះស្រាយកិច្ចការ សំខាន់ៗ របស់ប្រទេស ពិសេសឯកសារជាផ្លូវការទាំងអស់ត្រូវមានត្រាព្រមទាំងមានព្រហស្ថលេខារបស់ព្រះមហា ក្សត្រឬអ្នកដឹកនាំផងដែរ។ ព្រះបាទអង្គដួងបានធ្វើការឃោសនាឱ្យពលរដ្ឋទាំងអស់សាមគ្គីជាធ្លុងមួយ ជាមួយព្រះមហាក្សត្រឬអ្នកដឹកនាំដោយប្រើពាក្យស្លោកនិយមទាំងឡាយ។ ច្បាប់ព្រហ្មទណ្ឌនៃប្រទេស កម្ពុជាត្រូវបានកែប្រែ រៀបចំឡើងវិញ ចំណែកឯការប្រាក់ត្រូវបានបន្ថយមានច្បាប់កំណត់ឱ្យយក(ការ) ប្រាក់ត្រឹមតែ ៣០% ក្នុងមួយឆ្នាំហើយបំណុលណាដែលមិនមានឯកសារបញ្ជាក់ត្រឹមត្រូវត្រូវចាត់ទុកជា មោឃៈ ចំពោះការទារពន្ធដារត្រូវបានកាត់បន្ថយ ឯកាលបរិច្ឆេទទារពន្ធត្រូវបានប្រព្រឹត្តក្នុងពេលតែមួយ សមស្រប ដែលមិនប៉ះពាល់ដល់ការងារធ្វើស្រែចម្ការរបស់កសិករ។ រដ្ឋអំណាច បានយកចិត្តទុកដាក់ កសាងបណ្តាញផ្លូវថ្នល់ក្នុងតំបន់សំខាន់ៗនៃប្រទេស រួមមានផ្លូវថ្នល់ពីឧដុង្គស្ពោះទៅកំពង់ផែកំពត និងពី ឧដុង្គទៅទីក្រុងភ្នំពេញ ត្រូវបានកសាងឡើង។ នៅតាមផ្លូវទាំងនោះគេបានកសាងសាលាសំណាក់ និង ស្រះទឹកសម្រាប់អ្នកដំណើរ និងសត្វពាហនៈ។ព្រះបាទអង្គឌួងបានយកចិត្តទុកដាក់ ចំពោះព្រះពុទ្ធ សាសនាដោយបង្ករលក្ខណៈដល់ព្រះសង្ឃនិងពុទ្ធបរិស័ទទាំងឡាយ បានទទួលនូវពន្លឺនៃចំណេះវិជ្ជា ហើយព្រមទាំងផ្តល់លទ្ធភាពឱ្យមានការសម្អាតដល់គណៈសង្ឃទាំងឡាយ។ ការនេះធ្វើឱ្យព្រះបាទអង្គ ដួងទទួលជ័យជំនះលើពួកប្រឆាំងនឹងព្រះអង្គទៀតផងការកែទម្រង់មួយដ៏សំខាន់ខាងផ្នែកសង្គមកិច្ច

ដែលមានលក្ខណៈជឿនលឿន គឺការផ្តល់លទ្ធភាពដល់ការរំដោះ និងការរំដោះខ្លួនពីស្ថានភាពទាសភាពឱ្យមកជាអ្នកជាវិញ។ ទន្ទឹមនឹងនេះព្រះអង្គបានឱ្យពង្រឹងកងកម្លាំងប្រដាប់អាវុធនៃប្រទេសកម្ពុជា។ ដើម្បីសម្រេចនូវកិច្ចការនេះព្រះអង្គបានមានព្រះតម្រិះថាត្រូវចងសម្ព័ន្ធភាពជាមួយមហាអំណាចណាមួយនៅអឺរ៉ុបគឺបារាំង[38]។

### **៣.១១. ព្រះបាទអង្គដួង**(**១៨៤០គ.ស.-១៨៥៩គ.ស.**)

ព្រះអង្គដួងទ្រង់ប្រសូត្រនៅថ្ងៃទី៩ ខែអាសាធ ឆ្នាំរោង អដ្ឋស័កព.ស ២៣៤០ ត្រូវនឹងឆ្នាំ១៧៩១ គ.ស. នៅទីក្រុងឧដុង្គ។ ជាបុត្រពៅរបស់អង្គអេង និងមានមាតានាម អ្នកម្នាងរស់ មានព្រះរាម៤អង្គគឺ អង្គចន្ទ អង្គភឹម អង្គស្ងួន និងអង្គអឹម។

ព្រះអង្គចូលទីវង្គត នៅថ្ងៃសុក្រ ៥កើត ខែកត្តិក ឆ្នាំវក ទោស័កព.ស២៤០៤ ត្រូវនឹងថ្ងៃទី១៦ ខែតុលា គ.ស.១៨៦០នៅវេលាម៉ោង៤:១៥នាទី ដោយរោគមនោបាតក្នុងព្រះជន្មាយុ ៦៥វស្សា ។ ព្រះបាទអង្គដួងមានរាជបុត្របីព្រះអង្គ គឺ ព្រះនរោត្តម ព្រះស៊ីសុវត្ថា និង ព្រះស៊ីសុវត្ថិ។



Google Search)

[38] -ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ១៩៧៣

# សំណួរពិភាក្សា

១.តើព្រះរាជាអង្គណាដែលផ្តើមបង្កើតទំនាក់ទំនងជាមួយយួន? ហេតុអ្វីបានជាព្រះអង្គបង្កើតទំនាក់ទំនងជាមួយយួន?

២.តើព្រះរាជាអង្គណាយាងទៅតាំងរាជធានីនៅឧដុង្គ?តើរាជធានីនៅឧដុង្គមានទីតាំងស្ថិតនៅឯណា?

៣.ហេតុអ្វីបានជាខ្មែរ មានវិបត្តិរាជវង្ស?តើយួនឆ្លៀតឱកាសទាញចំណេញដូចម្តេចពីវិបត្តិរាជវង្សខ្មែរ?

៤.ហេតុអ្វីបានជាសៀមនិង យួនប្រជែងអំណាចគ្នាដើម្បីគ្រប់គ្រងខ្មែរ?តើការប្រកួតប្រជែងអំណាចរវាងយួននិងសៀមបង្កផលវិបាកអ្វីខ្លះដល់ខ្មែរ?

៥.តើយួនប្រើយុទ្ធសាស្ត្របែបណាខ្លះ ដើម្បីកាន់កាប់ទឹកដីកម្ពុជាក្រោម?

៦.តើព្រះបាទអង្គដួងបានធ្វើកំណែទម្រង់អ្វីខ្លះ ?តើកំណែទម្រង់នោះបានផ្តល់ផលប្រយោជន៍ដូចម្តេចខ្លះដល់ប្រទេសជាតិនិងប្រជារាស្ត្រខ្មែរ?

៧.ការបង្កើនឥទ្ធិពលសៀមមកលើខ្មែរ បង្ករឱ្យមានផលវិបាកដូចម្តេចខ្លះចំពោះខ្មែរ?

៨.តើព្រះបាទអង្គដួងបានប្រើមធ្យោបាយអ្វីខ្លះដើម្បីបង្កើតទំនាក់ទំនងជាមួយបារាំង?តើការខំប្រឹងប្រែងរបស់ព្រះអង្គក្នុងការបង្កើតទំនាក់ទំនងជាមួយបារាំងបន្សល់នូវឥទ្ធិពលនិងបទពិសោធន៍អ្វីខ្លះសម្រាប់ខ្មែរ?

៩.តើការសម្រេចព្រះទ័យ និងវិធីរើបម្រាស់ចេញពីសៀមនិងយួនរបស់ព្រះអង្គ សមស្របនឹងបរិបទក្នុងសម័យកាលនោះដែរឬយ៉ាងណា?ពីព្រោះអ្វី?

# ឯកសារយោង


| | | |
|---|---|---|
| ១. ត្រឹងងា | ប្រវត្តិសាស្ត្រខ្មែរ | ឆ្នាំ ១៩៧៣ |
| ២. លោក អាដេម៉ាឡឺក្លែរ | ប្រវត្តិសាស្ត្រប្រទេសកម្ពុជា | ឆ្នាំ ២០០៦ |
| ៣. លាងហាប់អាន | សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ | ឆ្នាំ១៩៦៧ |
| ៤. សម្តេចសង្ឃរាជ ជួន ណាត | វចនានុក្រមខ្មែរ ភ្នំពេញ | ឆ្នាំ ១៩៣៨ |
| ៥. នួន សុនិមន្ត | ប្រវត្តិសាស្ត្រខ្មែរសង្ខេប | ឆ្នាំ២០០០ |
| ៦. មហាបុរសខ្មែរ | | ឆ្នាំ២០០៩ |
| ៧. ម៉ាយឃើល វិកឃីរី | ប្រវត្តិសាស្ត្រខ្មែរ | ឆ្នាំ២០០៦ |
| ៨. នួន សុនិមន្ត | ប្រវត្តិសាស្ត្រខ្មែរសង្ខេប | ឆ្នាំ២០០០ |
| ៩. លោក អេង សុត | មហាបុរសខ្មែរ | ឆ្នាំ ២០០៩ |
| ១០. សៀវភៅសិក្សាសង្គមថ្នាក់ទី១១ | | ឆ្នាំ ២០១១ |
| ១១. លោក ប៊ុន ធឿន | ប្រវត្តិសាស្ត្រខ្មែរ | ឆ្នាំ ២០០៥ គ.ស. |
| ១២. លោក សូរ អឿ | ប្រវត្តិសាស្ត្រខ្មែរ | ឆ្នាំ១៩៩៥ គ.ស. |
| ១៣. លោក ពន់ ឆាយ | វប្បធ៌ម.អរិយធ៌ម | ឆ្នាំ២០០៨ គ.ស. |
| ១៤. បណ្ឌិត ចៅលិន | អភិបាលកិច្ចល្អក្នុងវិស័យអប់រំ | ឆ្នាំ២០១១ គ.ស. |

១៥.https://km.wikipedia.org/wiki/សម័យលង្វែក



